# ព្រះរាជក្រម

នស/រកម/០៧០៦/០២១

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

# ក្រម
# នីតិវិធីរដ្ឋប្បវេណី

# គន្ថីទី ១
# បទប្បញ្ញត្តិទូទៅ

## ជំពូកទី ១
## គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី ការទទួលខុសត្រូវរបស់តុលាការ និង គូភាគី

**មាត្រា ១.-** គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី

នីតិវិធីដែលទាក់ទងទៅនឹងបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើតាមបញ្ញត្តិនៃក្រមនេះ លើកលែងតែក្នុងករណីដែលច្បាប់ផ្សេងបានកំណត់ពិសេស ។

**មាត្រា ២.-** គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី សិទ្ធិពឹងពាក់តុលាការ

១-បណ្តឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ។

២-ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី ។

**មាត្រា ៣.-** សិទ្ធិទាមទារឱ្យសាកសួរ គោលការណ៍ចំពោះមុខ

១-ភាគីណាក៏មិនអាចត្រូវបានជម្រះក្តីដោយមិនបានសាកសួរ ឬ កោះហៅឡើយ ។

២-ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ ។

**មាត្រា ៤.-** ការទទួលខុសត្រូវរបស់តុលាការ និង ភាគី

តុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិតនិងស្មោះត្រង់ ។

**មាត្រា ៥.-** ភាសាដែលប្រើក្នុងតុលាការ សិទ្ធិរបស់ភាគីក្នុងការស្នើសុំឱ្យមានអ្នកបកប្រែ

១-នៅក្នុងតុលាការ ត្រូវប្រើភាសាខ្មែរ ។

២-ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចស្នើសុំរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ហើយប្រសិនបើសាមីខ្លួនពុំមានលទ្ធភាពរកខ្លួនឯងបានទេ រដ្ឋ

ត្រូវរកជំនួស ។

**មាត្រា ៦.–** ការចូលរួមរបស់តំណាងអយ្យការ

១-ក្នុងករណីដែលយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការថា ពាក្យបណ្ដឹងត្រូវបានទទួល ។

២-ទោះបីជាគ្មានការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះពីតុលាការក៏ដោយ ក៏តំណាងអយ្យការ អាចចូលរួមក្នុងនីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណី និងបញ្ចេញយោបល់បានដែរ ប្រសិនបើខ្លួនយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ ។

## ជំពូកទី ២

## តុលាការ

### ផ្នែកទី ១

### សមត្ថកិច្ចសាលាជម្រះក្ដី

**មាត្រា ៧.–** និយមន័យនៃតុលាការដែលមានសមត្ថកិច្ច

តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្ដឹង វិនិច្ឆ័យលើរឿងក្ដី ហើយចេញសាលក្រម ឬ សាលដីកាបាន ។

**មាត្រា ៨.–** សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍

បណ្ដឹងចំពោះចុងចម្លើយដែលបានកំណត់ក្នុងចំណុចខាងក្រោមនេះ ត្រូវដាក់ពាក្យបណ្ដឹងទៅសាលាដំបូង ដែលមានសមត្ថកិច្ចជម្រះក្ដីនៅទីកន្លែងដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-រូបវន្តបុគ្គល :

-លំនៅឋានរបស់ចុងចម្លើយ ។

-ទីសំណាក់ បើពុំមានលំនៅឋាន ឬ មានលំនៅឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

-លំនៅឋានចុងក្រោយ បើពុំមានទីសំណាក់ ឬ មានទីសំណាក់មិនពិតប្រាកដ ។

ខ-នីតិបុគ្គលក្នុងប្រទេស :

-ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បង ។

-លំនៅឋានរបស់អ្នកតំណាង ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង បើគ្មានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មទេ ។

គ-នីតិបុគ្គលបរទេស :

-ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បង ។

-លំនៅឋានរបស់អ្នកតំណាងប្រចាំព្រះរាជាណាចក្រកម្ពុជា ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បងក្នុងព្រះរាជាណាចក្រកម្ពុជា បើគ្មានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ។

**មាត្រា ៩.-** សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមទ្រព្យសម្បត្តិ ជាអាទិ៍

ក្រៅពីតុលាការដែលបានកំណត់ក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) ខាងលើនេះ ពាក្យបណ្តឹងដែលបានកំណត់ក្នុងចំណុចខាងក្រោមនេះ អាចប្តឹងនៅតុលាការដែលមានសមត្ថកិច្ចនៅទីកន្លែងដែលបានកំណត់ក្នុងចំណុចនីមួយៗ ក៏បានដែរ :

ក-បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច : កន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច ។

ខ-បណ្តឹងទាមទារឱ្យបង់ប្រាក់ដោយរូបិយាណត្តិ ឬ មូលប្បទានប័ត្រ : កន្លែងបង់រូបិយាណត្តិ ឬ មូលប្បទានប័ត្រ ។

គ-បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច ចំពោះបុគ្គលដែលពុំមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋានមិនពិតប្រាកដ : កន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ កម្មវត្ថុនៃប្រាតិភោគដែលធានាលើការទាមទារនោះ ឬ ទ្រព្យរបស់ចុងចម្លើយដែលអាចរឹបអូសបាន ស្ថិតនៅ ។

ឃ-បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច ចំពោះនីតិបុគ្គលដែលពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មមិនពិត

ប្រាកដ : កន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ កម្មវត្ថុនៃប្រាតិភោគដែលធានាលើការទាមទារនោះ ឬ ទ្រព្យរបស់ចុងចម្លើយដែលអាចរឹបអូសបានស្ថិតនៅ ។

ង-បណ្តឹងចំពោះបុគ្គលដែលមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មដែលទាក់ទងនឹងសកម្មភាពការងាររបស់ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ : ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ ។

ច-បណ្តឹងទាក់ទងនឹងអំពើអនីត្យានុកូល : កន្លែងដែលអំពើអនីត្យានុកូលកើតឡើង ។

ឆ-បណ្តឹងទាក់ទងនឹងអចលនវត្ថុ : កន្លែងដែលអចលនវត្ថុនោះស្ថិតនៅ ។

ជ-បណ្តឹងទាក់ទងនឹងការចុះបញ្ជី : កន្លែងដែលត្រូវចុះបញ្ជី ។

ឈ-បណ្តឹងទាក់ទងនឹងមត៌ក : លំនៅឋានរបស់មតកជន នៅពេលសន្តតិកម្មត្រូវចាប់ផ្តើម ឬ ទីសំណាក់ បើមតកជនពុំមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឬ មានលំនៅឋានមិនពិតប្រាកដ ឬ លំនៅឋានចុងក្រោយ បើមតកជននោះពុំមានទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ មានទីសំណាក់មិនពិតប្រាកដ ។

**មាត្រា ១០.-** សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និង រឿងក្តីអំពីបុគ្គភាព

១-បណ្តឹងលែងលះគ្នា និង បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃបុគ្គភាព ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខ របស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬ លំនៅឋាននាពេលដែលភាគីនោះទទួលមរណភាព ។

២-បើលំនៅឋានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេ សមត្ថកិច្ចសាលាជម្រះក្តី ត្រូវកំណត់តាមទីសំណាក់ ។ បើពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះត្រូវកំណត់តាមលំនៅឋានចុងក្រោយ ។

**មាត្រា ១១.-** សមត្ថកិច្ចសាលាជម្រះក្តីចំពោះការទាមទារច្រើនចំណុចដោយបញ្ចូលជាមួយគ្នា

ចំពោះបណ្តឹងមួយដែលមានការទាមទារច្រើនចំណុច ដែលស្ថិតនៅក្រោមសមត្ថកិច្ច

សាលាជម្រះក្តីផ្សេងគ្នា អាចប្តឹងទៅតុលាការដែលមានសមត្ថកិច្ចលើការទាមទារណាមួយក៏បានដែរ ដោយបញ្ចូលការទាមទារផ្សេងទៀតជាមួយគ្នា ។

**មាត្រា ១២.‒** ការកំណត់តុលាការដែលមានសមត្ថកិច្ច

ក្នុងករណីដែលតុលាការមានសមត្ថកិច្ចមិនអាចអនុវត្តនូវសិទ្ធិជម្រះក្តីបានដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនអាចកំណត់បានដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេច តាមពាក្យសុំ ។

**មាត្រា ១៣.‒** ការព្រមព្រៀងក្នុងការកំណត់តុលាការដែលមានសមត្ថកិច្ច

១-ការព្រមព្រៀងដែលកំណត់តុលាការដែលមានសមត្ថកិច្ចជម្រះក្តី នឹងមានអានុភាពលុះត្រាតែការព្រមព្រៀងនោះ ត្រូវបានធ្វើឡើងរវាងពាណិជ្ជករនិងពាណិជ្ជករ ឬ នីតិបុគ្គលនិងនីតិបុគ្គល ឬ ពាណិជ្ជករនិងនីតិបុគ្គល ចំពោះតែការជំនុំជម្រះក្តីលើកទី ១ ។

២-ការព្រមព្រៀងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងមានអានុភាពលុះត្រាតែការព្រមព្រៀងនោះ ត្រូវបានធ្វើឡើង ចំពោះបណ្តឹងដែលផ្អែកលើទំនាក់ទំនងគតិយុត្តដែលបានកំណត់ ហើយត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

**មាត្រា ១៤.‒** សមត្ថកិច្ចសាលាជម្រះក្តីដែលបានកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ

នៅពេលដែលចុងចម្លើយបានធ្វើសេចក្តីដោះសាអំពីអង្គសេចក្តី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ បានឆ្លើយទាញហេតុផលអំពីអង្គសេចក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ នៅតុលាការនៃការជំនុំជម្រះលើកទី ១ ដោយគ្មានការតវ៉ាអំពីកំហុសនៃសមត្ថកិច្ចសាលាជម្រះក្តីនោះ តុលាការនេះត្រូវមានសមត្ថកិច្ចជម្រះក្តី ។

**មាត្រា ១៥.‒** ករណីលើកលែងនៃការអនុវត្តចំពោះសមត្ថកិច្ចផ្តាច់មុខរបស់សាលាជម្រះក្តី ដែលច្បាប់បានកំណត់

បញ្ញត្តិនៃមាត្រា ១៣ (ការព្រមព្រៀងក្នុងការកំណត់តុលាការដែលមានសមត្ថកិច្ច) និង មាត្រា១៤ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិនៃច្បាប់កំណត់

សមត្ថកិច្ចផ្តាច់មុខចំពោះបណ្តឹង ។

**មាត្រា ១៦.–** ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

តុលាការអាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចសាលាជម្រះក្តី ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

**មាត្រា ១៧.–** មូលដ្ឋាននៃពេលវេលាសម្រាប់កំណត់សមត្ថកិច្ចសាលាជម្រះក្តី

សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមពេលដាក់ពាក្យបណ្តឹង ។

**មាត្រា ១៨.–** ការចាត់ចែងបណ្តឹងខុសសមត្ថកិច្ចសាលាជម្រះក្តី

១-ប្រសិនបើតុលាការយល់ឃើញថា បណ្តឹងទាំងមូល ឬ ផ្នែកណាមួយ មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេរបណ្តឹងនោះទៅតុលាការដែលមានសមត្ថ-កិច្ច តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២-ពាក្យសុំផ្ទេរបណ្តឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែករណីដែលដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ នៅពេលធ្វើពាក្យសុំនេះ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

**មាត្រា ១៩.–** ការផ្ទេរដើម្បីជៀសវាងពីការយឺតយ៉ាវ ជាអាទិ៍

១-ទោះបីជាបណ្តឹងណាមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ប្រសិនបើតុលាការនៃការជំនុំជម្រះលើកទី ១ យល់ឃើញថាចាំបាច់ដើម្បីជៀសវាងពីការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីធ្វើឱ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគីនិងសាក្សីដែលត្រូវសាកសួរ ទីតាំងនៃវត្ថុដែលនឹងត្រូវបានត្រួតពិនិត្យ និង កាលៈទេសៈផ្សេងៗ តុលាការនោះអាចផ្ទេរបណ្តឹងទាំងមូល ឬ ផ្នែកណាមួយ ទៅតុលាការផ្សេងទៀត ដែលមានសមត្ថកិច្ច តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

២-ក្នុងករណីដែលមានពាក្យសុំ ដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសម្រេច ដោយសួរយោបល់របស់ភាគីម្ខាងទៀត ។ ក្នុងករណីដែលតុលាការសម្រេចនូវការផ្ទេរដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន នោះតុលាការអាចសួរយោបល់គូភាគីបាន ។

**មាត្រា ២០.–** ការកម្រិតនូវការផ្ទេរក្នុងករណីសមត្ថកិច្ចផ្តាច់មុខដែលបានកំណត់ដោយច្បាប់

បញ្ញត្តិនៃមាត្រា ១៩ (ការផ្ទេរដើម្បីជៀសវាងពីការយឺតយ៉ាវ ជាអាទិ៍) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបណ្តឹងស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខដែលបានកំណត់ដោយច្បាប់របស់តុលាការដែលចាត់ការបណ្តឹងនោះ ។

**មាត្រា ២១.–** បណ្តឹងជំទាស់

ចំពោះដីកាសម្រេចផ្ទេរ និង ដីកាសម្រេចលើកចោលពាក្យសុំផ្ទេរ អាចប្តឹងជំទាស់បាន ។

**មាត្រា ២២.–** អានុភាពនៃដីកាសម្រេចផ្ទេរ ជាអាទិ៍

១-ដីកាសម្រេចស្ថាពរនៃការផ្ទេរ ត្រូវមានអានុភាពឱ្យតុលាការដែលទទួលការផ្ទេរប្រតិបត្តិតាម ។

២-តុលាការដែលបានទទួលការផ្ទេរ មិនអាចផ្ទេររឿងក្តីទៅតុលាការផ្សេងទៀតបានទេ ។

៣-នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ បណ្តឹងនោះត្រូវចាត់ទុកថាតុលាការដែលទទួលការផ្ទេរ ចាត់ការតាំងពីដើម ។

៤-នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ តុលាការដែលបានសម្រេចការផ្ទេរត្រូវបញ្ជូនសំណុំរឿងអំពីបណ្តឹងនេះ ទៅតុលាការដែលទទួលការផ្ទេរ ។

## ផ្នែកទី ២
## រចនាសម្ព័ន្ធនៃតុលាការ

**មាត្រា ២៣.–** ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

១-នៅសាលាដំបូង រឿងក្តីត្រូវទទួលបន្ទុកដោះស្រាយដោយចៅក្រមម្នាក់ លើកលែងតែករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-ចំពោះរឿងក្តីខាងក្រោមនេះ ត្រូវទទួលបន្ទុកដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម :

ក-រឿងក្តីដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃមិនតិចជាង ៥.០០០.០០០ (ប្រាំលាន) រៀល ហើយដែលតុលាការទទួលស្គាល់ថា គួរតែត្រូវបានវិនិច្ឆ័យនិងជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃគូភាគី និង បញ្ហាផ្សេងទៀត ។

ខ-រឿងក្តីដែលច្បាប់កំណត់ថាត្រូវវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។

៣-ក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវមានចៅក្រម ៣ (បី) នាក់ ហើយចាត់តាំងម្នាក់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៤-ដីកាសម្រេចឱ្យវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមដោយយោងតាមចំណុច ក នៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ។

**មាត្រា ២៤.-** ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ

១-ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវបានធ្វើជាសាធារណៈទេ ។

២-ការពិភាក្សាត្រូវបានបើក និង ដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៣-ចៅក្រមម្នាក់ៗត្រូវបញ្ចេញមតិយោបល់របស់ខ្លួនក្នុងការពិភាក្សានេះ ។

៤-ដំណើរការនៃការពិភាក្សា មតិយោបល់របស់ចៅក្រមម្នាក់ៗ និង ចំនួនសំឡេងនៃមតិ ត្រូវរក្សាទុកជាសម្ងាត់ ។

**មាត្រា ២៥.-** ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ

១-ការសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ ។

២-ចៅក្រមម្នាក់ៗក្នុងក្រុមប្រឹក្សាជំនុំជម្រះនេះ ត្រូវមានសិទ្ធិសម្រេចស្មើគ្នា ។

# ផ្នែកទី ៣
# ការបែងចែករឿងក្តី និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ និង បណ្តឹងជំទាស់ចៅក្រម

**មាត្រា ២៦.-** ការបែងចែករឿងក្តី

១-ការបែងចែករឿងក្តីនៅតុលាការមួយ និង លំដាប់សម្រាប់ជំនួសក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ ត្រូវកំណត់ទុកជាមុនជារៀងរាល់ឆ្នាំដោយដីកាសម្រេចរបស់ប្រធានតុលាការនោះ ។

២-រឿងក្តីនីមួយៗត្រូវបានបែងចែកឱ្យចៅក្រមម្នាក់ៗទទួលបន្ទុកជាស្វ័យប្រវត្តិតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣-ការបែងចែករឿងក្តីនៅតុលាការមួយ និង លំដាប់សម្រាប់ជំនួសក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈដែលត្រូវបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចត្រូវប្តូរក្នុងឆ្នាំនោះបានឡើយ លើកលែងតែក្នុងករណីដែលចៅក្រមណាម្នាក់មានការងារច្រើនពេក ឬ ករណីដែលចៅក្រមត្រូវឈប់ ឬ ប្តូរទៅតុលាការផ្សេង ឬ ករណីដែលចៅក្រមបន្តមានធុរៈ ដោយសារហេតុផលដូចជាត្រូវឈប់សម្រាកក្នុងរយៈពេលវែង ជាអាទិ៍ ។ ការប្តូរចំពោះករណីនេះ ត្រូវកំណត់ដោយដីកាសម្រេចរបស់ប្រធានតុលាការ ។

**មាត្រា ២៧.-** ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ

១-ចៅក្រមត្រូវដកហូតពីការអនុវត្តមុខការរបស់ខ្លួន ក្នុងករណីដែលបានកំណត់ដូចខាងក្រោមនេះ :

ក-កាលណាចៅក្រម ឬ សហព័ទ្ធរបស់ចៅក្រម ឬ អតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី ។

ខ-កាលណាចៅក្រមជាញាតិលោហិតក្នុងថ្នាក់ទី ៦ (ប្រាំមួយ) ឬ ញាតិពន្ធក្នុងថ្នាក់ទី ៣ (បី) ឬ អតីតញាតិពន្ធក្នុងថ្នាក់ទី ៣ (បី) របស់ភាគីណាមួយ ។

គ-កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ ។

ឃ-កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្លាប់ ឬ កំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ ។

ង-កាលណាចៅក្រមបានធ្វើជាសាក្សី ឬ ធ្វើជាអ្នកជំនាញក្នុងរឿងក្តី ។

ច-កាលណាចៅក្រមជាអ្នកតំណាង ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តី ។

ឆ-កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីមជ្ឈត្តករចំពោះរឿងក្តី ឬ បានចូលរួមក្នុងការសម្រេចសេចក្តីនៅក្នុងការជំនុំជម្រះលើកទី ១ ដែលបានឧបាស្រ័យ ឬ ការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬ បង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ ចំពោះរឿងក្តី ។

២-ក្នុងករណីដូចមានមូលហេតុនៃការដកហូត ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសម្រេចសេចក្តីអំពីការដកហូតនោះ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

**មាត្រា ២៨.–** បណ្តឹងជំទាស់ចៅក្រម

១-ក្នុងករណីដែលមានកាលៈទេសៈដែលបណ្តាលឱ្យមានការលំអៀងក្នុងការជម្រះក្តី ចំពោះចៅក្រមណាម្នាក់ នោះភាគីអាចប្តឹងជំទាស់ចៅក្រមនោះបាន ។

២-ក្នុងករណីដែលភាគីបានឆ្លើយទាញហេតុផលចំពោះមុខចៅក្រម ឬ បានធ្វើសេចក្តីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចំពោះមុខចៅក្រមរួចហើយ នោះភាគីមិនអាចប្តឹងជំទាស់ចៅក្រមនោះបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីនោះមិនបានដឹងអំពីមូលហេតុដែលអាចប្តឹងជំទាស់ ឬ ករណីដែលមូលហេតុនៃបណ្តឹងជំទាស់បានកើតឡើងនៅពេលក្រោយ ។

**មាត្រា ២៩.–** ការដកខ្លួនរបស់ចៅក្រម

ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) ឬ កថាខណ្ឌទី ១ នៃមាត្រា ២៨ (បណ្តឹងជំទាស់ចៅក្រម) នៃក្រមនេះ ចៅក្រមអាចដកខ្លួនបាន ដោយទទួលការអនុញ្ញាតពីប្រធានតុលាការដែលខ្លួនស្ថិតនៅក្រោម ។

**មាត្រា ៣០.–** ការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជំទាស់

១-ចំពោះការដកហូតចៅក្រម ឬ បណ្តឹងជំទាស់ចំពោះចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះ

នៅតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម ត្រូវសម្រេចសេចក្តី ដោយដីកាសម្រេច ។

២-ចៅក្រមមិនអាចចូលរួមក្នុងការសម្រេចសេចក្តីអំពីការដកហូត ឬ បណ្តឹងជិតចិត្ត ចំពោះខ្លួនបានទេ ។ ប៉ុន្តែ ចៅក្រមនោះអាចបញ្ចេញមតិយោបល់អំពីពាក្យសុំនូវការដកហូត ឬ បណ្តឹងជិតចិត្តបាន ។

៣-ពាក្យសុំនូវការដកហូត ឬ បណ្តឹងជិតចិត្ត ត្រូវបានធ្វើឡើងដោយធ្វើសេចក្តីបញ្ជាក់ដំបូងជាលាយល័ក្ខណ៍អក្សរនូវមូលហេតុ ។

៤-ពេលដែលមានពាក្យសុំនូវការដកហូត ឬ បណ្តឹងជិតចិត្ត នីតិវិធីនៃបណ្តឹងត្រូវបានផ្អាករហូតដល់ពេលដែលដីកាសម្រេចអំពីបណ្តឹងនេះ ចូលជាស្ថាពរ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពដែលត្រូវការជាបន្ទាន់ ដូចជាការថែរក្សាការពារភស្តុតាង ជាអាទិ៍ ។

៥-ចំពោះដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្តឹងជិតចិត្តមានមូលហេតុត្រឹមត្រូវនោះ មិនអាចប្តឹងឧបាស្រ័យឡើយ ។

៦-ចំពោះដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្តឹងជិតចិត្តពុំត្រឹមត្រូវ អាចប្តឹងជំទាស់បាន ។

**មាត្រា ៣១.-** ការអនុវត្តដូចគ្នាចំពោះក្រឡាបញ្ជី

បញ្ញត្តិនៃផ្នែកនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះក្រឡាបញ្ជី ។ ក្នុងករណីនេះ ការសម្រេចសេចក្តីអំពីពាក្យសុំនូវការដកហូត ឬ បណ្តឹងជិតចិត្ត ត្រូវធ្វើដោយតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅក្រោម ។

# ជំពូកទី ៣
# ភាគី

## ផ្នែកទី ១
## សមត្ថភាពភាគី និង សមត្ថភាពក្នុងការធ្វើបណ្តឹង

**មាត្រា ៣២.-** សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង ការតំណាងដែលច្បាប់បាន

កំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្ដឹង

១-បុគ្គលដែលអាចមានសិទ្ធិ និង ករណីយកិច្ច តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត អាចជាដើមចោទ ឬ ចុងចម្លើយនៅក្នុងបណ្ដឹងរដ្ឋប្បវេណី ។

២-បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯង តាមបញ្ញត្តិនៃក្រមរដ្ឋ-ប្បវេណី និង ច្បាប់ផ្សេងទៀត អាចដាក់ពាក្យបណ្ដឹងដោយខ្លួនឯងដោយតាំងខ្លួនជាដើមចោទ ឬ អាចឆ្លើយដោះសាចំពោះបណ្ដឹង ដោយតាំងខ្លួនជាចុងចម្លើយ ឬ អាចធ្វើសកម្មភាពបណ្ដឹងផ្សេងទៀតដែលជាចាំបាច់ ។

៣-អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើសកម្មភាពបណ្ដឹងសុពលបាន លុះត្រាតែត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ ។

៤-បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ត្រូវយកមកអនុវត្ត ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិតំណាងរបស់អ្នកតំណាងនោះ ។

**មាត្រា ៣៣.–** បញ្ញត្តិពិសេសស្ដីពីសកម្មភាពបណ្ដឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់

១-ជននៅក្រោមហិតូបត្ថម្ភ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ អាចធ្វើសកម្មភាពបណ្ដឹង ចំពោះបណ្ដឹង ឬ បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវបានធ្វើដោយភាគីម្ខាងទៀត ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ឬ ការប្រគល់សិទ្ធិផ្សេងទៀត ។

២-ជននៅក្រោមហិតូបត្ថម្ភ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវមានការប្រគល់សិទ្ធិពិសេសដើម្បីធ្វើសកម្មភាពបណ្ដឹងខាងក្រោមនេះ :

ក-ការដកពាក្យបណ្ដឹង ការផ្សះផ្សា ការលះបង់ការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ។

ខ-ការដកពាក្យបណ្ដឹងឧទ្ធរណ៍ ឬ ពាក្យបណ្ដឹងសាទុក្ខ ។

**មាត្រា ៣៤.–** បញ្ញត្តិពិសេសស្ដីពីសមត្ថភាពក្នុងការធ្វើបណ្ដឹងរបស់ជនបរទេស

ជនបរទេសត្រូវទុកជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹង ប្រសិនបើជននោះ

ត្រូវមានសមត្ថភាពក្នុងការធ្វើបណ្តឹងស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាជននោះគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹងតាមច្បាប់នៃប្រទេសរបស់ខ្លួនក៏ដោយ ។

**មាត្រា ៣៥.–** វិធានការក្នុងករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ជាអាទិ៍

១-ក្នុងករណីដែលមានការខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ សិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង តុលាការត្រូវបង្គាប់ឱ្យកែតម្រូវនូវចំណុចខ្វះនោះ ដោយកំណត់អំឡុងពេល ។ ក្នុងករណីនេះ ប្រសិនបើមានការខូចខាតណាមួយអាចកើតឡើងដោយសារការយឺតយ៉ាវ តុលាការអាចឱ្យបុគ្គលដែលមានការខ្វះនោះ ធ្វើសកម្មភាពបណ្តឹងជាបណ្តោះអាសន្នបាន ។

២-សកម្មភាពបណ្តឹងណាដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ ខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើង បើមានការទទួលស្គាល់នៅពេលក្រោយ ដោយភាគីដែលបានទទួលសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ ដោយអ្នកតំណាងដែលបានទទួលសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិ ។

៣-សិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្ម-ភាពបណ្តឹង ត្រូវបានបញ្ជាក់ដោយលិខិតជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ៣៦.–** អ្នកតំណាងពិសេស

១-ក្នុងករណីដែលគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ពុំអាចប្រតិបត្តិនូវសិទ្ធិតំណាងនោះ បុគ្គលដែលមានបំណងធ្វើសកម្ម-ភាពបណ្តឹងចំពោះបុគ្គលដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង អាចដាក់ពាក្យសុំទៅតុលា-ការដែលបានទទួលបណ្តឹង ឱ្យជ្រើសតាំងអ្នកតំណាងពិសេស ដោយធ្វើសេចក្តីបញ្ជាក់ដំបូងថា ការខូចខាតអាចនឹងកើតឡើងដោយសារការយឺតយ៉ាវនោះ ។

២-តុលាការអាចផ្លាស់ប្តូរអ្នកតំណាងពិសេស នៅពេលណាក៏បាន ។

៣-ការសម្រេចសេចក្តីអំពីការជ្រើសតាំង ឬ ការផ្លាស់ប្តូរអ្នកតំណាងពិសេសនឹងត្រូវបានជូនដំណឹងឱ្យអ្នកតំណាងពិសេសផងដែរ ។

៤-អ្នកតំណាងពិសេសត្រូវមានការប្រគល់សិទ្ធិដូចអាណាព្យាបាល ដើម្បីធ្វើសកម្ម-ភាពបណ្តឹង ។

**មាត្រា ៣៧.-** ការជូនដំណឹងអំពីការរលត់នៃសិទ្ធិតំណាងដែលច្បាប់បានកំណត់

១-ការរលត់នៃសិទ្ធិតំណាងដែលច្បាប់បានកំណត់ មិនត្រូវមានអានុភាព បើគ្មានការជូនដំណឹងអំពីការរលត់សិទ្ធិនោះ ពីសាមីខ្លួន ឬ អ្នកតំណាង ទៅភាគីម្ខាងទៀត ។

២-បុគ្គលដែលជូនដំណឹងអំពីការរលត់នៃសិទ្ធិតំណាងដែលច្បាប់បានកំណត់ ត្រូវរាយការណ៍ទៅតុលាការ អំពីការជូនដំណឹងអំពីការរលត់សិទ្ធិនោះ ជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ៣៨.-** ការអនុវត្តដូចគ្នាចំពោះអ្នកតំណាងនៃនីតិបុគ្គល

បញ្ញត្តិនៃក្រមនេះដែលទាក់ទងនឹងការតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងនៃនីតិបុគ្គល ។

## ផ្នែកទី ២
## សហបណ្តឹង

**មាត្រា ៣៩.-** ល័ក្ខខ័ណ្ឌទូទៅនៃសហបណ្តឹង

បើមានមូលហេតុណាមួយរវាងបុគ្គលច្រើននាក់ដូចមានចែងខាងក្រោមនេះ បុគ្គលទាំងនោះអាចប្តឹង ឬ អាចត្រូវគេប្តឹង ក្នុងនាមជាអ្នកសហបណ្តឹង ៖

ក-បើសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹងនោះដូចគ្នា ។

ខ-បើសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹងនោះ ផ្អែកលើមូលហេតុដូចគ្នាលើអង្គហេតុ និង អង្គច្បាប់ ។

គ-បើសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹងនោះ មានប្រភេទដូចគ្នា ហើយផ្អែកលើមូលហេតុ ដែលមានប្រភេទដូចគ្នាលើអង្គហេតុ និង អង្គច្បាប់ ។

**មាត្រា ៤០.-** ឋានៈនៃអ្នកធ្វើសហបណ្តឹង ក្នុងសហបណ្តឹងធម្មតា

សកម្មភាពបណ្តឹងដែលបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹងបានធ្វើ សកម្មភាពបណ្តឹងរបស់ភាគីម្ខាងទៀត ដែលបានធ្វើចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង

និង ហេតុដែលកើតមានឡើងចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្ដឹង ពុំមានឥទ្ធិពលទៅលើអ្នកធ្វើសហបណ្ដឹងផ្សេងទៀតទេ ។

**មាត្រា ៤១.-** បទបញ្ញាស្ដីពីការវិនិច្ឆ័យលើសហបណ្ដឹងចាំបាច់

១-ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹង នឹងត្រូវបានសម្រេចជាស្ថាពរទាល់តែមានការរួមគ្នា ចំពោះអ្នកធ្វើសហបណ្ដឹងទាំងអស់ ទោះជាមានបញ្ញត្តិដូចមាត្រា៤០ (ឋានៈនៃអ្នកធ្វើសហបណ្ដឹង ក្នុងសហបណ្ដឹងធម្មតា) ខាងលើនេះក៏ដោយ ក៏សកម្ម-ភាពនៃបណ្ដឹងរបស់បុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្ដឹង មានអានុភាពតែក្នុងករណីណាដែលមានផលប្រយោជន៍រួមតែប៉ុណ្ណោះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ សកម្មភាពបណ្ដឹងរបស់ភាគីម្ខាងទៀតដែលបានធ្វើចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្ដឹង មានអានុភាពទៅលើបុគ្គលទាំងអស់ ។

៣-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើមានមូល-ហេតុក្នុងការផ្អាក ឬ បង្អង់នូវនីតិវិធីនៃបណ្ដឹងចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហ-បណ្ដឹង ការផ្អាក ឬ ការបង្អង់នោះ មានអានុភាពទៅលើបុគ្គលទាំងអស់ ។

**មាត្រា ៤២.-** ការជ្រើសរើសភាគី

១-បុគ្គលច្រើននាក់ដែលមានផលប្រយោជន៍រួមមួយ អាចធ្វើការជ្រើសរើសបុគ្គលម្នាក់ ឬ ច្រើននាក់ ពីក្នុងចំណោមបុគ្គលទាំងនោះ ដើម្បីធ្វើជាដើមចោទ ឬ ចុងចម្លើយសម្រាប់បុគ្គលទាំងនោះបាន ។

២-ប្រសិនបើបានជ្រើសរើសដើមចោទ ឬ ចុងចម្លើយ តាមកថាខណ្ឌទី ១ ខាងលើនេះ នៅពេលដែលតុលាការកំពុងចាត់ការបណ្ដឹង ភាគីផ្សេងទៀតត្រូវដកខ្លួនពីបណ្ដឹងនោះដោយស្វ័យប្រវត្តិ ។

៣-អ្នកដែលបានធ្វើការជ្រើសរើសដើមចោទ ឬ ចុងចម្លើយតាមកថាខណ្ឌទី ១ ខាងលើនេះ អាចលុបចោលនូវការជ្រើសរើស ឬ អាចផ្លាស់ប្ដូរភាគីដែលត្រូវបានជ្រើសរើសនោះបាន ។

៤-ក្នុងចំណោមភាគីដែលត្រូវបានជ្រើសរើស ប្រសិនបើមានអ្នកណាបានបាត់បង់

នូវលក្ខណៈជាភាគីដែលត្រូវបានជ្រើសរើស ដោយសារបានទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ភាគីដែលត្រូវបានជ្រើសរើសផ្សេងទៀត អាចធ្វើសកម្មភាពបណ្តឹងសម្រាប់បុគ្គលទាំងអស់បាន ។

## ផ្នែកទី ៣
## ការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង

**មាត្រា ៤៣.-** ការចូលរួមជួយអន្តរាគមន៍

តតិយជនណាដែលមានការទាក់ទងនឹងផលប្រយោជន៍តាមផ្លូវច្បាប់ អំពីលទ្ធផលនៃបណ្តឹង អាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹង ដើម្បីជួយភាគីម្ខាងណាមួយបាន ។

**មាត្រា ៤៤.-** ពាក្យសុំចូលរួមជួយអន្តរាគមន៍

១-ពាក្យសុំចូលរួមជួយអន្តរាគមន៍ ត្រូវធ្វើទៅតុលាការដែលខ្លួននឹងត្រូវធ្វើសកម្មភាពបណ្តឹង តាមការចូលរួមជួយអន្តរាគមន៍ ដោយមានបញ្ជាក់ថា តើចូលរួមជួយអន្តរាគមន៍ សម្រាប់ភាគីណានៃបណ្តឹងណា ព្រមទាំងបញ្ជាក់នូវមូលហេតុនៃការចូលរួមឱ្យបានច្បាស់លាស់ផង ។

២-ពាក្យសុំចូលរួមជួយអន្តរាគមន៍ អាចធ្វើឡើងបាន ព្រមជាមួយគ្នានឹងសកម្មភាពបណ្តឹងដែលអ្នកចូលរួមជួយអន្តរាគមន៍អាចធ្វើបាន ។

**មាត្រា ៤៥.-** បណ្តឹងតវ៉ានឹងការចូលរួមជួយអន្តរាគមន៍ ជាអាទិ៍

១-ប្រសិនបើភាគីប្តឹងតវ៉ានឹងការចូលរួមជួយអន្តរាគមន៍ តុលាការត្រូវសម្រេចសេចក្តីនូវការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍ ដោយដីកាសម្រេច ។ ក្នុងករណីនេះ អ្នកចូលរួមជួយអន្តរាគមន៍ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុនៃការចូលរួម ។

២-បណ្តឹងតវ៉ាដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចធ្វើបានឡើយ ក្រោយពេលភាគីបានធ្វើសេចក្តីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ បានធ្វើការឆ្លើយទាញហេតុផលនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដោយគ្មានប្តឹងតវ៉ានោះ ។

៣-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹង

ជិទាស់បាន ។

**មាត្រា ៤៦.–** សកម្មភាពបណ្តឹងនៃអ្នកចូលរួមជួយអន្តរាគមន៍

១-អ្នកចូលរួមជួយអន្តរាគមន៍អាចដាក់វិធីតទល់ ឬ ការពារខ្លួន អាចធ្វើការប្តឹងតវ៉ា អាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អាចទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មី និង អាចធ្វើសកម្មភាពបណ្តឹងផ្សេងទៀតដែលទាក់ទងនឹងបណ្តឹងនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពដែលអ្នកត្រូវគេជួយចូលរួមអន្តរាគមន៍មិនអាចធ្វើបាននៅពេលដែលខ្លួនបានចូលរួមជួយអន្តរាគមន៍ ។

២-ប្រសិនបើសកម្មភាពបណ្តឹងដែលធ្វើដោយអ្នកចូលរួមជួយអន្តរាគមន៍ បានប៉ះពាល់ប្រឆាំងនឹងសកម្មភាពបណ្តឹងរបស់អ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ សកម្មភាពនោះពុំមានអានុភាពឡើយ ។

៣-ទោះជាមានការប្តឹងតវ៉ាចំពោះការចូលរួមជួយអន្តរាគមន៍ក៏ដោយ ក៏អ្នកចូលរួមជួយអន្តរាគមន៍អាចធ្វើសកម្មភាពបណ្តឹងបានដែរ រហូតដល់ពេលដែលការសម្រេចសេចក្តីរបស់តុលាការថា មិនអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍នោះ ចូលជាស្ថាពរ ។

៤-សកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ ទោះជាការសម្រេចសេចក្តីរបស់តុលាការថា មិនអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍ ចូលជាស្ថាពរក៏ដោយ ក៏សកម្មភាពនោះ នឹងមានអានុភាពដែរ ប្រសិនបើភាគីបានលើកឡើងនូវសកម្មភាពនោះ ។

**មាត្រា ៤៧.–** អានុភាពនៃការសម្រេចសេចក្តីទៅលើអ្នកចូលរួមជួយអន្តរាគមន៍

ចំពោះបណ្តឹងដែលមានការចូលរួមជួយអន្តរាគមន៍ បើសាលក្រមដែលសម្រេចឱ្យមានការខូចផលប្រយោជន៍របស់អ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ បានចូលជាស្ថាពរហើយ សេចក្តីវិនិច្ឆ័យរបស់សាលក្រមនោះមានចំណងទៅលើអ្នកចូលរួមជួយអន្តរាគមន៍ ក្នុងទំនាក់ទំនងជាមួយនឹងអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ លើកលែងតែក្នុងករណីដែលមានចែងដូចខាងក្រោមនេះ :

ក-បើអ្នកចូលរួមជួយអន្តរាគមន៍ មិនអាចធ្វើសកម្មភាពបណ្តឹង ដោយបញ្ញត្តិនៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៤៦ (សកម្មភាពបណ្តឹងនៃអ្នកចូលរួមជួយអន្តរាគមន៍) ខាងលើនេះ ។

ខ-បើសកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ គ្មានអានុភាព ដោយបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៤៦ (សកម្មភាពបណ្តឹងនៃអ្នកចូលរួមជួយអន្តរាគមន៍) ខាងលើនេះ ។

គ-បើអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ បានរារាំងសកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ ។

ឃ-បើអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍មិនបានធ្វើសកម្មភាពបណ្តឹងដែលអ្នកចូលរួមជួយអន្តរាគមន៍មិនអាចធ្វើបាន ដោយចេតនា ឬ ដោយកំហុសរបស់ខ្លួន ។

**មាត្រា ៤៨.–** ការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង

១-បើសាលក្រមមានអានុភាពស្ថាពររវាងអ្នកចូលរួមជួយអន្តរាគមន៍ និង ភាគីម្ខាងទៀតនៃអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ ឋានៈរបស់អ្នកចូលរួមជួយអន្តរាគមន៍លើបណ្តឹងមានដូចគ្នានឹងអ្នកធ្វើសហបណ្តឹងដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ៤១ (បទបញ្ញាស្តីពីការវិនិច្ឆ័យលើសហបណ្តឹងចាំបាច់) នៃក្រមនេះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ កថាខណ្ឌទី ២ នៃមាត្រា ៤៦ (សកម្មភាពបណ្តឹងនៃអ្នកចូលរួមជួយអន្តរាគមន៍) និង ចំណុច ខ និង ចំណុច គ នៃមាត្រា ៤៧ (អានុភាពនៃការសម្រេចសេចក្តីទៅលើអ្នកចូលរួមជួយអន្តរាគមន៍) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ។

**មាត្រា ៤៩.–** ការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹង

១-ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង នឹងត្រូវបានសម្រេចជាស្ថាពរ ទាល់តែមានការរួមគ្នា ចំពោះភាគីណាមួយ និង តតិយជន តតិយជននោះអាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹងនោះ ក្នុងនាមជាអ្នកធ្វើសហបណ្តឹងបាន ។

២-បញ្ញត្តិនៃមាត្រា ៤៤ (ពាក្យសុំចូលរួមជួយអន្តរាគមន៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំចូលរួមអន្តរាគមន៍ក្នុងបណ្តឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣-ពាក្យសុំចូលរួមអន្តរាគមន៍ក្នុងបណ្តឹងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

៤-ពាក្យសុំជាលាយល័ក្ខណ៍អក្សរដែលបានកំណត់នៅកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបញ្ជូនទៅអ្នកផ្សេងដែលធ្វើសហបណ្តឹង និង ភាគីម្ខាងទៀត ។

**មាត្រា ៥០.–** ការជូនដំណឹងអំពីបណ្តឹង

១-ភាគីអាចជូនដំណឹងអំពីបណ្តឹង ទៅតតិយជនដែលអាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹងនោះបាន នៅពេលដែលតុលាការកំពុងចាត់ការបណ្តឹង ។

២-ការជូនដំណឹងអំពីបណ្តឹង ត្រូវធ្វើឡើងដោយដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលបញ្ជាក់អំពីមូលហេតុក្នុងការជូនដំណឹង និង អំពីដំណើរការនៃបណ្តឹងនោះ ទៅតុលាការ ។ តុលាការត្រូវបញ្ជូនលិខិតនេះទៅអ្នកដែលត្រូវទទួលដំណឹង និង ភាគីម្ខាងទៀតនៃបណ្តឹង ។

៣-ទោះបីជាអ្នកទទួលដំណឹងអំពីបណ្តឹងនេះមិនបានចូលរួមអន្តរាគមន៍ក៏ដោយ ចំពោះការអនុវត្តបញ្ញត្តិនៃមាត្រា ៤៧ (អានុភាពនៃការសម្រេចសេចក្តីទៅលើអ្នកចូលរួមជួយអន្តរាគមន៍) នៃក្រមនេះ អ្នកទទួលដំណឹងអំពីបណ្តឹងនេះត្រូវបានចាត់ទុកថា បានចូលរួមហើយ នៅពេលអ្នកនោះអាចចូលរួមបាន ។

**មាត្រា ៥១.–** បណ្តឹងដែលមានដើមចោទ និង ចុងចម្លើយ ជាសហចុងចម្លើយ

១-តតិយជនដែលអះអាងថា ចំពោះសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹងរវាងភាគីដទៃ សិទ្ធិទាំងមូល ឬ មួយភាគជាសិទ្ធិរបស់ខ្លួន អាចដាក់ពាក្យបណ្តឹងចំពោះភាគីទាំងសងខាងនៃបណ្តឹងខាងលើនោះ ជាសហចុងចម្លើយ ទៅតុលាការនៃការជំនុំជម្រះលើកទី ១ ដែលបានទទួលពាក្យបណ្តឹងរវាងភាគីដទៃនោះ នៅពេលបណ្តឹងនោះកំពុងនៅក្រោមការចាត់ការរបស់តុលាការណាមួយ ។

២-ក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតុលាការនៃការជំនុំជម្រះលើកទី ១ កំពុងចាត់ការបណ្តឹងរវាងភាគីដទៃនោះ តុលាការដែលទទួលពាក្យបណ្តឹងពីតតិយជននោះ អាចបញ្ចូលបណ្តឹងទាំងពីរជាមួយគ្នាបាន ។

# ផ្នែកទី ៤
# អ្នកតំណាងដោយអាណត្តិ និង អ្នកជំនួយ

**មាត្រា ៥២.-** សកម្មភាពបណ្តឹងដែលបានធ្វើដោយអ្នកតំណាងដោយអាណត្តិ

១-ភាគីអាចធ្វើរាល់សកម្មភាពដែលទាក់ទងនឹងបណ្តឹង ដោយខ្លួនឯងផ្ទាល់ ឬ ឆ្លងតាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនបានជ្រើសតាំង ។

២-ទោះបីភាគីបានជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ភាគីនោះអាចចូលរួមទៅតុលាការ និង ឆ្លើយទាញហេតុផលដោយខ្លួនឯងបានដែរ ។

៣-សកម្មភាពបណ្តឹងដែលអ្នកតំណាងដោយអាណត្តិបានធ្វើ ត្រូវបង្កើតអានុភាពដូចគ្នាជាមួយសកម្មភាពបណ្តឹងដែលភាគីបានធ្វើដោយផ្ទាល់ខ្លួន ។ ប៉ុន្តែ ការសារភាព និង ចម្លើយដទៃទៀតស្តីពីអង្គហេតុដែលអ្នកតំណាងដោយអាណត្តិបានធ្វើ ពុំមានអានុភាពឡើយ ប្រសិនបើភាគីលុបចោល ឬ កែតម្រូវភ្លាមៗ ។

**មាត្រា ៥៣.-** លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ

១-អ្នកតំណាងដោយអាណត្តិដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ៥២ (សកម្មភាពបណ្តឹងដែលបានធ្វើដោយអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ត្រូវតែជាមេធាវី លើកលែងតែករណីដែលបានកំណត់ក្នុងចំណុចនីមួយៗ ដូចខាងក្រោម :

ក-ករណីដែលក្រមនេះ ឬ ច្បាប់ដទៃទៀត អនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវី ធ្វើសកម្មភាពបណ្តឹងជំនួសភាគី ។

ខ-ករណីដែលភាគីជារដ្ឋ ស្ថាប័ននីតិរដ្ឋបាល ឬ ស្ថាប័នរដ្ឋដទៃទៀត និង ដែលស្ថាប័ននោះ ឬ អ្នកតំណាងនៃស្ថាប័ននោះ តែងតាំងបុគ្គលិកនៃស្ថាប័ននោះជាអ្នកតំណាង ។

គ-ករណីដែលតុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជនដែលមិនមែនជាមេធាវី ក្នុងរឿងក្តីដែលតម្លៃកម្មវត្ថុនៃបណ្តឹងតិចជាង ១.០០០.០០០ (មួយលាន) រៀល ។

២-សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ ត្រូវបញ្ជាក់ជាលាយល័ក្ខណ៍អក្សរ ។

៣-តុលាការអាចលុបចោលការអនុញ្ញាត ដែលបានកំណត់ក្នុងចំណុច គ នៃកថា-

ខណ្ឌទី ១ ខាងលើនេះ នៅពេលណាក៏បាន ។

**មាត្រា ៥៤.-** សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ

១-អ្នកតំណាងដោយអាណត្តិមានសិទ្ធិអំណាចក្នុងការធ្វើរាល់សកម្មភាពបណ្តឹង ព្រមទាំងការដាក់ពាក្យបណ្តឹង ការឆ្លើយដោះសាចំពោះបណ្តឹង ការប្តឹងតប ការចូលរួមអន្តរាគមន៍បណ្តឹង ការប្តឹងទៅតុលាការជាន់ខ្ពស់ ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់នូវការទាមទារ ចំពោះរឿងក្តីដែលខ្លួនបានទទួលអាណត្តិ ។

២-សិទ្ធិតំណាងដែលត្រូវបានប្រគល់សម្រាប់បណ្តឹងរាប់បញ្ចូលទាំងសិទ្ធិលើការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ការជ្រើសតាំងអនុតំណាង និង ការទទួលនូវការសង ។

៣-ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាមេធាវី ភាគីពុំអាចកម្រិតនូវសិទ្ធិតំណាងបានទេ លើកលែងតែករណីទាក់ទងនឹងការដាក់ពាក្យបណ្តឹងតប ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់នូវការទាមទារ ការដកខ្លួនពីបណ្តឹង ការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ការដកពាក្យបណ្តឹងឧបាស្រ័យពីតុលាការជាន់ខ្ពស់ និង ការជ្រើសតាំងអនុតំណាង ។

៤-ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិមិនមែនជាមេធាវី ភាគីក៏អាចឱ្យអ្នកតំណាងដោយអាណត្តិនោះ ធ្វើតំណាងចំពោះតែសកម្មភាពបណ្តឹងមួយចំនួនដែលបានកំណត់ដោយឡែកៗដោយភាគីបានដែរ ។

៥-បញ្ញត្តិនៃកថាខណ្ឌទាំងបួនខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអ្នកតំណាងដែលត្រូវបានអនុញ្ញាតដោយច្បាប់ក្នុងការធ្វើសកម្មភាពបណ្តឹងជំនួសភាគី ។

**មាត្រា ៥៥.-** ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់

សិទ្ធិអំណាចនៃអ្នកតំណាងដោយអាណត្តិមិនត្រូវរលត់ឡើយ ទោះបីជាមានករណីដែលភាគីទទួលមរណភាព ឬ បាត់បង់សមត្ថភាពក្នុងការធ្វើបណ្តឹង ឬ មានករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានប្តូរ ជាអាទិ៍ ក៏ដោយ ។

**មាត្រា ៥៦.-** ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ

១-សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិត្រូវរលត់ ដោយហេតុដូចជាមរណ-

ភាពនៃអ្នកតំណាង ការបាត់បង់លក្ខណសម្បត្តិរបស់អ្នកតំណាង ឬ ការបញ្ចប់កិច្ចការអាណត្តិ ជាអាទិ៍ ។

២-ភាគីអាចដកសិទ្ធិតំណាងដោយអាណត្តិនៅពេលណាក៏បាន រីឯអ្នកតំណាងដោយអាណត្តិអាចឈប់ធ្វើជាអ្នកតំណាង នៅពេលណាក៏បានដែរ ។

៣-ការរលត់នូវសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ មិនត្រូវមានអានុភាពឡើយ ប្រសិនបើគ្មានការជូនដំណឹងអំពីការរលត់សិទ្ធិនោះ ពីសាមីខ្លួន ឬ អ្នកតំណាងទៅភាគីម្ខាងទៀត ។

**មាត្រា ៥៧.-** វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង

១-ក្នុងករណីដែលមានការសង្ស័យនៃការខ្វះសិទ្ធិតំណាងដោយអាណត្តិ តុលាការត្រូវស្រាវជ្រាវអំពីអត្ថិភាពនៃសិទ្ធិតំណាង ដោយឆន្ទានុសិទ្ធិ ទោះបីជាការសង្ស័យនោះកើតឡើង នៅក្នុងដំណាក់កាលណាមួយក្នុងបណ្ដឹងក៏ដោយ ។

២-បើមានការខ្វះសិទ្ធិតំណាងដោយអាណត្តិ តុលាការត្រូវណែនាំកែតម្រូវនូវចំណុចខ្វះនោះ ដោយកំណត់អំឡុងពេល ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឱ្យបុគ្គលដែលខ្វះសិទ្ធិតំណាងនោះធ្វើសកម្មភាពបណ្ដឹងជាបណ្ដោះអាសន្នបាន ។

៣-សកម្មភាពបណ្ដឹងណាដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលមានការខ្វះសិទ្ធិតំណាងដោយអាណត្តិ ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើងដោយយោងទៅតាមសច្ចានុមតិរបស់ភាគី ។

**មាត្រា ៥៨.-** អ្នកជំនួយ

១-បើមានភាពចាំបាច់ដើម្បីឱ្យបំភ្លឺនូវទំនាក់ទំនងនៃបណ្ដឹងឱ្យបានច្បាស់លាស់ នោះភាគី ឬ អ្នកតំណាងដោយអាណត្តិ អាចចូលទៅតុលាការជាមួយអ្នកជំនួយ ដោយមានការអនុញ្ញាតពីតុលាការ ។

២-ការអនុញ្ញាតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចលុបចោលនៅពេលណាក៏បានដែរ ។

៣-សេចក្ដីថ្លែងការណ៍របស់អ្នកជំនួយ ត្រូវទុកជាសេចក្ដីថ្លែងការណ៍ដែលភាគី ឬ តំណាងដោយអាណត្តិ បានធ្វើឡើងដោយខ្លួនឯង លើកលែងតែករណីដែលភាគី ឬ តំណាង

ដោយអាណត្តិ លុបចោល ឬ កែតម្រូវភ្លាមៗ ។

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្តី

### ផ្នែកទី ១
### អត្ថន័យ និង ប្រភេទនៃប្រាក់ប្រដាប់ក្តី

**មាត្រា ៥៩.-** ទំហំ និង ចំនួននៃប្រាក់ប្រដាប់ក្តីរដ្ឋប្បវេណីដែលភាគី ឬ បុគ្គលផ្សេង ត្រូវទទួលបន្ទុក

យោងទៅតាមបញ្ញត្តិនៃមាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនេះ ភាគី ឬ បុគ្គលផ្សេង ត្រូវទទួលបន្ទុកក្នុងការបង់ប្រាក់ប្រដាប់ក្តីតុលាការដែលបានកំណត់នៅក្នុងមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) និង មាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង ប្រាក់ប្រដាប់ក្តីភាគីដែលបានកំណត់នៅក្នុងមាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីភាគី) នៃក្រមនេះ ។

**មាត្រា ៦០.-** ការគណនាតម្លៃកម្មវត្ថុនៃបណ្តឹង ការគណនាតម្លៃក្នុងករណីបណ្តឹងទាមទារច្រើនចំណុច

១-តម្លៃកម្មវត្ថុនៃបណ្តឹងត្រូវបានគណនា ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ដែលបានទាមទារក្នុងបណ្តឹងនោះ ។ ក្នុងករណីដែលការទាមទារច្រើនចំណុចក្នុងបណ្តឹងតែមួយ តម្លៃសរុបនៃការទាមទារទាំងនោះ ត្រូវបានចាត់ទុកជាតម្លៃកម្មវត្ថុនៃបណ្តឹង ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះការទាមទារនីមួយៗ ក្នុងករណីដែលផលប្រយោជន៍ដែលបានទាមទារ មានលក្ខណៈដូចគ្នាចំពោះការទាមទារនីមួយៗនោះ ។

២-ក្នុងករណីដែលការទាមទារលើផល សំណងនៃការខូចខាត ប្រាក់ធានាសងក្នុងករណីបំពានកិច្ចសន្យា ឬ សោហ៊ុយ គឺជាកម្មវត្ថុបន្ទាប់បន្សំនៃបណ្តឹង នោះតម្លៃទាំងនោះមិនត្រូវបូកសរុបលើការគណនាតម្លៃកម្មវត្ថុនៃបណ្តឹងឡើយ ។

៣-ក្នុងករណីដែលមានការពិបាកក្នុងការគណនាតម្លៃដែលបានកំណត់ក្នុងកថា-

ខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវកំណត់តម្លៃនោះ ដោយឆន្ទានុសិទ្ធិសមហេតុផល ។ ក្នុងករណីដែលតម្លៃនោះមិនអាចគណនាបានទេ នោះត្រូវចាត់ទុកថា មានចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល ។

**មាត្រា ៦១.-** ពន្ធដាក់ពាក្យសុំ

១-ពេលដែលដាក់ពាក្យបណ្តឹង ត្រូវបង់ពន្ធដែលមានចំនួនប្រាក់ដោយគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹង ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ ទៅតុលាការ :

ក-ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដល់ ១០.០០០.០០០ (ដប់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ១.០០០ (មួយពាន់) រៀល ។

ខ-ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១០.០០០.០០០ (ដប់លាន) រៀលដល់ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ៧០០ (ប្រាំពីររយ) រៀល ។

គ-ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១០០.០០០.០០០ (មួយរយលាន) រៀលដល់ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ៣០០ (បីរយ) រៀល ។

ឃ-ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១.០០០.០០០.០០០(មួយពាន់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ១០០ (មួយរយ) រៀល ។

២-តម្លៃកម្មវត្ថុនៃបណ្តឹង ដែលជាមូលដ្ឋានដើម្បីធ្វើការគណនាពន្ធដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាតាមបញ្ញត្តិនៃមាត្រា ៦០ (ការគណនាតម្លៃកម្មវត្ថុនៃបណ្តឹង ការគណនាតម្លៃក្នុងករណីបណ្តឹងទាមទារច្រើនចំណុច) នៃក្រមនេះ ។

៣-ចំពោះការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវបង់ពន្ធ ១,៥ ដង (មួយក្បៀសប្រាំដង) នៃពន្ធដែលបានគណនាតាមកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ រីឯចំពោះការដាក់ពាក្យបណ្តឹងសាទុក្ខវិញ ត្រូវបង់ពន្ធ ២ ដង (ពីរដង) នៃពន្ធដែលបានគណនាតាមកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ទៅតុលាការ ។

៤-ចំពោះការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ត្រូវបង់ ១០.០០០ (មួយម៉ឺន) រៀល ទៅតុលាការ ។

៥-ចំពោះការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវបង់ពន្ធដែលមានចំនួន ១ ភាគ ២ (មួយភាគពីរ) នៃចំនួនប្រាក់ដោយគណនាតាមកថាខណ្ឌទី ១ ខាងលើនេះ ទៅតាមតម្លៃកម្មវត្ថុនៃការទាមទារ ។ បើចាត់ទុកថា មានការដាក់ពាក្យបណ្ដឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣២៧ (អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) ឬ មាត្រា ៣៣១ (ការផ្ទេរនីតិវិធីដាស់តឿនទៅនីតិវិធីនៃបណ្ដឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) នៃក្រមនេះ អ្នកដែលបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវបង់ពន្ធចំនួនប្រាក់ដែលគណនា ដោយដកចំនួនពន្ធដែលខ្លួនបានបង់ចំពោះការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ពីចំនួនពន្ធដែលបានគណនាតាមកថាខណ្ឌទី ១ ខាងលើនេះ ។

៦-ចំពោះករណីដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្ដី ក្រៅពីការកំណត់នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ និង បញ្ញត្តិពីកថាខណ្ឌទី ៣ ទៅទី ៥ ត្រូវបង់ ៥.០០០ (ប្រាំពាន់) រៀលទៅតុលាការ ។

៧-ការបង់ពន្ធត្រូវធ្វើដោយការបង់ជាប្រាក់នៅកន្លែងទទួលពាក្យនៃតុលាការ ។ ពាក្យសុំដែលមិនបានបង់ពន្ធនៅពេលដាក់ទេ ត្រូវចាត់ទុកថាជាពាក្យសុំមិនស្របច្បាប់ ។

៨-ក្នុងករណីដែលបានរៀបរាប់ខាងក្រោមនេះ យោលទៅតាមពាក្យសុំរបស់អ្នកដែលបានបង់ តុលាការនឹងត្រូវសងនូវពន្ធដែលកំណត់ដោយចំណុចខាងក្រោមនេះ :

ក-ករណីដែលបង់ពន្ធលើស : សងពន្ធដែលបានបង់លើសទៅវិញ ។

ខ-ករណីដែលការផ្សះផ្សាបានលទ្ធផលមុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ករណីដែលដកពាក្យបណ្ដឹងមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង និង ករណីដែលសេចក្ដីសម្រេចលើកចោលពាក្យបណ្ដឹងដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ចូលជាស្ថាពរ : សងពាក់កណ្ដាលនៃពន្ធដែលបានបង់ហើយទៅវិញ ។

**មាត្រា ៦២.-** ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

១-ភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្ដី ត្រូវបង់ប្រាក់ប្រដាប់ក្ដីខាងក្រោមនេះ ទៅ

តាមចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ :

ក-ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬ សកម្មភាពផ្សេងទៀត តាមនីតិវិធីក្នុងបណ្តឹងរដ្ឋប្បវេណី ។

ខ-ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និង ក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវ-ជ្រាវអង្គហេតុ ឬ សកម្មភាពផ្សេងទៀត ដែលប្រព្រឹត្តទៅនៅក្រៅតុលាការ ។

២-ភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្តី ដែលត្រូវបង់ប្រាក់ប្រដាប់ក្តីដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់សកម្មភាពដែលធ្វើឡើងដោយពាក្យសុំ គឺអ្នកដាក់ពាក្យសុំ រីឯចំពោះប្រាក់ប្រដាប់ក្តីសម្រាប់សកម្មភាពដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ គឺអ្នកដែលតុលាការបានកំណត់ឱ្យបង់ ។

៣-ចំពោះសកម្មភាពដែលត្រូវបង់ប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវបង្គាប់ឱ្យភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្តី បង់ចំនួននោះជាមុន ។

៤-ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីជាមុន តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ តែសាមីខ្លួនមិនបានបង់ជាមុនទេនោះ តុលាការអាចមិនធ្វើនូវសកម្មភាពដែលចាំបាច់ត្រូវមានប្រាក់ប្រដាប់ក្តីនោះបាន ។

៥-ចំពោះប្រាក់ប្រដាប់ក្តីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ដែលមិនបានបង់ជាមុនទេ តុលាការអាចប្រមូលពីអ្នកដែលត្រូវទទួលបន្ទុកលើការបង់ប្រាក់ប្រដាប់ក្តីនោះបាន ដោយអាស្រ័យលើដីកាសម្រេចរបស់តុលាការ តាមបញ្ញត្តិនៃមាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនេះ ។

**មាត្រា ៦៣.-** ប្រាក់ប្រដាប់ក្តីភាគី

ក្រៅពីការកំណត់នៅក្នុងមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) និង មាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) ខាងលើនេះ ចំនួនទឹកប្រាក់ដែលតុលាការកំណត់ថាសមរម្យដោយគិតពិចារណានូវលក្ខណៈនៃរឿងក្តី ឬ លទ្ធភាពទ្រព្យធនរបស់ភាគី ជាអាទិ៍ ក្នុងចំណោមការកំណត់ក្នុងចំណុចខាងក្រោមនេះ ក៏ត្រូវចាត់ទុកថាជាប្រាក់ប្រដាប់ក្តីដែរ :

ក-ថ្លៃធ្វើលិខិត ដូចជា លិខិតពាក្យបណ្តឹង លិខិតពាក្យសុំផ្សេងទៀត ឬ ឯក-

សារផ្សេងៗ ដូចជា ឯកសារត្រៀម ជាអាទិ៍ និង ថ្ងៃដាក់ឯកសារនោះទៅតុលាការ ។

ខ-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និង សោហ៊ុយស្នាក់នៅសម្រាប់ភាគីនិងអ្នកតំណាង ដើម្បីបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ ។

គ-សោហ៊ុយផ្សេងទៀត ដែលតុលាការទទួលស្គាល់ថាជាសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនូវនីតិវិធីបណ្តឹង ។

## ផ្នែកទី ២
## បន្ទុកនៃប្រាក់ប្រដាប់ក្តី

**មាត្រា ៦៤.-** ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ

១-ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។ ក្នុងករណីដែលបានចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗត្រូវទទួល ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២-ទោះបីមានកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏តុលាការអាចសម្រេចតាមកាលៈទេសៈ ឱ្យភាគីឈ្នះក្តីទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីទាំងអស់ ឬ មួយភាគបាន ក្នុងករណីដែលភាគីឈ្នះក្តីនោះបានប្រព្រឹត្តសកម្មភាពបណ្តឹងណាមួយ ដែលមិនចាំបាច់ក្នុងការតទល់ ឬ ការការពារខ្លួន ឬ បានធ្វើនីតិវិធីនៃបណ្តឹងឱ្យមានការយឺតយ៉ាវ ។

៣-អ្នកដែលធ្វើសហបណ្តឹងត្រូវទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីស្មើភាគគ្នា ។ ប៉ុន្តែតុលាការអាចសម្រេចតាមកាលៈទេសៈ ឱ្យភាគីដែលធ្វើសហបណ្តឹងទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ដោយសាមគ្គីភាពបាន ឬ អាចសម្រេចឱ្យភាគីណាមួយដែលបានប្រព្រឹត្តសកម្មភាពបណ្តឹងណាដែលមិនចាំបាច់ក្នុងការតទល់ ឬ ការការពារខ្លួន ទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីច្រើនជាងភាគីដែលធ្វើសហបណ្តឹងផ្សេងទៀតបាន ។

៤-ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងដោយអាណត្តិ ឬ ក្រឡាបញ្ជី បានធ្វើឱ្យចំនួនទឹកប្រាក់ប្រដាប់ក្តីដែលគ្មានប្រយោជន៍កើតឡើង ដោយចេតនា ឬ ដោយមានកំហុសធ្ងន់ធ្ងររបស់ខ្លួន តុលាការដែលបានទទួលពាក្យបណ្តឹង អាចបង្គាប់ឱ្យអ្នកនោះសងនូវចំនួននៃប្រាក់ប្រដាប់ក្តីនោះវិញបាន ដោយដីកាសម្រេច តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

៥-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៦៥.–** ការសម្រេចសេចក្ដីលើបន្ទុកនៃការបង់ប្រាក់ប្រដាប់ក្ដី

១-ក្នុងការសម្រេចសេចក្ដីដើម្បីបញ្ចប់រឿងក្ដី តុលាការត្រូវធ្វើការសម្រេចសេចក្ដីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដីទាំងអស់ នៅថ្នាក់នៃការជម្រះក្ដីនោះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២-ក្នុងករណីដែលតុលាការជាន់ខ្ពស់បានផ្លាស់ប្ដូរសេចក្ដីសម្រេចអង្គសេចក្ដី តុលាការត្រូវធ្វើការសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដីទាំងអស់ឡើងវិញ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលតុលាការដែលទទួលបណ្ដឹងដែលត្រូវបានបញ្ជូនត្រឡប់មកវិញ ឬ ត្រូវបានផ្ទេរ សម្រេចសេចក្ដីដើម្បីបញ្ចប់រឿងក្ដីនោះ ។

៣-ក្នុងករណីដែលរឿងក្ដីនោះបានចប់ដោយមិនធ្វើទៅតាមការសម្រេចសេចក្ដីទេនោះ តុលាការនៃការជំនុំជម្រះលើកទី ១ ត្រូវបង្គាប់ឱ្យទទួលបន្ទុកក្នុងការបង់ប្រាក់ប្រដាប់ក្ដីនោះ តាមពាក្យសុំ ដោយដីកាសម្រេច ។ ប៉ុន្ដែ ចំពោះបណ្ដឹងដែលបានផ្សះផ្សាគ្នាហើយនោះ ប្រាក់ប្រដាប់ក្ដីត្រូវបានបង់ទៅតាមការព្រមព្រៀងគ្នា ហើយប្រសិនបើគ្មានការព្រមព្រៀងគ្នាទេ ភាគីនីមួយៗត្រូវទទួលបន្ទុកក្នុងការបង់រៀងៗខ្លួន ។

**មាត្រា ៦៦.–** នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្ដី

១-ចំនួនប្រាក់ប្រដាប់ក្ដីដែលត្រូវទទួលបន្ទុកបង់ ត្រូវកំណត់ដោយក្រឡាបញ្ជីរបស់តុលាការនៃការជំនុំជម្រះលើកទី ១ តាមពាក្យសុំ នៅក្រោយពេលដែលសេចក្ដីសម្រេចអំពីបន្ទុកនោះបានបង្កើតអានុភាពនៃការអនុវត្ត ។

២-ចំពោះករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគូភាគីទាំងសងខាងទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី ប្រាក់ដែលភាគីនីមួយៗត្រូវទទួលបន្ទុកបង់នោះ ត្រូវបានចាត់ទុកថា បានធ្វើការទូទាត់ជាមួយនឹងគ្នា ចំពោះចំនួនទឹកប្រាក់ដែលត្រូវគ្នារួចហើយ ។

៣-ការចាត់ចែងលើពាក្យសុំដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងមានអានុភាព បន្ទាប់ពីបានជូនដំណឹង តាមរបៀបដែលអាចចាត់ទុកថាសមរម្យ ។

៤-ការធ្វើបណ្ដឹងតវ៉ាចំពោះការចាត់ចែងដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ ក្រោយពីបានទទួលដំណឹងនោះ ។

ក្នុងករណីដែលតុលាការទទួលស្គាល់ថា បណ្តឹងតវ៉ានោះមានមូលហេតុត្រឹមត្រូវ តុលាការត្រូវកំណត់ចំនួននៃបន្ទុកប្រាក់ប្រដាប់ក្តី ដោយខ្លួនឯង ។

៥-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ៣
## ប្រាតិភោគលើប្រាក់ប្រដាប់ក្តី

**មាត្រា ៦៧.–** ដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ

១-ប្រសិនបើដើមចោទគ្មានលំនៅឋាន ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជាទេ តុលាការត្រូវបង្គាប់ឱ្យដើមចោទដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្តី តាមពាក្យសុំរបស់ចុងចម្លើយ ដោយដីកាសម្រេច ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរចំពោះករណីដែលប្រាតិភោគនោះមានការខ្វះខាត ។

២-ប្រសិនបើចុងចម្លើយបានធ្វើសេចក្តីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ បានឆ្លើយទាញហេតុផលអំពីអង្គសេចក្តីនៃបណ្តឹងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ក្រោយពីបានដឹងថា មានមូលហេតុដែលតម្រូវឱ្យដាក់ប្រាតិភោគ នោះចុងចម្លើយមិនអាចដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបានឡើយ ។

៣-ចុងចម្លើយដែលបានដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបដិសេធមិនព្រមតទល់នឹងបណ្តឹងនេះរហូតដល់ពេលដែលដើមចោទដាក់ប្រាតិភោគបាន ។

៤-តុលាការត្រូវកំណត់នូវចំនួននៃប្រាតិភោគ និង អំឡុងពេលដែលត្រូវដាក់ប្រាតិភោគ នៅក្នុងដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៥-ចំនួននៃប្រាតិភោគ ត្រូវកំណត់ដោយយកចំនួនសរុបនៃប្រាក់ប្រដាប់ក្តីដែលចុងចម្លើយត្រូវចំណាយនៅគ្រប់ថ្នាក់នៃការជំនុំជម្រះ ជាមូលដ្ឋាន ។

៦-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ៦៨.–** អានុភាពនៃការមិនដាក់ប្រាតិភោគ

ប្រសិនបើដើមចោទ មិនបានដាក់ប្រាតិភោគ ក្នុងអំឡុងពេលដែលត្រូវដាក់នោះទេ តុលាការអាចលើកចោលនូវបណ្តឹងដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្រាតិភោគត្រូវបានដាក់មុនពេលចេញសាលក្រម ។

## ផ្នែកទី ៤
## ជំនួយសង្គ្រោះលើបណ្តឹង

**មាត្រា ៦៩.–** ការផ្តល់ជំនួយសង្គ្រោះលើបណ្តឹង

១-ចំពោះបុគ្គលដែលគ្មានលទ្ធភាពទ្រព្យធននឹងបង់ប្រាក់ដែលចាំបាច់ដើម្បីរៀបចំ និង ប្រព្រឹត្តទៅនីតិវិធីបណ្តឹង ឬ បុគ្គលដែលអាចមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាព ដោយសារការបង់ប្រាក់នេះ តុលាការអាចចេញដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្តឹង តាមពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលច្បាស់ជាគ្មានលទ្ធភាពនឹងឈ្នះក្តីសោះ ។

២-ដីកាសម្រេចឱ្យជួយសង្គ្រោះនេះ ត្រូវធ្វើឡើងតាមថ្នាក់នៃការជំនុំជម្រះនីមួយៗ ។

៣-ចំពោះហេតុនៃការផ្តល់ជំនួយសង្គ្រោះលើបណ្តឹង ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

**មាត្រា ៧០.–** ខ្លឹមសារនៃជំនួយសង្គ្រោះលើបណ្តឹង

១-ដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្តឹង ត្រូវមានអានុភាពទៅតាមការកំណត់ក្នុងដីកាសម្រេចដូចខាងក្រោមនេះ :

ក-ការពន្យារពេលបង់ប្រាក់ប្រដាប់ក្តីតុលាការ ។

ខ-ការអនុគ្រោះមិនបាច់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការ ។ ប៉ុន្តែ ការសម្រេចនេះ អាចធ្វើបានចំពោះតែករណីណាដែលតុលាការបានយល់ឃើញថាសមរម្យ ដោយគិតពិចារណាលើលទ្ធភាពទ្រព្យធនរបស់ភាគី ជាអាទិ៍ នៅក្រោយពេលដែលការពន្យារពេលនេះបានរលត់ ។

២-ដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្តឹងនេះ អាចមានអានុភាពទៅលើតែបុគ្គល

ដែលបានទទួលដីកានោះតែប៉ុណ្ណោះ ។

៣-ក្នុងករណីដែលបុគ្គលដែលបានទទួលដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្ដឹង ត្រូវបានយល់ឃើញថា គ្មានល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងមាត្រា ៦៩ (ការផ្ដល់ជំនួយសង្គ្រោះលើបណ្ដឹង) ខាងលើនេះ ឬ បុគ្គលនោះបានបាត់បង់ល័ក្ខខ័ណ្ឌនោះ តុលាការដែលមានសំណុំរឿង អាចលុបចោលដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្ដឹងនេះ ហើយបង្គាប់ឱ្យភាគីនោះ បង់ប្រាក់ដែលតុលាការបានពន្យារ ឬ អនុគ្រោះមិនឱ្យបង់ នៅពេលណាក៏បាន តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនដោយដីកាសម្រេច ។

៤-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងមាត្រា ៦៩ (ការផ្ដល់ជំនួយសង្គ្រោះលើបណ្ដឹង) នៃក្រមនេះ និង មាត្រានេះ អាចប្ដឹងជំទាស់បាន ។

## ជំពូកទី ៥
## ប្រាតិភោគលើបណ្ដឹង

**មាត្រា ៧១.–** វិធីដាក់ប្រាតិភោគ និង ការប្ដូរប្រាតិភោគ

១-ការដាក់ប្រាតិភោគ ត្រូវធ្វើតាមវិធីតម្កល់ជាប្រាក់ ឬ ជាឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់ថាសមរម្យ នៅកន្លែងតម្កល់ ឬ វិធីធ្វើប្រាក់ ឬ ឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់ថាសមរម្យ នៅតុលាការ ឬ វិធីដែលបានកំណត់ផ្សេង ។

២-តុលាការអាចបង្គាប់ឱ្យប្ដូរប្រាតិភោគ តាមពាក្យសុំរបស់អ្នកដែលបានដាក់ប្រាតិភោគនោះដោយដីកាសម្រេចបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនបិទសិទ្ធិរបស់ភាគី ក្នុងការប្ដូរប្រាតិភោគនោះ ទៅប្រាតិភោគផ្សេងទៀត តាមកិច្ចសន្យាឡើយ ។

**មាត្រា ៧២.–** សិទ្ធិរបស់អ្នកដែលទទួលការផ្ដល់ប្រាតិភោគ

បុគ្គលដែលទទួលការផ្ដល់ប្រាតិភោគដើម្បីជាផលប្រយោជន៍របស់ខ្លួន មានសិទ្ធិជាអាទិភាពទៅលើម្ចាស់បំណុលផ្សេងទៀត ក្នុងការទទួលការសងចំពោះប្រាក់ ឬ ឧបករណ៍អាចជួញដូរបានដែលត្រូវបានតម្កល់ ឬ ផ្ញើ តាមបញ្ញត្តិនៃមាត្រា ៧១ (វិធីដាក់ប្រាតិភោគ

និង ការប្តូរប្រាតិភោគ) ខាងលើនេះ ដើម្បីសងចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានា ។

**មាត្រា ៧៣.-** ការលុបចោលនូវប្រាតិភោគ

១-អ្នកមានសិទ្ធិលើប្រាតិភោគ ក្នុងមាត្រានេះ សំដៅទៅលើបុគ្គលដែលទទួលការផ្តល់ប្រាតិភោគ ដើម្បីជាផលប្រយោជន៍របស់ខ្លួន ។

២-ប្រសិនបើអ្នកដែលបានដាក់ប្រាតិភោគ បានបញ្ជាក់នូវការរលត់នៃហេតុដែលត្រូវដាក់ប្រាតិភោគ តុលាការត្រូវចេញដីកាសម្រេចលុបចោលនូវប្រាតិភោគនោះ តាមពាក្យសុំ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នា ចំពោះករណីអ្នកដែលបានដាក់ប្រាតិភោគ បានបញ្ជាក់ថា ខ្លួនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិលើប្រាតិភោគអំពីការលុបចោលប្រាតិភោគនោះ ។

៤-ក្រោយពីហេតុដែលអ្នកមានសិទ្ធិលើប្រាតិភោគអាចប្រើសិទ្ធិរបស់ខ្លួននោះ បានកើតមានឡើង ប្រសិនបើតុលាការជូនដំណឹងឱ្យអ្នកមានសិទ្ធិលើប្រាតិភោគថា ខ្លួនត្រូវប្រើសិទ្ធិរបស់ខ្លួននោះក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ តាមពាក្យសុំរបស់អ្នកដែលបានដាក់ប្រាតិភោគ តែអ្នកមានសិទ្ធិលើប្រាតិភោគនោះមិនបានប្រើសិទ្ធិរបស់ខ្លួនទេ អ្នកមានសិទ្ធិលើប្រាតិភោគនោះ ត្រូវបានចាត់ទុកថា បានយល់ព្រមចំពោះការលុបចោលនូវប្រាតិភោគនោះ ។

៥-ចំពោះដីកាសម្រេច ដែលបានកំណត់នៅកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

# គន្ថីទី ២
# នីតិវិធីនៃការជម្រះក្ដីលើកទី ១

## ជំពូកទី ១
## បណ្ដឹង

**មាត្រា ៧៤.–** ផលប្រយោជន៍នៃបណ្ដឹង

បណ្ដឹងអាចធ្វើឡើងបាន ក្នុងករណីដែលបណ្ដឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្ដែង និង ដែលវិវាទនោះអាចដោះស្រាយដោយសាលក្រម ។

**មាត្រា ៧៥.–** របៀបដាក់ពាក្យបណ្ដឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង

១-ការប្ដឹង ត្រូវធ្វើដោយដាក់ពាក្យបណ្ដឹងជាលាយល័ក្ខណ៍អក្សរ ទៅតុលាការ ។

២-នៅក្នុងលិខិតនៃពាក្យបណ្ដឹង ត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។

៣-នៅក្នុងពាក្យបណ្ដឹង ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខណ្ឌទី ២ ខាងលើនេះ ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង ។

៤-ពាក្យបណ្ដឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវចាត់ជាឯកសារត្រៀមផងដែរ ។

**មាត្រា ៧៦.–** បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនៅពេលអនាគត

បណ្ដឹងទាមទារការផ្ដល់តាវកាលិកនៅពេលអនាគត អាចធ្វើឡើងបាន លុះត្រាតែមាន

ភាពចាំបាច់តម្រូវឱ្យធ្វើការទាមទារនោះជាមុន ។

**មាត្រា ៧៧.-** ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ

ការទាមទារច្រើនចំណុច អាចយកមកបញ្ចូលក្នុងបណ្តឹងតែមួយបាន លុះត្រាតែបណ្តឹងនោះដោះស្រាយដោយនីតិវិធីប្រភេទដូចគ្នា ។

**មាត្រា ៧៨.-** ការពិនិត្យពាក្យបណ្តឹង

១-ក្នុងករណីដែលពាក្យបណ្តឹងផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៧៥ (របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង) ខាងលើនេះ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះ ចំពោះពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលពន្ធសម្រាប់ដាក់ពាក្យបណ្តឹង មិនត្រូវបានបង់តាមបញ្ញត្តិនៃមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) នៃក្រមនេះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះទេ តុលាការត្រូវលើកពាក្យបណ្តឹងចោល ដោយដីកាសម្រេច ។

៣-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ៧៩.-** ការបញ្ជូនពាក្យបណ្តឹង

១-ពាក្យបណ្តឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ។

២-បញ្ញត្តិនៃមាត្រា ៧៨ (ការពិនិត្យពាក្យបណ្តឹង) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពាក្យបណ្តឹងមិនអាចបញ្ជូនទៅបាន ។ បញ្ញត្តិនោះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលដើមចោទមិនបានបង់ប្រាក់សម្រាប់បញ្ជូនពាក្យបណ្តឹងទុកជាមុន ។

**មាត្រា ៨០.-** ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង

១-នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងរហ័ស និង កោះហៅគូភាគី ។

២-កាលបរិច្ឆេទដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស ។

**មាត្រា ៨១.-** ការលើកបណ្តឹងចោល ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់

ក្នុងករណីដែលបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការអាចលើកបណ្តឹងនោះចោល ដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

**មាត្រា ៨២.-** ការលើកបណ្តឹងចោលក្នុងករណីដែលមិនបានបង់ជាមុននូវប្រាក់សម្រាប់ធ្វើការកោះហៅ

១-ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យដើមចោទបង់ជាមុននូវប្រាក់ ដែលជាចាំបាច់សម្រាប់កោះហៅភាគីឱ្យចូលមកនៅកាលបរិច្ឆេទតាមបញ្ញត្តិនៃក្រមនេះ ដោយកំណត់អំឡុងពេលសមរម្យ តែដើមចោទមិនបានបង់ប្រាក់នោះជាមុនទេ តុលាការអាចលើកចោលបណ្តឹងដោយដីកាសម្រេចបាន លុះត្រាតែចុងចម្លើយគ្មានការតវ៉ា ។

២-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ៨៣.-** ការហាមបណ្តឹងជាន់គ្នា

ចំពោះរឿងក្តីដែលតុលាការកំពុងចាត់ការ ភាគីមិនអាចប្តឹងទៀតបានឡើយ ។

**មាត្រា ៨៤.-** ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង

១-ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែមិនមានការប្តូរមូលដ្ឋាននៃការទាមទារ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលធ្វើឱ្យនីតិវិធីនៃបណ្តឹងមានការយឺតយ៉ាវខ្លាំងដោយសារការបន្ថែម ឬ ការផ្លាស់ប្តូរនោះ ។

២-ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។

៣-ឯកសារដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ត្រូវបញ្ជូនទៅភាគីម្ខាងទៀត ។

៤-ពេលដែលយល់ឃើញថា ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង មិនត្រឹមត្រូវទេ តុលាការត្រូវចេញដីកាសម្រេចមិនយល់ព្រមនឹងការបន្ថែម ឬ ការផ្លាស់ប្តូរនោះ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

**មាត្រា ៨៥.-** ការប្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី

១-ក្នុងករណីដែលការសម្រេចសេចក្តី អាស្រ័យទៅលើអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងគតិយុត្តដែលជាចំណុចវិវាទ ក្នុងដំណើរការពាក់កណ្តាលទី ដើមចោទអាចពង្រីកការទាមទារ ឬ ចុងចម្លើយអាចប្តឹងតប ដើម្បីឱ្យតុលាការបញ្ជាក់ពីអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងគតិយុត្តដែលជាចំណុចវិវាទ នៅក្នុងសាលក្រមបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការទាមទារការបញ្ជាក់នោះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដទៃទៀតតាមច្បាប់ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៨៤ (ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការពង្រីកការទាម-ទារតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៨៦.-** បណ្តឹងតប

១-ចុងចម្លើយអាចប្តឹងតប ទៅតុលាការដែលកំពុងចាត់ការបណ្តឹងដើម រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងតបនោះទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬ មធ្យោបាយការ-ពារខ្លួនសម្រាប់បណ្តឹងដើម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការទាមទារជាកម្មវត្ថុនៃបណ្តឹងតបនោះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលា-ការដទៃទៀតតាមច្បាប់ ឬ ករណីដែលការប្តឹងតបនោះនឹងធ្វើឱ្យមានការយឺតយ៉ាវយ៉ាងខ្លាំងក្នុងនីតិវិធីនៃបណ្តឹង ។

២-បញ្ញត្តិដែលទាក់ទងនឹងបណ្តឹង ត្រូវយកមកអនុវត្ត ចំពោះបណ្តឹងតប ។

**មាត្រា ៨៧.-** ពេលនៃការបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាល ជាអាទិ៍

ការទាមទារតាមផ្លូវតុលាការដែលចាំបាច់សម្រាប់ការផ្អាកអាជ្ញាយុកាល ឬ សម្រាប់ការប្រព្រឹត្តទៅតាមអំឡុងពេលគតិយុត្ត នឹងបង្កើតអានុភាពនៅពេលបានដាក់ពាក្យបណ្តឹង ឬ ពេលដែលដាក់ទៅតុលាការនូវឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ៨៤ (ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង) ឬ កថាខណ្ឌទី ២ មាត្រា ៨៤ (ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង) ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងបញ្ញត្តិនៃកថា-ខណ្ឌទី ២ មាត្រា ៨៥ (ការប្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី) នៃក្រមនេះ ។

**មាត្រា ៨៨.–** អនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍

១-ទោះបីបណ្តឹងកំពុងត្រូវបានចាត់ការក៏ដោយ ក៏ភាគីនៃបណ្តឹងមិនត្រូវបានរារាំងក្នុងការធ្វើអនុប្បទាន ឬ ការផ្ទេរវត្ថុដែលជាកម្មវត្ថុនៃវិវាទ ឬ សិទ្ធិឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនោះដែរ ។

២-អនុប្បទាន ឬ ការផ្ទេរដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំមានឥទ្ធិពលទៅលើបណ្តឹងទេ ។ អ្នកដែលបានធ្វើអនុប្បទាន ឬ ផ្ទេរ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក៏នៅតែមានឋានៈជាភាគីនៃបណ្តឹងដដែល ក្រោយពីបានផ្ទេរ ។

៣-បញ្ញត្តិនៃមាត្រា ៤៨ (ការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះករណីដែលអ្នកដែលបានទទួលអនុប្បទាន ឬ ការផ្ទេរដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្លាយជាអ្នកចូលរួមជួយអន្តរាគមន៍ ។

## ជំពូកទី ២
## ការទាញហេតុផលដោយផ្ទាល់មាត់ និង ការរៀបចំ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៩.–** ការដឹកនាំនីតិវិធីនៃបណ្តឹងដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ

១-ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវដឹកនាំចាត់ចែងនីតិវិធីត្រៀមសម្រាប់ការទាញ

ហេតុផល និង ត្រូវដឹកនាំចាត់ចែងការទាញហេតុផលដោយផ្ទាល់មាត់ ។

២-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់និយាយបាន និង អាចហាមជនដែលមិនស្ដាប់បញ្ជារបស់ខ្លួនមិនឱ្យនិយាយបាន ។

**មាត្រា ៩០.–** សិទ្ធិឱ្យបំភ្លឺ ជាអាទិ៍

១-ដើម្បីឱ្យចំណុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងនឹងបណ្ដឹង មានភាពច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់ភស្ដុតាង ចំពោះចំណុចនោះ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២-ភាគីអាចទាមទារឱ្យតុលាការសួរសំណួរចាំបាច់ទៅភាគីម្ខាងទៀត នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

៣-នៅក្រៅពីកាលបរិច្ឆេទ តុលាការអាចបង្គាប់ឱ្យភាគីត្រៀមខ្លួននឹងរៀបចំការឆ្លើយបំភ្លឺ នៅកាលបរិច្ឆេទបន្ទាប់ ដោយបញ្ជាក់ចំណុចដែលតុលាការយល់ឃើញថា ត្រូវការឱ្យបំភ្លឺជាចាំបាច់ ។

**មាត្រា ៩១.–** បណ្ដឹងតវ៉ាចំពោះការដឹកនាំនីតិវិធីបណ្ដឹង

ក្នុងករណីដែលភាគីបានធ្វើបណ្ដឹងតវ៉ា ចំពោះការដឹកនាំការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់ ឬ ចំពោះការចាត់ចែងរបស់តុលាការ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩០ (សិទ្ធិឱ្យបំភ្លឺ ជាអាទិ៍) ខាងលើនេះ តុលាការត្រូវសម្រេចសេចក្ដី ចំពោះបណ្ដឹងតវ៉ានោះ ដោយដីកាសម្រេច ។

**មាត្រា ៩២.–** ករណីយកិច្ចស្រាវជ្រាវរបស់ភាគី

ភាគីត្រូវធ្វើការស្រាវជ្រាវឱ្យបានលំអិតជាមុន នូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី និង ភស្ដុតាងផ្សេងៗ ដើម្បីធ្វើការអះអាង និង បញ្ជាក់ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ក្នុងបណ្ដឹង ។

**មាត្រា ៩៣.–** ពេលដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

មធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសម-

រម្យ ទៅតាមដំណើរការនៃបណ្តឹង ។

**មាត្រា ៩៤.-** ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ

១-ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់ទៅតុលាការយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ ដោយចេតនា ឬ ដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនបាន តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា ការដាក់មធ្យោបាយនោះ ធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីនៃបណ្តឹង ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដែរ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលមានអត្ថន័យមិនច្បាស់លាស់ ក្នុងករណីដែលភាគីមិនបានធ្វើការបំភ្លឺចាំបាច់ ឬ មិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកោះហៅឱ្យមកបំភ្លឺទេ ។

**មាត្រា ៩៥.-** អង្គហេតុដែលអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រម

តុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ។

**មាត្រា ៩៦.-** ការចាត់ទុកថាបានសារភាព

១-ក្នុងករណីដែលភាគីមិនបានបង្ហាញច្បាស់លាស់ នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ទេ ភាគីនោះត្រូវបានចាត់ទុកថា បានសារភាពអំពីអង្គហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតុលាការគិតពិចារណាអំពីដំណើរការ និង ខ្លឹមសារនៃរឿងក្តី ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុ ។

២-ក្នុងករណីដែលភាគីធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនដឹងអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង ភាគីនោះ ត្រូវបានសន្មតថា បានតវ៉ាអំពីអង្គហេតុនោះ ។

**មាត្រា ៩៧.-** ការសាកល្បងធ្វើការផ្សះផ្សា

តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាល

ណាក៏ដោយ ។

**មាត្រា ៩៨.–** ការបាត់បង់នូវសិទ្ធិប្ដឹងតវ៉ាស្ដីអំពីនីតិវិធីនៃបណ្ដឹង

១-ក្នុងករណីដែលភាគីម្ខាង ឬ តុលាការ បានធ្វើសកម្មភាពបណ្ដឹងណាមួយដែលផ្ទុយពីបញ្ញត្តិអំពីនីតិវិធីនៃបណ្ដឹង ភាគីអាចប្ដឹងតវ៉ាចំពោះសកម្មភាពនោះទៅតុលាការ ហើយអាចអះអាងអំពីមោឃភាពនៃសកម្មភាពនោះបាន ។

២-ក្នុងករណីដែលភាគីដឹង ឬ អាចដឹងអំពីភាពខុសច្បាប់ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយមិនបានធ្វើការប្ដឹងតវ៉ានៅពេលសមរម្យទេ ភាគីនោះត្រូវបាត់បង់សិទ្ធិប្ដឹងតវ៉ានេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមិនអាចបោះបង់សិទ្ធិនេះបាន ។

**មាត្រា ៩៩.–** ការបំបែក និង ការរួមបញ្ចូលរឿងក្ដី

១-តុលាការអាចបង្គាប់ឱ្យបំបែក ឬ បញ្ចូលរឿងក្ដី ដោយដីកាសម្រេច ឬ អាចលុបចោលដីកាសម្រេចនោះបាន ។

២-ក្នុងករណីតុលាការបានបង្គាប់ឱ្យបញ្ចូលរឿងក្ដីដែលមានភាគីខុសគ្នា នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលភាគីដែលមិនមានឱកាសសាកសួរសាក្សី ដោយសារសាក្សីនោះត្រូវបានសាកសួររួចហើយមុនពេលបញ្ចូលរឿងក្ដី បានដាក់ពាក្យសុំសាកសួរសាក្សីនោះ តុលាការត្រូវសាកសួរសាក្សីនោះ ។

**មាត្រា ១០០.–** ការចូលរួមរបស់អ្នកបកប្រែ ជាអាទិ៍

១-ប្រសិនបើជនដែលទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណី មិនអាចយល់ភាសាខ្មែរ ឬ ថ្លង់ ឬ គ តុលាការត្រូវឱ្យមានអ្នកបកប្រែដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ចូលរួមជាមួយនឹងជននោះ ។ ប៉ុន្តែ តុលាការអាចសួរជនដែលថ្លង់ ជាអក្សរ ឬ ឱ្យជនដែលគ ធ្វើសេចក្ដីថ្លែងការណ៍ ជាអក្សរ បាន ។

២-បញ្ញត្តិស្ដីពីអ្នកធ្វើកោសលវិច័យនៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកបកប្រែ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនោះ ។

## ផ្នែកទី ២
## ឯកសារត្រៀម

**មាត្រា ១០១.‒** ឯកសារត្រៀម

១-នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀមបាន ។

២-នៅក្នុងឯកសារត្រៀម ត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន និង សេចក្ដីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត ។

៣-នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្ដឹង និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង និង អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង ជាអាទិ៍ ។

**មាត្រា ១០២.‒** ពេលវេលាដែលត្រូវដាក់ឯកសារត្រៀម ជាអាទិ៍

តុលាការអាចកំណត់អំឡុងពេលដែលត្រូវដាក់ឯកសារត្រៀមលើកដំបូងរបស់ចុងចម្លើយ ឬ ឯកសារត្រៀមដែលមានសរសេរអំពីការអះអាងចំពោះចំណុចជាក់លាក់ណាមួយ ឬ ត្រូវធ្វើការស្នើសុំឱ្យពិនិត្យភស្តុតាងដែលទាក់ទងនឹងចំណុចជាក់លាក់ណាមួយ ។

## ផ្នែកទី ៣
## នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**មាត្រា ១០៣.‒** គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្ដីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីយល់មិនស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្ដីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្ដីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ ។

**មាត្រា ១០៤.–** ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ ។

**មាត្រា ១០៥.–** កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១-នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន ។

២-កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ ។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។

**មាត្រា ១០៦.–** សកម្មភាពនៃបណ្តឹង ជាអាទិ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង ឬ ដីកាសម្រេចផ្សេងទៀតដែលអាចសម្រេចបាន ក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និង អាចពិនិត្យភស្តុតាងជាឯកសារ ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និង ភស្តុតាង ។

**មាត្រា ១០៧.–** ការបញ្ជាក់អំពីអង្គហេតុដែលនឹងត្រូវបំភ្លឺ ជាអាទិ៍

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿងក្តី និង ភស្តុតាងហើយ នោះតុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅពេលក្រោយ ។

**មាត្រា ១០៨.–** អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីបានទៀតទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមធ្យោបាយនោះ ទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬ ករណីដែលការដាក់មធ្យោបាយថ្មីនោះ មិនធ្វើឱ្យមានការយឺត

យ៉ាវដល់នីតិវិធីនៃបណ្ដឹង ឬ ករណីដែលភាគីបានធ្វើសេចក្ដីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះ មុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយគ្មានកំហុសធ្ងន់ធ្ងរឡើយ ។

**មាត្រា ១០៩.–** កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅគ្រប់កាលបរិច្ឆេទនីមួយៗ ។

**មាត្រា ១១០.–** ចំណុចជារូបមន្តនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១-នៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ :

ក-សញ្ញាណរឿងក្ដី ។

ខ-ឈ្មោះចៅក្រម និង ក្រឡាបញ្ជី ។

គ-ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន ។

ឃ-ពេលវេលា និង ទីកន្លែង ។

២-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១១១.–** ចំណុចសារធាតុនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវសេចក្ដីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ :

ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង ចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ ។

ខ-ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និង ការស្នើសុំឱ្យពិនិត្យភស្តុតាង ។

គ-ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវ

នៃឯកសារ ។

ឃ-ការដកពាក្យបណ្ដឹង ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់ការទាមទារ ។

ង-ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រា តាមការទាមទាររបស់ភាគី ។

ច-ការសម្រេចសេចក្ដីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ១១២.-** ការប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៃកំណត់ហេតុ ស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍

១-ក្នុងករណីដែលភាគី ឬ អ្នកដទៃទៀតដែលពាក់ព័ន្ធ ប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ត្រូវកត់សេចក្ដីប្ដឹងតវ៉ានេះ នៅក្នុងកំណត់ហេតុនោះ ។

២-ភាពត្រឹមត្រូវក្នុងការអនុវត្តតាមបញ្ញត្តិទាក់ទងនឹងរបៀបធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចបញ្ជាក់បាន ដោយកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកំណត់ហេតុនេះបានបាត់ ឬ បានវិនាស ។

## ផ្នែកទី ៤
## ការទាញហេតុផលដោយផ្ទាល់មាត់

**មាត្រា ១១៣.-** ការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម ។

**មាត្រា ១១៤.–** ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់

១-ដើម្បីចេញសាលក្រមទៅលើបណ្តឹង តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែ ចំពោះរឿងក្តី ឬ ចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ មិនត្រូវធ្វើ ។

២-ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដោយអនុលោមទៅតាមវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចសួរភាគីបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

**មាត្រា ១១៥.–** ការទាញហេតុផលដោយផ្ទាល់មាត់

១-ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន ។

២-ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើង នៅសាលសវនាការជាសាធារណៈ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាពជាសាធារណៈនេះ បណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

**មាត្រា ១១៦.–** សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផល

១-នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

២-សេចក្តីថ្លែងការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយចង្អុលបង្ហាញឱ្យបានច្បាស់លាស់នូវអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាងនៅពេលក្រោយ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ។

៣-នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ភាគីអាចអះអាងបន្ថែមទៀត

អំពីអង្គហេតុ និង ដាក់ភស្តុតាងមកទៀតបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការអះអាងអង្គហេតុ ឬ ការដាក់ភស្តុតាងនោះ ផ្ទុយនឹងមាត្រា ១០៨ (អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) នៃក្រមនេះ ។

៤-ក្រោយពីបានពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយ បើយល់ឃើញថា ត្រូវការជាចាំបាច់ពិសេស តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីម្តងទៀតបាន ដោយដីកាសម្រេច ។

៥-តុលាការអាចអនុញ្ញាតឱ្យភាគីនីមួយៗធ្វើការទាញហេតុផលចុងក្រោយបាន មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

**មាត្រា ១១៧.-** កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់

១-តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ នៅគ្រប់កាលបរិច្ឆេទនីមួយៗ ។

២-បញ្ញត្តិនៃមាត្រា ១១២ (ការប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៃកំណត់ហេតុ ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់នេះ ។

**មាត្រា ១១៨.-** ចំណុចជារូបមន្តនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់

១-នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ :

ក-សញ្ញាណរឿងក្តី ។

ខ-ឈ្មោះចៅក្រម និង ក្រឡាបញ្ជី ។

គ-ឈ្មោះតំណាងអយ្យការដែលបានចូលរួម ប្រសិនបើមាន ។

ឃ-ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន ។

ង-ពេលវេលា និង ទីកន្លែងនៃការទាញហេតុផលដោយផ្ទាល់មាត់ ។

ច-ហេតុការណ៍ដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬ ហេតុការណ៍ និង មូលហេតុ ដែលមិនបានធ្វើជាសាធារណៈក្នុងករណីមិនធ្វើជាសាធារណៈ ។

២-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី ត្រូវចុះហត្ថលេខានៅក្នុងកំណត់-

ហេតុ ដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១១៩.–** ចំណុចសារធាតុនៃកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់

១-នៅក្នុងកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវសេចក្ដីសង្ខេបអំពីការទាញហេតុផលនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ :

ក-ការដកពាក្យបណ្ដឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ និង ការសារភាព ។

ខ-សេចក្ដីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ ។

គ-ការធ្វើសម្បថ ឬ មិនធ្វើសម្បថរបស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ និង មូលហេតុដែលមិនបានឱ្យសាក្សី និង អ្នកធ្វើកោសលវិច័យធ្វើសម្បថ ។

ឃ-លទ្ធផលនៃការត្រួតពិនិត្យ ។

ង-ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាត ឱ្យកត់ត្រាតាមការទាមទាររបស់ភាគី ។

ច-ការសម្រេចសេចក្ដីដែលបានធ្វើឡើងដោយមិនបានធ្វើជាលាយល័ក្ខណ៍អក្សរ ។

ឆ-ការប្រកាសសេចក្ដីសម្រេច ។

២-ទោះបីមានបញ្ញត្តិនៅកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក្នុងករណីដែលបណ្ដឹងត្រូវបានបញ្ចប់ដោយមិនតាមការសម្រេចសេចក្ដីទេ សេចក្ដីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ និង លទ្ធផលនៃការត្រួតពិនិត្យ អាចមិនសរសេរក្នុងកំណត់ហេតុបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាមទារឱ្យកត់ត្រាក្នុងកំណត់ហេតុ ក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលខ្លួនបានដឹងថាបណ្ដឹងនោះត្រូវបានចប់ ។

**មាត្រា ១២០.–** ការកត់ត្រាដោយថតខ្សែអាត់ ជាអាទិ៍ ជំនួសកំណត់ហេតុ

១-ទោះបីមានបញ្ញត្តិដូចកថាខណ្ឌទី ១ នៃមាត្រា ១១៩ (ចំណុចសារធាតុនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់) ខាងលើនេះក៏ដោយ ប្រសិនបើមានការអនុញ្ញាតពីតុលាការ ក្រឡាបញ្ជីអាចថតខ្សែអាត់ ឬ ខ្សែវីដេអូ នូវសេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ ឬ របស់អ្នកធ្វើកោសលវិច័យ ដើម្បីជំនួសកំណត់ហេតុជាលាយល័ក្ខណ៍អក្សរបាន ។ ក្នុងករណីនេះ នៅពេលដែលតុលាការអនុញ្ញាត ភាគីអាចបញ្ចេញមតិយោបល់របស់ខ្លួនបាន ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើមានការស្នើសុំរបស់ភាគី រហូតដល់បណ្តឹងនេះបានបញ្ចប់ ក្រឡាបញ្ជីត្រូវធ្វើឯកសារដែលកត់សេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ ឬ របស់អ្នកធ្វើកោសលវិច័យជាលាយល័ក្ខណ៍អក្សរ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលតុលាការជាន់ខ្ពស់យល់ឃើញថាចាំបាច់ នៅពេលតុលាការជាន់ខ្ពស់នេះកំពុងចាត់ការបណ្តឹងនោះ ។

**មាត្រា ១២១.–** ការយកឯកសារ ជាអាទិ៍ ជាអាគតដ្ឋាន និង ការភ្ជាប់ជាឧបសម្ព័ន្ធ

ឯកសារ រូបថត ខ្សែអាត់ ខ្សែវីដេអូ ឬ វត្ថុផ្សេងទៀតដែលតុលាការយល់ឃើញថាសមរម្យ អាចយកធ្វើជាផ្នែកមួយនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ដោយយកធ្វើជាអាគតដ្ឋានក្នុងកំណត់ហេតុនោះ ហើយភ្ជាប់ជាមួយសំណុំរឿងជាឧបសម្ព័ន្ធបាន ។

**មាត្រា ១២២.–** ការកម្រិតនៃការថតរូប ជាអាទិ៍ ក្នុងសាលសវនាការ

ការថតរូប ការកត់ជាជវលេខ ការថតខ្សែអាត់ ការថតខ្សែវីដេអូ ឬ ការផ្សាយបន្តផ្ទាល់ ក្នុងសាលសវនាការ មិនអាចធ្វើបានឡើយ បើគ្មានការអនុញ្ញាតពីតុលាការ ។

# ជំពូកទី ៣
# ភស្តុតាង
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៣.–** គោលការណ៍សម្រេចសេចក្តីដោយភស្តុតាង

១-តុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន ។ ប៉ុន្តែតុលាការអាចពិចារណាអំពីស្ថានភាពទាំងមូល ដែលបានលេចឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២-អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាងទេ ។

៣-ភាគីអាចដកសេចក្តីសារភាពបាន ក្នុងករណីដូចខាងក្រោមនេះ :

ក-ភាគីម្ខាងទៀតពុំតវ៉ា ។

ខ-ការសារភាពនោះ ផ្ទុយនឹងការពិត ដោយភាន់ច្រឡំ ។

គ-ការសារភាពនេះបណ្តាលមកពីសកម្មភាពបទល្មើសរបស់អ្នកដទៃ ។

**មាត្រា ១២៤.–** ការពិនិត្យភស្តុតាង

១-ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងតាមការស្នើសុំឱ្យពិនិត្យរបស់ភាគី ។

២-ប្រសិនបើតុលាការពុំអាចសម្រេចថា ត្រូវទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគីបានស្នើសុំឱ្យពិនិត្យ ឬ បើយល់ឃើញថាមានការចាំបាច់ផ្សេងទៀត នោះតុលាការអាចធ្វើការពិនិត្យភស្តុតាង ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ១២៥.–** ការស្នើសុំឱ្យពិនិត្យភស្តុតាង

១-ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង ត្រូវតែកំណត់ឱ្យបានជាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់ ។

២-ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង គប្បីបំភ្លឺឱ្យច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និង ទំនាក់ទំនងរវាងអង្គហេតុនោះនិងភស្តុតាង ។

៣-ការស្នើសុំឱ្យពិនិត្យភស្តុតាង ក៏អាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បានដែរ ។

៤-ការស្នើសុំឱ្យសាកសួរសាក្សី និង សាមីភាគី បើអាចធ្វើបាន ត្រូវធ្វើជាមួយគ្នាឱ្យស្រេចតែម្តង ។

**មាត្រា ១២៦.–** ការទទួលយកភស្តុតាង

តុលាការត្រូវពិនិត្យភស្តុតាងដែលភាគីបានស្នើសុំឱ្យពិនិត្យ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះភស្តុតាងដែលគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ និង ភស្តុតាងឯទៀតដែលតុលាការយល់ឃើញថាមិនចាំបាច់ឡើយ ។

**មាត្រា ១២៧.–** ការពិនិត្យភស្តុតាងដោយសម្ងហវិធី

១-តុលាការត្រូវធ្វើឱ្យការពិនិត្យភស្តុតាងអាចប្រព្រឹត្តទៅជាបន្ទាន់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដំបូង បន្ទាប់ពីបានបញ្ចប់ការរៀបចំចំណុចវិវាទ និងភស្តុតាងរួចហើយ ។

២-ការសាកសួរទៅលើសាក្សី ឬ សាមីភាគី បើអាចធ្វើបាន ត្រូវតែធ្វើដោយសម្ងហវិធី ។

៣-ឯកសារដែលបម្រុងនឹងប្រើនៅក្នុងការសាកសួរសាក្សី ជាអាទិ៍ ត្រូវដាក់ជូននៅក្នុងអំឡុងពេលដែលសមរម្យ មុនពេលចាប់ផ្តើមធ្វើការសាកសួរទៅលើសាក្សី ជាអាទិ៍ នោះលើកលែងតែឯកសារដែលនឹងប្រើជាភស្តុតាង ដើម្បីប្រជែងលើភាពជំនឿនៃសេចក្តីថ្លែង-ការណ៍របស់សាក្សី ជាអាទិ៍ ។

**មាត្រា ១២៨.–** សិទ្ធិចូលរួមរបស់ភាគី

១-តុលាការត្រូវធានានូវឱកាសឱ្យមានវត្តមានរបស់ភាគី ដើម្បីចូលរួមក្នុងការពិនិត្យភស្តុតាង ។

២-ការពិនិត្យភស្តុតាង អាចធ្វើទៅបាន ទោះជាក្នុងករណីដែលភាគីមិនបានចូលខ្លួនតាមកាលបរិច្ឆេទក៏ដោយ ។

**មាត្រា ១២៩.–** ការពិនិត្យភស្តុតាងនៅបរទេស

១-ការពិនិត្យភស្តុតាងដែលត្រូវធ្វើនៅបរទេស តុលាការត្រូវប្រគល់កិច្ចការនេះទៅក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះ ឬ ឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសនោះ ។

២-ការពិនិត្យភស្តុតាងដែលបានធ្វើនៅបរទេស ទោះបីជាក្នុងករណីដែលការពិនិត្យភស្តុតាងនោះខុសច្បាប់របស់ប្រទេសនោះក៏ដោយ ក៏នៅតែមានសុពលភាពដែរ បើការពិនិត្យភស្តុតាងនោះមិនផ្ទុយនឹងក្រមនេះទេ ។

**មាត្រា ១៣០.–** ការប្រគល់កិច្ចការស្រាវជ្រាវ

តុលាការអាចប្រគល់កិច្ចការស្រាវជ្រាវដែលចាំបាច់ ទៅស្ថាប័នក្នុងប្រទេស ឬ ស្ថាប័នបរទេសបាន ។

**មាត្រា ១៣១.–** សេចក្តីបញ្ជាក់ដំបូង

សេចក្តីបញ្ជាក់ដំបូង ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន ។

## ផ្នែកទី ២
## ការសាកសួរសាក្សី

**មាត្រា ១៣២.–** ករណីយកិច្ចរបស់សាក្សី

១-លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេង តុលាការអាចសាកសួរជនណាមួយជាសាក្សីក៏បាន ។

២-តុលាការអាចបង្គាប់ឱ្យនាំខ្លួនសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ដោយដីកាសម្រេចបាន ។

៣-ប្រសិនបើសាក្សីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀលបាន ដោយដីកាសម្រេច ។

៤-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ឬ ទី ៣ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ១៣៣.–** ការសាកសួរសាក្សីជាមន្ត្រីរាជការ

១-ក្នុងករណីសាកសួរសាក្សីជាមន្ត្រីរាជការ ឬ អតីតមន្ត្រីរាជការ អំពីកិច្ចការសម្ងាត់ក្នុងមុខនាទីនោះ តុលាការត្រូវទទួលការយល់ព្រមពីសំណាក់ស្ថាប័នដែលគ្រប់គ្រងលើសាក្សីនោះ ។

២-ស្ថាប័នគ្រប់គ្រងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺព្រឹទ្ធសភា ចំពោះសមាជិកព្រឹទ្ធសភា ឬ អតីតសមាជិកព្រឹទ្ធសភា រដ្ឋសភា ចំពោះសមាជិករដ្ឋសភា ឬ អតីតសមាជិករដ្ឋសភា រីឯចំពោះសមាជិករាជរដ្ឋាភិបាល ឬ អតីតសមាជិករាជរដ្ឋាភិបាលវិញ គឺគណៈរដ្ឋមន្ត្រី ។

៣-ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចបដិសេធបានឡើយ លើកលែងតែក្នុងករណីដែលអាចធ្វើឱ្យខូចផលប្រយោជន៍សាធារណៈ ឬ បណ្តាលឱ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ ។

**មាត្រា ១៣៤.–** សិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី

១-ប្រសិនបើការផ្តល់នូវចម្លើយជាកសិណសាក្សី ទាក់ទងនឹងហេតុដែលធ្វើឱ្យសាក្សី ឬ សហព័ទ្ធរបស់សាក្សី ឬ ញាតិឯទៀតរបស់សាក្សី អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោស នោះសាក្សីអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះការផ្តល់ចម្លើយជាកសិណសាក្សីទាក់ទងនឹងហេតុដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលបានរៀបរាប់ខាងលើនេះ ឬ បណ្តាលឱ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ ។

២-សាក្សីអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីបាន :

ក-ក្នុងករណីដូចកថាខណ្ឌទី ១ នៃមាត្រា ១៣៣ (ការសាកសួរសាក្សីជាមន្ត្រីរាជការ) ខាងលើ ។

ខ-ក្នុងករណីដែលវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឆ្មប គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឱសថការី មេធាវី អ្នកមានមុខងារក្នុងសាសនា ឬ អ្នកដែលធ្លាប់មានមុខងារខាងលើនេះ ត្រូវទទួលការសាកសួរអំពីអង្គហេតុដែលបានដឹង ក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលត្រូវលាក់ការសម្ងាត់ ។

គ-ក្នុងករណីដែលសាកសួរអំពីហេតុដែលទាក់ទងនឹងការសម្ងាត់ក្នុងបច្ចេក-ទេស ឬវិជ្ជាជីវៈ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាក្សីទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់ ។

**មាត្រា ១៣៥.–** ដីកាសម្រេចទៅលើការបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី

១-មូលហេតុនៃការបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

២-លើកលែងតែក្នុងករណីនៃចំណុច ក កថាខណ្ឌទី ២ នៃមាត្រា ១៣៤ (សិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី) មុននេះ តុលាការដែលទទួលបណ្តឹង ត្រូវសាកសួរទៅលើភាគី ហើយសម្រេចដោយដីកាសម្រេចអំពីការបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីថា ត្រឹមត្រូវ ឬ មិនត្រឹមត្រូវ ។

៣-ភាគី និង សាក្សី អាចប្តឹងជំទាស់ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបាន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) ខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាក្សីបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីដោយគ្មានមូលហេតុត្រឹមត្រូវ ក្រោយពេលដែលដីកាសម្រេចរបស់តុលាការដែលបានសម្រេចថា ពុំមានមូលហេតុក្នុងការបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីចូលជាស្ថាពរ ។

**មាត្រា ១៣៦.–** ការសាកសួរសាក្សីនៅក្រៅតុលាការ

១-តុលាការអាចសាកសួរសាក្សីនៅក្រៅតុលាការបាន ក្នុងករណីដូចខាងក្រោមនេះ :

ក-សាក្សីគ្មានករណីយកិច្ចចូលខ្លួនទៅតុលាការដែលទទួលបណ្តឹង ឬ មានមូលហេតុត្រឹមត្រូវ ដែលមិនអាចចូលខ្លួនទៅតុលាការបាន ។

ខ-ការចូលខ្លួនរបស់សាក្សីទៅតុលាការដែលទទួលបណ្តឹង បណ្តាលឱ្យមានការចំណាយទៅលើពេលវេលា ឬ សោហ៊ុយមិនសមរម្យ ។

គ-គូភាគីពុំមានការតវ៉ា ។

២-ចំពោះបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចឱ្យចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ទៅធ្វើការសាកសួរសាក្សីនៅក្រៅតុលាការបាន ។

៣-ក្នុងករណីចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ធ្វើការសាកសួរសាក្សី ចៅក្រមនោះត្រូវបំពេញមុខនាទីរបស់តុលាការ ឬ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

**មាត្រា ១៣៧.–** សម្បថ

១-តុលាការត្រូវឱ្យសាក្សីធ្វើសម្បថ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស ។

២-ក្នុងករណីសាក្សីដែលនឹងត្រូវសួរ ជាជនដែលមានអាយុក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឬ ជនដែលមិនយល់អំពីអត្ថន័យនៃសម្បថ តុលាការមិនអាចឱ្យសាក្សីនោះធ្វើសម្បថបានឡើយ ។

៣-នៅពេលសាកសួរសាក្សីដែលត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១៣៤ (សិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី) នៃក្រមនេះ ហើយសាក្សីនោះមិនប្រើសិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី តុលាការអាចមិនឱ្យធ្វើសម្បថបាន ។

៤-សម្បថរបស់សាក្សី ត្រូវធ្វើនៅមុនពេលសាកសួរ ។ ប៉ុន្តែ បើមានមូលហេតុពិសេសអាចធ្វើនៅក្រោយពេលសាកសួរបាន ។

៥-ទម្រង់នៃការធ្វើសម្បថ ត្រូវធ្វើតាមការកំណត់ក្នុងឧបសម្ព័ន្ធនៃក្រមនេះ ។

៦-មុនពេលធ្វើសម្បថ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវពន្យល់អំពីគោលបំណងនៃសម្បថ ហើយប្រាប់ឱ្យដឹងជាមុន អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីភាពក្លែងក្លាយ ។

**មាត្រា ១៣៨.–** វិធីសាកសួរសាក្សី

១-ការស្នើសុំសាកសួរសាក្សី ត្រូវធ្វើឡើង ដោយកំណត់ឱ្យបានច្បាស់លាស់ទៅលើសាក្សីណាមួយ ។

២-អ្នកដែលស្នើសុំសាកសួរសាក្សី ត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចត្រូវសាកសួរ ។

៣-សាក្សីត្រូវទទួលការកោះហៅយ៉ាងតិច ២ (ពីរ) សប្តាហ៍ មុនថ្ងៃសាកសួរ ។

៤-ដីកាកោះហៅសាក្សី ត្រូវសរសេរនូវកំណត់សំគាល់ដូចខាងក្រោម ហើយត្រូវភ្ជាប់មកជាមួយនូវឯកសារដែលកំណត់អំពីចំណុចសាកសួរ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ។

ខ-ពេលវេលា និង ទីកន្លែងដែលត្រូវចូលខ្លួន ។

គ-ទណ្ឌកម្មដែលកំណត់ដោយច្បាប់ នឹងកើតមាន បើមិនចូលខ្លួន ។

៥-ការសាកសួរសាក្សីត្រូវធ្វើតាមលំដាប់ : ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ភាគីដែលស្នើសុំឱ្យសាកសួរសាក្សីនោះ និង ភាគីម្ខាងទៀត ។ ចៅក្រមប្រឹក្សាអាចសាកសួរទៅសាក្សីបាន នៅក្រោយពេលបានជម្រាបទៅប្រធានក្រុមប្រឹក្សាជំនុំជម្រះឱ្យបានដឹងហើយ ។

៦-ប្រសិនបើយល់ឃើញថាត្រឹមត្រូវ តុលាការអាចកែសម្រួលលំដាប់ដែលត្រូវសាកសួរសាក្សី ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះបាន ។

៧-សាក្សីមិនអាចឆ្លើយដោយយកឯកសារមកអានធ្វើជាមូលដ្ឋានបានឡើយ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការអនុញ្ញាតពីតុលាការ ។

៨-ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចអនុញ្ញាតឱ្យសាក្សីដែលត្រូវបានសាកសួរហើយ ឬ សាក្សីដែលបម្រុងនឹងត្រូវសាកសួរ ឱ្យនៅក្នុងសាលសវនាការបាន ។

៩-នៅពេលដែលតុលាការទទួលស្គាល់ថា សាក្សីពុំអាចឆ្លើយឱ្យគ្រប់គ្រាន់បាន នៅចំពោះមុខអ្នកសង្កេតការណ៍ណាម្នាក់ ដោយសារតែអ្នកនោះជាហេតុនាំឱ្យមានការភ័យព្រួយ តុលាការអាចបង្គាប់ឱ្យអ្នកសង្កេតការណ៍នោះចេញក្រៅសាលសវនាការ នៅពេលដែលសាក្សីនោះឆ្លើយ ។

១០-នៅពេលដែលយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឱ្យធ្វើការសាកសួរសាក្សី និង សាក្សីផ្សេងទៀត នៅពេលជាមួយគ្នាបាន ។

**មាត្រា ១៣៩.–** ការកម្រិតទៅលើសំណួរ

១-ចំពោះសំណួរ បើអាចធ្វើបាន ត្រូវធ្វើដាច់ដោយឡែក និង ច្បាស់លាស់ ។

២-លើកលែងតែករណីដែលមានមូលហេតុត្រឹមត្រូវ មិនអាចសាកសួរបានឡើយនូវសំណួរខាងក្រោមនេះ :

ក-សំណួរដែលប្រមាថមើលងាយ ឬ ធ្វើឱ្យច្របូកច្របល់ដល់សាក្សី ។

ខ-សំណួរនាំមុខ ។

គ-សំណួរច្រំដែល ។

ឃ-សំណួរដែលគ្មានទំនាក់ទំនងនឹងចំណុចវិវាទ ។

ង-សំណួរដែលទាមទារឱ្យថ្លែងយោបល់របស់សាក្សីផ្ទាល់ខ្លួន ។

ច-សំណួរដែលទាមទារឱ្យថ្លែងនូវយោបល់អំពីអង្គហេតុដែលសាក្សីពុំបានជួបប្រទះផ្ទាល់ ។

៣-តុលាការអាចកម្រិតនូវសំណួរ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន នៅពេលដែលយល់ឃើញថា សំណួរនោះផ្ទុយនឹងបញ្ញត្តិដែលមានចែងនៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

៤-ភាគីអាចតវ៉ា ចំពោះការកម្រិតដែលធ្វើទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះបាន ។

## ផ្នែកទី ៣
## ការសាកសួរភាគី

**មាត្រា ១៤០.-** ការសាកសួរសាមីភាគី

១-តុលាការអាចធ្វើការសាកសួរសាមីភាគីបាន ។ នៅក្នុងករណីនេះ តុលាការអាចឱ្យភាគីនោះស្បថបាន ។

២-ក្នុងករណីដែលធ្វើការសាកសួរសាមីភាគី បើភាគីនោះពុំចូលខ្លួន ឬ បដិសេធនូវការធ្វើសម្បថ ឬ ផ្តល់ចម្លើយ ដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀត ជាការពិតបាន ។

៣-ប្រសិនបើភាគីដែលបានស្បថក្លែងបន្លំសេចក្តីថ្លែងការណ៍ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី២.០០០.០០០ (ពីរលាន) រៀលបាន ដោយដីកាសម្រេច ។

៤-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ១៤១.–** ការអនុវត្តដូចគ្នានឹងបញ្ញត្តិស្តីពីការសាកសួរសាក្សី ជាអាទិ៍

១-បញ្ញត្តិនៃមាត្រា ១៣៦ (ការសាកសួរសាក្សីនៅក្រៅតុលាការ) មាត្រា ១៣៧ (សម្បថ) (ក្រៅពីកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣) មាត្រា ១៣៨ (វិធីសាកសួរសាក្សី) (ក្រៅពីកថាខណ្ឌទី ៨ និង កថាខណ្ឌទី ១០) និង មាត្រា ១៣៩ (ការកម្រិតទៅលើសំណួរ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសាកសួរសាមីភាគី ។

២-នៅពេលយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឱ្យធ្វើការសាកសួរសាមីភាគី ជាមួយនឹងភាគីម្ខាងទៀត ឬ ជាមួយនឹងសាក្សី នៅពេលជាមួយគ្នាបាន ។

**មាត្រា ១៤២.–** ការសាកសួរអ្នកតំណាងដែលច្បាប់បានកំណត់

បញ្ញត្តិអំពីការសាកសួរសាមីភាគីនៅក្នុងក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ហើយធ្វើជាតំណាងរបស់ភាគីនៅក្នុងបណ្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះពុំមានការរារាំងដល់ការសាកសួរសាមីភាគីឡើយ ។

## ផ្នែកទី ៤
## កោសលវិច័យ

**មាត្រា ១៤៣.–** ការស្នើសុំឱ្យធ្វើកោសលវិច័យ ចំណុចធ្វើកោសលវិច័យ

១-តុលាការអាចបង្គាប់ឱ្យធ្វើកោសលវិច័យ តាមពាក្យសុំរបស់ភាគីបាន ។

២-ពេលស្នើសុំឱ្យធ្វើកោសលវិច័យ ភាគីដែលស្នើសុំត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចដែលសុំឱ្យធ្វើកោសលវិច័យ ។ ប៉ុន្តែ ប្រសិនបើមានមូលហេតុដែលពុំអាចជៀសវាងបាន ឯកសារនោះអាចដាក់ នៅក្នុងអំឡុងពេលដែលតុលាការបានកំណត់ ។

៣-តុលាការត្រូវសួរយោបល់របស់ភាគីម្ខាងទៀត អំពីការស្នើសុំដែលមានចែងនៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

៤-តុលាការត្រូវកំណត់នូវចំណុចដែលត្រូវធ្វើកោសលវិច័យ ដោយយោងទៅតាមឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ហើយពិចារណាអំពីយោបល់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ តុលាការត្រូវផ្ញើឯកសារអំពីចំណុចដែលត្រូវធ្វើកោសលវិច័យនោះ ទៅអ្នកជំនាញ ។

**មាត្រា ១៤៤.–** ការចាត់តាំងអ្នកជំនាញខាងកោសលវិច័យ ករណីយកិច្ចធ្វើកោសលវិច័យ

១-អ្នកជំនាញខាងកោសលវិច័យត្រូវបានចាត់តាំងដោយតុលាការ ។

២-ជនដែលមានចំណេះវិជ្ជា និង បទពិសោធន៍ចាំបាច់ក្នុងការធ្វើកោសលវិច័យមានករណីយកិច្ចធ្វើកោសលវិច័យ ។

៣-ជនទាំងឡាយពុំអាចធ្វើជាអ្នកជំនាញខាងកោសលវិច័យបាន ក្នុងករណីដូចខាងក្រោមនេះ :

ក-ការធ្វើកោសលវិច័យនោះ បណ្តាលឱ្យអ្នកជំនាញផ្ទាល់ខ្លួន ឬ សហព័ទ្ធ ឬ ញាតិឯទៀតរបស់ខ្លួន អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោស ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការធ្វើកោសលវិច័យនោះ អាចធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលបានរៀបរាប់ខាងលើនេះ ឬ បណ្តាលឱ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ ។

ខ-ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធទៅនឹងកិច្ចការសម្ងាត់ក្នុងមុខនាទីរបស់ខ្លួន ជាមន្ត្រីរាជការ ឬ អតីតមន្ត្រីរាជការ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលជនទាំងនេះ បានទទួលនូវការយល់ព្រមពីសំណាក់ក្រសួង ឬ ស្ថាប័នគ្រប់គ្រង ។ ក្រសួង ឬ ស្ថាប័នគ្រប់គ្រង មិនអាចបដិសេធមិនផ្តល់ការយល់ព្រមបានឡើយ លើកលែងតែក្នុងករណីដែលអាចធ្វើឱ្យខូចផលប្រយោជន៍សាធារណៈ ឬ បណ្តាលឱ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ ។

គ-ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានដឹងដោយវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឱសថការី គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឆ្មប មេធាវី អ្នកមានមុខងារក្នុងសាសនា ឬ អ្នកដែលធ្លាប់មានមុខងារខាងលើនេះ ក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលត្រូវលាក់ការសម្ងាត់ ។

ឃ-ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធនឹងការសម្ងាត់ក្នុងបច្ចេកទេស ឬវិជ្ជាជីវៈ ។

៤-ស្ថាប័នគ្រប់គ្រងដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ ចំណុច ខ គឺព្រឹទ្ធសភា ចំពោះសមាជិកព្រឹទ្ធសភា ឬ អតីតសមាជិកព្រឹទ្ធសភា រដ្ឋសភា ចំពោះសមាជិករដ្ឋសភា ឬ អតីតសមាជិករដ្ឋសភា រីឯចំពោះសមាជិករាជរដ្ឋាភិបាល ឬ អតីតសមាជិករាជរដ្ឋាភិបាលវិញ

គឺគណៈរដ្ឋមន្ត្រី ។

៥-បញ្ញត្តិនៃចំណុច ខ គ និង ឃ នៃកថាខណ្ឌទី ៣ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកជំនាញខាងកោសលវិច័យនោះ ទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់ ។

**មាត្រា ១៤៥.-** បណ្តឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យ

១-ក្នុងករណីមានហេតុដែលរារាំងសច្ចភាពនៃការធ្វើកោសលវិច័យរបស់អ្នកជំនាញ ភាគីអាចប្តឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យនោះបាន នៅមុនពេលដែលអ្នកជំនាញនោះធ្វើសេចក្តីសន្និដ្ឋានអំពីចំណុចដែលត្រូវធ្វើកោសលវិច័យ ។ ទោះជាក្នុងករណីដែលអ្នកជំនាញខាងកោសលវិច័យបានធ្វើសេចក្តីសន្និដ្ឋានរួចហើយក៏ដោយ ក៏បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមូលហេតុនៃបណ្តឹងផាត់ចោលនោះ បានកើតឡើងនៅពេលក្រោយ ឬ ភាគីបានដឹងអំពីមូលហេតុនោះ ក្រោយពេលដែលអ្នកជំនាញនោះបានធ្វើសេចក្តីសន្និដ្ឋានរួច ។

២-ពាក្យសុំផាត់ចោលត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែក្នុងករណីដែលពាក្យសុំនោះត្រូវបានធ្វើឡើងនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ។

៣-ភាគីដែលដាក់ពាក្យសុំផាត់ចោល ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុនៃបណ្តឹងផាត់ចោលនោះ ។

៤-ចំពោះដីកាសម្រេចដែលសម្រេចថា បណ្តឹងផាត់ចោលមានមូលហេតុត្រឹមត្រូវ មិនអាចធ្វើបណ្តឹងឧបាស្រ័យបានទេ ។

៥-ចំពោះដីកាសម្រេចដែលសម្រេចថា បណ្តឹងផាត់ចោលគ្មានមូលហេតុត្រឹមត្រូវ អាចប្តឹងជំទាស់បាន ។

**មាត្រា ១៤៦.-** ទម្រង់នៃសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញខាងកោសលវិច័យ និង សំណួររបស់អ្នកជំនាញ ជាអាទិ៍

១-តុលាការអាចឱ្យអ្នកជំនាញខាងកោសលវិច័យ បញ្ចេញយោបល់ជាលាយល័ក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន ។

២-ក្នុងករណីដែលមានការចាំបាច់សម្រាប់កិច្ចការធ្វើកោសលវិច័យ អ្នកជំនាញខាងកោសលវិច័យអាចចូលរួមក្នុងសវនាការ ហើយអាចស្នើសុំឱ្យតុលាការធ្វើការសាកសួរសាក្សី ឬ សាមីភាគី ឬ ដោយទទួលការអនុញ្ញាតពីតុលាការ អាចសាកសួរដោយផ្ទាល់ទៅលើជនទាំងនោះបាន ។

**មាត្រា ១៤៧.-** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីការសាកសួរសាក្សី ទម្រង់សម្បថ

បញ្ញត្តិនៃផ្នែកទី ២ (ការសាកសួរសាក្សី) ជំពូកទី ៣ គន្ថីទី ២ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការធ្វើកោសលវិច័យ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស ។ ប៉ុន្តែ បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

## ផ្នែកទី ៥
## ភស្តុតាងជាឯកសារ

**មាត្រា ១៤៨.-** ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ជាអាទិ៍

១-ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយផ្តល់នូវឯកសារដែលសាមីភាគីមាន ឬ ដោយដាក់ពាក្យសុំទៅតុលាការឱ្យបង្គាប់ឱ្យម្ចាស់ឯកសារផ្តល់ឯកសារនោះមក ។

២-ទោះបីជាមានបញ្ញត្តិក្នុងកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារនេះអាចធ្វើបាន ដោយដាក់ពាក្យសុំទៅតុលាការឱ្យស្នើសុំឱ្យម្ចាស់ឯក-សារផ្ញើឯកសារនោះមក ។

៣-ក្នុងករណីដែលយល់ឃើញថាចាំបាច់ តុលាការអាចឃាត់ទុកនូវឯកសារដែលបានផ្តល់មក ឬ ដែលបានផ្ញើមកបាន ។

**មាត្រា ១៤៩.-** ការភ្ជាប់មកជាមួយនូវឯកសារបកប្រែ ជាអាទិ៍

១-ក្នុងករណីដែលការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារដែលសរសេរជាភាសាបរទេស ភាគីដែលស្នើសុំត្រូវភ្ជាប់មកជាមួយនូវសេចក្តីបកប្រែត្រង់ចំណុចដែលខ្លួនសុំឱ្យពិនិត្យនោះ ។

២-ក្នុងករណីដែលភាគីម្ខាងទៀត មានយោបល់អំពីភាពត្រឹមត្រូវនៃសេចក្ដីបកប្រែ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភាគីនោះត្រូវដាក់ជូនតុលាការនូវយោបល់របស់ខ្លួនជាលាយលក្ខណ៍អក្សរ ។

**មាត្រា ១៥០.-** ករណីយកិច្ចផ្ដល់ឯកសារ

១-បុគ្គលដែលជាម្ចាស់ឯកសារ ពុំអាចបដិសេធនូវការផ្ដល់ឯកសារបានឡើយ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេង ។

២-បុគ្គលដែលជាម្ចាស់ឯកសារ អាចបដិសេធនូវការផ្ដល់ឯកសារបាន នៅក្នុងករណីដែលឯកសារនោះត្រូវនឹងចំណុចណាមួយដូចខាងក្រោមនេះ :

ក-ឯកសារមានសរសេរអំពីហេតុដែលបណ្ដាលឱ្យម្ចាស់ឯកសារ ឬ សហព័ទ្ធ ឬ ញាតិដទៃទៀតរបស់ខ្លួន អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្ដន្ទាទោស ឬ ហេតុដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលរៀបរាប់ខាងលើ ឬ អាចបណ្ដាលឱ្យមានការបាក់បែកធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ ។

ខ-ឯកសារមានការពាក់ព័ន្ធទៅនឹងកិច្ចការសម្ងាត់ក្នុងមុខនាទីរបស់មន្ត្រីរាជការ ហើយការផ្ដល់ឯកសារនោះ អាចបណ្ដាលឱ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ ។

គ-ឯកសារមានសរសេរអំពីអង្គហេតុដែលបានដឹងដោយវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឆ្មប គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឱសថការី មេធាវី អ្នកមានមុខងារក្នុងសាសនា ឬ អ្នកដែលធ្លាប់មានមុខងារខាងលើនេះ នៅក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលខ្លួនមិនបានទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់ ឬ ហេតុដែលពាក់ព័ន្ធទៅនឹងការសម្ងាត់ក្នុងបច្ចេកទេស ឬ វិជ្ជាជីវៈ ហើយដែលខ្លួនមិនបានទទួលការលើកលែងពីករណីយ-កិច្ចលាក់ការសម្ងាត់ ។

**មាត្រា ១៥១.-** ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ

១-ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ត្រូវធ្វើឡើងដោយបញ្ជាក់ឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ :

ក-ចំណងជើង និង ខ្លឹមសារនៃឯកសារ ។

ខ-ម្ចាស់ឯកសារ ។

គ-អង្គហេតុដែលត្រូវបញ្ជាក់បំភ្លឺ ។

២-ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

៣-បើភាគីម្ខាងទៀតមានយោបល់ស្តីពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើ ភាគីនោះត្រូវដាក់ជូនទៅតុលាការនូវយោបល់របស់ខ្លួនជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ១៥២.–** ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍

១-ក្នុងករណីដែលតុលាការយល់ឃើញថា ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯក-សារមានមូលហេតុត្រឹមត្រូវ តុលាការត្រូវបង្គាប់ដោយដីកាសម្រេច ឱ្យម្ចាស់ឯកសារផ្តល់ឯកសារនោះ ។ ក្នុងករណីនេះ បើមានផ្នែកខ្លះនៃឯកសារដែលតុលាការយល់ឃើញថា មិនចាំបាច់ពិនិត្យ ឬ មានផ្នែកខ្លះដែលពុំអាចទទួលស្គាល់ថា មានករណីយកិច្ចក្នុងការផ្តល់ជូននោះតុលាការអាចបង្គាប់ឱ្យផ្តល់ដោយលើកលែងចោលនូវផ្នែកនោះបាន ។

២-ក្នុងករណីដែលតុលាការមានបំណងនឹងបង្គាប់ឱ្យតតិយជនផ្តល់ឯកសារ តុលា-ការ ត្រូវសួរតតិយជននោះ ។

៣-ចំពោះដីកាសម្រេចអំពីពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ អាចប្តឹងជំទាស់បាន ។

**មាត្រា ១៥៣.–** អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍

១-ក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារទេ តុលា-ការអាចទទួលស្គាល់ថា សេចក្តីអះអាងរបស់ភាគីម្ខាងទៀតដែលពាក់ព័ន្ធនឹងខ្លឹមសារក្នុងឯកសារនោះ ជាការពិតបាន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលភាគីបានធ្វើឱ្យវិនាសបាត់បង់នូវឯកសារដែលខ្លួនមានករណីយកិច្ចត្រូវផ្តល់ ឬ ធ្វើឱ្យឯកសារនោះមិនអាចប្រើប្រាស់បាន ក្នុងគោលបំណងរារាំងដល់ការប្រើប្រាស់របស់ភាគីម្ខាងទៀត ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ បើភាគីម្ខាងទៀតមានការពិបាកយ៉ាងខ្លាំង ក្នុងការធ្វើសេចក្តីអះអាងឱ្យបានច្បាស់លាស់អំពី

ខ្លឹមសារក្នុងឯកសារនោះ និង ក្នុងការបំភ្លឺអង្គហេតុដែលត្រូវបញ្ជាក់ដោយឯកសារនោះ ទោះបីប្រើភស្តុតាងផ្សេងទៀតក៏ដោយ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងរបស់ភាគីម្ខាងទៀតដែលពាក់ព័ន្ធនឹងអង្គហេតុនោះជាការពិតបាន ។

**មាត្រា ១៥៤.–** ប្រាក់ពិន័យក្នុងករណីដែលតតិយជនមិនគោរពតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ

១-ក្នុងករណីដែលតតិយជនមិនគោរពតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន) រៀល ដោយដីកាសម្រេចបាន ។

២-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ១៥៥.–** ភាពត្រឹមត្រូវក្នុងការធ្វើឯកសារ

១-ភាគីដែលបានស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវបញ្ជាក់ថា ឯកសារនោះត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ។

២-បើទទួលស្គាល់ថា ឯកសារត្រូវបានធ្វើឡើងដោយមន្ត្រីរាជការនៅក្នុងមុខនាទី ដោយផ្អែកលើទម្រង់ និង ខ្លឹមសារនៃឯកសារ នោះត្រូវសន្មតថាជាឯកសារសាធារណៈដែលបានធ្វើឡើងដោយត្រឹមត្រូវ ។

៣-បើមានមន្ទិលសង្ស័យទៅលើភាពត្រឹមត្រូវក្នុងការធ្វើឯកសារសាធារណៈ នោះតុលាការអាចសួរដោយឆន្ទានុសិទ្ធិ ទៅក្រសួង ឬ ស្ថាប័នដែលពាក់ព័ន្ធបាន ។

៤-ចំពោះឯកសារឯកជនដែលមានចុះហត្ថលេខារបស់សាមីខ្លួនផ្ទាល់ ឬ អ្នកតំណាង ត្រូវសន្មតថាជាឯកសារដែលបានធ្វើឡើងដោយត្រឹមត្រូវ ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឯកសារដែលត្រូវទទួលស្គាល់ថា ត្រូវបានធ្វើឡើងដោយក្រសួង ឬ ស្ថាប័នបរទេស ។

**មាត្រា ១៥៦.–** ការបញ្ជាក់ដោយប្រៀបធៀបអក្សរដែលសរសេរដោយដៃ

១-ភាពត្រឹមត្រូវក្នុងការធ្វើឯកសារ ក៏អាចបញ្ជាក់ដោយការប្រៀបធៀបអក្សរដែល

សរសេរដោយដៃបានដែរ ។

២-បញ្ញត្តិនៃមាត្រា ១៤៨ (ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ជាអាទិ៍) មាត្រា ១៥២ (ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) និង កថាខណ្ឌទី ១ និង ទី ២ នៃមាត្រា ១៥៣ (អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការដាក់ ឬ ផ្ញើនូវឯកសារ ឬ វត្ថុឯទៀត ដែលមានសរសេរអក្សរដោយដៃ ដើម្បីប្រើប្រាស់ក្នុងការប្រៀបធៀប ។

៣-បើគ្មានអក្សរដែលសរសេរដោយដៃរបស់ភាគីម្ខាងទៀត ដែលមានលក្ខណៈសមរម្យដើម្បីធ្វើការប្រៀបធៀប តុលាការអាចបង្គាប់ឱ្យភាគីនោះសរសេរអក្សរដើម្បីប្រើប្រាស់ក្នុងការប្រៀបធៀប ដោយដីកាសម្រេចបាន ។

៤-ក្នុងករណីដែលភាគីម្ខាងទៀតពុំព្រមធ្វើតាមដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចទទួលស្គាល់ថាសេចក្តីអះអាងអំពីភាពត្រឹមត្រូវក្នុងការធ្វើឯកសាររបស់អ្នកស្នើសុំឱ្យពិនិត្យឯកសារ ជាការពិត ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការសរសេរអក្សរនោះកែរូបរាង ។

៥-ក្នុងករណីដែលតតិយជនពុំព្រមធ្វើតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៥៣ (អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ ដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលា-ការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន) រៀល ដោយដីកាសម្រេចបាន ។

៦-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ១៥៧.–** ប្រាក់ពិន័យចំពោះអ្នកប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ

១-ក្នុងករណីដែលភាគី ឬ អ្នកតំណាងរបស់ភាគីនោះប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ ដោយផ្ទុយពីការពិត ដោយចេតនា ឬ ដោយកំហុសធ្ងន់ធ្ងរ តុលាការអាច

ពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល ដោយដីកាសម្រេចបាន ។

២-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៣-ចំពោះករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើភាគី ឬ អ្នកតំណាង ដែលប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ បានទទួលស្គាល់ថា ឯកសារនោះ មានភាពត្រឹមត្រូវវិញ នៅក្នុងពេលដែលបណ្ដឹងកំពុងត្រូវបានចាត់ការ នោះតុលាការអាចលុបចោលនូវដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយយោលទៅតាមស្ថានភាពបាន ។

**មាត្រា ១៥៨.-** ការអនុវត្តដូចគ្នាចំពោះវត្ថុដែលទុកដូចជាឯកសារ

បញ្ញត្តិនៃផ្នែកនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវត្ថុដែលមិនមែនជាឯកសារ ដូចជាប្លង់រូបថត ខ្សែអាត់ ខ្សែវីដេអូ និង វត្ថុឯទៀតដែលបង្កើតឡើងសម្រាប់ផ្ដល់ព័ត៌មាន ។

**មាត្រា ១៥៩.-** របៀបចាត់ចែងក្នុងករណីដែលមានការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារដែលកត់ចម្លងពីខ្សែអាត់ ជាអាទិ៍

ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ដោយដាក់ឯកសារដែលកត់ចម្លងជាលាយល័ក្ខណ៍អក្សរ ពីខ្សែអាត់ ឬ ខ្សែវីដេអូ ឬ វត្ថុដែលអាចថតរូបធាតុដែលទៀងទាត់បានតាមវិធីផ្សេងទៀត កាលបើភាគីម្ខាងទៀតសុំឱ្យផ្ដល់នូវវត្ថុចម្លងពីវត្ថុទាំងឡាយនោះ ភាគីត្រូវផ្ដល់វត្ថុចម្លងនោះ ទៅភាគីម្ខាងទៀត ។

**មាត្រា ១៦០.-** ការដាក់ឯកសារពន្យល់អំពីអត្ថន័យនៃខ្សែអាត់ ជាអាទិ៍

១-ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាងជាខ្សែអាត់ ឬ ខ្សែវីដេអូ ឬ វត្ថុដែលអាចថតរូបធាតុដែលទៀងទាត់បានតាមវិធីផ្សេងទៀត បើមានសំណូមពរពីតុលាការ ឬ ភាគីម្ខាងទៀត ភាគីនោះត្រូវដាក់ជូននូវឯកសារដែលបានកត់ចម្លងអត្ថន័យចេញពីវត្ថុនោះ ឬ ឯក-សារដែលពន្យល់អំពីអត្ថន័យនៃវត្ថុនោះ ។

២-ប្រសិនបើភាគីម្ខាងទៀត មានយោបល់អំពីសេចក្ដីពន្យល់អត្ថន័យនៅក្នុងឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភាគីនោះត្រូវដាក់ជូនទៅតុលាការនូវ

ឯកសារដែលសរសេរអំពីយោបល់របស់ខ្លួន ។

## ផ្នែកទី ៦
## ការត្រួតពិនិត្យ

**មាត្រា ១៦១.–** ការស្នើសុំឱ្យត្រួតពិនិត្យ

ការស្នើសុំឱ្យត្រួតពិនិត្យត្រូវធ្វើឡើង ដោយចង្អុលបង្ហាញនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យ ។

**មាត្រា ១៦២.–** ការបង្ហាញនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យ ជាអាទិ៍

១-បញ្ញត្តិនៃមាត្រា ១៤៨ (ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ជាអាទិ៍) មាត្រា ១៥២ (ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) និង មាត្រា ១៥៣ (អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបង្ហាញ ឬ ការផ្ញើមកនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យ ។

២-ក្នុងករណីដែលតតិយជនមិនព្រមធ្វើតាមដីកាសម្រេចបង្គាប់ឱ្យបង្ហាញ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៥២ (ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន) រៀល ដោយដីកាសម្រេចបាន ។

៣-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

## ផ្នែកទី ៧
## ការថែរក្សាការពារភស្តុតាង

**មាត្រា ១៦៣.–** ការថែរក្សាការពារភស្តុតាង

១-ក្នុងករណីដែលតុលាការយល់ឃើញថា មានស្ថានភាពដែលនឹងមានការលំបាកក្នុងការប្រើប្រាស់ភស្តុតាង បើមិនធ្វើការពិនិត្យភស្តុតាងនោះជាមុនទេ នោះតុលាការអាចធ្វើការពិនិត្យភស្តុតាងជាមុនបាន តាមពាក្យសុំ ដោយអនុលោមតាមបញ្ញត្តិនៃជំពូកនេះ ។

២-លទ្ធផលនៃការពិនិត្យភស្តុតាងដែលធ្វើឡើង ដោយអនុលោមទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានប្រសិទ្ធភាពនៅក្នុងបណ្តឹងអង្គសេចក្តី ។

៣-ក្នុងការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងអង្គសេចក្តី ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការពិនិត្យភស្តុតាងដែលបានធ្វើឡើង ដោយអនុលោមទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១៦៤.-** តុលាការមានសមត្ថកិច្ច

១-ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងដែលធ្វើក្រោយពេលដាក់ពាក្យបណ្តឹង ត្រូវធ្វើនៅតុលាការនៃលំដាប់ថ្នាក់ដែលភស្តុតាងនោះនឹងត្រូវបានប្រើប្រាស់ ។

២-ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងដែលធ្វើមុនពេលដាក់ពាក្យបណ្តឹង ត្រូវធ្វើនៅសាលាដំបូងដែលមានសមត្ថកិច្ចនៅទីសំណាក់របស់បុគ្គលដែលត្រូវទទួលការសាកសួរ ឬរបស់បុគ្គលដែលជាម្ចាស់ឯកសារ ឬ នៅទីកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ ។

៣-ក្នុងករណីដែលមានស្ថានភាពជាបន្ទាន់ ទោះជានៅក្រោយពេលបានដាក់ពាក្យបណ្តឹងក៏ដោយ ក៏ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង អាចធ្វើនៅសាលាដំបូងដូចបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបានដែរ ។

**មាត្រា ១៦៥.-** របៀបដាក់ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង

១-ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

២-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគីម្ខាងទៀត ។

ខ-អង្គហេតុដែលត្រូវបញ្ជាក់ ។

គ-ភស្តុតាងដែលត្រូវថែរក្សាការពារ ។

ឃ-មូលហេតុនៃការថែរក្សាការពារភស្តុតាង ។

៣-មូលហេតុនៃការថែរក្សាការពារភស្តុតាង ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

**មាត្រា ១៦៦.-** វិធីចាត់ចែងក្នុងករណីដែលពុំអាចកំណត់ភាគីម្ខាងទៀតបាន

ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងអាចធ្វើទៅបាន ទោះជាមិនអាចកំណត់ភាគីម្ខាងទៀតបានក៏ដោយ ។ ក្នុងករណីនេះ តុលាការអាចជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់ជនដែលនឹងក្លាយជាភាគីម្ខាងទៀតបាន ។

**មាត្រា ១៦៧.-** ការថែរក្សាការពារភស្តុតាងដោយឆន្ទានុសិទ្ធិ

នៅពេលដែលបណ្តឹងកំពុងចាត់ការ បើយល់ឃើញថាចាំបាច់ តុលាការអាចចេញដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាង ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ១៦៨.-** ការធ្វើឧបាស្រ័យ

ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យថែរក្សាការពារភស្តុតាង អ្នកដាក់ពាក្យសុំអាចប្តឹងជំទាស់បាន ។

**មាត្រា ១៦៩.-** ការកោះហៅតាមកាលបរិច្ឆេទ

នៅកាលបរិច្ឆេទពិនិត្យភស្តុតាង តុលាការត្រូវធ្វើការកោះហៅអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីចាំបាច់បន្ទាន់ ។

**មាត្រា ១៧០.-** សោហ៊ុយសម្រាប់ថែរក្សាការពារភស្តុតាង

សោហ៊ុយដែលពាក់ព័ន្ធនឹងការថែរក្សាការពារភស្តុតាង គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្តី ។

**មាត្រា ១៧១.-** ការសាកសួរសាជាថ្មីនៅពេលទាញហេតុផលដោយផ្ទាល់មាត់

ចំពោះសាក្សីដែលបានសាកសួរនៅក្នុងនីតិវិធីនៃការថែរក្សាការពារភស្តុតាង បើភាគីស្នើសុំឱ្យសាកសួរនៅពេលទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវសាកសួរសាក្សីនោះ ។

**មាត្រា ១៧២.-** ការធ្វើកំណត់ហេតុស្តីពីការថែរក្សាការពារភស្តុតាង

ក្នុងករណីដែលធ្វើការពិនិត្យភស្តុតាងដើម្បីថែរក្សាការពារភស្តុតាង តុលាការដែលបានធ្វើការពិនិត្យភស្តុតាង ត្រូវធ្វើនូវកំណត់ហេតុស្តីពីការពិនិត្យភស្តុតាងនោះ ទៅតុលាការដែលរក្សាទុកនូវសំណុំរឿងនៃបណ្តឹងអង្គសេចក្តី ។

# ជំពូកទី ៤
# ការផ្អាក និង បន្តនីតិវិធីនៃបណ្តឹង

**មាត្រា ១៧៣.–** ការផ្អាក និង ការទទួលបន្តនីតិវិធីនៃបណ្តឹង

១-នីតិវិធីនៃបណ្តឹងត្រូវផ្អាក ពេលមានហេតុដូចចំណុចខាងក្រោមនេះ :

ក-មរណភាពរបស់ភាគី ។

ខ-ការរំលត់នីតិបុគ្គលដែលជាភាគី ដោយការរួមបញ្ចូលនីតិបុគ្គល ។

គ-ការបាត់បង់នូវសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ភាគី ឬ មរណភាពរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ការរលត់នូវសិទ្ធិតំណាង ។

ឃ-មរណភាព ឬ ការបាត់បង់នូវលក្ខណសម្បត្តិដោយហេតុផ្សេងរបស់បុគ្គលដែលមានលក្ខណសម្បត្តិដែលបានកំណត់ ហើយធ្វើបណ្តឹងក្នុងនាមផ្ទាល់ខ្លួន ជំនួសអ្នកដទៃ ។

ង-មរណភាព ឬ ការបាត់បង់នូវលក្ខណសម្បត្តិដោយហេតុផ្សេងរបស់ភាគីដែលត្រូវបានជ្រើសរើសទាំងអស់ ដោយបញ្ញត្តិនៃមាត្រា ៤២ (ការជ្រើសរើសភាគី) នៃក្រមនេះ ។

២-ពេលមានហេតុដូចបានកំណត់នៅចំណុចនីមួយៗនៃកថាខណ្ឌទី ១ ខាងលើនេះ បុគ្គលដែលត្រូវទទួលបន្តនីតិវិធីនៃបណ្តឹង គឺ :

ក-បើមរណភាពរបស់ភាគី គឺ សន្តតិជន ឬ បុគ្គលដែលត្រូវបន្តបណ្តឹងតាមច្បាប់ ឬ បទដ្ឋានផ្សេងទៀត ។

ខ-បើការរំលត់នីតិបុគ្គលដែលជាភាគី ដោយការរួមបញ្ចូលនីតិបុគ្គល គឺ នីតិ-បុគ្គលដែលទទួលបន្តនូវសិទ្ធិ និង កាតព្វកិច្ចក្រោយការរួមបញ្ចូលនីតិបុគ្គល ។

គ-បើការបាត់បង់នូវសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ភាគី ឬ មរណភាពរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ការរលត់នូវសិទ្ធិតំណាង គឺ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ភាគីដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងឡើងវិញ ។

ឃ-បើមរណភាព ឬ ការបាត់បង់នូវលក្ខណសម្បត្តិដោយហេតុផ្សេងរបស់បុគ្គលដែលមានលក្ខណសម្បត្តិដែលបានកំណត់ ហើយធ្វើបណ្តឹងក្នុងនាមផ្ទាល់ខ្លួនជំនួសអ្នកដទៃ គឺ បុគ្គលដែលមានលក្ខណសម្បត្តិដូចគ្នា ។

ង-បើមរណភាព ឬ ការបាត់បង់នូវលក្ខណសម្បត្តិដោយហេតុផ្សេងរបស់ភាគីដែលត្រូវបានជ្រើសរើសទាំងអស់ ដោយបញ្ញត្តិនៃមាត្រា ៤២ (ការជ្រើសរើសភាគី) នៃក្រមនេះ គឺ អ្នកដែលបានជ្រើសរើសទាំងអស់ ដោយមាត្រា ៤២ ឬ ភាគីដែលត្រូវបានជ្រើសរើសសាជាថ្មីដោយមាត្រា ៤២ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានអ្នកតំណាងដោយអាណត្តិ ។ ប៉ុន្តែ អ្នកតំណាងដោយអាណត្តិ ត្រូវរាយការណ៍ទៅតុលាការ អំពីការកើតឡើងនូវហេតុដែលបានកំណត់ក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ ខាងលើនេះ ។

៤-ទោះបីជាមានហេតុដូចបានកំណត់ក្នុងចំណុច ក នៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏សន្តតិជនមិនអាចទទួលបន្តនីតិវិធីនៃបណ្តឹងបានដែរ ក្នុងអំឡុងពេលដែលសន្តតិ-ជននោះអាចបោះបង់ចោលនូវសន្តតិកម្មបាន ។

**មាត្រា ១៧៤.–** ការបញ្ចប់នូវនីតិវិធីនៃបណ្តឹងដោយស្វ័យប្រវត្តិ

ក្នុងករណីដែលភាគីបានទទួលមរណភាព ឬ បានរលត់ដោយការរួមបញ្ចូលនៃនីតិ-បុគ្គល ហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង ឬ សិទ្ធិឬកាតព្វកិច្ចនោះបានធ្លាក់ទៅលើបុគ្គលតែម្នាក់ នោះនីតិវិធីនៃបណ្តឹងត្រូវបានបញ្ចប់ ។ ក្នុងករណីនេះ តុលាការត្រូវចេញសាលក្រមប្រកាសបញ្ចប់បណ្តឹងនោះ ។

**មាត្រា ១៧៥.–** នីតិវិធីដើម្បីទទួលបន្ត

១-ការដាក់ពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹង អាចធ្វើឡើងដោយបុគ្គលដែលមានបំណងទទួលបន្ត ឬ ដោយភាគីម្ខាងទៀត ។

២-ប្រសិនបើមានពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹង តុលាការត្រូវជូនដំណឹងទៅភាគីម្ខាងទៀត ។

៣-ប្រសិនបើមានពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹង តុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ហើយបើយល់ឃើញថា គ្មានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវលើកចោលនូវពាក្យសុំនោះ ដោយដីកាសម្រេច ។ ចំពោះដីកាសម្រេចនេះ អាចប្តឹងជំទាស់បាន ។

៤-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ប្រសិនបើយល់ឃើញថា មានមូលហេតុត្រឹមត្រូវ តុលាការត្រូវអនុញ្ញាតការទទួលបន្តនីតិវិធីនៃបណ្តឹងនោះ ដោយដីកាសម្រេច ។

៥-ក្នុងករណីដែលមានពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹងដែលត្រូវបានផ្អាក ក្រោយការបញ្ជូនសាលក្រម តុលាការដែលបានចេញសាលក្រមនោះ ត្រូវធ្វើការសម្រេចសេចក្តីអំពីពាក្យសុំនោះ ។

**មាត្រា ១៧៦.–** ការបង្គាប់ឱ្យបន្តដោយឆន្ទានុសិទ្ធិ

ទោះបីជាភាគីទាំងសងខាងមិនបានដាក់ពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹងក៏ដោយក៏តុលាការអាចបង្គាប់ឱ្យបន្តនីតិវិធីនៃបណ្តឹង ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ដោយដីកាសម្រេចបានដែរ ។

**មាត្រា ១៧៧.–** ការបង្អង់នីតិវិធីនៃបណ្តឹង

១-ប្រសិនបើតុលាការមិនអាចបំពេញកិច្ចការរបស់ខ្លួន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ ហេតុផ្សេងទៀត នីតិវិធីនៃបណ្តឹងត្រូវបានបង្អង់រហូតដល់ហេតុនោះរលត់ ។

២-ប្រសិនបើភាគីមិនអាចបន្តនីតិវិធីនៃបណ្តឹង ដោយសារឧបសគ្គដែលមានរយៈពេលវែង ហើយមិនអាចប៉ាន់ស្មានបានថា ពេលណាចប់ តុលាការអាចបង្គាប់ឱ្យបង្អង់នូវនីតិវិធីនៃបណ្តឹងនោះ ដោយដីកាសម្រេចបាន ។ ក្នុងករណីនេះ ពេលដែលឧបសគ្គនោះត្រូវបានកន្លងផុតទៅ តុលាការអាចលុបចោលនូវដីកាសម្រេចនោះបាន ។

៣-ប្រសិនបើរឿងក្តីព្រហ្មទណ្ឌដែលទាក់ទងនឹងអង្គហេតុ ដែលជាមូលដ្ឋាននៃការទាមទារណាមួយក្នុងរឿងក្តីរដ្ឋប្បវេណី កំពុងត្រូវបានចាត់ការ នោះតុលាការអាចបង្គាប់ឱ្យបង្អង់នូវនីតិវិធីនៃបណ្តឹងរបស់រឿងក្តីរដ្ឋប្បវេណីនោះ ដោយដីកាសម្រេចបាន ។ នៅក្នុងករណីនេះ ពេលដែលរឿងក្តីព្រហ្មទណ្ឌនោះត្រូវបានបញ្ចប់ តុលាការអាចលុបចោលនូវដីកាសម្រេចនោះបាន ។

**មាត្រា ១៧៨.–** អានុភាពនៃការផ្អាក ឬ បង្អង់នីតិវិធីនៃបណ្តឹង

១-នៅពេលដែលមានការផ្អាក ឬ បង្អង់នីតិវិធីនៃបណ្តឹង ភាគី និង តុលាការ មិនអាច

ធ្វើសកម្មភាពបណ្ដឹងបានឡើយ ។ ប៉ុន្តែ តុលាការអាចប្រកាសសាលក្រមបាន ទោះបីជានីតិវិធីនៃបណ្ដឹងនោះត្រូវបានផ្អាកក៏ដោយ ។

២-នៅពេលដែលមានការផ្អាក ឬ បង្អង់នីតិវិធីនៃបណ្ដឹង អំឡុងពេលក៏ត្រូវបញ្ឈប់ដំណើរការដែរ ។ ក្នុងករណីនេះ អំឡុងពេលទាំងអស់នោះត្រូវចាប់ផ្ដើមពីដំបូងវិញ ចាប់ពីពេលដែលធ្វើការជូនដំណឹងស្ដីពីការទទួលបន្តនីតិវិធីនៃបណ្ដឹង ឬ ពេលដែលបន្តនីតិវិធីនៃបណ្ដឹងនោះ ។

## ជំពូកទី ៥
## ការសម្រេចសេចក្ដី

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅស្ដីពីការសម្រេចសេចក្ដី

**មាត្រា ១៧៩.-** ប្រភេទនៃការសម្រេចសេចក្ដី

១-សាលក្រម គឺជាការសម្រេចសេចក្ដី ដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងក្រមនេះ ឬ នៅក្នុងច្បាប់ផ្សេង ហើយកើតអានុភាព ដោយការប្រកាស ដោយផ្អែកលើលិខិតសាលក្រមនោះ ។

២-ដីកាសម្រេច គឺជាការសម្រេចសេចក្ដីដែលតុលាការ ឬ ចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន ហើយមិនមែនជាសាលក្រម ។

### ផ្នែកទី ២
### បទប្បញ្ញត្តិទូទៅស្ដីពីសាលក្រម

**មាត្រា ១៨០.-** សាលក្រមចុងក្រោយ

១-បើយល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលដែលបានមកពីការទាញហេតុផលដោយផ្ទាល់មាត់ និង ការពិនិត្យលើភស្តុតាង តុលាការត្រូវបញ្ចប់ការ

ទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រមចុងក្រោយ ។

២-បើយល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យចំពោះការទាមទារមួយ ក្នុងចំណោមការទាមទារច្រើនដែលត្រូវបានបញ្ចូលគ្នា តុលាការអាចចេញសាលក្រមសម្រេចដល់អង្គសេចក្តីចំពោះការទាមទារតែមួយនោះបាន ។

៣-បើយល់ឃើញថា មានការចាំបាច់ដើម្បីចេញសាលក្រមចុងក្រោយ តុលាការអាចបង្គាប់ឱ្យធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានបញ្ចប់ហើយនោះ សាជាថ្មីឡើងវិញបាន ។

**មាត្រា ១៨១.–** សាលក្រមរបៀប

បើមានវិវាទអំពីហេតុណាមួយដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ តុលាការអាចបញ្ចប់ការវិនិច្ឆ័យ ចំពោះតែហេតុនោះសិន ហើយចេញសាលក្រមរបៀបបាន :

ក-អត្ថិភាពនៃការទាមទារក្នុងករណីដែលមានវិវាទលើអត្ថិភាព និង ចំនួនទឹកប្រាក់នៃការទាមទារ ។

ខ-មធ្យោបាយតទល់ ឬ ការពារខ្លួនដែលអាចវិនិច្ឆ័យដោយឯករាជ្យបាន ។

គ-អត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌបណ្តឹង ។

ឃ-ហេតុដែលទាក់ទងនឹងការបញ្ចប់បណ្តឹង ។

**មាត្រា ១៨២.–** ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម

១-តុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ ។

២-តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ ។

៣-តុលាការត្រូវសម្រេចសេចក្តីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ ។

**មាត្រា ១៨៣.–** ការខកខានវិនិច្ឆ័យ

បើតុលាការខកខានមិនបានធ្វើការវិនិច្ឆ័យលើការទាមទារផ្នែកណាមួយ ផ្នែកនៃការទាមទារដែលខកខាននោះ ត្រូវបានចាត់ការបន្តនៅតុលាការនោះតទៅទៀត ។

**មាត្រា ១៨៤.-** គោលការណ៍ជំនឿទុកចិត្តដោយសេរី

ក្នុងការចេញសាលក្រម តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ ឬ មិនទទួលស្គាល់ថាការអះអាងអំពីអង្គហេតុ មាន ឬ គ្មានភាពពិត ដោយគិតពិចារណាយ៉ាងហ្មត់ចត់នូវលទ្ធផលនៃការពិនិត្យភស្តុតាង និង ដំណើរការនិងខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់ តាមជំនឿទុកចិត្តដោយសេរីរបស់ខ្លួន ។

**មាត្រា ១៨៥.-** គោលការណ៍វិនិច្ឆ័យដោយផ្ទាល់

១-មានតែចៅក្រមដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលជាមូល-ដ្ឋាននៃសាលក្រមនោះតែប៉ុណ្ណោះ ទើបអាចចេញសាលក្រមបាន ។

២-ក្នុងករណីដែលមានការផ្លាស់ប្តូរចៅក្រមនៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍នូវលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក ។

៣-ក្នុងករណីដែលចៅក្រមទទួលបន្ទុកមានតែម្នាក់ត្រូវបានផ្លាស់ប្តូរ ឬ ករណីដែលចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបានផ្លាស់ប្តូរលើសពីពាក់កណ្តាល ប្រសិនបើភាគីដាក់ពាក្យសុំសាកសួរសាក្សីដែលបានសាកសួរពីមុនមករួចហើយ តុលាការត្រូវសាកសួរសាក្សីនោះឡើងវិញ ។

## ផ្នែកទី ៣

## ការប្រកាសសាលក្រម

**មាត្រា ១៨៦.-** កំណើតអានុភាពនៃសាលក្រម

សាលក្រមនឹងមានអានុភាពដោយការប្រកាស ។

**មាត្រា ១៨៧.-** កាលបរិច្ឆេទនៃការប្រកាស

ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះរឿងក្តីដែលមានភាពស្មុគស្មាញខ្លាំង ឬ មានកាលៈទេសៈពិសេសផ្សេងទៀត ។

**មាត្រា ១៨៨.–** របៀបនៃការប្រកាស

១-ការប្រកាសសាលក្រមត្រូវធ្វើឡើងតាមកាលបរិច្ឆេទ នៅក្នុងសាលសវនាការដែលបើកជាសាធារណៈ ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេចបញ្ចប់ ដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម ។ ប៉ុន្តែ ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះមានធុរៈ ចៅក្រមប្រឹក្សាអាចអានជំនួសបាន ។

២-ការប្រកាសសាលក្រមអាចធ្វើបាន ទោះបីជាគ្មានវត្តមានរបស់គូភាគីនៅក្នុងសាលសវនាការក៏ដោយ ។

៣-ប្រសិនបើយល់ឃើញថាសមរម្យ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអានសំអាងហេតុនៃសាលក្រម ឬ អាចពន្យល់ខ្លឹមសារនៃសំអាងហេតុនោះដោយផ្ទាល់មាត់បាន ។

**មាត្រា ១៨៩.–** លិខិតសាលក្រម

១-នៅក្នុងលិខិតសាលក្រម ត្រូវសរសេរចំណុចដូចខាងក្រោមនេះ :

ក-តុលាការ ។

ខ-ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

គ-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ឃ-អង្គហេតុ និង ចំណុចវិវាទ ។

ង-សំអាងហេតុ ។

ច-សេចក្តីសម្រេចបញ្ចប់ ។

២-ចំពោះអង្គហេតុ និង ចំណុចវិវាទ ត្រូវសរសេរខ្លឹមសារសំខាន់ៗដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ភាគី ។

៣-ចៅក្រមដែលចេញសាលក្រមត្រូវចុះហត្ថលេខាលើលិខិតសាលក្រមនោះ ។

៤-ក្នុងករណីដែលចៅក្រមណាម្នាក់ក្នុងចំណោមក្រុមប្រឹក្សាជំនុំជម្រះ មានធុរៈក្នុងការចុះហត្ថលេខាលើលិខិតសាលក្រម ចៅក្រមផ្សេងទៀតត្រូវចុះហត្ថលេខា ដោយចុះនិទ្ទេសអំពីហេតុដែលចៅក្រមនោះមិនអាចចុះហត្ថលេខាបាន ។

**មាត្រា ១៩០.–** ការបញ្ជូនលិខិតសាលក្រម

១-លិខិតសាលក្រមត្រូវបញ្ជូនទៅឱ្យគូភាគី ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនោះ ។

២-ការបញ្ជូនដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានធ្វើឡើងដោយអនុសារសាលក្រម ។

## ផ្នែកទី ៤
## អានុភាពនៃសាលក្រម

**មាត្រា ១៩១.–** អត្ថពន្ធភាពនៃសាលក្រម

លើកលែងតែក្នុងករណីដែលបានកំណត់ក្នុងមាត្រា ១៩២ (ដីកាសម្រេចកែតម្រូវ) នៃក្រមនេះ តុលាការដែលបានចេញសាលក្រម មិនអាចលុប ឬ កែប្រែសាលក្រមនោះបានទេ ។

**មាត្រា ១៩២.–** ដីកាសម្រេចកែតម្រូវ

១-ក្នុងករណីដែលសាលក្រមមានការគណនាលេខខុស ឬ កត់ខុស ឬ កំហុសជាក់ស្ដែងផ្សេងទៀតដែលមានប្រភេទប្រហាក់ប្រហែលគ្នា តុលាការអាចចេញដីកាសម្រេចកែតម្រូវសាលក្រម តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

២-ចំពោះដីកាសម្រេចកែតម្រូវសាលក្រម អាចប្ដឹងជំទាស់បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបណ្ដឹងឧទ្ធរណ៍ស្របច្បាប់ចំពោះសាលក្រមនោះ ។

៣-ដីកាសម្រេចកែតម្រូវត្រូវសរសេរបន្ថែមនៅលើច្បាប់ដើមនៃមូលសាលក្រម និង អនុសារសាលក្រម ។ ប៉ុន្តែ ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចធ្វើដីកាសម្រេចនេះជាលិខិត ជំនួសការសរសេរបន្ថែមនៅលើច្បាប់ដើមនៃមូលសាលក្រម និង អនុសារសាលក្រម ហើយបញ្ជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនេះ ទៅឱ្យគូភាគីបាន ។

**មាត្រា ១៩៣.–** ពេលដែលសាលក្រមចូលជាស្ថាពរ

១-សាលក្រមមិនអាចចូលជាស្ថាពរ នៅមុនពេលផុតអំឡុងពេលដែលបានកំណត់

សម្រាប់ការប្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់ដែលស្របច្បាប់ ឬ ការប្តឹងទាស់ដែលស្រប ច្បាប់បានទេ ។

២-ការចូលជាស្ថាពរនៃសាលក្រម ត្រូវបានបង្អាក់ ដោយការដាក់ពាក្យបណ្តឹងឧបា-ស្រ័យទៅតុលាការជាន់ខ្ពស់ ឬ ពាក្យបណ្តឹងទាស់ ដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេលដែល បានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១៩៤.–** អាជ្ញាអស់ជំនុំនៃចំណុចដែលត្រូវបានវិនិច្ឆ័យដោយសាលក្រម

១-នៅពេលសាលក្រមចូលជាស្ថាពរហើយ អានុភាពនៃអាជ្ញាអស់ជំនុំត្រូវកើតឡើង ។

២-អាជ្ញាអស់ជំនុំដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ជាស្ថាពរ នូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់ មាត់ ។

៣-ទំហំនៃអាជ្ញាអស់ជំនុំដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានត្រឹម តែទំហំដែលបានវិនិច្ឆ័យនៅក្នុងសេចក្តីសម្រេចបញ្ចប់ ចំពោះការទាមទារដែលបានសុំ ដោយពាក្យបណ្តឹង ឬ ពាក្យបណ្តឹងតបតែប៉ុណ្ណោះ ហើយអានុភាពនៃអាជ្ញាអស់ជំនុំនេះ មិន អាចមានទៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រមបានទេ ។

៤-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះក៏ដោយ បើចុងចម្លើយទាម ទារការទូទាត់ ដោយសិទ្ធិលើបំណុលតប សេចក្តីវិនិច្ឆ័យក្នុងសាលក្រមស្ថាពរដែលសម្រេច ថា គ្មានសិទ្ធិលើបំណុលតបទេនោះ ត្រូវបង្កើតអានុភាពនៃអាជ្ញាអស់ជំនុំ លើចំនួនប្រាក់ដែល បានតវ៉ា ដោយការទូទាត់នោះ ។

**មាត្រា ១៩៥.–** ពេលដែលអានុភាពអនុវត្តកើតឡើង

លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ សាលក្រមអាចអនុវត្តបាន ចាប់តាំងពី ពេលដែលអាជ្ញាអស់ជំនុំបានកើតឡើង ដូចបានកំណត់ក្នុងមាត្រា ១៩៤ (អាជ្ញាអស់ជំនុំនៃ ចំណុចដែលត្រូវបានវិនិច្ឆ័យដោយសាលក្រម) នៃក្រមនេះ ។

**មាត្រា ១៩៦.–** ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១-ចំពោះសាលក្រមដែលសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ បើយល់ឃើញ

ថាចាំបាច់ តុលាការអាចប្រកាសថា សាលក្រមនោះអាចអនុវត្តជាបណ្តោះអាសន្នបាន ដោយឱ្យដើមចោទដែលឈ្នះក្តីដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២-តុលាការអាចប្រកាសថា ភាគីអាចរួចផុតពីការអនុវត្តជាបណ្តោះអាសន្នបាន ដោយឱ្យដាក់ប្រាតិភោគ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

៣-ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវចែងនៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រកាសដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

៤-ក្នុងករណីដែលមិនបានសម្រេចសេចក្តីអំពីពាក្យសុំប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ក្នុងករណីដែលត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយឆន្ទានុសិទ្ធិ តែមិនបានធ្វើ តុលាការត្រូវចេញដីកាសម្រេចបន្ថែម តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតុលាការមិនបានសម្រេចសេចក្តីអំពីពាក្យសុំដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

**មាត្រា ១៩៧.-** ការបាត់បង់អានុភាពនៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និង បដិទានស្ថានភាពដើម

១-ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នត្រូវបាត់បង់អានុភាព ដោយការប្រកាសសាលដីការបស់តុលាការជាន់ខ្ពស់ដែលសម្រេចផ្លាស់ប្តូរការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះ ឬ សាលក្រមសម្រេចអង្គសេចក្តី តាមទំហំនៃការផ្លាស់ប្តូរ ។

២-ក្នុងករណីដែលតុលាការផ្លាស់ប្តូរសាលក្រមសម្រេចអង្គសេចក្តី តុលាការត្រូវបង្គាប់ក្នុងសាលដីកាឱ្យដើមចោទសងតាវកាលិកដែលចុងចម្លើយបានផ្តល់ ដោយផ្អែកលើការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និង ឱ្យសងការខូចខាតដែលចុងចម្លើយបានទទួលដោយសារការអនុវត្តជាបណ្តោះអាសន្ន ឬ ដើម្បីធ្វើឱ្យរួចផុតពីការអនុវត្តជាបណ្តោះអាសន្ននោះ តាមពាក្យសុំរបស់ចុងចម្លើយ ។

៣-ក្នុងករណីដែលតុលាការបានផ្លាស់ប្តូរតែចំពោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នប៉ុណ្ណោះ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះសាល

ដីកាដែលផ្លាស់ប្តូរសាលក្រមសម្រេចអង្គសេចក្តីនៅពេលក្រោយ ។

**មាត្រា ១៩៨.–** វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ

សាលក្រមស្ថាពរមានអានុភាពចំពោះបុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ភាគី ។

ខ-តតិយជន ក្នុងករណីដែលភាគីធ្វើជាដើមចោទ ឬ ចុងចម្លើយនៃបណ្តឹងជំនួសតតិយជននោះ ។

គ-បុគ្គលដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច ពីអ្នកដែលបានកំណត់ក្នុងចំណុចទាំងពីរខាងលើនេះ ក្រោយពីបណ្តឹងត្រូវបានចាត់ការ ។

ឃ-បុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការទាមទារ សម្រាប់ផលប្រយោជន៍របស់បុគ្គលដែលបានកំណត់ក្នុងចំណុចទាំងបីខាងលើនេះ ។

**មាត្រា ១៩៩.–** អានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស

សាលក្រមស្ថាពររបស់តុលាការបរទេស ត្រូវមានអានុភាព លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌទាំងអស់ ដូចខាងក្រោមនេះ :

ក-បើសិទ្ធិជម្រះក្តីរបស់តុលាការបរទេសត្រូវបានទទួលស្គាល់ ដោយច្បាប់ ឬ សន្ធិសញ្ញា ឬ អនុសញ្ញា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

ខ-បើចុងចម្លើយដែលចាញ់ក្តី បានទទួលការបញ្ជូនដីកាកោះហៅ ឬ ដីកាបង្គាប់ដែលចាំបាច់ដើម្បីចាប់ផ្តើមនីតិវិធី ឬ មិនបានទទួលទេ តែបានឆ្លើយដោះសាតបចំពោះបណ្តឹងនោះ ។

គ-បើខ្លឹមសារនៃសាលក្រម និង នីតិវិធីនៃបណ្តឹងនោះ មិនប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា ។

ឃ-បើមានការធានាទៅវិញទៅមករវាងព្រះរាជាណាចក្រកម្ពុជា និង បរទេស ។

## ផ្នែកទី ៥
## សាលក្រមកំបាំងមុខ

**មាត្រា ២០០.–** សាលក្រមកំបាំងមុខដើមចោទ

១-បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវប្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ ។

២-បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការអាចបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់បាន ។

៣-បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការត្រូវប្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ ។

**មាត្រា ២០១.–** សាលក្រមកំបាំងមុខចុងចម្លើយ

១-បើចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់ ។

២-បើចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ ហើយបើយល់ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ តែបើយល់ឃើញថា ការទាមទាររបស់ដើមចោទមិនត្រឹមត្រូវទេ តុលាការត្រូវប្រានចោលការទាមទារនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចុងចម្លើយធ្វើវិវាទលើការអះអាងរបស់ដើមចោទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ពីមុនមក ។

**មាត្រា ២០២.–** ករណីដែលមិនអាចចេញសាលក្រមកំបាំងមុខ

បើមានករណីណាមួយដូចខាងក្រោមនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខ បានឡើយ ៖

ក-ភាគីដែលមិនបានបង្ហាញខ្លួន មិនបានទទួលការកោះហៅស្របច្បាប់ ។

ខ-ភាគីដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបានមែន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ កាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន ។

គ-បណ្ដឹងមិនស្របច្បាប់ ។

ឃ-ខ្លឹមសារនៃសេចក្ដីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្ដីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅចុងចម្លើយ មុនកាលបរិច្ឆេទនោះ ។

**មាត្រា ២០៣.-** ការពន្យារកាលបរិច្ឆេទ

១-បើយល់ឃើញថា អំឡុងពេលនៃការកោះហៅមានរយៈពេលខ្លីពេក ឬ យល់ឃើញថា ភាគីមិនអាចមកបង្ហាញខ្លួនបានដោយគ្មានកំហុសទេ តុលាការអាចពន្យារកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២-បើតុលាការ បានពន្យារកាលបរិច្ឆេទតាមកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវធ្វើការកោះហៅភាគីដែលមិនបានបង្ហាញខ្លួននោះ តាមកាលបរិច្ឆេទថ្មី ។

**មាត្រា ២០៤.-** បណ្ដឹងទាស់

១-បើភាគីមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ដោយសារមានហេតុដែលមិនអាចព្យាករបាន ឬ ហេតុដែលមិនអាចជៀសវាងបាន ហើយបានទទួលសាលក្រមកំបាំងមុខ ភាគីនោះអាចប្ដឹងទាស់ចំពោះសាលក្រមនោះបាន ។

២-បណ្ដឹងទាស់ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ ។ អំឡុងពេលនេះពុំអាចពន្យារបានឡើយ ។

៣-បើសាលក្រមកំបាំងមុខ ត្រូវបានបញ្ជូនតាមរយៈការបិទប្រកាសជាសាធារណៈ ឬ តាមរយៈការបញ្ជូននៅបរទេស តុលាការត្រូវកំណត់អំឡុងពេលដែលអាចប្ដឹងទាស់ នៅក្នុងសាលក្រមកំបាំងមុខនោះ ។

**មាត្រា ២០៥.–** របៀបប្តឹងទាស់

១-ការប្តឹងទាស់ត្រូវធ្វើឡើងដោយដាក់ពាក្យបណ្តឹងទាស់ទៅតុលាការដែលបានចេញសាលក្រមកំបាំងមុខ ។

២-នៅក្នុងពាក្យបណ្តឹងទាស់ ត្រូវសរសេរចំណុចដូចខាងក្រោម:

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់គូភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្តឹងទាស់ ។

គ-បំណងនៃការប្តឹងទាស់ចំពោះសាលក្រមដែលបានកំណត់ក្នុងចំណុច ខ ខាងលើនេះ ។

ឃ-មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ។

**មាត្រា ២០៦.–** ការពិនិត្យ និង ការបញ្ជូនពាក្យបណ្តឹងទាស់

១-ក្នុងករណីដែលពាក្យបណ្តឹងទាស់មិនស្របនឹងបញ្ញត្តិនៃមាត្រា ២០៥ (របៀបប្តឹងទាស់) នៃក្រមនេះ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៃពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលនោះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើភាគីដែលប្តឹងទាស់មិនបានកែតម្រូវចំណុចខ្វះខាតទេ តុលាការត្រូវលើកពាក្យបណ្តឹងទាស់នោះចោលដោយដីកាសម្រេច ។

៣-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៤-ក្នុងករណីដែលពាក្យបណ្តឹងទាស់គ្មានចំណុចខ្វះខាតទេ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងទាស់នោះទៅភាគីម្ខាងទៀត ហើយកំណត់កាលបរិច្ឆេទថ្មីដើម្បីវិនិច្ឆ័យបណ្តឹងទាស់នោះ និង កោះហៅគូភាគី ។

**មាត្រា ២០៧.–** ការវិនិច្ឆ័យ និង ការសម្រេចសេចក្តីលើបណ្តឹងទាស់

១-តុលាការត្រូវធ្វើការស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន អំពីភាពត្រឹមត្រូវនៃពាក្យបណ្តឹងទាស់តាមទម្រង់ និង អំឡុងពេលដែលកំណត់ដោយច្បាប់ និង អំពីភាពត្រឹម

ត្រូវនៃមូលហេតុបណ្ដឹងទាស់ ។

២-តុលាការត្រូវលើកចោលនូវបណ្ដឹងទាស់ ដោយដីកាសម្រេច ប្រសិនបើយល់ឃើញថា ពាក្យបណ្ដឹងទាស់នោះមិនត្រឹមត្រូវតាមច្បាប់ តែបើយល់ឃើញថា ពាក្យបណ្ដឹងទាស់នោះ គ្មានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវច្រានចោលបណ្ដឹងនោះដោយដីកាសម្រេច ។

**មាត្រា ២០៨.–** អានុភាពនៃបណ្ដឹងទាស់ដែលត្រូវបានទទួលស្គាល់

១-ក្នុងករណីដែលពាក្យបណ្ដឹងទាស់ត្រូវបានទទួលស្គាល់ នីតិវិធីនៃបណ្ដឹងនោះត្រូវត្រឡប់ទៅសភាពដើមវិញ ពីត្រឹមពេលអវត្តមាននោះកើតឡើង ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវកំណត់កាលបរិច្ឆេទថ្មីដើម្បីចាប់ផ្ដើមអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ដើម្បីចាប់ផ្ដើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ឡើងវិញ ហើយត្រូវជូនដំណឹងនេះទៅឱ្យគូភាគី ។

**មាត្រា ២០៩.–** សាលក្រមថ្មី

១-បើសាលក្រមដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្ដើមអនុវត្តនីតិវិធីឡើងវិញ មានលទ្ធផលដូចសាលក្រមកំបាំងមុខ នោះតុលាការត្រូវចេញសាលក្រមថ្មីដែលប្រកាសថា តម្កល់សាលក្រមកំបាំងមុខនោះទុកជាបានការ ។

២-បើសាលក្រមដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្ដើមអនុវត្តនីតិវិធីឡើងវិញ គ្មានលទ្ធផលដូចសាលក្រមកំបាំងមុខទេ នោះតុលាការត្រូវលុបចោលសាលក្រមកំបាំងមុខនោះនៅក្នុងសាលក្រមថ្មី ។

**មាត្រា ២១០.–** សោហ៊ុយដែលកើតឡើងដោយសារអវត្តមាន

បើសាលក្រមកំបាំងមុខត្រូវបានធ្វើឡើងស្របតាមទម្រង់ដែលច្បាប់បានកំណត់ ទោះបីជាត្រូវលុបចោលសាលក្រមនោះ ដោយផ្អែកលើពាក្យបណ្ដឹងទាស់ក៏ដោយ ក៏សោហ៊ុយដែលកើតឡើងដោយសារអវត្តមាន ត្រូវជាបន្ទុករបស់ភាគីដែលមិនបានបង្ហាញខ្លួនដែរ លើកលែងតែករណីដែលសោហ៊ុយនោះបានកើតឡើង ដោយសារសកម្មភាពបណ្ដឹងមិនត្រឹមត្រូវរបស់ភាគីម្ខាងទៀត ។

**មាត្រា ២១១.–** សាលក្រមកំបាំងមុខលើកទី ២

១-បើភាគីដែលបានប្ដឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងក្រោយពេលចាប់ផ្ដើមអនុវត្តនីតិវិធីឡើងវិញទេ តុលាការត្រូវច្រានចោលបណ្ដឹងទាស់ ដោយសាលក្រមកំបាំងមុខម្ដងទៀត លើកលែងតែក្នុងករណីដែលបានកំណត់ក្នុងមាត្រា ២០២ (ករណីដែលមិនអាចចេញសាលក្រមកំបាំងមុខ) និង កថាខណ្ឌទី ២ នៃមាត្រា ២០៣ (ការពន្យារកាលបរិច្ឆេទ) នៃក្រមនេះ ។

២-ចំពោះសាលក្រមកំបាំងមុខលើកទី ២ ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចប្ដឹងទាស់បានទៀតទេ ។

**មាត្រា ២១២.–** បញ្ញត្តិដែលអនុវត្តដូចគ្នា

១-បញ្ញត្តិស្ដីពីការដកពាក្យបណ្ដឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការដកពាក្យបណ្ដឹងទាស់ ។

២-បញ្ញត្តិនៃផ្នែកនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងតប ។

## ផ្នែកទី ៦
## ដីកាសម្រេច

**មាត្រា ២១៣.–** ការជូនដំណឹងអំពីដីកាសម្រេច

១-ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែត្រូវបានជូនដំណឹងតាមវិធីដែលអាចទទួលស្គាល់ថាសមរម្យ ។

២-ក្នុងករណីចេញដីកាសម្រេចជាលាយលក្ខណ៍អក្សរ ចៅក្រមដែលបានចេញដីកាសម្រេច ត្រូវចុះហត្ថលេខាលើដីកាសម្រេចនោះ ។

៣-នៅពេលជូនដំណឹងអំពីដីកាសម្រេច ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និងវិធីនៃការជូនដំណឹងនោះ ដាក់នៅក្នុងសំណុំរឿង ។

**មាត្រា ២១៤.–** ការលុបចោលនូវដីកាសម្រេចទាក់ទងនឹងការដឹកនាំនីតិវិធី

ដីកាសម្រេចទាក់ទងនឹងការដឹកនាំនីតិវិធីនៃបណ្ដឹង អាចលុបចោលនាពេលណាក៏បាន ។

**មាត្រា ២១៥.–** បណ្តឹងតវ៉ាអំពីការចាត់ចែងរបស់ក្រឡាបញ្ជី

ចំពោះបណ្តឹងតវ៉ាអំពីការចាត់ចែងរបស់ក្រឡាបញ្ជី តុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅក្រោមឱវាទ ត្រូវសម្រេចសេចក្តី ដោយដីកាសម្រេច ។

**មាត្រា ២១៦.–** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីសាលក្រម

បញ្ញត្តិស្តីពីសាលក្រមត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេច លើកលែងតែបញ្ញត្តិស្តីពីសាលក្រមនោះ មានភាពផ្ទុយពីលក្ខណៈនៃដីកាសម្រេច ។

## ជំពូកទី ៦
## ការបញ្ចប់នីតិវិធីដោយមិនធ្វើទៅតាមការសម្រេចសេចក្តី

**មាត្រា ២១៧.–** ការដកពាក្យបណ្តឹង

១-ដើមចោទអាចដកពាក្យបណ្តឹងទាំងអស់ ឬ មួយផ្នែកបាន រហូតដល់ពេលដែលសាលក្រមចូលជាស្ថាពរ ។

២-ក្រោយពីចុងចម្លើយបានដាក់ឯកសារត្រៀមអំពីអង្គសេចក្តី ឬ បានឆ្លើយក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអំពីអង្គសេចក្តី ឬ បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់អំពីអង្គសេចក្តីហើយ ការដកពាក្យបណ្តឹង មិនត្រូវមានអានុភាពឡើយ លើកលែងតែបានទទួលការយល់ព្រមពីចុងចម្លើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះការដកពាក្យបណ្តឹងតបក្នុងករណីដែលដើមចោទបានដកពាក្យបណ្តឹងដើម ។

៣-ការដកពាក្យបណ្តឹង ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ការដកពាក្យបណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់ក៏បាន ។

៤-ក្នុងករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ២ ខាងលើនេះ ប្រសិនបើការដកពាក្យបណ្តឹង ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ តុលាការត្រូវបញ្ជូនលិខិតនេះទៅចុងចម្លើយ ហើយប្រសិនបើការដកពាក្យបណ្តឹង ត្រូវបានធ្វើឡើងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញ

ហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា តុលាការត្រូវបញ្ជូនឯកសារចម្លងនៃកំណត់ហេតុនៃកាលបរិច្ឆេទនេះ ទៅចុងចម្លើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការដកពាក្យបណ្តឹង ត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ហើយចុងចម្លើយបានចូលរួមនៅក្នុងកាលបរិច្ឆេទនោះ ។

៥-ប្រសិនបើចុងចម្លើយមិនបានប្តឹងត៍វ៉ា ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ បន្ទាប់ពីបានទទួលលិខិតដកពាក្យបណ្តឹងដែលត្រូវបានបញ្ជូនទេ នោះត្រូវចាត់ទុកថា ចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្តឹងនេះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដែរ ចំពោះករណីដែលការដកពាក្យបណ្តឹង ត្រូវបានធ្វើឡើងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ហើយចុងចម្លើយមិនបានប្តឹងត៍វ៉ា ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ បន្ទាប់ពីថ្ងៃដែលមានការដកពាក្យបណ្តឹង ប្រសិនបើចុងចម្លើយក៏បានចូលរួមនៅកាលបរិច្ឆេទនោះដែរ ឬ ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូនឯកសារចម្លងដែលបានកំណត់ក្នុងកថាខណ្ឌទី ៤ ខាងលើនេះ ប្រសិនបើចុងចម្លើយមិនបានចូលរួមនៅកាលបរិច្ឆេទនោះទេ ។

**មាត្រា ២១៨.–** អានុភាពនៃការដកពាក្យបណ្តឹង

១-ផ្នែកដែលត្រូវបានដកពាក្យបណ្តឹង ត្រូវចាត់ទុកថា មិនបានចាត់ការតាំងពីដំបូង ។

២-ភាគីដែលបានដកពាក្យបណ្តឹងក្រោយពីចេញសាលក្រមចុងក្រោយអំពីអង្គសេចក្តីមិនអាចដាក់ពាក្យបណ្តឹងដូចគ្នាម្តងទៀតបានទេ ។

**មាត្រា ២១៩.–** ការចាត់ទុកថា ដកពាក្យបណ្តឹង

ក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយមិនបានដាក់ពាក្យសុំឱ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីទៀត ក្នុងអំឡុងពេល ១ (មួយ) ខែទេ នោះត្រូវចាត់ទុកថា បានដកពាក្យបណ្តឹង ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះ

ករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ពីរដងជាប់គ្នា ។

**មាត្រា ២២០.–** ការផ្សះផ្សាលើបណ្តឹង

១-ភាគីអាចធ្វើការផ្សះផ្សានៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សាបាន ។

២-ការផ្សះផ្សាដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើនៅក្រៅទីតាំងតុលាការក៏បានដែរ ប្រសិនបើតុលាការយល់ឃើញថាសមរម្យ ។

**មាត្រា ២២១.–** ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ

ការលះបង់នូវការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ។

**មាត្រា ២២២.–** អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍

ក្នុងករណីដែលមានការសះជា ការលះបង់នូវការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ។

## ជំពូកទី ៧
## បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច

**មាត្រា ២២៣.–** គោលបំណងនៃនីតិវិធី

នីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច មានគោលបំណងដើម្បីដោះស្រាយវិវាទដ៏ឆាប់រហ័សតាមនីតិវិធីសង្ខេប ។

**មាត្រា ២២៤.–** ល័ក្ខខ័ណ្ឌនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ជាអាទិ៍

១-ចំពោះបណ្តឹងដែលមានគោលបំណងទាមទារសំណងជាទឹកប្រាក់មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ដែលជាតម្លៃកម្មវត្ថុនៃបណ្តឹង ដើមចោទអាចស្នើសុំការជំនុំជម្រះ និង សម្រេចសេចក្តី តាមនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចបាន ។

២-សេចក្តីថ្លែងការណ៍ដែលស្នើសុំការជំនុំជម្រះ និង សម្រេចសេចក្តី តាមនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ត្រូវធ្វើឡើងនៅពេលដាក់ពាក្យបណ្តឹង ។

**មាត្រា ២២៥.–** ការដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់ ចំណុចដែលត្រូវបញ្ជាក់ច្បាស់លាស់នៅពេលដាក់ពាក្យបណ្តឹង

១-ការដាក់ពាក្យបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច អាចធ្វើដោយផ្ទាល់មាត់បាន ។

២-ចំពោះការដាក់ពាក្យបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច ទោះបីជាមានបញ្ញត្តិនៅក្នុងចំណុច ខ កថាខណ្ឌទី ២ នៃមាត្រា ៧៥ (របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង) នៃក្រមនេះក៏ដោយ ក៏ជាការគ្រប់គ្រាន់ហើយ កាលបើមានការបង្ហាញឱ្យ បានច្បាស់លាស់អំពីចំណុចសំខាន់ៗនៃវិវាទនោះ ។

៣-នៅពេលដែលដើមចោទដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវកត់ត្រានូវសេចក្តីថ្លែងការណ៍របស់ដើមចោទនោះក្នុងកំណត់ហេតុ ។ ក្នុងករណីនេះ កំណត់ហេតុនោះ ត្រូវបានចាត់ទុកថាជាពាក្យបណ្តឹង ។

**មាត្រា ២២៦.–** ការចង្អុលបង្ហាញអំពីនីតិវិធី

១-ក្រឡាបញ្ជីត្រូវប្រគល់ទៅភាគីនូវលិខិតលាយល័ក្ខណ៍អក្សរដែលពន្យល់នូវអត្ថន័យនៃនីតិវិធីនៃការជំនុំជម្រះ និង ការសម្រេចសេចក្តីតាមរឿងក្តីចំនួនទឹកប្រាក់តិច នៅពេលកោះហៅតាមកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងរឿងក្តីចំនួនទឹកប្រាក់តិច ។

២-នៅពេលដំបូងនៃកាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវពន្យល់ភាគីនូវចំណុចដូចខាងក្រោមនេះ :

ក-លើកលែងតែក្នុងករណីដែលមានសភាពការណ៍ពិសេស តុលាការត្រូវបញ្ចប់នូវការជំនុំជម្រះនៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

ខ-ចំពោះសាលក្រមចុងក្រោយនៃរឿងក្ដីចំនួនទឹកប្រាក់តិច ភាគីពុំអាចធ្វើឧបាស្រ័យបានឡើយ លើកលែងតែបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ ។

គ-ការពិនិត្យភស្តុតាង អាចធ្វើបានចំពោះតែភស្តុតាងដែលអាចពិនិត្យបានភ្លាមៗប៉ុណ្ណោះ ។

ឃ-ចុងចម្លើយអាចធ្វើសេចក្ដីថ្លែងការណ៍ឱ្យផ្ទេរបណ្ដឹង ទៅនីតិវិធីបណ្ដឹងធម្មតាបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចុងចម្លើយបានធ្វើការឆ្លើយទាញហេតុផលនៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្រោយពេលកាលបរិច្ឆេទនោះបានបញ្ចប់ហើយ ។

**មាត្រា ២២៧.–** ការហាមឃាត់ចំពោះបណ្ដឹងតប

នៅក្នុងរឿងក្ដីចំនួនទឹកប្រាក់តិច ការប្ដឹងតបមិនអាចធ្វើបានឡើយ ។

**មាត្រា ២២៨.–** ការកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់

១-នៅពេលដែលមានការដាក់ពាក្យបណ្ដឹង តុលាការត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ឱ្យបានឆាប់រហ័ស និង ត្រូវធ្វើការកោះហៅភាគី ។

២-កាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើនៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹង លើកលែងតែក្នុងករណីដែលមានសភាពការណ៍ពិសេស ។

**មាត្រា ២២៩.–** គោលការណ៍នៃការជំនុំជម្រះតាមកាលបរិច្ឆេទតែមួយថ្ងៃ

១-ចំពោះរឿងក្ដីចំនួនទឹកប្រាក់តិច តុលាការត្រូវតែបញ្ចប់នូវការជំនុំជម្រះ នៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់លើកទី ១ លើកលែងតែក្នុងករណីដែលមានសភាពការណ៍ពិសេស ។

២-ភាគីត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនទាំងអស់ នៅមុន ឬ ក្នុងកាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបន្ត ។

**មាត្រា ២៣០.–** ការបង្គាប់ឱ្យសាមីភាគីបង្ហាញខ្លួន

ទោះបីជាអ្នកតំណាងដោយអាណត្តិត្រូវបានជ្រើសតាំងក៏ដោយ ក៏តុលាការអាចបង្គាប់ឱ្យសាមីភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ភាគីនោះ បង្ហាញខ្លួនបានដែរ ។

**មាត្រា ២៣១.–** ការកម្រិតនូវការពិនិត្យភស្តុតាង

ការពិនិត្យភស្តុតាង អាចធ្វើបានចំពោះតែភស្តុតាងដែលអាចពិនិត្យបានភ្លាមៗប៉ុណ្ណោះ ។

**មាត្រា ២៣២.–** ការស្នើសុំសាកសួរសាក្សី និង ការសាកសួរសាក្សី

១-ភាគីមិនចាំបាច់ដាក់ឯកសារដែលកំណត់អំពីចំណុចត្រូវសាកសួរឡើយ នៅពេលដែលស្នើសុំសាកសួរសាក្សី ។

២-តុលាការអាចសាកសួរសាក្សីបាន ដោយមិនចាំបាច់ឱ្យធ្វើសម្បថ ។

**មាត្រា ២៣៣.–** ការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតា ដោយសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ

១-ចុងចម្លើយអាចធ្វើសេចក្ដីថ្លែងការណ៍ឱ្យផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតាបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចុងចម្លើយនោះបានឆ្លើយទាញហេតុផលនៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

២-សេចក្ដីថ្លែងការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែករណីដែលធ្វើនៅក្នុងកាលបរិច្ឆេទ ។

៣-នៅពេលដែលមានសេចក្ដីថ្លែងការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីត្រូវជូនដំណឹងទៅដើមចោទភ្លាម អំពីការដែលផ្ទេរបណ្ដឹងនេះទៅនីតិ-វិធីធម្មតាវិញ ដោយសេចក្ដីថ្លែងការណ៍នោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសេចក្ដីថ្លែងការណ៍នោះត្រូវបានធ្វើឡើង នៅកាលបរិច្ឆេទដែលដើមចោទបានបង្ហាញខ្លួន ។

**មាត្រា ២៣៤.–** ការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតា ដោយដីកាសម្រេចរបស់តុលាការ

១-តុលាការត្រូវចេញដីកាសម្រេចដែលសម្រេចថា ការជំនុំជម្រះ និង ការសម្រេចសេចក្ដីលើបណ្ដឹងត្រូវធ្វើតាមនីតិវិធីធម្មតា ក្នុងករណីដូចខាងក្រោមនេះ :

ក-ពេលដែលដើមចោទបានស្នើសុំឱ្យជំនុំជម្រះ និង សម្រេចសេចក្តីតាមនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ដោយផ្ទុយពីបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២២៤ (ល័ក្ខខ័ណ្ឌនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ជាអាទិ៍) ។

ខ-ពេលដែលតុលាការមិនអាចកោះហៅចុងចម្លើយ តាមកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ប្រសិនបើការកោះហៅនោះពុំធ្វើដោយការបញ្ជូនតាមការផ្សាយជាសាធារណៈ ។

គ-ពេលដែលតុលាការយល់ឃើញថា ការជំនុំជម្រះ និង សម្រេចសេចក្តីតាមនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចនោះ មិនសមរម្យ ។

២-នៅពេលដែលមានដីកាសម្រេចដូចមានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីត្រូវជូនដំណឹងអំពីការណ៍នេះ ទៅភាគីភ្លាម ។

**មាត្រា ២៣៥.–** ពេលនៃការផ្ទេរបណ្តឹងទៅនីតិវិធីធម្មតា ជាអាទិ៍

១-នៅពេលដែលមានសេចក្តីថ្លែងការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៣៣ (ការផ្ទេរបណ្តឹងទៅនីតិវិធីធម្មតា ដោយសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ) ឬ ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៣៤ (ការផ្ទេរបណ្តឹងទៅនីតិវិធីធម្មតា ដោយដីកាសម្រេចរបស់តុលាការ) នៃក្រមនេះ បណ្តឹងត្រូវបានផ្ទេរទៅនីតិ-វិធីធម្មតា ។

២-នៅពេលដែលបណ្តឹងត្រូវបានផ្ទេរទៅនីតិវិធីធម្មតា កាលបរិច្ឆេទដែលបានកំណត់រួចហើយសម្រាប់បណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច ត្រូវចាត់ទុកថា បានកំណត់សម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៃនីតិវិធីធម្មតា ។

**មាត្រា ២៣៦.–** សាលក្រម និង ការប្រកាសសាលក្រម

១-តុលាការត្រូវប្រកាសសាលក្រមភ្លាម ក្រោយពេលដែលការទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់ លើកលែងតែករណីដែលយល់ឃើញថាមិនសមរម្យ ។

២-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ការប្រកាសសាលក្រមអាចធ្វើឡើងបាន ដោយមិនចាំបាច់ផ្អែកលើច្បាប់ដើមនៃមូលសាលក្រមឡើយ ។ ក្នុងករណីនេះ តុលាការត្រូវប្រកាសសាលក្រម ដោយប្រាប់សេចក្តីសម្រេចបញ្ចប់ និង ខ្លឹមសារនៃ

សំអាងហេតុ ។

៣-នៅពេលធ្វើការប្រកាសសាលក្រម ដោយអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ តុលាការត្រូវឱ្យក្រឡាបញ្ជីកត់ត្រានូវហេតុដែលបានកំណត់ក្នុងចំណុចនីមួយៗ ខាងក្រោមនេះ ក្នុងកំណត់ហេតុនៃកាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ដែលតុលាការប្រកាសសាលក្រម ជំនួសការធ្វើលិខិតសាលក្រម:

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ។

គ-សេចក្តីសម្រេចបញ្ចប់ ។

៤-នៅលើលិខិតសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច ឬ លើកំណត់ហេតុជំនួសលិខិតសាលក្រមនោះ ត្រូវសរសេរថាជាសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច ។

**មាត្រា ២៣៧.–** ការពន្យារពេលបង់ប្រាក់ដោយសាលក្រម

១-ក្នុងករណីដែលតុលាការចេញសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទ បើយល់ឃើញថា ចាំបាច់ពិសេស ដោយគិតពិចារណានូវលទ្ធភាពទ្រព្យធន និង ស្ថានភាពផ្សេងទៀតរបស់ចុងចម្លើយ នោះតុលាការអាចកំណត់ចំណុច ក ឬ ចំណុច ខ ឬ កំណត់ចំណុច គ ដោយកំណត់ជាមួយគ្នានឹងចំណុច ក ឬ ចំណុច ខ ចំពោះការសងប្រាក់ អំពីការទាមទារដែលតុលាការទទួលស្គាល់ ក្នុងអំឡុងពេលមិនលើសពី ៣ (បី) ឆ្នាំ បន្ទាប់ពីថ្ងៃដែលតុលាការប្រកាសសាលក្រម:

ក-កំណត់ពេលបង់ប្រាក់ ។

ខ-កំណត់ការបង់ប្រាក់ដោយកាត់សងបណ្តើរៗ ។

គ-នៅពេលដែលសងតាមបញ្ញត្តិនៃចំណុច ក ឬ ពេលដែលសងដោយមិនបាត់បង់តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងក្រោមនេះ នូវផលប្រយោជន៍នៃកំណត់ពេលដែលបានកំណត់នៅចំណុច ខ កំណត់ការអនុគ្រោះ ចំពោះកាតព្វកិច្ចនៃការសងការខូចខាតដោយសារការយឺតយ៉ាវ ក្រោយពេលដាក់ពាក្យបណ្តឹង ។

២-នៅពេលដែលធ្វើការកំណត់ការបង់ប្រាក់ ដោយកាត់សងបណ្តើរៗដែលបាន

កំណត់ក្នុងចំណុច ខ នៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវកំណត់អំពីការបាត់បង់ផលប្រយោជន៍នៃពេលកំណត់ក្នុងករណីដែលចុងចម្លើយមិនសង ។

**មាត្រា ២៣៨.–** ការហាមឃាត់ចំពោះឧបាស្រ័យ

ចំពោះសាលក្រមចុងក្រោយនៃរឿងក្តីចំនួនទឹកប្រាក់តិច មិនអាចធ្វើឧបាស្រ័យបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបណ្តឹងទាស់ ។

**មាត្រា ២៣៩.–** បញ្ញត្តិដែលមិនអនុវត្ត

បញ្ញត្តិពីមាត្រា ១០៣ (គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ដល់មាត្រា ១១២ (ការប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៃកំណត់ហេតុ ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិវិធីនៃ រឿងក្តីចំនួនទឹកប្រាក់តិចដែលបានកំណត់នៅក្នុងជំពូកទី ៧ នេះ ។

# ជំពូកទី ៨
# កាលបរិច្ឆេទ អំឡុងពេល និង ការបញ្ជូន

## ផ្នែកទី ១
## កាលបរិច្ឆេទ និង អំឡុងពេល

**មាត្រា ២៤០.–** ការកំណត់កាលបរិច្ឆេទ

១-តុលាការត្រូវកំណត់កាលបរិច្ឆេទ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ។ ប៉ុន្តែ ចំពោះកាលបរិច្ឆេទនៃនីតិវិធីដែលត្រូវបានធ្វើឡើងដោយចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ចៅក្រមនោះជាអ្នកកំណត់ ។

២-ក្នុងករណីដែលមិនអាចជៀសវាងបាន កាលបរិច្ឆេទនេះអាចកំណត់យកថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬបទដ្ឋានគតិយុត្តបាន ។

**មាត្រា ២៤១.–** ការប្តូរកាលបរិច្ឆេទ

១-បើភាគីបានដាក់ពាក្យសុំឱ្យប្តូរកាលបរិច្ឆេទ ភាគីនោះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុដែលការប្តូរកាលបរិច្ឆេទនោះត្រូវធ្វើជាចាំបាច់ ។

២-ការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ មិនត្រូវបានអនុញ្ញាតទេ លើកលែងតែករណីដែលមានមូលហេតុមិនអាចជៀសវាងបាន ។

៣-ការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង អាចអនុញ្ញាតឱ្យ បាន ប្រសិនបើមានការព្រមព្រៀងគ្នាពីសំណាក់គូភាគី ។

**មាត្រា ២៤២.–** ការកោះហៅតាមកាលបរិច្ឆេទ

ការកោះហៅតាមកាលបរិច្ឆេទ ត្រូវធ្វើដោយបញ្ជូនដីកាកោះ ឬ ដោយជូនដំណឹងអំពីកាលបរិច្ឆេទ ទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្តឹងដែលពាក់ព័ន្ធ ។

**មាត្រា ២៤៣.–** ការគណនាអំឡុងពេល

១-ការគណនាអំឡុងពេល ត្រូវធ្វើតាមបញ្ញត្តិស្តីពីអំឡុងពេលនៃក្រមរដ្ឋប្បវេណី ។

២-ក្នុងការសម្រេចសេចក្តីដែលកំណត់អំឡុងពេល បើពុំបានកំណត់ពេលចាប់ផ្តើមទេ អំឡុងពេលនោះ ត្រូវគិតចាប់ពីពេលដែលអានុភាពនៃការសម្រេចសេចក្តីនោះមានដំណើរការឡើង ។

៣-ប្រសិនបើថ្ងៃចុងក្រោយនៃអំឡុងពេល ត្រូវនឹងថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ អំឡុងពេលនោះត្រូវចប់ នៅថ្ងៃបន្ទាប់ពីថ្ងៃឈប់នោះ ។

**មាត្រា ២៤៤.–** ការពន្យារអំឡុងពេល

១-មានតែករណីដែលមិនអាចជៀសវាងបានប៉ុណ្ណោះទេ ទើបតុលាការអាចពន្យារអំឡុងពេលដែលច្បាប់បានកំណត់ ឬ អំឡុងពេលដែលតុលាការបានកំណត់ហើយបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ ។

២-មានតែករណីដែលមិនអាចជៀសវាងបានប៉ុណ្ណោះទេ ទើបចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិអាចពន្យារអំឡុងពេលដែលបានកំណត់ហើយនោះបាន ។

**មាត្រា ២៤៥.–** ការបំពេញនូវសកម្មភាពបណ្តឹងនៅពេលក្រោយ

១-ក្នុងករណីដែលមិនអាចគោរពតាមអំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ២៨៤ (ការពន្យារអំឡុងពេល) ខាងលើនេះ ដោយគ្មានកំហុសរបស់ភាគី ភាគីនោះអាចបំពេញនូវសកម្មភាពបណ្តឹងដែលគួរតែបានធ្វើនៅក្នុងអំឡុងពេលនោះបាន ក្នុងអំឡុងពេលតែ ១ (មួយ) សប្តាហ៍ ក្រោយពេលដែលមូលហេតុនោះរលត់ហើយ ។ ប៉ុន្តែ ចំពោះភាគីដែលនៅបរទេសវិញ អំឡុងពេលនោះ មានចំនួន ២ (ពីរ) ខែ ។

២-អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ២
## ការបញ្ជូន

**មាត្រា ២៤៦.–** គោលការណ៍នៃការបញ្ជូនដោយឆន្ទានុសិទ្ធិ ជាអាទិ៍

១-ការបញ្ជូនត្រូវធ្វើដោយឆន្ទានុសិទ្ធិ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

២-កិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី ។

៣-ការបញ្ជូនត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី ។

**មាត្រា ២៤៧.–** គោលការណ៍នៃការបញ្ជូនដោយការប្រគល់

១-ការបញ្ជូនត្រូវធ្វើឡើង ដោយការប្រគល់នូវឯកសារដែលត្រូវបញ្ជូនទៅជនដែលត្រូវទទួលការបញ្ជូននោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

២-ឯកសារដែលត្រូវបញ្ជូន គឺជាឯកសារចម្លងទាំងអស់ដែលពាក់ព័ន្ធ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

៣-ក្នុងករណីដែលអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុកការបញ្ជូនគប្បីពន្យល់នូវខ្លឹមសារនៃឯកសារនោះ នៅពេលប្រគល់ឯកសារ ។

**មាត្រា ២៤៨.–** ការបញ្ជូនទៅបុគ្គលអសមត្ថភាពក្នុងបណ្តឹង ជាអាទិ៍

១-ការបញ្ជូនទៅបុគ្គលអសមត្ថភាពក្នុងបណ្តឹង ត្រូវធ្វើទៅចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ។

២-ចំពោះករណីដែលអ្នកមានសិទ្ធិជាតំណាងរួមគ្នាច្រើននាក់ ការបញ្ជូនអាចធ្វើទៅចំពោះតែជនណាម្នាក់ ជាការគ្រប់គ្រាន់ ។

៣-ការបញ្ជូនទៅអ្នកជាប់ពន្ធនាគារ ត្រូវធ្វើទៅចំពោះប្រធានពន្ធនាគារ ។

**មាត្រា ២៤៩.-** កន្លែងបញ្ជូន

ការបញ្ជូនត្រូវធ្វើទៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន ។ ប៉ុន្តែ ចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់សាមីខ្លួនបាន ។

**មាត្រា ២៥០.-** ការជូនដំណឹងអំពីកន្លែងបញ្ជូន ជាអាទិ៍

១-ភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ អាចជូនដំណឹងអំពីកន្លែងដែលខ្លួន ត្រូវទទួលការបញ្ជូនទៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ អ្នកដែលទទួលការបញ្ជូន ទៅតុលាការទទួលបណ្ដឹង ។

២-ភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ អាចជូនដំណឹងដើម្បីប្ដូរកន្លែង ដែលបានជូនដំណឹងថាជាកន្លែងដែលខ្លួនត្រូវទទួលការបញ្ជូន ឬ អ្នកដែលបានជូនដំណឹងថាជាអ្នកទទួលការបញ្ជូននោះបាន ។

៣-ការជូនដំណឹងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

៤-ទោះជាមានបញ្ញត្តិនៃមាត្រា ២៤៩ (កន្លែងបញ្ជូន) ខាងលើនេះក៏ដោយ ប្រសិនបើមានការជូនដំណឹងអំពីកន្លែងដែលត្រូវទទួលការបញ្ជូនតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក៏ការបញ្ជូនត្រូវធ្វើទៅកន្លែងដែលបានកំណត់ ក្នុងដំណឹងនោះដែរ ។

**មាត្រា ២៥១.-** ការបញ្ជូននៅកន្លែងជួបប្រទះ

ទោះបីមានបញ្ញត្តិដូចមាត្រា ២៤៩ (កន្លែងបញ្ជូន) ខាងលើនេះក៏ដោយ ប្រសិនបើជនដែលត្រូវទទួលការបញ្ជូននោះ ពុំច្បាស់លាស់ថា មានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការ នៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅកន្លែងដែលបានជួបប្រទះអ្នកនោះ លើកលែងតែករណីបញ្ជូនចំពោះអ្នកដែលបានជូនដំណឹងតាម

បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ២៥០ (ការជូនដំណឹងអំពីកន្លែងបញ្ជូន ជាអាទិ៍) ខាងលើ នេះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាដែរ ចំពោះករណីដែលអ្នកដែលមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការ ច្បាស់លាស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ អ្នកដែល បានជូនដំណឹងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២៥០ ដដែលនេះ មិនប្រកែកទទួល ការបញ្ជូន ។

**មាត្រា ២៥២.–** ការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល

១-ប្រសិនបើមិនបានជួបជនដែលត្រូវទទួលការបញ្ជូន នៅទីកន្លែងដែលត្រូវបញ្ជូន ទេ មន្ត្រីទទួលបន្ទុកការបញ្ជូន អាចប្រគល់ឯកសារទៅឱ្យអ្នកបម្រើ ឬ អ្នកផ្សេងដែលធ្វើការ នៅទីនោះ ឬអ្នកនៅជាមួយ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន ។

២-ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវទទួលការប្រគល់ឯកសារ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុ ត្រឹមត្រូវ ឯកសារនោះអាចទុកនៅកន្លែងដែលត្រូវបញ្ជូននោះបាន ។

**មាត្រា ២៥៣.–** ការបញ្ជូនដែលត្រូវធ្វើនៅបរទេស

១-ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស តុលាការត្រូវប្រគល់កិច្ចការនេះឱ្យក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះ ឬ ឯកអគ្គរាជទូត ឬ ភារធារី ឬ កុងស៊ុលរបស់ ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ ឱ្យធ្វើបាន ។

២-បើការបញ្ជូននៅបរទេសត្រូវបានធ្វើឡើង ក្នុងនីតិវិធីដែលចៅក្រមដែលទទួល បណ្ដឹង ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ត្រូវធ្វើ ចៅក្រមនោះអាចប្រគល់កិច្ចការបញ្ជូន នេះ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ២៥៤.–** របាយការណ៍អំពីការបញ្ជូន ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកការបញ្ជូនដែលបានធ្វើការបញ្ជូនរួចហើយ ត្រូវធ្វើរបាយការណ៍ អំពីការបញ្ជូននោះ ជូនទៅតុលាការ ។

២-របាយការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជាក់អំពី ចំណុចដូចតទៅ :

ក-សញ្ញាណនៃរឿងក្តី និង ឯកសារដែលបានបញ្ជូន ។

ខ-ជនដែលត្រូវទទួលការបញ្ជូន ។

គ-ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងដែលបានធ្វើការបញ្ជូន ។

ឃ-វិធីបញ្ជូន ។

ង-ចំណាត់ការតាមកថាខណ្ឌទី ៣ នៃមាត្រា ២៤៧ (គោលការណ៍នៃការបញ្ជូនដោយការប្រគល់) នៃក្រមនេះ នៅក្នុងករណីជនដែលត្រូវទទួលការបញ្ជូននោះមិនចេះអក្សរ ។

ច-ហត្ថលេខា ឬ ស្នាមមេដៃរបស់អ្នកដែលបានទទួលឯកសារ ។

ឆ-ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូន នៅក្នុងករណីជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវទទួលការប្រគល់ឯកសារតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២៥២ (ការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល) នៃក្រមនេះ ប្រកែកមិនព្រមទទួល ។

ជ-ហេតុការណ៍ នៅក្នុងករណីដែលការបញ្ជូនបានធ្វើតាមបញ្ញត្តិនៃមាត្រា ២៥២ (ការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល) នៃក្រមនេះ ។

ឈ-ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន ។

៣-ក្នុងករណីដែលបានព្យាយាមបញ្ជូន តែមិនអាចសម្រេចបាន មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីហេតុការណ៍នោះ និង ចំណុចដែលបានកំណត់នៅកថាខណ្ឌទី ២ ខាងលើ ចាប់ពីចំណុច ក រហូតដល់ចំណុច ឃ និង ចំណុច ឈ ជូនទៅតុលាការ ។

**មាត្រា ២៥៥.–** ល័ក្ខខ័ណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ

១-ក្នុងករណីដូចខាងក្រោមនេះ ក្រឡាបញ្ជីអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន តាមពាក្យសុំ ដោយទទួលការអនុញ្ញាតពីតុលាការ :

ក-ទោះបីបានខំប្រឹងប្រែងធ្វើការស្រាវជ្រាវរកលំនៅឋាន ឬ ទីសំណាក់របស់ភាគី ឬ កន្លែងផ្សេងទៀតដែលត្រូវធ្វើការបញ្ជូនក៏ដោយ ក៏នៅតែរកមិនឃើញ ។

ខ-មិនអាចបញ្ជូន តាមបញ្ញត្តិនៃមាត្រា ២៥២ (ការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល) នៃក្រមនេះ ។

គ-មិនអាចធ្វើការបញ្ជូន តាមបញ្ញត្តិនៃមាត្រា ២៥៣ (ការបញ្ជូនដែលត្រូវធ្វើនៅបរទេស) នៃក្រមនេះបាន ឬ ត្រូវបានទទួលស្គាល់ថា គ្មានលទ្ធភាពនឹងធ្វើបានតាមបញ្ញត្តិនោះ ក្នុងករណីដែលត្រូវធ្វើការបញ្ជូននៅបរទេស ។

ឃ-បានធ្វើការបញ្ជូនដោយប្រគល់ឱ្យក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសឱ្យធ្វើតាមបញ្ញត្តិនៃមាត្រា ២៥៣ (ការបញ្ជូនដែលត្រូវធ្វើនៅបរទេស) នៃក្រមនេះ តែមិនបានទទួលលិខិតបញ្ជាក់អំពីការបញ្ជូននោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចាប់តាំងពីពេលបញ្ជូននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើយល់ឃើញថាចាំបាច់ដើម្បីជៀសវាងការយឺតយ៉ាវក្នុងដំណើរការនីតិវិធី តុលាការអាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន ទោះបីជាគ្មានពាក្យសុំក៏ដោយ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីគប្បីជូនដំណឹងដោយរបៀបសមរម្យមួយ អំពីហេតុការណ៍ដែលបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ទៅភាគីដែលត្រូវទទួលការបញ្ជូននោះ ។

៤-ការបញ្ជូនជាលើកទី ២ តាមការផ្សាយជាសាធារណៈចំពោះភាគីដដែល ត្រូវធ្វើដោយឆន្ទានុសិទ្ធិ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់ក្នុងចំណុច គ នៃកថាខណ្ឌទី ១ ។

**មាត្រា ២៥៦.-** របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ

១-ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការថា ក្រឡាបញ្ជីរក្សាទុកនូវឯកសារដែលត្រូវបញ្ជូន និង អាចប្រគល់ឯកសារនោះទៅជនដែលត្រូវទទួលការបញ្ជូន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបញ្ជូនដីកាកោះតាមការផ្សាយជាសាធារណៈវិញ ត្រូវបិទដីកាកោះនោះ នៅកន្លែងសម្រាប់បិទប្រកាស ។

២-នៅក្នុងករណីដែលធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ តាមបញ្ញត្តិនៃចំណុច ខ កថាខណ្ឌទី ១ នៃមាត្រា ២៥៥ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ) នៃក្រមនេះ ការបិទប្រកាសដែលកំណត់នៅកថាខណ្ឌទី ១ នេះ អាចធ្វើបាននៅកន្លែង

ដែលតុលាការទទួលស្គាល់ថាសមរម្យ ក្រៅពីកន្លែងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-តុលាការអាចចុះនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ផ្សាយថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ ។ ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស ក្រឡាបញ្ជីតុលាការអាចជូនដំណឹងថា បានធ្វើការបញ្ជូន តាមការផ្សាយជាសាធារណៈហើយ ជំនួសការប្រកាសផ្សាយនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ។

**មាត្រា ២៥៧.–** ពេលដែលការបញ្ជូនតាមការផ្សាយជាសាធារណៈមានអានុភាព

១-ការបញ្ជូនតាមការផ្សាយជាសាធារណៈ នឹងមានអានុភាពនៅក្រោយអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃ ដែលបានបិទប្រកាសតាមបញ្ញត្តិនៃមាត្រា ២៥៦ (របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ) ខាងលើនេះ ។ ប៉ុន្តែ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ នៃមាត្រា ២៥៥ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ) នៃក្រមនេះ នឹងមានអានុភាពនៅថ្ងៃបន្ទាប់ពីថ្ងៃបិទប្រកាស ។

២-ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដែលបានធ្វើឡើង សម្រាប់ការបញ្ជូនដែលត្រូវធ្វើនៅបរទេសវិញ អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺ ៦ (ប្រាំមួយ) សប្តាហ៍ ។

## ជំពូកទី ៩
## ការមើលសំណុំរឿង

**មាត្រា ២៥៨.–** ការទាមទារមើលសំណុំរឿងនៃបណ្តឹង ជាអាទិ៍

១-ភាគីនៃបណ្តឹង និង តតិយជនដែលធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបណ្តឹង អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងបណ្តឹងពីតុលាការបាន ដោយបង់ពន្ធ ។ ចំពោះឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់

ឬ ឯកសារដកស្រង់នៃសំណុំរឿង ក្រឡាបញ្ជីត្រូវបញ្ជាក់ថាជាឯកសារចម្លងយថាភូត ឯក-សារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់ ហើយនិង ចុះហត្ថលេខា ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្ត ចំពោះខ្សែអាត់ ខ្សែវីដេអូ ឬ វត្ថុដែលកត់ត្រាអំពីចំណុចដែលមានកំណត់ដោយវិធីប្រហែលគ្នា ក្នុងសំណុំរឿងឡើយ ។ ក្នុងករណីនេះ ប្រសិនបើមានការទាមទារពីសំណាក់ភាគីនៃបណ្តឹង ឬ តតិយជនដែលធ្វើសេចក្តីបញ្ជាក់ដំបូងថាមានការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបណ្តឹង តុលាការត្រូវអនុញ្ញាតឱ្យថតចម្លងវត្ថុទាំងនោះ ។

៣-ការទាមទារមើល ចម្លង ថតចម្លងនូវសំណុំរឿង មិនអាចធ្វើបានឡើយ បើការនោះធ្វើឱ្យមានឧបសគ្គដល់ការរក្សាទុកសំណុំរឿង ឬដល់ការចាត់ចែងការងាររបស់តុលាការ ។

# គន្ថីទី ៣
# បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៥៩.–** ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

១-ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះការសម្រេចសេចក្តីដែលមិនទាន់ចូលជាស្ថាពរ មានដូចខាងក្រោមនេះ :

ក-បណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមរបស់សាលាដំបូង ឬ បណ្តឹងសាទុក្ខ ក្នុងករណីមានការព្រមព្រៀងរវាងភាគីដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី ១ នៃមាត្រា ២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍) នៃក្រមនេះ ។

ខ-បណ្តឹងសាទុក្ខ ចំពោះសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ។

គ-បណ្តឹងជំទាស់ ចំពោះដីកាសម្រេច ។

២-បណ្តឹងជំទាស់ អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់ ។

៣-ចំពោះដីកាសម្រេចលើបណ្តឹងជំទាស់ មិនអាចប្តឹងជំទាស់ទៀតបានឡើយ ។

## ជំពូកទី ២
## បណ្តឹងឧទ្ធរណ៍

**មាត្រា ២៦០.–** សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍

១-បណ្តឹងឧទ្ធរណ៍អាចធ្វើចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងបាន លើកលែងតែករណីដែលបានកំណត់ខាងក្រោមនេះ :

ក-គូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខក្រោយពេលតុលាការបានចេញសាលក្រមចុងក្រោយ ។

ខ-សាលក្រមចុងក្រោយនោះវិនិច្ឆ័យទៅលើរឿងក្តីរដ្ឋប្បវេណី ឬ ពាណិជ្ជកម្ម ដែលមានតម្លៃកម្មវត្ថុនៃបណ្តឹង មិនលើសពី៥.០០០.០០០ (ប្រាំលាន) រៀល ។

២-សេចក្តីព្រមព្រៀងដែលបានកំណត់នៅក្នុងចំណុច ក នៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើលិខិតជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ២៦១.–** ការកម្រិតបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី

ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី មិនអាចប្តឹងឧទ្ធរណ៍ដោយឯករាជ្យតែឯកឯងបានឡើយ ។

**មាត្រា ២៦២.–** សេចក្តីសម្រេចដែលត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍

សេចក្តីសម្រេចនៅមុនសាលក្រមចុងក្រោយ ត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្តីសម្រេចដែលមិនអាចធ្វើឧបាស្រ័យបាន និង សេចក្តីសម្រេចដែលអាចធ្វើឧបាស្រ័យបានដោយការប្តឹងជំទាស់ ។

**មាត្រា ២៦៣.–** ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍

១-ភាគីអាចលះបង់ចោលនូវសិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួនបាន ។

២-នៅក្រោយពេលបានប្តឹងឧទ្ធរណ៍រួចហើយ សេចក្តីថ្លែងការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាមួយគ្នានឹងការដកពាក្យបណ្តឹងឧទ្ធរណ៍ ។

**មាត្រា ២៦៤.–** អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍

១-បណ្តឹងឧទ្ធរណ៍ត្រូវធ្វើនៅក្នុងអំឡុងពេល ១ (មួយ) ខែ ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ។ ប៉ុន្តែ ករណីនេះមិនមែនជាការរារាំងលើអានុភាពនៃបណ្តឹងឧទ្ធរណ៍ដែលបានដាក់នៅមុនអំឡុងពេលនេះឡើយ ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

**មាត្រា ២៦៥.–** របៀបប្តឹងឧទ្ធរណ៍

១-ដើម្បីប្តឹងឧទ្ធរណ៍ ភាគីត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើម ត្រូវផ្ញើឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងឧទ្ធរណ៍ និង សំណុំរឿងទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ។

២-ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយ-ដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី ១ និង សេចក្តីដែលប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ ។

៣-ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ក្នុងពាក្យបណ្តឹងឧទ្ធរណ៍ទេ ដើមបណ្តឹងឧទ្ធរណ៍គប្បីដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរអំពីចំណុចនោះ ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ នៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍នោះ ។

**មាត្រា ២៦៦.–** សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍

១-ក្នុងករណីដែលពាក្យបណ្តឹងឧទ្ធរណ៍ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៦៥ (របៀបប្តឹងឧទ្ធរណ៍) នៃក្រមនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវកំណត់អំឡុងពេលសមរម្យមួយ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៅក្នុងអំឡុងពេលនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពន្ធសម្រាប់ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ មិនត្រូវបានបង់តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ មាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) នៃក្រមនេះ ។

២-ករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើដើមបណ្តឹងឧទ្ធរណ៍មិនបានកែតម្រូវចំណុចខ្វះខាតនោះទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះ ដោយដីកាសម្រេច ។

៣-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើ អាចប្តឹងជំទាស់បាន ។

**មាត្រា ២៦៧.–** ការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍

១-ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនទៅចុងបណ្តឹងឧទ្ធរណ៍ ។

២-បញ្ញត្តិនៃមាត្រា ២៦៦ (សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍បាន រួមទាំងករណីដែលមិនបានបង់ជាមុន នូវសោហ៊ុយចាំបាច់សម្រាប់បញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ ។

**មាត្រា ២៦៨.–** ការលើកចោលបណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់

ក្នុងករណីដែលបណ្តឹងឧទ្ធរណ៍មានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចលើកចោលបណ្តឹងឧទ្ធរណ៍នោះដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ដោយសាលដីកាបាន ។

**មាត្រា ២៦៩.–** ការដកពាក្យបណ្តឹងឧទ្ធរណ៍

១-បណ្តឹងឧទ្ធរណ៍អាចដកវិញបាន រហូតដល់ពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវបានប្រកាស ។

២-ការដកពាក្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ការដកពាក្យបណ្តឹងឧទ្ធរណ៍នោះ អាចធ្វើឡើងដោយផ្ទាល់មាត់បាន ។

៣-ផ្នែកនៃបណ្តឹងឧទ្ធរណ៍ដែលត្រូវបានដកចេញ ត្រូវចាត់ទុកថាមិនបានចាត់ការតាំងពីដំបូងនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៤-បញ្ញត្តិនៃមាត្រា ២១៩ (ការចាត់ទុកថា ដកពាក្យបណ្តឹង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចាត់ទុកថា ដកពាក្យបណ្តឹងឧទ្ធរណ៍ ។

**មាត្រា ២៧០.–** បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

១-ចុងបណ្តឹងឧទ្ធរណ៍ ទោះជាសិទ្ធិប្តឹងឧទ្ធរណ៍នោះត្រូវបានរលត់ហើយក៏ដោយ ក៏

អាចប្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ រហូតដល់ពេលដែលការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវបានបញ្ចប់ ។

២-បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវអស់អានុភាព នៅក្នុងករណីដែលពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវបានដក ឬ នៅក្នុងករណីដែលបណ្តឹងឧទ្ធរណ៍នោះ ត្រូវបានលើកចោលដោយសារមានភាពផ្ទុយនឹងច្បាប់ ។ ប៉ុន្តែ ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែលមានល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍គ្រប់គ្រាន់ ត្រូវចាត់ទុកថាជាបណ្តឹងឧទ្ធរណ៍ឯករាជ្យ ។

៣-បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ។

**មាត្រា ២៧១.–** ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយតុលាការនៃបណ្តឹងឧទ្ធរណ៍

១-តុលាការនៃបណ្តឹងឧទ្ធរណ៍អាចប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រឹមតែផ្នែកដែលពុំមានពាក្យសុំប្តឹងឧបាស្រ័យ ចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ បាន តាមពាក្យសុំ ដោយដីកាសម្រេច ។

២-ចំពោះការសម្រេចសេចក្តីរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍អំពីការអនុវត្តជាបណ្តោះអាសន្ន មិនអាចធ្វើឧបាស្រ័យបានឡើយ ។

**មាត្រា ២៧២.–** ទំហំនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍

១-ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើ ត្រឹមតែក្នុងទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ តែប៉ុណ្ណោះ ។

២-ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងការជំនុំជម្រះលើកទី ១ ។

**មាត្រា ២៧៣.–** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១

លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស បញ្ញត្តិនៃគន្ថីទី ២ (នីតិវិធីនៃការជម្រះក្តីលើកទី ១) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះមាត្រា ៨០ (ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង) មាត្រា ១០៤

(ការសាកល្បងផ្ទុះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ផ្នែកទី ៥ (សាលក្រមកំបាំងមុខ) ជំពូកទី ៥ នៃគន្ថីទី ២ និង ជំពូកទី ៧ (បទប្បញ្ញត្តិពិសេសស្ដីពីរឿងក្ដីចំនួនទឹកប្រាក់តិច) នៃគន្ថីទី ២ នៃក្រមនេះ ។

**មាត្រា ២៧៤.–** អានុភាពនៃសកម្មភាពបណ្ដឹងនៅក្នុងការជំនុំជម្រះលើកទី ១ ជាអាទិ៍

១-សកម្មភាពបណ្ដឹងដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ។

២-នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ។

**មាត្រា ២៧៥.–** ការកម្រិតនូវការអះអាងស្ដីពីអសមត្ថកិច្ចក្នុងការជំនុំជម្រះលើកទី ១

នៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ភាគីមិនអាចអះអាងអំពីអសមត្ថកិច្ចរបស់សាលាដំបូងបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសមត្ថកិច្ចផ្ដាច់មុខ ។

**មាត្រា ២៧៦.–** ការដាក់ពាក្យបណ្ដឹងតប

១-ការដាក់ពាក្យបណ្ដឹងតបនៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ អាចធ្វើបាន លុះត្រាតែមានការយល់ព្រមពីភាគីម្ខាងទៀត ។

២-បើភាគីម្ខាងទៀតមិនបានតវ៉ា តែបានធ្វើការទាញហេតុផលលើអង្គសេចក្ដីអំពីការប្ដឹងតប នោះត្រូវចាត់ទុកថា ភាគីនោះបានយល់ព្រមនឹងការដាក់ពាក្យបណ្ដឹងតប ។

**មាត្រា ២៧៧.–** ការច្រានចោលបណ្ដឹងឧទ្ធរណ៍

១-តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវច្រានចោលនូវបណ្ដឹងឧទ្ធរណ៍ ក្នុងករណីដែលយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រឹមត្រូវ ។

២-ទោះជាក្នុងករណីដែលសំអាងហេតុនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវក៏ដោយ ក៏តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវច្រានចោលនូវបណ្ដឹងឧទ្ធរណ៍នោះដែរ បើយល់ឃើញថា សេចក្ដីសម្រេចបញ្ចប់នៃសាលក្រមនោះ ត្រឹមត្រូវ ដោយផ្អែកលើសំអាងហេតុផ្សេងទៀត ។

**មាត្រា ២៧៨.‒** ទំហំនៃការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១

ការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១ អាចធ្វើបាន ត្រឹមតែកម្រិតនៃឧបាស្រ័យ ដោយបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំតែប៉ុណ្ណោះ ។

**មាត្រា ២៧៩.‒** ការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១

១-តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ក្នុងករណីដូចមានខាងក្រោមនេះ :

ក-បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ ។

ខ-បើនីតិវិធីនៅតុលាការជាន់ទី ១ នោះផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ ។

២-ក្នុងករណីដូចកថាខណ្ឌទី ១ ខាងលើនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះទៅលើបណ្តឹងនោះ លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ២៨០ (ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ) ឬ មាត្រា ២៨១ (ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្តាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១) នៃក្រមនេះ ។

**មាត្រា ២៨០.‒** ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ

១-ក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលលើកចោលបណ្តឹង ដោយយល់ឃើញថា បណ្តឹងនោះមិនត្រឹមត្រូវតាមច្បាប់ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនរឿងក្តីនោះ ត្រឡប់ទៅសាលាដំបូងវិញ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគ្មានការចាំបាច់ត្រូវទាញហេតុផលបន្ថែមទៀតអំពីរឿងក្តីនោះ ។

២-ក្រៅពីករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ បើមានភាពចាំបាច់ទាញហេតុផលបន្ថែមទៀត អំពីរឿងក្តីនោះ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចបញ្ជូនរឿងក្តីនោះត្រឡប់ទៅសាលាដំបូងវិញបាន ។

៣-ប្រសិនបើរឿងក្តីនោះត្រូវបានបញ្ជូនត្រឡប់ទៅវិញ ដោយសារមូលហេតុថា នីតិវិធីបណ្តឹងនៅសាលាដំបូងផ្ទុយនឹងច្បាប់ នីតិវិធីនៃបណ្តឹងនោះត្រូវចាត់ទុកថា បានលុបចោល ដោយសារការបញ្ជូនត្រឡប់ទៅវិញ ។

**មាត្រា ២៨១.–** ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១

ប្រសិនបើតុលាការនៃបណ្ដឹងឧទ្ធរណ៍លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ដោយមូលហេតុថា រឿងក្ដីនោះ ខុសសមត្ថកិច្ចផ្ដាច់មុខ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវចេញសាលដីកាផ្ទេររឿងក្ដីនោះទៅតុលាការដែលមានសមត្ថកិច្ចវិញ ។

**មាត្រា ២៨២.–** ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នក្នុងសាលដីកានៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍

ចំពោះសាលដីកាអំពីការទាមទារសំណងជាប្រាក់ បើមានពាក្យសុំ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវប្រកាសថា សាលដីកាអាចអនុវត្តជាបណ្ដោះអាសន្នបានដោយពុំចាំបាច់ឱ្យដាក់ប្រាតិភោគ លើកលែងតែករណីដែលយល់ឃើញថា ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះមិនមានលក្ខណៈចាំបាច់ ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចកំណត់ល័ក្ខខ័ណ្ឌឱ្យដាក់ប្រាតិភោគសម្រាប់ការអនុវត្តជាបណ្ដោះអាសន្ននោះបាន ។

## ជំពូកទី ៣
## បណ្ដឹងសាទុក្ខ

**មាត្រា ២៨៣.–** តុលាការនៃបណ្ដឹងសាទុក្ខ

១-បណ្ដឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលបាន ចំពោះសាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី ២ ដោយសាលាឧទ្ធរណ៍ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះសាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី ១ តាមបញ្ញត្តិនៃច្បាប់ពិសេស ។

២-ចំពោះសាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី ១ ដោយសាលាដំបូង នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍នៅក្រោយពេលដែលតុលាការបានចេញសាលក្រមនោះ ដោយរក្សាទុកនូវសិទ្ធិប្ដឹងសាទុក្ខ បណ្ដឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលដោយផ្ទាល់បាន ។

**មាត្រា ២៨៤.–** មូលហេតុទូទៅនៃបណ្ដឹងសាទុក្ខ

បណ្ដឹងសាទុក្ខអាចធ្វើបាន ដោយយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬ សាលក្រម ។

**មាត្រា ២៨៥.–** មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ

១-ក្នុងករណីណាមួយដូចបានកំណត់ខាងក្រោមនេះ ត្រូវចាត់ទុកថា មានមូលហេតុនៃបណ្ដឹងសាទុក្ខជាដរាប:

ក-តុលាការដែលចេញសាលដីកា ឬ សាលក្រម មិនត្រូវបានចាត់តាំង ដោយស្របទៅតាមច្បាប់ ។

ខ-ចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលដីកា ឬ សាលក្រម តែបានចូលរួម ។

គ-ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការ ។

ឃ-ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្ដឹង ។

ង-ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសា-ធារណៈ ។

ច-សាលដីកា ឬ សាលក្រម គ្មានសំអាងហេតុ ឬ មានសំអាងហេតុ តែផ្ទុយនឹងគ្នា ។

២-បញ្ញត្តិនៃចំណុច ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការទទួលស្គាល់ពេលក្រោយ តាមបញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៣៥ (វិធានការក្នុងករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ជាអាទិ៍) ឬ កថាខណ្ឌទី ៣ នៃមាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនេះ ។

**មាត្រា ២៨៦.–** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍

បញ្ញត្តិនៃជំពូកទី ២ នៃគន្ថីទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងសាទុក្ខ និង នីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ លើកលែងតែមានបញ្ញត្តិពិសេស ។

**មាត្រា ២៨៧.–** របៀបប្ដឹងសាទុក្ខ

ដើម្បីប្ដឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្ដឹងសាទុក្ខទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើមត្រូវធ្វើឱ្យបានឆាប់រហ័ស នូវពាក្យបណ្ដឹងសាទុក្ខ និង សំណុំរឿងទៅតុលាការនៃបណ្ដឹងសាទុក្ខ ។

**មាត្រា ២៨៨.–** ការបញ្ជូនលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ ជាអាទិ៍

១-នៅក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងសាទុក្ខ តុលាការនៃបណ្ដឹងសាទុក្ខត្រូវបញ្ជូនលិខិតទទួលពាក្យបណ្ដឹងសាទុក្ខទៅភាគី លើកលែងតែក្នុងករណីដែលលើកចោលពាក្យបណ្ដឹងសាទុក្ខនោះ ។

២-នៅពេលដែលតុលាការបញ្ជូនលិខិតទទួលពាក្យបណ្ដឹងសាទុក្ខទៅចុងបណ្ដឹងសាទុក្ខ ដោយយោលតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការនៃបណ្ដឹងសាទុក្ខត្រូវបញ្ជូនទាំងពាក្យបណ្ដឹងសាទុក្ខទៅជាមួយផង ។

**មាត្រា ២៨៩.–** ការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ

១-ប្រសិនបើមិនបានសរសេរនូវមូលហេតុនៃបណ្ដឹងសាទុក្ខក្នុងពាក្យបណ្ដឹងសាទុក្ខទេ ដើមបណ្ដឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខនេះ ជូនទៅតុលាការនៃបណ្ដឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូននូវលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ ។

២-ក្នុងករណីដែលបណ្ដឹងសាទុក្ខធ្វើឡើង ដោយយកមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨៤ (មូលហេតុទូទៅនៃបណ្ដឹងសាទុក្ខ) ខាងលើនេះ ដើមបណ្ដឹងសាទុក្ខត្រូវសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខនេះ ដោយបញ្ជាក់អំពីបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត និង ហេតុដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តនោះ ។ នៅក្នុងករណីនេះ ប្រសិនបើហេតុនោះមានទំនាក់ទំនងនឹងនីតិវិធីនៃបណ្ដឹង ត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវអង្គហេតុដែលផ្ទុយនោះ ។

៣-ក្នុងករណីដែលបណ្ដឹងសាទុក្ខធ្វើឡើង ដោយយកមូលហេតុដូចចំណុចណាមួយដែលបានកំណត់នៅកថាខណ្ឌទី ១ នៃមាត្រា ២៨៥ (មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ) នៃក្រមនេះ ដើមបណ្ដឹងសាទុក្ខត្រូវសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ ដោយបញ្ជាក់នូវ

ចំណុចក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨៥ និង អង្គហេតុដែលត្រូវនឹងចំណុចនោះ ។

**មាត្រា ២៩០.–** ការលើកចោលបណ្ដឹងសាទុក្ខ

ប្រសិនបើត្រូវនឹងចំណុចណាមួយខាងក្រោមនេះយ៉ាងជាក់ច្បាស់ តុលាការនៃបណ្ដឹងសាទុក្ខ ត្រូវលើកចោលបណ្ដឹងសាទុក្ខ ដោយដីកាសម្រេច :

ក-បើបណ្ដឹងសាទុក្ខនោះមិនស្របច្បាប់ ហើយមិនអាចកែតម្រូវចំណុចខ្វះខាតនោះបាន ។

ខ-បើមិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២៨៩ (ការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ) ខាងលើនេះ ឬ បើការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ២៨៩ ។

**មាត្រា ២៩១.–** ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ

១-ប្រសិនបើការសរសេរមូលហេតុទាំងមូលនៃបណ្ដឹងសាទុក្ខ ដែលត្រូវបានបញ្ជាក់ក្នុងពាក្យបណ្ដឹងសាទុក្ខ ឬ ក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ដែលត្រូវបានដាក់ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨៩ (ការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ) នៃក្រមនេះ ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ២៨៩ នោះយ៉ាងជាក់ច្បាស់ តុលាការនៃបណ្ដឹងសាទុក្ខ ត្រូវកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ឱ្យដើមបណ្ដឹងសាទុក្ខកែតម្រូវនូវចំណុចខ្វះខាត ក្នុងអំឡុងពេលនោះ ដោយដីកាសម្រេច ។

២-ដីកាសម្រេចលើកចោលនូវបណ្ដឹងសាទុក្ខដែលបានកំណត់ក្នុងចំណុច ខ នៃមាត្រា ២៩០ (ការលើកចោលបណ្ដឹងសាទុក្ខ) ខាងលើនេះ ត្រូវធ្វើឡើង ក្នុងករណីដែលដើមបណ្ដឹងសាទុក្ខមិនបានធ្វើការកែតម្រូវនូវចំណុចខ្វះខាត នៅក្នុងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ២៩២.–** ការបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ

ប្រសិនបើតុលាការនៃបណ្ដឹងសាទុក្ខមិនចេញដីកាសម្រេចលើកចោលបណ្ដឹងសាទុក្ខតាមបញ្ញត្តិនៃមាត្រា ២៩០ (ការលើកចោលបណ្ដឹងសាទុក្ខ) នៃក្រមនេះទេ តុលាការនៃ

បណ្តឹងសាទុក្ខត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនោះ ទៅចុងបណ្តឹងសាទុក្ខ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតុលាការនៃបណ្តឹងសាទុក្ខជំនុំជម្រះ និង សម្រេចសេចក្តី ដោយពុំឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ហើយយល់ឃើញថា ពុំចាំបាច់បញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនោះ ។

**មាត្រា ២៩៣.–** ការបង្គាប់ឱ្យដាក់ឯកសារត្រៀម

តុលាការនៃបណ្តឹងសាទុក្ខអាចកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ឱ្យចុងបណ្តឹងសាទុក្ខដាក់ឯកសារត្រៀមលើកដំបូងបាន ។

**មាត្រា ២៩៤.–** ការច្រានចោលបណ្តឹងសាទុក្ខដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់

តុលាការនៃបណ្តឹងសាទុក្ខអាចច្រានចោលបណ្តឹងសាទុក្ខដោយសាលដីកាបាន ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ បើយល់ឃើញថា បណ្តឹងសា-ទុក្ខនោះគ្មានមូលហេតុ ក្រោយពីបានពិនិត្យពាក្យបណ្តឹងសាទុក្ខ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដែលចុងបណ្តឹងសាទុក្ខបានដាក់លើកដំបូង ឬ ឯកសារផ្សេងទៀត ។

**មាត្រា ២៩៥.–** ទំហំនៃការស្រាវជ្រាវ

តុលាការនៃបណ្តឹងសាទុក្ខ ត្រូវធ្វើការស្រាវជ្រាវត្រឹមតែកម្រិតនៃឧបាស្រ័យ ដោយផ្អែកលើមូលហេតុនៃបណ្តឹងសាទុក្ខ ។

**មាត្រា ២៩៦.–** ចំណងនៃអង្គហេតុស្ថាពររបស់សាលដីកាដើម ឬ សាលក្រមដើម

១-អង្គហេតុដែលបានចូលជាស្ថាពរដោយត្រឹមត្រូវតាមច្បាប់ក្នុងសាលដីកាដើម ឬ សាលក្រមដើម ត្រូវមានចំណងចំពោះតុលាការនៃបណ្តឹងសាទុក្ខ ។

២-ក្នុងករណីដែលមានបណ្តឹងសាទុក្ខដែលយោលទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៨៣ (តុលាការនៃបណ្តឹងសាទុក្ខ) នៃក្រមនេះ តុលាការនៃបណ្តឹងសាទុក្ខមិនអាចបដិសេធចោលសាលក្រមដើមឡើយ ដោយយកមូលហេតុថា ការចូលជាស្ថាពរនៃអង្គហេតុ

ក្នុងសាលក្រមដើមនោះ ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ។

**មាត្រា ២៩៧.–** ករណីលើកលែងនៃការអនុវត្តចំពោះចំណុចដែលស្រាវជ្រាវដោយឆន្ទានុសិទ្ធិ

បញ្ញត្តិនៃមាត្រា ២៩៥ (ទំហំនៃការស្រាវជ្រាវ) និង មាត្រា ២៩៦ (ចំណងនៃអង្គហេតុស្ថាពររបស់សាលដីកាដើម ឬ សាលក្រមដើម) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះចំណុចដែលតុលាការត្រូវស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

**មាត្រា ២៩៨.–** ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

តុលាការនៃបណ្តឹងសាទុក្ខអាចប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន តាមពាក្យសុំ ដោយដីកាសម្រេចបាន ត្រឹមតែចំពោះផ្នែកដែលពុំមានឧបាស្រ័យនៅក្នុងសាលដីកាដើម ឬ សាលក្រមដើមតែប៉ុណ្ណោះ ។

**មាត្រា ២៩៩.–** ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍

១-នៅក្នុងករណីដែលមានមូលហេតុដែលបានកំណត់ក្នុងមាត្រា ២៨៤ (មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ) ឬ មាត្រា ២៨៥ (មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ) នៃក្រមនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ហើយត្រូវបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញ ឬ ផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៣០០ (ការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង) នៃក្រមនេះ ។

២-តុលាការដែលបានទទួលរឿងក្តីដោយការបញ្ជូនត្រឡប់មកវិញ ឬ ការផ្ទេរ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើការសម្រេចសេចក្តីដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីម្តងទៀត ។ ក្នុងករណីនេះ សេចក្តីវិនិច្ឆ័យលើអង្គហេតុ និងអង្គច្បាប់ ដែលតុលាការនៃបណ្តឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធចោល មានចំណងទៅលើតុលាការដែលបានទទួលការបញ្ជូន ឬ ការផ្ទេរ ។

៣-ចៅក្រមដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬ សាលក្រមដើម មិនអាចចូលរួមក្នុងការសម្រេចសេចក្តីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះទេ ។

**មាត្រា ៣០០.-** ការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្ដឹងសាទុក្ខត្រូវធ្វើការសម្រេចសេចក្ដីអំពីរឿងក្ដីផ្ទាល់ដោយខ្លួនឯង ចំពោះករណីដូចខាងក្រោមនេះ :

ក-តុលាការនៃបណ្ដឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា តុលាការនៃការជំនុំជម្រះដើមមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ចំពោះអង្គហេតុ ដែលបានចូលជាស្ថាពរ ហើយតុលាការនៃបណ្ដឹងសាទុក្ខអាចសម្រេចសេចក្ដីអំពីរឿងក្ដីនោះ ដោយផ្អែកលើអង្គហេតុនេះបាន ។

ខ-តុលាការនៃបណ្ដឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា រឿងក្ដីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្ដីរបស់តុលាការ ។

## ជំពូកទី ៤
## បណ្ដឹងជំទាស់

**មាត្រា ៣០១.-** របៀបប្ដឹងជំទាស់

១-ដើម្បីប្ដឹងជំទាស់ ភាគីត្រូវដាក់ពាក្យបណ្ដឹងជំទាស់ទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើម ត្រូវធ្វើឱ្យបានឆាប់រហ័ស នូវពាក្យបណ្ដឹងជំទាស់ និង សំណុំរឿងទៅតុលាការនៃបណ្ដឹងជំទាស់ ។

២-ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្ដូរនូវដីកាសម្រេចដើម ក្នុងពាក្យបណ្ដឹងជំទាស់ទេ ម្ចាស់បណ្ដឹងជំទាស់គប្បីដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរអំពីចំណុចនោះ ទៅតុលាការនៃបណ្ដឹងជំទាស់ នៅក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹងជំទាស់នោះ ។

**មាត្រា ៣០២.-** បណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ

១-ភាគីដែលមិនយល់ព្រមចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ អាចដាក់ពាក្យសុំប្ដឹងតវ៉ាទៅតុលាការទទួលបណ្ដឹងបាន

តែក្នុងករណីដែលច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់តុលាការទទួលបណ្តឹង ។ ប៉ុន្តែ ក្នុងករណីដែលតុលាការទទួលបណ្តឹងជាតុលាការកំពូល ឬ សាលាឧទ្ធរណ៍ ភាគីអាចដាក់ពាក្យសុំប្តឹងតវ៉ាបាន លុះត្រាតែច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់សាលាដំបូង ។

២-ចំពោះដីកាសម្រេចលើពាក្យសុំនៃកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបណ្តឹងជំទាស់បាន ។

**មាត្រា ៣០៣.–** អំឡុងពេលសម្រាប់ប្តឹងជំទាស់

១-បណ្តឹងជំទាស់ត្រូវធ្វើក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច ។

២-អំឡុងពេលនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

**មាត្រា ៣០៤.–** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ

១-បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និង នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចរបស់សាលាដំបូង និង នីតិវិធីនៃតុលាការនៃបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈបណ្តឹង ឬ នីតិវិធីនោះ ។

២-បញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីទាក់ទងនឹងការជំនុំជម្រះបណ្តឹងសាទុក្ខនោះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ និង នីតិវិធីទាក់ទងនឹងបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្តឹង ឬ នីតិវិធីនោះ ។

**មាត្រា ៣០៥.–** ការផ្អាកអានុភាពនៃដីកាសម្រេចដើម

១-បណ្តឹងជំទាស់ត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើម ។

២-តុលាការនៃបណ្តឹងជំទាស់ ឬ តុលាការដែលបានចេញដីកាសម្រេចដើម អាចបង្គាប់ឱ្យផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចដើម

ឬ បង្គាប់ឱ្យចាត់ចែងជាចាំបាច់ផ្សេងទៀតបាន រហូតដល់ពេលមានដីកាសម្រេចអំពីបណ្ដឹងជំទាស់ ។

**មាត្រា ៣០៦.–** ការទាញហេតុផលដោយផ្ទាល់មាត់តាមឆន្ទៈស្ម័គ្រចិត្ត និង ការសួរជំនួសការទាញហេតុផលដោយផ្ទាល់មាត់

១-ការសម្រេចសេចក្ដីលើបណ្ដឹងជំទាស់ អាចធ្វើបាន ដោយមិនបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ។

២-ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់អំពីបណ្ដឹងជំទាស់ទេ តុលាការអាចធ្វើការសួរម្ចាស់បណ្ដឹងជំទាស់ ឬ អ្នកផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នៃបណ្ដឹងបាន ។

# គន្ថីទី ៤
# ការជំនុំជម្រះសាជាថ្មី

## ជំពូកទោល
## ការជំនុំជម្រះសាជាថ្មី

**មាត្រា ៣០៧.-** មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)

១-ភាគីអាចស្នើសុំប្តឹងឧបាស្រ័យ តាមបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ចំពោះសាលក្រមចុងក្រោយ ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ ក្នុងករណីដែលមានមូលហេតុណាមួយដូចរៀបរាប់ខាងក្រោមនេះ :

ក-បើពុំបានចាត់តាំងតុលាការដែលបានចេញសាលក្រម ឬ សាលដីកា ទៅតាមច្បាប់កំណត់ ។

ខ-បើចៅក្រមដែលពុំអាចចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាតាមច្បាប់ បានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកានោះ ។

គ-បើខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ឬ ខ្វះសិទ្ធិតំណាងដោយអាណត្តិ ។

ឃ-បើចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកា បានប្រព្រឹត្តអំពើល្មើសដែលពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនចំពោះរឿងក្តី ។

ង-បើភាគីបានសារភាព ឬ ត្រូវបានរារាំងក្នុងការដាក់មធ្យោបាយតទល់ ឬ ការ-ពារខ្លួនដែលមានឥទ្ធិពលដល់សាលក្រម ឬ សាលដីកា ដោយសារបទល្មើសរបស់អ្នកដទៃ ។

ច-បើឯកសារ ឬ វត្ថុឯទៀតដែលបានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ត្រូវបានក្លែង ឬ កែប្រែដោយបន្លំ ។

ឆ-បើសេចក្តីថ្លែងការណ៍មិនពិតរបស់សាក្សី អ្នកធ្វើកោសលវិច័យ អ្នកបកប្រែ ភាគីដែលបានធ្វើសម្បថ ឬ របស់អ្នកតំណាងដែលច្បាប់បានកំណត់ដែលបានធ្វើសម្បថ បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ។

ជ-បើសាលក្រម ឬ សាលដីកា ឬ សេចក្តីសម្រេចឯទៀត ផ្នែករដ្ឋប្បវេណី ឬ ផ្នែកព្រហ្មទណ្ឌ ឬ ការចាត់ចែងផ្នែករដ្ឋបាល ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ត្រូវបានផ្លាស់ប្តូរ ដោយសារសេចក្តីសម្រេច ឬ ការចាត់ចែងផ្នែករដ្ឋបាលនៅពេលក្រោយ ។

ឈ-បើមានការភ្លេចបញ្ចូលសេចក្តីវិនិច្ឆ័យលើចំណុចសំខាន់ៗ ដែលអាចមានឥទ្ធិពលទៅលើសាលក្រម ឬ សាលដីកា ។

ញ-បើសាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានការប៉ះពាល់ដល់សាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរហើយ ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីបានធ្វើការអះអាងអំពីមូលហេតុនោះ នៅពេលធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬ ភាគីបានដឹងអំពីមូលហេតុនេះហើយ តែមិនធ្វើការអះអាង ។

២-ចំពោះមូលហេតុដែលបានកំណត់ពីចំណុច ឃ រហូតដល់ចំណុច ឆ នៃកថាខណ្ឌទី ១ ខាងលើនេះ ភាគីអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន លុះត្រាតែមានករណីដូចបានរៀបរាប់ខាងក្រោមនេះ :

ក-ករណីដែលសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ប្រាក់ពិន័យបានចូលជាស្ថាពរចំពោះអំពើដែលត្រូវដាក់ទណ្ឌកម្ម ។

ខ-ករណីដែលមិនអាចទទួលបាននូវសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោសជាស្ថាពរ ឬ សេចក្តីសម្រេច ដែលដាក់ប្រាក់ពិន័យជាស្ថាពរ ដោយសារមូលហេតុផ្សេងពីមូលហេតុថា គ្មានភស្តុតាង ។

៣-បើសាលដីកាសម្រេចអង្គសេចក្តីអំពីរឿងក្តី ត្រូវបានសម្រេចនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍រួចហើយ ភាគីមិនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រមរបស់តុលាការនៃការជំនុំជម្រះលើកទី ១ បានឡើយ ។

**មាត្រា ៣០៨.-** មូលហេតុនៃការជំនុំជម្រះសាជាថ្មី (ពីរ)

ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) ខាងលើនេះ ចំពោះសេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ទោះជាមានការកំណត់នូវមធ្យោបាយនៃឧបាស្រ័យ

ដោយឯកឯងចំពោះសេចក្តីសម្រេចនោះក៏ដោយ ក៏ភាគីអាចយកមូលហេតុនោះមកធ្វើជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកានោះបានដែរ ។

**មាត្រា ៣០៩.—** តុលាការនៃការជំនុំជម្រះសាជាថ្មី

១-បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដែលបានចេញសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីនោះ ។

២-បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកាអំពីរឿងក្តីតែមួយដែលត្រូវបានចេញដោយតុលាការច្រើនដែលមានថ្នាក់ខុសគ្នា តុលាការជាន់ខ្ពស់មានសមត្ថកិច្ចរួមបញ្ចូលនូវសាលក្រម ឬ សាលដីកាទាំងនោះ ។

៣-ចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ពុំអាចចូលរួមក្នុងការជំនុំជម្រះ និង សម្រេចសេចក្តីអំពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះបានឡើយ ។

**មាត្រា ៣១០.—** នីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី

បញ្ញត្តិស្តីពីនីតិវិធីបណ្តឹងទៅតាមលំដាប់ថ្នាក់នៃការជំនុំជម្រះនីមួយៗ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្តឹងនៃការជំនុំជម្រះសាជាថ្មី ។

**មាត្រា ៣១១.—** អំឡុងពេលនៃការជំនុំជម្រះសាជាថ្មី

១-បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវធ្វើនៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលភាគីបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក្រោយពេលដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរហើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលយកមូលហេតុដែលបានកំណត់នៅក្នុងចំណុច គ ឬ ចំណុច ញ កថាខណ្ឌទី ១ នៃមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) នៃក្រមនេះ ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារ

បានឡើយ ។

៣-ភាគីពុំអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ ប្រសិនបើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងផុត ដោយគិតពីថ្ងៃដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ឬ គិតពីថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតឡើង ក្នុងករណីដែលមូលហេតុនោះកើតឡើងក្រោយពេលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលយកមូលហេតុដែលបានកំណត់នៅក្នុងចំណុច គ ឬ ចំណុច ញ កថាខណ្ឌទី ១ នៃមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) នៃក្រមនេះ ។

**មាត្រា ៣១២.-** ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

១-នៅក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង សេចក្ដីទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកានោះ ។

គ-អង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី ។

២-ឯកសារចម្លងនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវភ្ជាប់ជាមួយនឹងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

**មាត្រា ៣១៣.-** ការកែប្រែមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ភាគីដែលបានដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចកែប្រែមូលហេតុនៃការជំនុំជម្រះសាជាថ្មីបាន ។

**មាត្រា ៣១៤.-** ការលើកចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង ការច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី

១-ក្នុងករណីដែលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានភាពផ្ទុយនឹងច្បាប់ តុលា-

ការត្រូវលើកចោលបណ្តឹងនោះ ដោយដីកាសម្រេច ។

២-ក្នុងករណីដែលគ្មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវប្រទានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយដីកាសម្រេច ។

៣-ប្រសិនបើដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ចូលជាស្ថាពរហើយ ភាគីមិនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៀត ដោយយកមូលហេតុដូចគ្នាបានឡើយ ។

៤-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ៣១៥.-** ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី

១-ក្នុងករណីដែលមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវចេញដីកាសម្រេចដើម្បីចាប់ផ្តើមធ្វើការជំនុំជម្រះសាជាថ្មី ។

២-តុលាការត្រូវសួរភាគីម្ខាងទៀតជាមុន ក្នុងករណីចេញដីកាសម្រេចដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ៣១៦.-** ការវិនិច្ឆ័យ និង សម្រេចសេចក្តីលើអង្គសេចក្តី

១-តុលាការត្រូវធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីលើអង្គសេចក្តី តាមទំហំនៃឧបាស្រ័យ នៅក្នុងករណីដែលដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីចូលជាស្ថាពរ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា សាលក្រម ឬ សាលដីកាត្រឹមត្រូវ តុលាការត្រូវប្រទានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ។

៣-លើកលែងតែក្នុងករណីដូចកថាខណ្ឌទី ២ ខាងលើនេះ តុលាការត្រូវលុបចោលនូវសាលក្រម ឬ សាលដីកា ហើយត្រូវសម្រេចសេចក្តីជាថ្មីទៀត ។

**មាត្រា ៣១៧.-** ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច

១-ចំពោះដីកាសម្រេចដែលអាចប្តឹងឧបាស្រ័យដោយបណ្តឹងជំទាស់ ហើយបានចូល

ជាស្ថាពរ អាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីបាន ។

២-បញ្ញត្តិចាប់ពីមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) រហូតដល់មាត្រា ៣១៦ (ការវិនិច្ឆ័យ និង សម្រេចសេចក្ដីលើអង្គសេចក្ដី) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៣១៨.-** បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយតតិយជន

១-បើដើមចោទ និង ចុងចម្លើយបានទទួលនូវសាលក្រម ឬ សាលដីកា ដោយរួមគំនិតគ្នាក្នុងគោលបំណងធ្វើឱ្យបាត់បង់សិទ្ធិ ឬ ផលប្រយោជន៍របស់តតិយជន តតិយជននោះអាចធ្វើឧបាស្រ័យ ដោយបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរនោះបាន ។

២-បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដើមចោទ និង ចុងចម្លើយ ត្រូវក្លាយជាសហចុងចម្លើយ ។

៣-បញ្ញត្តិនៃមាត្រា ៤១ (បទបញ្ញាស្ដីពីការវិនិច្ឆ័យលើសហបណ្ដឹងចាំបាច់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះជនដែលជាសហចុងចម្លើយតាមកថាខណ្ឌទី ២ ខាងលើ និង តតិយជនដែលបានដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីតាមកថា-ខណ្ឌទី ១ ខាងលើនេះ ។

# គន្ថីទី ៥
# នីតិវិធីដាស់តឿន

## ជំពូកគោល
## នីតិវិធីដាស់តឿន

**មាត្រា ៣១៩.–** លក្ខខណ្ឌនៃដីកាសម្រេចដាស់តឿន

ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ តុលាការអាចចេញដីកាសម្រេចដាស់តឿន តាមពាក្យសុំរបស់ម្ចាស់បំណុលបាន ។ ប៉ុន្តែ ករណីនេះអាចធ្វើទៅបាន លុះត្រាតែអាចធ្វើការបញ្ជូនដីកានោះនៅព្រះរាជាណាចក្រកម្ពុជាបាន តាមវិធីក្រៅពីការបញ្ជូនតាមការផ្សាយជាសាធារណៈ ។

**មាត្រា ៣២០.–** ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន

១-ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនចំពោះកូនបំណុលដូចមានកំណត់ក្នុងចំណុចខាងក្រោម ត្រូវធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-រូបវន្តបុគ្គល : លំនៅឋាន ឬ បើពុំមានលំនៅឋាន ឬ មានលំនៅឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ គឺទីសំណាក់ ។

ខ-នីតិបុគ្គលក្នុងប្រទេស : ទីស្នាក់ការកណ្តាល ឬ ទីកន្លែងអាជីវកម្មចម្បង ឬ បើពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មទេ គឺលំនៅឋានរបស់អ្នកតំណាង ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង ។

គ-នីតិបុគ្គលបរទេស : ទីស្នាក់ការកណ្តាល ឬ ទីកន្លែងអាជីវកម្មចម្បងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ បើពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ គឺលំនៅឋានរបស់អ្នកតំណាងប្រចាំព្រះរាជាណាចក្រកម្ពុជា ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនអំពីការទាមទារដែលបានកំណត់ក្នុង

ចំណុចខាងក្រោមនេះ អាចធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះបានដែរ :

ក-ការទាមទារចំពោះបុគ្គលដែលមានទីស្នាក់ការ ឬ កន្លែងអាជីវកម្ម ហើយការទាមទារនោះទាក់ទងនឹងការងារនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ : កន្លែងដែលមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ ។

ខ-ការទាមទារឱ្យសងជាប្រាក់ដោយរូបិយាណត្តិ ឬ មូលប្បទានប័ត្រ និង ការទាមទារបន្ទាប់បន្សំដែលទាក់ទងនឹងវត្ថុទាំងនេះ : កន្លែងដែលត្រូវសងរូបិយាណត្តិ ឬ មូលប្បទានប័ត្រនោះ ។

២-សមត្ថកិច្ចដែលកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ ។

**មាត្រា ៣២១.–** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹង

បញ្ញត្តិស្តីពីបណ្តឹង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន លុះត្រាតែគ្មានភាពផ្ទុយនឹងលក្ខណៈរបស់ពាក្យសុំនោះ ។

**មាត្រា ៣២២.–** ការលើកចោលនូវពាក្យសុំ

ក្នុងករណីដែលពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន មានភាពផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៣១៩ (ល័ក្ខខ័ណ្ឌនៃដីកាសម្រេចដាស់តឿន) ឬ មាត្រា ៣២០ (ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន) ខាងលើនេះ ឬ ក្នុងករណីដែលមានភាពច្បាស់លាស់ថា គ្មានមូលហេតុក្នុងការទាមទារ ដោយគិតអំពីខ្លឹមសារនៃពាក្យសុំទេ តុលាការត្រូវលើកចោលពាក្យសុំនេះ ដោយដីកាសម្រេច ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដែរ ចំពោះការទាមទារមួយភាគដែលមិនអាចចេញដីកាសម្រេចដាស់តឿនភាគនោះ ។

**មាត្រា ៣២៣.–** ការចេញដីកាសម្រេចដាស់តឿន ជាអាទិ៍

១-ដីកាសម្រេចដាស់តឿន ត្រូវចេញដោយមិនបាច់សួរកូនបំណុល ។

២-កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ទៅតុលាការដែលបានចេញដីកាសម្រេចនោះបាន ។

**មាត្រា ៣២៤.-** ចំណុចដែលត្រូវសរសេរបញ្ជាក់ក្នុងដីកាសម្រេចដាស់តឿន

១-ដីកាសម្រេចដាស់តឿន ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ដីកាសម្រេចដែលម្ចាស់បំណុលទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារនេះ ។

គ-សេចក្តីបង្គាប់ឱ្យសងជាប្រាក់ដែលមានកំណត់នូវចំនួន ។

២-ក្នុងដីកាសម្រេចដាស់តឿននៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរបន្ថែមថា បើកូនបំណុលមិនបានដាក់ពាក្យប្តឹងតវ៉ាការដាស់តឿន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូននូវដីកាសម្រេចដាស់តឿននេះទេ នោះតុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

**មាត្រា ៣២៥.-** ការបញ្ជូនដីកាសម្រេចដាស់តឿន

១-តុលាការត្រូវជូនដំណឹងអំពីដីកាសម្រេចដាស់តឿនទៅឱ្យម្ចាស់បំណុល ហើយត្រូវបញ្ជូនដីកាសម្រេចនោះ ទៅកូនបំណុលផងដែរ ។

២-ដីកាសម្រេចដាស់តឿននេះត្រូវមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុល ។

៣-ប្រសិនបើមិនអាចបញ្ជូនដីកាសម្រេចដាស់តឿន ដោយសារគ្មានលំនៅឋាន ទីសំណាក់ ទីស្នាក់ការ ទីកន្លែងអាជីវកម្ម របស់កូនបំណុល ឬ លំនៅឋានរបស់អ្នកទទួលបន្ទុកភារកិច្ចការងារចម្បង នៅទីកន្លែងដែលម្ចាស់បំណុលបានរាយការណ៍ទេ តុលាការត្រូវជូនដំណឹងអំពីហេតុការណ៍នេះទៅម្ចាស់បំណុល ។ ក្នុងករណីនេះ ប្រសិនបើម្ចាស់បំណុលមិនបានរាយការណ៍អំពីទីកន្លែងដែលត្រូវបញ្ជូន ក្រៅពីទីកន្លែងដែលខ្លួនបានរាយការណ៍ពីមុន ក្នុងអំឡុងពេល ២ (ពីរ) ខែ ដោយគិតចាប់ពីថ្ងៃដែលម្ចាស់បំណុលទទួលដំណឹង ត្រូវចាត់ទុកថា ម្ចាស់បំណុលនោះបានដកពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនវិញ ។

៤-អំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

**មាត្រា ៣២៦.-** ការលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១-ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន មិនស្របច្បាប់ទេ តុលាការត្រូវលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះ ដោយដីកាសម្រេច ។

២-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៣២៧.-** អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១-ប្រសិនបើមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន នៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ដីកាសម្រេចដាស់តឿននោះ ត្រូវបាត់បង់អានុភាពក្នុងទំហំនៃការតវ៉ានោះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្ដឹងទៅតុលាការដែលបានកំណត់នៅមាត្រា ៣២០ (ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន) នៃក្រមនេះ នៅពេលដែលមានពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ។ ក្នុងករណីនេះ ប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្ដី ។

**មាត្រា ៣២៨.-** ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១-ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ បន្ទាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿន ឬ បើដីកាសម្រេចដែលលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន មុនការប្រកាសឱ្យអនុវត្តជាបណ្ដោះ-

អាសន្នបានចូលជាស្ថាពរ តុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយកំណត់បញ្ជាក់បន្ថែមនូវប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿនលើដីកាសម្រេចដាស់តឿន ដោយឆន្ទានុសិទ្ធិ ។

២-ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចដាស់តឿន ហើយត្រូវបញ្ជូនទៅភាគី ។

៣-បញ្ញត្តិនៃមាត្រា ១៩៧ (ការបាត់បង់អានុភាពនៃការប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្ន និង បដិទានស្ថានភាពដើម) និង កថាខណ្ឌទី ២ នៃមាត្រា ៣២៥ (ការបញ្ជូនដីកាសម្រេចដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៣២៩.-** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១-ពាក្យសុំតវ៉ាការដាស់តឿននៃកថាខណ្ឌទី ២ មាត្រា ៣២៣ (ការចេញដីកាសម្រេចដាស់តឿន ជាអាទិ៍) នៃក្រមនេះ ចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវធ្វើនៅក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ក្រោយពីបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿននោះ ។

២-អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

**មាត្រា ៣៣០.-** ការលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១-ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះ មិនស្របច្បាប់ទេ តុលាការត្រូវលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះ ដោយដីកាសម្រេច ។

២-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំ-ទាស់បាន ។

**មាត្រា ៣៣១.–** ការផ្ទេរនីតិវិធីដាស់តឿនទៅនីតិវិធីនៃបណ្តឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

ប្រសិនបើមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្តឹងទៅតុលាការដែលបានចេញដីកាសម្រេចដាស់តឿននោះ នៅពេលដែលមានពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ។ ក្នុងករណីនេះ ប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្តី ។

**មាត្រា ៣៣២.–** សាលក្រមនៃបណ្តឹងដែលត្រូវបានផ្ទេរ នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១-ប្រសិនបើសាលក្រមនៃបណ្តឹងដែលត្រូវបានផ្ទេរ តាមបញ្ញត្តិនៃមាត្រា ៣៣១ (ការផ្ទេរនីតិវិធីដាស់តឿនទៅនីតិវិធីនៃបណ្តឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) ខាងលើនេះ ស្របគ្នានឹងដីកាសម្រេចដាស់តឿននោះ តុលាការត្រូវទទួលស្គាល់នូវដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ក្នុងសាលក្រមនេះ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលនីតិវិធីដាស់តឿនត្រូវបានធ្វើឡើងដោយខុសច្បាប់ ។

២-ក្នុងសាលក្រមនៃបណ្តឹងដែលត្រូវបានផ្ទេរ តាមបញ្ញត្តិនៃមាត្រា ៣៣១ (ការផ្ទេរនីតិវិធីដាស់តឿនទៅនីតិវិធីនៃបណ្តឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) នៃក្រមនេះ តុលាការត្រូវលុបចោលនូវដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន លើកលែងតែក្នុងករណីដែលតុលាការទទួលស្គាល់នូវដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៣៣៣.–** អានុភាពនៃដីកាសម្រេចដាស់តឿន

ប្រសិនបើគ្មានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ឬ ប្រសិនបើដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នបានចូលជាស្ថាពរ ដីកាសម្រេចដាស់តឿននោះនឹងមានអានុភាពដូចសាលក្រមស្ថាពរដែរ ។

# គន្ថីទី ៦
# ការអនុវត្តដោយបង្ខំ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### គោលគំនិត

**មាត្រា ៣៣៤.–** គោលគំនិត

បុគ្គលដែលមានសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត អាចទាមទារឱ្យសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

**មាត្រា ៣៣៥.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤

បញ្ញត្តិពីគន្ថីទី ២ ដល់ គន្ថីទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ លើកលែងតែមានបញ្ញត្តិពិសេស ។

### ផ្នែកទី ២
### ស្ថាប័នអនុវត្ត

**មាត្រា ៣៣៦.–** ស្ថាប័នអនុវត្ត

១-ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត តាមពាក្យសុំរបស់ភាគី ។

២-ស្ថាប័នអនុវត្ត គឺតុលាការអនុវត្ត ឬ អាជ្ញាសាលា ។

៣-សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ថីនេះ គឺជាតុលាការអនុវត្ត ។

៤-ការសម្រេចសេចក្តីអំពីបណ្តឹងឧបាស្រ័យ ចំពោះការចាត់ចែងការអនុវត្តដែលធ្វើឡើងដោយអាជ្ញាសាលា ត្រូវធ្វើឡើងដោយសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។

**មាត្រា ៣៣៧.–** ការសម្រេចសេចក្ដីរបស់តុលាការអនុវត្ត ជាអាទិ៍

១-ការសម្រេចសេចក្ដីរបស់តុលាការអនុវត្ត ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ ឬ ជនផ្សេងទៀតដែលពាក់ព័ន្ធបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាលាដំបូង ត្រូវសម្រេចសេចក្ដីអំពីឧបាស្រ័យ ចំពោះការចាត់ចែងការអនុវត្តដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៣៣៨.–** ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍

១-ប្រសិនបើអាជ្ញាសាលាជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលានោះអាចប្រើកម្លាំង ឬ អាចសុំជំនួយពីនគរបាល ឬ កងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ច ដើម្បីបំបាត់នូវការប្រឆាំងនោះបាន ។

២-ប្រសិនបើអ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អ្នកនោះអាចសុំជំនួយពីអាជ្ញាសាលាបាន ។

**មាត្រា ៣៣៩.–** អ្នកសង្កេតការណ៍

នៅពេលចូលទៅទីកន្លែងរស់នៅដើម្បីបំពេញមុខនាទីរបស់ខ្លួន បើមិនបានជួបនឹងអ្នកចម្បងនៃទីកន្លែងរស់នៅ ឬ អ្នកតំណាងរបស់អ្នកនោះ ឬ ញាតិនៅជាមួយឬអ្នកបម្រើឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវឱ្យមានវត្តមានមន្ត្រីឃុំ សង្កាត់ មន្ត្រីនគរបាល ឬ អ្នកដទៃទៀតដែលអាចទទួលស្គាល់ថាជាសាក្សីសមរម្យ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអាជ្ញាសាលាប្រើកម្លាំង ឬ បានទទួលជំនួយពីនគរបាល ឬ កងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ច តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ ។

**មាត្រា ៣៤០.-** ការអនុវត្តនៅថ្ងៃសម្រាក ឬ ពេលយប់

១-អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុ-វត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ឬ តុលាការអនុវត្តដែលចេញការបង្គាប់ ដើម្បីចូលទៅបំពេញមុខនាទីក្នុងទីកន្លែងរស់នៅ នៅថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ ឬ ពីម៉ោងប្រាំមួយល្ងាច ដល់ម៉ោងប្រាំមួយព្រឹកនៃថ្ងៃបន្ទាប់ ។

២-នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវបង្ហាញលិខិតដែលបញ្ជាក់ថា ខ្លួនបានទទួលការអនុញ្ញាត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៣៤១.-** ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ ជាអាទិ៍

នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំ-ពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬ លក្ខណសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍ បើជននោះទាមទារ ។

**មាត្រា ៣៤២.-** ការស្នើសុំជំនួយពីក្រសួងមានសមត្ថកិច្ច

ក្នុងករណីដែលមានភាពចាំបាច់ក្នុងការអនុវត្តដោយបង្ខំ តុលាការអនុវត្តអាចស្នើសុំជំនួយពីក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចបាន ។

**មាត្រា ៣៤៣.-** បញ្ញត្តិពិសេសស្ដីពីបណ្ដឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ

១-ទោះជាមានបញ្ញត្តិនៃមាត្រា ៣០៩ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនេះក៏ដោយ ក៏បណ្ដឹងជំទាស់ដែលបានកំណត់នៅក្នុងគន្ថីនេះ មិនត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើមឡើយ ។

២-ក្នុងអំឡុងពេលរហូតដល់សេចក្ដីសម្រេចអំពីបណ្ដឹងជំទាស់មានអានុភាព តុលាការនៃបណ្ដឹងជំទាស់អាចចេញដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចខាងក្រោមនេះបាន :

ក-បង្គាប់ឱ្យផ្អាកអានុភាពនៃដីកាសម្រេចដើម ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ ។

ខ-បង្គាប់ឱ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំមួយផ្នែក ឬ ទាំងមូល ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ ។

**មាត្រា ៣៤៤.-** ការតវ៉ាចំពោះការអនុវត្ត

១-ចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ដែលមិនអាចប្ដឹងជំទាស់បាន អាចតវ៉ាទៅតុលាការអនុវត្តបាន ។

២-ចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា និង ការយឺតយ៉ាវ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងអនុវត្តនោះ អាចតវ៉ាទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៤៣ (បញ្ញត្តិពិសេសស្ដីពីបណ្ដឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានការតវ៉ាចំពោះការអនុវត្ត ។

**មាត្រា ៣៤៥.-** បណ្ដឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍

១-ចំពោះដីកាសម្រេចដូចខាងក្រោមនេះ អាចប្ដឹងជំទាស់បាន:

ក-ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

ខ-ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ឱ្យអាជ្ញាសាលាលុបចោលនីតិ-វិធីនៃការអនុវត្តដោយបង្ខំ ។

គ-ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចាត់ចែងរបស់អាជ្ញាសាលា ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

២-ដីកាសម្រេចដែលអាចប្ដឹងជំទាស់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

**មាត្រា ៣៤៦.-** សមត្ថកិច្ចផ្ដាច់មុខ

សមត្ថកិច្ចនៃតុលាការដែលបានកំណត់នៅក្នុងគន្ថីនេះ គឺជាសមត្ថកិច្ចផ្ដាច់មុខ ។

## ផ្នែកទី ៣
## ភាគីនៃការអនុវត្ត និង អ្នកតំណាង

**មាត្រា ៣៤៧.-** ឈ្មោះហៅរបស់ភាគី

នៅក្នុងគន្ថីនេះ ភាគីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវហៅថាម្ចាស់បំណុលនៃការអនុវត្តរីឯភាគីម្ខាងទៀត ត្រូវហៅថា កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៣៤៨.-** អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ

១-បញ្ញត្តិដែលបានកំណត់ខាងក្រោមនេះ ត្រូវយកមកអនុវត្តចំពោះការតំណាងដោយអាណត្តិក្នុងនីតិវិធីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំ:

ក-បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៣ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះនីតិវិធីនៃបណ្ដឹង ឬ បណ្ដឹងជំទាស់ដែលបានកំណត់នៅក្នុងគន្ថីទី ៦ នេះ ។

ខ-លើកលែងតែករណីដែលបានកំណត់នៅក្នុងចំណុច ក ខាងលើនេះ នៅក្នុងនីតិវិធីដែលតុលាការអនុវត្ត ឬ សាលាដំបូងធ្វើឡើងចំពោះការអនុវត្តដោយបង្ខំ អ្នកក្រៅពីអ្នកដែលអាចធ្វើជាអ្នកតំណាងដោយអាណត្តិ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៣ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) នៃក្រមនេះ អាចធ្វើជាអ្នកតំណាងដោយអាណត្តិបាន ដោយទទួលការអនុញ្ញាតពីតុលាការអនុវត្ត ឬ សាលាដំបូង ។

គ-នៅក្នុងនីតិវិធីដែលធ្វើឡើងដោយអាជ្ញាសាលា អ្នកណាក៏អាចធ្វើជាអ្នកតំណាងដោយអាណត្តិបានដែរ ។

២-តុលាការអនុវត្ត ឬ សាលាដំបូង អាចលុបចោលការអនុញ្ញាតដែលបានកំណត់នៅចំណុច ខ នៃកថាខណ្ឌទី ១ ខាងលើនេះ នៅពេលណាក៏បានដែរ ។

# ផ្នែកទី ៤
# លំនាំនៃការអនុវត្តដោយបង្ខំ

**មាត្រា ៣៤៩.-** របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ

១-ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

២-នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវមានបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ហើយត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តៈ

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណនៃលិខិតអនុវត្ត ។

គ-សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល ។

ឃ-សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុ-វត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ។

ង-ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល ។

៣-ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និង ទំហំនៃសេចក្តីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ។

**មាត្រា ៣៥០.-** លិខិតអនុវត្ត

១-ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើលិខិតអនុវត្ត ។

២-លិខិតអនុវត្ត គឺជាលិខិតដែលបានកំណត់ខាងក្រោមនេះ ៖

ក-សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ ។

ខ-សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ។

គ-ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក ។ ប៉ុន្តែ ចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ ។

ឃ-ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្ន ។

ង-ការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៦៦ (នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី) នៃក្រមនេះ ។

ច-លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ ។ ប៉ុន្តែ មានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែង-ការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ ។

ឆ-សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុ-វត្ត ដែលបានចូលជាស្ថាពរ តាមបញ្ញត្តិនៃមាត្រា ៣៥២ (សាលក្រមអនុវត្តសាលក្រម ឬ សាលដីការបស់តុលាការបរទេស) នៃក្រមនេះ ។

ជ-សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថា-ពរតាមបញ្ញត្តិនៃមាត្រា ៣៥៣ (ដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ) នៃក្រមនេះ ។

ឈ-កំណត់ហេតុដែលបានកំណត់នៅក្នុងមាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនេះ និង កំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ។

**មាត្រា ៣៥១.-** វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ

១-ការអនុវត្តដោយបង្ខំ អាចធ្វើបាន ដោយចង្អុលអ្នកដែលបានកំណត់ខាងក្រោមនេះ ជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ៖

ក-ភាគីដែលត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ។

ខ-តតិយជន ក្នុងករណីភាគីដែលត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ធ្វើជាភាគីសម្រាប់តតិយជននោះ ។

គ-អ្នកដែលទទួលបន្តសិទ្ធិ ឬ ករណីយកិច្ចពីបុគ្គលដែលបានកំណត់នៅក្នុងចំណុច ក និង ចំណុច ខ ក្រោយពីលិខិតអនុវត្តនោះត្រូវបានធ្វើឡើង ។ ប៉ុន្តែ ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ក ខ ឆ និង ជ នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ គឺអ្នកទទួលបន្តសិទ្ធិ ឬ ករណីយកិច្ចក្រោយពីបណ្ដឹងត្រូវបានចាត់ការ ។

២-ការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ក ខ គ ឆ ជ ឬ ឈ នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ អាចធ្វើចំពោះបុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការទាមទារ សម្រាប់បុគ្គលដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ ខាងលើនេះបានដែរ ។

**មាត្រា ៣៥២.-** សាលក្រមអនុវត្តសាលក្រម ឬ សាលដីការបស់តុលាការបរទេស

១-ដើម្បីអនុវត្តដោយបង្ខំ ដោយផ្អែកលើសាលក្រម ឬ សាលដីការបស់តុលាការបរទេស ត្រូវទទួលសាលក្រមអនុវត្តពីតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

២-បណ្ដឹងទាមទារឱ្យចេញសាលក្រមអនុវត្ត ចំពោះសាលក្រម ឬ សាលដីការបស់តុលាការបរទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើកន្លែងរបស់កូនបំណុលនៃការអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ហើយក្នុងករណីដែលមិនអាចកំណត់តុលាការដែលមានសមត្ថកិច្ច តាមមាត្រា ៨ ទេនោះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យរបស់កូនបំណុលនៃការអនុវត្តដែលអាចរឹបអូសបានស្ថិតនៅ ។

៣-ប្រសិនបើមិនអាចបញ្ជាក់ថាសាលក្រម ឬ សាលដីការបស់តុលាការបរទេសបានចូលជាស្ថាពរ ឬ ប្រសិនបើសាលក្រម ឬ សាលដីកានេះមិនបានបំពេញល័ក្ខខ័ណ្ឌនានា ដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃមាត្រា ១៩៩ (អានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស) នៃក្រមនេះទេ តុលាការត្រូវលើកចោលបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

៤-ការចេញសាលក្រមអនុវត្ត ត្រូវធ្វើឡើងដោយមិនស្រាវជ្រាវអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រម ឬ សាលដីការបស់តុលាការបរទេសទេ ។

៥-ក្នុងសាលក្រមអនុវត្ត តុលាការត្រូវប្រកាសអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ តាមសាលក្រម ឬ សាលដីការបស់តុលាការបរទេស ។

**មាត្រា ៣៥៣.–** ដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ

១-ដើម្បីធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើសេចក្តីសម្រេចមជ្ឈត្តករ ទោះបីជាសេចក្តីសម្រេចមជ្ឈត្តករក្នុងប្រទេសក៏ដោយ សេចក្តីសម្រេចមជ្ឈត្តករបរទេសក៏ដោយ ត្រូវទទួលដីកាសម្រេចអនុវត្តរបស់តុលាការនៅព្រះរាជាណាចក្រកម្ពុជា ។

២-ភាគីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ត្រូវដាក់លិខិតដូចខាងក្រោមនេះ :

ក-ច្បាប់ដើមនៃសេចក្តីសម្រេចមជ្ឈត្តករដែលត្រូវបានបញ្ជាក់ដោយត្រឹមត្រូវ ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ត្រឹមត្រូវ ។

ខ-ច្បាប់ដើមនៃកិច្ចសន្យាមជ្ឈត្តកម្ម ឬ ឯកសារចម្លងនៃកិច្ចសន្យានោះ ដែលមានសេចក្តីបញ្ជាក់ត្រឹមត្រូវ ។

៣-តុលាការអាចបដិសេធការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបាន បើភាគីដែលនឹងទទួលការខូចខាតផលប្រយោជន៍ពីការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ សំអាងបញ្ជាក់អំពីហេតុដូចខាងក្រោមនេះ :

ក-ភាគីនៃកិច្ចសន្យាមជ្ឈត្តកម្ម គ្មានសមត្ថភាព ឬ កិច្ចសន្យាមជ្ឈត្តកម្មនោះ ត្រូវចាត់ទុកថាមោឃៈ តាមបទដ្ឋានគតិយុត្តដែលគូភាគីកំណត់ជាច្បាប់យោង ឬ តាមបទដ្ឋានគតិយុត្តនៃប្រទេសដែលសេចក្តីសម្រេចមជ្ឈត្តករ ត្រូវបានធ្វើឡើង បើគ្មានការកំណត់ដោយគូភាគី ។

ខ-ភាគីដែលនឹងទទួលការខូចខាតផលប្រយោជន៍ ពីការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ មិនបានទទួលសេចក្តីជូនដំណឹងសមរម្យអំពីការជ្រើសតាំងមជ្ឈត្តករ ឬ នីតិវិធីមជ្ឈត្តកម្ម ឬ មិនអាចការពារខ្លួនដោយសារមូលហេតុផ្សេងទៀត ។

គ-សេចក្តីសម្រេចមជ្ឈត្តករ ទាក់ទងនឹងវិវាទដែលមិនបានកំណត់នៅក្នុងចំណុច

ដែលត្រូវទទួលមជ្ឈត្តកម្ម ឬ វិវាទក្រៅទំហំនៃចំណុចនោះ ឬ មានសេចក្តីសម្រេចអំពីចំណុចដែលហួសពីទំហំនៃចំណុចដែលត្រូវទទួលមជ្ឈត្តកម្ម ។

ឃ-ការរៀបចំអង្គភាពវិនិច្ឆ័យនៃមជ្ឈត្តកម្ម ឬ នីតិវិធីនៃមជ្ឈត្តកម្ម មិនស្របតាមការព្រមព្រៀងរបស់ភាគី ឬ បើគ្មានការព្រមព្រៀងនោះ មិនស្របតាមបទដ្ឋានគតិយុត្តនៃប្រទេសដែលមជ្ឈត្តកម្មត្រូវបានធ្វើឡើង ។

ង-សេចក្តីសម្រេចមជ្ឈត្តករ មិនទាន់មានអានុភាពចងភាគី ឬ ត្រូវបានលុបចោល ដោយតុលាការនៃប្រទេសដែលសេចក្តីសម្រេចមជ្ឈត្តករនោះត្រូវបានធ្វើឡើង ឬ ប្រទេសដែលមានបទដ្ឋានគតិយុត្តដែលជាមូលដ្ឋាននៃសេចក្តីសម្រេចមជ្ឈត្តករនោះ ។

៤-តុលាការអាចបដិសេធការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ប្រសិនបើយល់ឃើញថា មានហេតុដូចខាងក្រោមនេះ :

ក-ចំណុចដែលជាកម្មវត្ថុនៃវិវាទ មិនអាចដោះស្រាយបាន ដោយមជ្ឈត្តកម្ម ។

ខ-ការទទួលស្គាល់ ឬ ការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ។

៥-ពាក្យសុំចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករក្នុងប្រទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើកន្លែងរបស់កូនបំណុលនៃការអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ហើយក្នុងករណីដែលមិនអាចកំណត់តុលាការដែលមានសមត្ថកិច្ច តាមមាត្រា ៨ ទេនោះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យរបស់កូនបំណុលនៃការអនុវត្តដែលអាចរឹបអូសបានស្ថិតនៅ ។

៦-ពាក្យសុំចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបរទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ ។

៧-ការចេញដីកាសម្រេចអនុវត្ត ត្រូវធ្វើឡើងដោយមិនស្រាវជ្រាវអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសេចក្តីសម្រេចមជ្ឈត្តករ លើកលែងតែករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ ខាងលើនេះ ។

៨-ក្នុងដីកាសម្រេចអនុវត្ត តុលាការត្រូវប្រកាសអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ តាម

សេចក្ដីសម្រេចមជ្ឈត្តករ ។

៩-ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្ត អាចប្ដឹងជំទាស់បាន ។

១០-ដីកាសម្រេចអនុវត្ត មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

**មាត្រា ៣៥៤.-** ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត

១-ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ។ ប៉ុន្តែ ក្នុងករណីដែលយកឯកសារដែលបានកំណត់ដូចខាងក្រោមនេះជាលិខិតអនុវត្ត ការអនុវត្តដោយបង្ខំ ដោយយកភាគីដែលបានកំណត់ក្នុងលិខិតអនុវត្តនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្តត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះ :

ក-សាលក្រមនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិចដែលចូលជាស្ថាពរ ។

ខ-សាលក្រមនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិចដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។

គ-ដីកាសម្រេចដាស់តឿនដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។

២-រូបមន្តអនុវត្ត ត្រូវផ្ដល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះតាមពាក្យសុំ ។ ប៉ុន្តែ ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ច កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ត្រូវផ្ដល់ដោយសារការីដែលរក្សាទុកនូវលិខិតដើមនោះ ។

**មាត្រា ៣៥៥.-** ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត

១-ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងដោយលិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរចំណុចដូចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណនៃលិខិតអនុវត្ត ។

គ-ហេតុការណ៍ និង មូលហេតុ បើការទាមទារឱ្យផ្ដល់រូបមន្តអនុវត្តត្រូវធ្វើឡើង

តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ឬ កថាខណ្ឌទី ១ នៃមាត្រា ៣៥៨ (ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍) នៃក្រមនេះ ។

២-ក្នុងករណីដែលលិខិតអនុវត្តជាសេចក្តីសម្រេចដែលមិនបង្កើតអានុភាពបើមិនចូលជាស្ថាពរទេ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តចំពោះលិខិតអនុវត្តនោះ ម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់មកជាមួយពាក្យសុំនូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេចនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលច្បាស់លាស់ថា សេចក្តីសម្រេចនោះបានចូលជាស្ថាពរហើយ ក្នុងសំណុំរឿង ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលនៃការអនុវត្ត ទាមទារឱ្យប្រគល់ថែមទៀតនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

**មាត្រា ៣៥៦.-** រូបមន្តអនុវត្តពិសេស

១-នៅក្នុងករណីដែលសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ក្រឡាបញ្ជី ឬ សារការីអាចប្រគល់រូបមន្តអនុវត្តបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់អំពីការបំពេញល័ក្ខខ័ណ្ឌ ឬ ការមកដល់នូវពេលកំណត់មិនពិតប្រាកដនោះ ។

២-ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយយកបុគ្គលផ្សេង ក្រៅពីភាគីដែលត្រូវបានសរសេរលើលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលការផ្តល់រូបមន្តអនុវត្ត ដែលមានសរសេរនូវហេតុការណ៍នោះ ។

៣-ក្នុងករណីដែលមានភាពច្បាស់លាស់ថា អាចនឹងធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលផ្សេងក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ឬ ករណីដែលម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់ដោយលិខិតអំពីហេតុការណ៍នោះ ក្រឡាបញ្ជី ឬ សារការីអាចផ្តល់នូវរូបមន្តអនុវត្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ ខាងលើនេះបាន ។

៤-នៅពេលក្រឡាបញ្ជីផ្តល់រូបមន្តអនុវត្តដោយយោលតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ៣ ខាងលើនេះ ក្រឡាបញ្ជីនោះត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅ ។

**មាត្រា ៣៥៧.–** ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត

១-ការផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែម នៅផ្នែកក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត នូវចំណុចនីមួយៗដូចខាងក្រោមនេះ :

ក-បុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបាន ដោយលិខិតអនុវត្តនោះ និង ភាគីម្ខាងទៀត ។

ខ-ហេតុការណ៍ ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ ។

គ-ទំហំដែលអាចអនុវត្តដោយបង្ខំបាន បើបានផ្តល់រូបមន្តអនុវត្តតែមួយផ្នែកនៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ។

ឃ-ហេតុការណ៍ ក្នុងករណីដែលផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៣៥៨ (ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍) នៃក្រមនេះ ។

២-ក្រឡាបញ្ជី ឬ សារការី ត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្ត ដោយសរសេរថ្ងៃ ខែ ឆ្នាំនៃការផ្តល់ ។

**មាត្រា ៣៥៨.–** ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍

១-មានតែនៅក្នុងករណីដែលចាំបាច់ត្រូវការឯកសារចម្លងយថាភូតច្រើនច្បាប់នៃលិខិតអនុវត្ត ដែលភ្ជាប់នឹងរូបមន្តអនុវត្ត ដើម្បីទទួលសំណងពេញលេញនៃសិទ្ធិទាមទារ ឬ នៅក្នុងករណីដែលឯកសារចម្លងយថាភូតនោះបានបាត់បង់តែប៉ុណ្ណោះទេ ទើបអាចផ្តល់រូបមន្តអនុវត្តបន្ថែមទៀតបាន ។

២-បើផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជី ឬ សារ-ការីត្រូវជូនដំណឹងទៅកូនបំណុលនៃការអនុវត្ត អំពីហេតុការណ៍និងមូលហេតុនោះ និង ចំនួននៃឯកសារចម្លងយថាភូតដែលត្រូវបានផ្តល់រូបមន្តអនុវត្ត ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ

ចំពោះករណីដែលប្រគល់បន្ថែមទៀតនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបាន កំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

**មាត្រា ៣៥៩.-** ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត

១-នៅពេលផ្ដល់រូបមន្តអនុវត្ត ក្រឡាបញ្ជី ឬ សារការី ត្រូវសរសេរនៅក្នុងច្បាប់ដើម នៃលិខិតអនុវត្ត នូវចំណុចដូចខាងក្រោមនេះ :

ក-ហេតុការណ៍នៃការផ្ដល់រូបមន្តអនុវត្ត ថ្ងៃ ខែ ឆ្នាំដែលផ្ដល់ និង ចំនួនឯកសារ ចម្លងយថាភូតដែលត្រូវបានផ្ដល់រូបមន្តអនុវត្ត ។

ខ-ទំហំដែលអាចអនុវត្តដោយបង្ខំបាន ក្នុងករណីដែលបានផ្ដល់រូបមន្តអនុវត្ត ចំពោះតែមួយផ្នែកនៃសិទ្ធិទាមទារដែលបានកំណត់ នៅក្នុងលិខិតអនុវត្ត ។

គ-ហេតុការណ៍ និង ឈ្មោះ ឬ នាមករណ៍របស់ម្ចាស់បំណុលនៃការអនុវត្ត ឬ កូន បំណុលនៃការអនុវត្ត ក្នុងករណីដែលបានផ្ដល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ ។

២-បើក្រឡាបញ្ជីបានប្រគល់ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តថែមទៀត តាម បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) នៃក្រមនេះ ក្រឡាបញ្ជីនោះ ត្រូវសរសេរអំពីហេតុការណ៍នៃការ ផ្ដល់រូបមន្តអនុវត្តនេះ ថ្ងៃ ខែ ឆ្នាំដែលផ្ដល់ និង ចំនួនឯកសារចម្លងយថាភូតដែលបាន ប្រគល់ នៅក្នុងច្បាប់ដើមនៃសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចដាស់តឿន ។

**មាត្រា ៣៦០.-** ការបញ្ជូនលិខិតអនុវត្ត ជាអាទិ៍

ការអនុវត្តដោយបង្ខំ អាចចាប់ផ្ដើមធ្វើបាន តែក្នុងករណីដែលឯកសារចម្លងយថាភូត ឬ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្ត ឬ សេចក្ដីសម្រេចដែលនឹងក្លាយ ជាលិខិតអនុវត្តនៅពេលចូលជាស្ថាពរ ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន ។ នៅក្នុងករណីដែលរូបមន្តអនុវត្តត្រូវបានផ្ដល់ តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្ត ពិសេស) នៃក្រមនេះ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃរូបមន្តអនុវត្ត និង ឯកសារ ចម្លងដែលមានសេចក្ដីបញ្ជាក់នៃឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ តាម

បញ្ញត្តិនៃមាត្រា ៣៥៦ នោះ ក៏ត្រូវបញ្ជូនទៅជាមុនផងដែរ ។

**មាត្រា ៣៦១.-** លក្ខខណ្ឌនៃការចាប់ផ្ដើមអនុវត្តដែលស្ថាប័នអនុវត្តត្រូវស្រាវជ្រាវ

១-ក្នុងករណីសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងពេលកំណត់ពិតប្រាកដ ស្ថាប័នអនុវត្ត អាចចាប់ផ្ដើមអនុវត្តដោយបង្ខំបាន លុះត្រាតែពេលកំណត់នោះបានមកដល់ហើយ ។

២-ចំពោះការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តដែលមានដាក់លក្ខខណ្ឌត្រូវដាក់ប្រាតិភោគដើម្បីអនុវត្តដោយបង្ខំ ស្ថាប័នអនុវត្តអាចចាប់ផ្ដើមអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានដាក់លិខិតដែលបញ្ជាក់ថា ខ្លួនបានដាក់ប្រាតិភោគនោះរួចហើយ ។

៣-ក្នុងករណីតាវកាលិករបស់កូនបំណុលនៃការអនុវត្ត ត្រូវផ្ដល់ដោយប្ដូរនឹងតាវកាលិកតប ស្ថាប័នអនុវត្តអាចចាប់ផ្ដើមអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបញ្ជាក់ថា ខ្លួនបានផ្ដល់តាវកាលិកតបនោះ ឬ បានស្នើផ្ដល់តាវកាលិកតបនោះ ។

**មាត្រា ៣៦២.-** ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍

១-ចំពោះការចាត់ចែងពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត បើជាការចាត់ចែងរបស់ក្រឡាបញ្ជី អាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅ តែបើជាការចាត់ចែងរបស់សារការី អាចដាក់ពាក្យសុំតវ៉ា ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃការិយាល័យរបស់សារការីនោះ ។

២-ការសម្រេចសេចក្ដីអំពីពាក្យសុំតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយដីកាសម្រេច ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានពាក្យសុំឱ្យប្រគល់បន្ថែមទៀតនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

# ផ្នែកទី ៥
# បណ្ដឹងពាក់ព័ន្ធនឹងការអនុវត្ត

**មាត្រា ៣៦៣.–** បណ្ដឹងតវ៉ាចំពោះការទាមទារ

១-កូនបំណុលនៃការអនុវត្តដែលមានការតវ៉ាចំពោះអត្ថិភាព ឬ អត្ថន័យនៃសិទ្ធិទាមទារ ដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត អាចដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ដើម្បីកុំឱ្យតុលាការអនុញ្ញាតការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តនោះបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ខ ឬ ចំណុច ឃ នៃកថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ហើយមិនទាន់ចូលជាស្ថាពរ ។

២-មូលហេតុនៃការតវ៉ាចំពោះសាលក្រម ឬ សាលដីកាស្ថាពរ ត្រូវបានកម្រិតត្រឹមតែហេតុដែលកើតឡើងនៅក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់តែប៉ុណ្ណោះ ។

៣-បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ តាមការកំណត់នីមួយៗ យោលទៅតាមផ្នែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-លិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច ក រហូតទៅដល់ចំណុច ឃ ឬ ចាប់ពីចំណុច ឆ រហូតទៅដល់ចំណុច ឈ កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ : សាលាដំបូងនៃនីតិវិធីសម្រេចសេចក្ដីនោះ ។

ខ-លិខិតអនុវត្តដែលបានកំណត់នៅចំណុច ង កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ : តុលាការដែលក្រឡាបញ្ជីចាត់ចែងដូចចំណុចនោះ ស្ថិតនៅ ។

គ-លិខិតអនុវត្តដែលបានកំណត់នៅចំណុច ច កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ : តុលាការដែលមានសមត្ថកិច្ចលើទីកន្លែងរបស់ចុងចម្លើយដែលត្រូវបានកំណត់ដោយមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ។ បើពុំមានតុលាការដែលមានសមត្ថកិច្ចតាមមាត្រានេះទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ដែលអាចរឹបអូសបាន ស្ថិតនៅ ។

**មាត្រា ៣៦៤.-** បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត

១-នៅក្នុងករណីដែលរូបមន្តអនុវត្តត្រូវបានផ្តល់ តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ កូនបំណុលនៃការអនុវត្តដែលមានការតវ៉ាចំពោះការបំពេញល័ក្ខខ័ណ្ឌ ចំពោះការមកដល់ពេលកំណត់មិនពិតប្រាកដ ឬ ចំពោះលទ្ធភាពដែលអាចធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលក្រៅពីភាគីដែលបានកំណត់ក្នុងលិខិតអនុវត្ត មកធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត អាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ដើម្បីកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំបាន ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់នឹងរូបមន្តអនុវត្តនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៣៦៥.-** បណ្តឹងតវ៉ារបស់តតិយជន

១-តតិយជនដែលមានកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់ ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ អាចដាក់ពាក្យបណ្តឹងតវ៉ា ដើម្បីទាមទារកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំ ចំពោះម្ចាស់បំណុលនៃការអនុវត្តនោះបាន ។

២-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះការអនុវត្តដោយបង្ខំ ដោយតុលាការអនុវត្តដែលក្លាយជាស្ថាប័នអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការអនុវត្តនោះ រីឯចំពោះការអនុវត្តដោយបង្ខំ ដោយអាជ្ញាសាលាដែលក្លាយជាស្ថាប័នអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។

## ផ្នែកទី ៦
## ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ

**មាត្រា ៣៦៦.-** ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ជាអាទិ៍

១-តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ក្នុងករណីដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងឱ្យធ្វើការជំនុំជម្រះសាជាថ្មី បើស្ថានភាពដែលត្រូវបានអះអាងថាជាមូលហេតុឧបាស្រ័យនោះ ហាក់ដូចជាមានមូលហេតុផ្លូវច្បាប់ ហើយមានសេចក្ដីបញ្ជាក់ដំបូងអំពីហេតុការណ៍ពិតនោះ ។

ខ-ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងសាទុក្ខ ចំពោះសាលដីកា ឬ សាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន បើមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលត្រូវក្លាយជាមូលហេតុនៃការបដិសេធសាលដីកា ឬ សាលក្រមដើមចោល ។

គ-ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ចំពោះសាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ឬ ក្នុងករណីដែលមានការដាក់ពាក្យសុំតវ៉ា ចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន បើមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលត្រូវក្លាយជាមូលហេតុនៃការលុបចោល ឬ ផ្លាស់ប្ដូរសាលក្រមដើម ឬ ដីកាសម្រេចដាស់តឿននោះ ។

ឃ-ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងទាស់ ចំពោះសាលក្រមកំបាំងមុខដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន បើមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលត្រូវក្លាយជាមូលហេតុនៃការលុបចោល ឬ ផ្លាស់ប្ដូរសាលក្រមកំបាំងមុខនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចបង្គាប់ឱ្យលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយនោះ តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ជាមួយនឹងការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈបាន ។

៣-ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងសាទុក្ខចំពោះសាលដីកា ឬ សាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ឬ ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន បើសំណុំរឿងបណ្ដឹងនោះស្ថិតនៅតុលាការដើម តុលាការនោះត្រូវធ្វើការសម្រេចសេចក្ដីអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ។

**មាត្រា ៣៦៧.-** ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍

១-នៅក្នុងករណីដែលមានពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ពាក្យបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ឬ ពាក្យបណ្ដឹងតវ៉ារបស់តតិយជន បើមានសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលត្រូវបានអះអាងនោះ តុលាការដែលបានទទួលពាក្យបណ្ដឹង អាចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៦៨ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយជាអាទិ៍) នៃក្រមនេះ នៅក្នុងសាលក្រមចុងក្រោយ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលបានទទួលពាក្យបណ្ដឹងអាចបង្គាប់ឱ្យលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយនោះ តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ជាមួយនឹងការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈបាន។

៣-នៅក្នុងករណីដែលមានពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ឬ មានពាក្យបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត បើមានសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលត្រូវបានអះអាងនោះ ហើយមានស្ថានភាពបន្ទាន់ តុលាការអនុវត្ត ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះបាន ដោយកំណត់អំឡុងពេលត្រូវដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលធ្វើតាមកថាខណ្ឌទី ១ ខាងលើនេះ។ ការសម្រេចសេចក្ដីនេះ ក៏អាចធ្វើបានដែរនៅមុនពេលដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ។

៤-បើអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះត្រូវបានកន្លងផុត ឬ បើសេចក្ដីសម្រេច ដែលធ្វើតាមកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ត្រូវបានដាក់ជូនទៅតុលាការអនុវត្ត ឬ អាជ្ញាសាលា នៅក្នុងអំឡុងពេលនោះ ដីកាសម្រេចនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបាត់បង់នូវអានុភាព។

**មាត្រា ៣៦៨.-** ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍

នៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយអំពីបណ្ដឹងតវ៉ាចំពោះការទាមទារ បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ឬ បណ្ដឹងតវ៉ារបស់តតិយជន តុលាការដែលទទួលពាក្យបណ្ដឹងអាចបង្គាប់ឱ្យធ្វើការចាត់ចែងដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) នៃក្រមនេះ ឬ អាចលុបចោល ឬ ផ្លាស់ប្ដូរ ឬ ទទួលស្គាល់នូវសេចក្ដីសម្រេចដែលបានធ្វើរួចហើយតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នោះបាន ។ ការសម្រេចសេចក្ដីនេះត្រូវមានអានុភាព ចាប់ពីពេលដែលសាលក្រម ឬ សាលដីកាចុងក្រោយអំពីបណ្ដឹងដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវបានប្រកាស ។

**មាត្រា ៣៦៩.-** ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍

ក្នុងករណីដែលមានពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍ បើយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្ត តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ រហូតដល់ធ្វើការសម្រេចសេចក្ដីអំពីការតវ៉ានោះបាន ។

**មាត្រា ៣៧០.-** ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ

១-តុលាការអនុវត្ត ឬ អាជ្ញាសាលាត្រូវផ្អាកនូវការអនុវត្តដោយបង្ខំ ហើយត្រូវលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ បើឯកសារដែលបានកំណត់ខាងក្រោមនេះ ត្រូវបានដាក់ :

ក-ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ថា លុបចោលលិខិតអនុវត្តក្រៅពីលិខិតយថាភូត ដែលបានកំណត់នៅក្នុងចំណុច ច កថាខណ្ឌទី ២ នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ឬ ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលកំណត់ថា លុបចោលការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។

ខ-ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា មិនអនុញ្ញាតឱ្យអនុវត្ត ដោយបង្ខំ ។

គ-អនុសារសាលក្រមស្ថាពរ ឬ អនុសារសាលដីកាស្ថាពរដែលប្រកាសថា ការផ្សះផ្សា ឬ ការទទួលស្គាល់ ដែលទាក់ទងនឹងលិខិតអនុវត្ត គ្មានអានុភាព ។

ឃ-ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬ ឯកសារផ្សេងទៀតដែលក្រឡាបញ្ជីបានធ្វើ ដែលបញ្ជាក់ថា លិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច ខ រហូតដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ បាត់បង់អានុភាពដោយសារការដកពាក្យបណ្តឹង ឬ មូលហេតុផ្សេងទៀត ។

ង-ឯកសារចម្លងយថាភូតនៃកំណត់ហេតុអំពីការផ្សះផ្សាតាមនីតិវិធីនៃការសម្រេចសេចក្តី ដែលកំណត់ថា មិនអនុវត្តដោយបង្ខំ ឬ ដកពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះវិញ ។

ច-ឯកសារដែលបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំ ។

ឆ-ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ និង លុបចោលការចាត់ចែងការអនុវត្ត ។

២-តុលាការអនុវត្ត ឬ អាជ្ញាសាលា ត្រូវផ្អាកនូវការអនុវត្តដោយបង្ខំ បើឯកសារដែលបានកំណត់ខាងក្រោមនេះត្រូវបានដាក់មក ។ ប៉ុន្តែ ចំពោះករណីដែលបានកំណត់នៅក្នុងចំណុច ខ ខាងក្រោម អានុភាពផ្អាកមានត្រឹមតែ ២ (ពីរ) ខែប៉ុណ្ណោះ :

ក-ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ។

ខ-ឯកសារដែលសរសេរថា ម្ចាស់បំណុលទទួលសំណង ឬ បានយល់ព្រមពន្យារពេលត្រូវសង នៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត ។

៣-បញ្ញត្តិនៃមាត្រា ៣៤៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលលុបចោលនូវការចាត់ចែងការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

# ផ្នែកទី ៧
# សោហ៊ុយសម្រាប់ការអនុវត្ត និង ការមើលសំណុំរឿងនៃការអនុវត្ត

**មាត្រា ៣៧១.-** អត្ថន័យនៃសោហ៊ុយសម្រាប់ការអនុវត្ត និង សោហ៊ុយសម្រាប់នីតិវិធី

អត្ថន័យនៃពាក្យដែលកំណត់នៅក្នុងចំណុចនីមួយៗ ត្រូវអនុលោមទៅតាមបញ្ញត្តិក្នុងចំណុចនីមួយៗខាងក្រោមនេះ:

ក-សោហ៊ុយសម្រាប់ការអនុវត្ត : សំដៅទៅលើពន្ធដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ៣៧២ (ពន្ធដាក់ពាក្យសុំ) សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ៣៧៣ (សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ) និង សោហ៊ុយភាគីដែលបានកំណត់នៅក្នុងមាត្រា ៣៧៤ (សោហ៊ុយភាគី) នៃក្រមនេះ ។

ខ-សោហ៊ុយសម្រាប់នីតិវិធី : សំដៅទៅលើសោហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងចំណោមសោហ៊ុយសម្រាប់ការអនុវត្តដែលបានកំណត់នៅក្នុងចំណុច ក ខាងលើនេះ ។

**មាត្រា ៣៧២.-** ពន្ធដាក់ពាក្យសុំ

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ១០.០០០ (មួយម៉ឺន) រៀល ទៅតុលាការ ។

២-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធ តាមបញ្ញត្តិដែលកំណត់ផ្សេង ។

**មាត្រា ៣៧៣.-** សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់នូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ជាសោហ៊ុយចាំបាច់ក្នុងការបញ្ជូនឯកសារ ឬ ធ្វើសកម្មភាពផ្សេងទៀតដើម្បីនីតិវិធីក្នុងការអនុវត្តដោយបង្ខំ ។

**មាត្រា ៣៧៤.-** សោហ៊ុយភាគី

ក្រៅពីសោហ៊ុយដែលបានកំណត់នៅក្នុងមាត្រា ៣៧២ (ពន្ធដាក់ពាក្យសុំ) និង មាត្រា ៣៧៣ (សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ) នៃក្រមនេះ សោហ៊ុយដែលតុលាការទទួលស្គាល់

ចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ ត្រូវចាត់ទុកថាជាសោហ៊ុយភាគី ។

**មាត្រា ៣៧៥.–** ការបង់សោហ៊ុយជាមុន

១-នៅពេលដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត អ្នកដែលដាក់ពាក្យសុំត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលតុលាការអនុវត្តកំណត់ថាជាសោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសោហ៊ុយដែលត្រូវបានបង់ជាមុនមានភាពខ្វះ ហើយតុលាការអនុវត្តបង្គាប់ឱ្យបង់ជាមុននូវសោហ៊ុយដែលខ្វះនោះ ។

២-បើអ្នកដាក់ពាក្យសុំមិនបានបង់សោហ៊ុយជាមុនទេ តុលាការអនុវត្តអាចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬ អាចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបាន ។

៣-ចំពោះដីកាសម្រេចលើកចោលពាក្យសុំតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៣៧៦.–** បន្ទុកនៃសោហ៊ុយសម្រាប់ការអនុវត្ត

១-សោហ៊ុយសម្រាប់ការអនុវត្ត ជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត ។

២-ក្នុងករណីដែលអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ សោហ៊ុយសម្រាប់ការអនុវត្ត អាចប្រមូលយកព្រមគ្នាក្នុងនីតិវិធីនៃការអនុវត្តបាន ដោយពុំចាំបាច់មានលិខិតអនុវត្តទេ ។

**មាត្រា ៣៧៧.–** ការដាក់ប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្ត ។

**មាត្រា ៣៧៨.–** ការមើលសំណុំរឿងនៃរឿងក្ដីអនុវត្តដោយបង្ខំ ជាអាទិ៍

១-ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយតុលាការអនុវត្ត អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់

ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដីនោះ ពីតុលាការបាន ដោយបង់ពន្ធ ។

២-ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដីនោះ ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

## ជំពូកទី ២
## ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់

### ផ្នែកទី ១
### ទ្រព្យសម្បត្តិដែលអាចរឹបអូសបាន

**មាត្រា ៣៧៩.-** គោលការណ៍

ការរឹបអូស អាចធ្វើបានចំពោះរូបទ្រព្យ ឬ អរូបទ្រព្យទាំងអស់ដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេង ។

**មាត្រា ៣៨០.-** ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស

ចលនវត្ថុដែលបានកំណត់ដូចខាងក្រោមនេះ មិនអាចត្រូវរឹបអូសបានទេ :

ក-ប្រដាប់ស្លៀកពាក់ ប្រដាប់សម្រាប់ដំណេក តុ ទូ ប្រដាប់សម្រាប់ដាំស្ល និង ប្រដាប់សម្រាប់បិទឃាំងបន្ទប់ របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

ខ-គ្រឿងបរិភោគ និង ទហនវត្ថុ ដែលត្រូវការចាំបាច់ដើម្បីចិញ្ចឹមជីវិតក្នុងអំឡុងពេល ២ (ពីរ) ខែ របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

គ-របបឧបត្ថម្ភជីវភាព របបឧបត្ថម្ភផ្នែកអប់រំ របបឧបត្ថម្ភសុខភាព និង ប្រាក់ ឬ វត្ថុឧបត្ថម្ភផ្សេងទៀតដែលផ្តល់ពីរដ្ឋ ឬ ពីអាជ្ញាធរដែនដី ដើម្បីការពារដល់ជីវភាពរបស់កូនបំណុលនៃការអនុវត្ត ។

ឃ-ផ្នែកប្រាក់តិចជាង ឬ ស្មើនឹង ១.០០០.០០០ (មួយលាន) រៀល ក្រៅពីប្រាក់ដែលបានកំណត់នៅក្នុងចំណុច គ ខាងលើនេះ ។

ង-ឧបករណ៍ ជី សត្វពាហនៈដែលជាចាំបាច់សម្រាប់ការងារកសិកម្មរបស់ខ្លួន និង ចំណីសត្វទាំងនេះ ព្រមទាំងគ្រាប់ពូជ ឬ កសិផលដែលមានប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់បន្តការងារកសិកម្មរហូតដល់រដូវបានផលបន្ទាប់ របស់កសិករក្នុងការប្រកបរបរកសិកម្ម ។

ច-មង សំណាញ់ ឬ នេសាទុបករណ៍ផ្សេងៗចាំបាច់ ចំណី និង កូនត្រី ឬ ជលផលប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់រកជលផល ឬ ចិញ្ចឹមជលផលរបស់អ្នកប្រកបរបរនេសាទ ។

ឆ-ឧបករណ៍ និង វត្ថុផ្សេងៗដែលចាំបាច់សម្រាប់អ្នកបច្ចេកទេស សិប្បករ កម្មករ និង អ្នកផ្សេងទៀតដែលប្រកបរបរវិជ្ជាជីវៈ ឬ សាជីវកម្ម ដោយប្រើកម្លាំងប្រាជ្ញា កម្លាំងកាយ ។ ប៉ុន្តែ បើជាវត្ថុដែលអ្នកនោះមាន ក្នុងគោលបំណងសម្រាប់លក់ ឬ ជួលវិញ អាចរឹបអូសយកបាន ។

ជ-ព្រះពុទ្ធរូប ក្បួនរីតិសាសនា និងវត្ថុផ្សេងៗដែលចាំបាច់សម្រាប់ពិធីក្នុងសាសនា ។

ឈ-ពង្សាវលី កំណត់ប្រចាំថ្ងៃ បញ្ជីប្រកបមុខរបរ និង ឯកសារប្រភេទដូចគ្នាដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត ។

ញ-គ្រឿងឥស្សរិយយស និង ប័ណ្ណសរសើរផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត ឬរបស់ញាតិរបស់ជននោះ ។

ដ-ឯកសារ និង ឧបករណ៍ ដែលចាំបាច់ក្នុងការសិក្សា នៅសាលា ឬ នៅស្ថាប័នអប់រំផ្សេងទៀត របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

ឋ-វត្ថុដែលទាក់ទងនឹងតក្កកម្ម ឬ ស្នាដៃនិពន្ធ ដែលមិនទាន់បានផ្សាយជាសាធារណៈ ។

ឌ-អវយវៈសិប្បនិមិត្ត សរីរាង្គសិប្បនិមិត្តផ្សេងទៀត និង ឧបករណ៍ជំនួយខ្លួនប្រាណផ្សេងទៀត ដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ព្រមទាំងវត្ថុផ្សេងៗសម្រាប់ថែទាំអ្នកជម្ងឺ ដែលជាកូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

ឍ-ម៉ាស៊ីន ឬ ឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ជន្លៀសខ្លួនពេលមានអាសន្ន ឬ ឧបករណ៍ផ្សេងទៀត សម្រាប់អាគារ ឬ សំណង់ផ្សេងទៀត ដែលច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗតម្រូវឱ្យមានបរិក្ខារ ដើម្បីបង្ការមហន្តរាយ ឬ ការពារសន្តិសុខ ។

**មាត្រា ៣៨១.-** ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស

១-សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យលុបចោលទាំងអស់ ឬ មួយផ្នែកនូវការរឹបអូសដែលធ្វើឡើងដោយអាជ្ញាសាលា ឬ អាចអនុញ្ញាតឱ្យរឹបអូសនូវចលនវត្ថុ ដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃមាត្រា ៣៨០ (ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) នៃក្រមនេះ ដោយពិចារណាទៅលើជីវភាព និង ស្ថានភាពផ្សេងៗរបស់កូនបំណុលនៃការអនុវត្ត និង ម្ចាស់បំណុលនៃការអនុវត្ត តាមពាក្យសុំបាន ។

២-ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចអនុញ្ញាតឱ្យរឹបអូសចលនវត្ថុដែលត្រូវបានលុបចោលការរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ឬ អាចបង្គាប់ឱ្យលុបចោលទាំងអស់ ឬ មួយផ្នែកនូវការរឹបអូសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ដដែលនេះ តាមពាក្យសុំបាន ។

៣-ប្រសិនបើមានពាក្យសុំឱ្យចេញដីកាសម្រេចលុបចោលនូវការរឹបអូសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំនោះ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន រហូតដល់ដីកាសម្រេចនោះមានអានុភាព ។

៤-ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ និង ចំពោះដីកាសម្រេចអនុញ្ញាតឱ្យរឹបអូស តាមបញ្ញត្តិទាំងឡាយខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ៣៨២.-** សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស

១-បៀវត្ស ប្រាក់ឈ្នួល និង សិទ្ធិលើបំណុលដែលមានលក្ខណៈដូចប្រាក់បៀវត្សផ្សេងទៀត អាចរឹបអូសបាន ចំពោះប្រាក់សល់ក្រោយពីបានកាត់នូវពន្ធអាករ និង ប្រាក់ធានារ៉ាប់រងសង្គមកិច្ច ពីចំនួនទឹកប្រាក់ដែលកូនបំណុលនៃការអនុវត្តត្រូវទទួលសំណង នៅពេលកំណត់ត្រូវសងនោះលុះត្រាតែស្របតាមចំណុចនីមួយៗដែលកំណត់ដូចខាងក្រោមនេះ :

ក-ផ្នែកតិចជាង ឬ ស្មើនឹង ២០០.០០០ (ពីរសែន) រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសបានទេ ។

ខ-ផ្នែកក្នុងខ្ទង់លើសពី ២០០.០០០ (ពីរសែន) រៀល ទៅ ៦០០.០០០ (ប្រាំមួយសែន) រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើសចំនួនទឹកប្រាក់ ១ ភាគ ៤ (មួយភាគបួន) នៃផ្នែកនេះទេ ។

គ-ផ្នែកក្នុងខ្ទង់លើសពី ៦០០.០០០ (ប្រាំមួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើសចំនួនទឹកប្រាក់ ១ ភាគ ៣ (មួយភាគបី) នៃផ្នែកនេះទេ ។

ឃ-ផ្នែកក្នុងខ្ទង់លើសពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើសចំនួនទឹកប្រាក់ ១ ភាគ ២ (មួយភាគពីរ) នៃផ្នែកនេះទេ ។

ង-ផ្នែកក្នុងខ្ទង់លើសពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើសចំនួនទឹកប្រាក់ ២ ភាគ ៣ (ពីរភាគបី) នៃផ្នែកនេះទេ ។

ច-ផ្នែកលើសពី ៦.០០០.០០០ (ប្រាំមួយលាន) រៀល ក្នុងមួយខែ អាចរឹបអូសយកបានទាំងអស់ ។

២-ចំពោះសិទ្ធិលើបំណុលចំពោះប្រាក់ឧបត្ថម្ភជីវភាព ប្រាក់ឧបត្ថម្ភផ្នែកសិក្សា ប្រាក់ឧបត្ថម្ភសុខភាព និង សិទ្ធិលើបំណុលផ្សេងទៀតដែលមានគោលបំណងការពារជីវភាពរបស់កូនបំណុលនៃការអនុវត្ត ពុំអាចរឹបអូសបានឡើយ ។

**មាត្រា ៣៨៣.-** ការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស

១-តុលាការនៃការអនុវត្តអាចលុបចោលដីកាសម្រេចរឹបអូសទាំងអស់ ឬ មួយផ្នែក ឬ អាចចេញដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលទាំងអស់ ឬ មួយផ្នែកដែលត្រូវបានហាមឃាត់ការរឹបអូសតាមបញ្ញត្តិនៃមាត្រា ៣៨២ (សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស) នៃក្រមនេះ ដោយពិចារណាទៅលើជីវភាព និង ស្ថានភាពផ្សេងៗរបស់កូនបំណុលនៃការអនុវត្ត និង ម្ចាស់បំណុលនៃការអនុវត្ត តាមពាក្យសុំបាន ។

២-ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរ តុលាការនៃការអនុវត្តអាចរឹបអូសសិទ្ធិលើបំណុល ដែលត្រូវបានលុបចោលដីកាសម្រេចរឹបអូសនោះតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើ ឬ អាចលុបចោលនូវដីកាសម្រេចរឹបអូសទាំងអស់ ឬ មួយផ្នែកតាមបញ្ញត្តិនៃកថាខណ្ឌដដែលនេះ តាមពាក្យសុំបាន ។

៣-ប្រសិនបើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ តុលាការនៃការអនុវត្ត អាចបង្គាប់ហាមឃាត់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ មិនឱ្យបង់ ឬ ផ្តល់តាវកាលិកផ្សេងទៀត ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន រហូតដល់ដីកាសម្រេចនោះមានអានុភាព ។

៤-ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យលុបចោលដីកាសម្រេចរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

## ផ្នែកទី ២
## ការអនុវត្តចំពោះចលនវត្ថុ

**មាត្រា ៣៨៤.-** ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ

១-ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវផ្ញើទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ ។

២-នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ក្រៅពីចំណុចនីមួយៗដែលកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) នៃក្រមនេះ

ត្រូវសរសេរអំពីទីកន្លែងដែលចលនវត្ថុដែលត្រូវរឹបអូសនោះ ស្ថិតនៅ ។

៣-ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ នឹងត្រូវចាប់ផ្តើមដោយការរឹបអូសវត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលា ។

៤-ចលនវត្ថុដែលបានកំណត់ក្នុងគន្លឹះនេះ មានរួមបញ្ចូលទាំងផលធម្មជាតិដែលមិនទាន់បំបែកពីដីនៅឡើយ ហើយអាចនឹងទទួលផលបានយ៉ាងច្បាស់នៅក្នុងអំឡុងពេល ១ (មួយ) ខែ ។

៥-ប្រសិនបើបានជួបប្រទះកូនបំណុលនៃការអនុវត្តនៅកន្លែងដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវដាស់តឿនឱ្យកូនបំណុលនៃការអនុវត្តនោះសងបំណុលដោយស្ម័គ្រចិត្ត នៅមុនពេលចាប់ផ្តើមរឹបអូស ។

៦-ក្នុងការអនុវត្តចំពោះចលនវត្ថុ អាជ្ញាសាលាអាចទទួលសំណងនៃបំណុល និងសំណងសោហ៊ុយសម្រាប់ការអនុវត្ត ដើម្បីម្ចាស់បំណុលនៃការអនុវត្តបាន ។

**មាត្រា ៣៨៥.-** ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត

១-ចំពោះការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវធ្វើដោយកាន់កាប់ចលនវត្ថុនោះ ។

២-នៅពេលធ្វើការរឹបអូសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាអាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬ កន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់ ហើយអាចធ្វើការឆែកឆេររកចលនវត្ថុដែលអាចរឹបអូសនោះបាន ។ ក្នុងករណីនេះ បើមានភាពចាំបាច់ អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទ ទូដែក និង ប្រអប់ផ្សេងទៀតបាន ។

៣-ពេលធ្វើការជ្រើសរើសចលនវត្ថុដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវគិតពិចារណាដល់ផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត ក្នុងល័ក្ខខ័ណ្ឌពុំធ្វើឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ។

៤-ប្រសិនបើយល់ឃើញថាសមរម្យ អាជ្ញាសាលាអាចឱ្យកូនបំណុលនៃការអនុវត្តថែរក្សា គ្រប់គ្រងនូវចលនវត្ថុដែលត្រូវបានរឹបអូស ។ នៅក្នុងករណីនេះ ការរឹបអូសនោះមានអានុភាព លុះត្រាតែចលនវត្ថុដែលបានរឹបអូសនោះ ត្រូវបានបិទស្លាក ឬ ដាក់សញ្ញា

រឹបអូសដោយវិធីផ្សេងទៀត ។

៥-ក្នុងករណីដែលអាជ្ញាសាលាបានឱ្យកូនបំណុលនៃការអនុវត្តថែរក្សា គ្រប់គ្រងនូវចលនវត្ថុដែលបានរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យ អាជ្ញាសាលាអាចអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តប្រើចលនវត្ថុនោះបាន ។

៦-ប្រសិនបើយល់ថាចាំបាច់ អាជ្ញាសាលាអាចថែរក្សាគ្រប់គ្រងដោយខ្លួនឯងវិញនូវចលនវត្ថុដែលបានឱ្យកូនបំណុលនៃការអនុវត្តថែរក្សាគ្រប់គ្រង តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើ ឬ អាចលុបចោលនូវការអនុញ្ញាតដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ៥ ខាងលើនេះបាន ។ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងដោយខ្លួនឯងវិញ នូវចលនវត្ថុដែលបានឱ្យកូនបំណុលនៃការអនុវត្តថែរក្សា គ្រប់គ្រងនោះ ។

**មាត្រា ៣៨៦.–** ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត

បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ៣ ទី ៤ ទី ៥ និង ទី ៦ នៃមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយម្ចាស់បំណុលនៃការអនុវត្ត ឬ ចលនវត្ថុដែលកាន់កាប់ដោយតតិយជន ក្នុងករណីដែលតតិយជននោះមិនបដិសេធអំពីការប្រគល់ ។

**មាត្រា ៣៨៧.–** បទប្បញ្ញត្តិពិសេសស្តីពីរថយន្ត ជាអាទិ៍ ដែលបានចុះបញ្ជី

១-ប្រសិនបើរថយន្ត ឬ ទោចក្រយានយន្តដែលត្រូវបានរឹបអូស មានចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី អាជ្ញាសាលាត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចសរសេរនូវហេតុការណ៍នៃការរឹបអូស ចូលទៅក្នុងសៀវភៅចុះបញ្ជីនោះ ។

២-ការរឹបអូសចំពោះរថយន្ត ឬ ទោចក្រយានយន្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងត្រូវមានអានុភាព នៅពេលដែលបានសរសេរនូវហេតុការណ៍នៃការរឹបអូសនោះ ចូលទៅក្នុងសៀវភៅចុះបញ្ជី ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចលនវត្ថុ ក្រៅពីរថយន្ត ឬ ទោចក្រយានយន្តដែលចាំបាច់ត្រូវចុះបញ្ជី ។

**មាត្រា ៣៨៨.-** ការរួមបញ្ចូលរឿងក្តី

១-ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុបន្ថែមទៀត ទៅលើកូនបំណុលនៃការអនុវត្តដែលបានទទួលការរឹបអូសរួចមកហើយ នៅទីកន្លែងនៃការរឹបអូសដដែលនោះ បើមានចលនវត្ថុដែលមិនទាន់បានរឹបអូសនៅឡើយ អាជ្ញាសាលាត្រូវរឹបអូសចលនវត្ថុនោះ ហើយប្រសិនបើគ្មានចលនវត្ថុដែលអាចរឹបអូសបានទេនោះ អាជ្ញាសាលាត្រូវបញ្ជាក់ច្បាស់លាស់អំពីហេតុការណ៍នេះ ហើយត្រូវរួមបញ្ចូលរឿងក្តីអនុវត្តចំពោះចលន-វត្ថុថ្មីនេះ និង រឿងក្តីអនុវត្តចំពោះចលនវត្ថុមុនជាមួយគ្នា ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ទៅលើកូនបំណុលនៃការអនុវត្តដែលបានទទួលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន នៅទីកន្លែងនៃការអនុវត្តដដែលនោះ ។

២-បើរឿងក្តីអនុវត្តចំពោះចលនវត្ថុទាំងពីរ ត្រូវបានរួមបញ្ចូលគ្នា តាមបញ្ញត្តិនៃវាក្យ-ខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីពេលក្រោយនេះ ត្រូវចាត់ទុកថា បានរឹបអូសក្នុងរឿងក្តីពីមុន នៅពេលរួមបញ្ចូលរឿងក្តី ហើយពាក្យសុំនៃរឿងក្តីដែលធ្វើពេលក្រោយនេះ មានអានុភាពជាការទាមទារឱ្យចែកចំណែក ។ បើម្ចាស់បំណុលនៃការអនុវត្តមុន បានដកពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ឬ នីតិវិធីដែលបានចាប់ផ្តើម ដោយពាក្យសុំនោះ ត្រូវបានផ្អាក ឬ ត្រូវបានលុបចោល ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីមុននេះ ត្រូវចាត់ទុកថា បានរឹបអូសដើម្បីរឿងក្តីនៅពេលក្រោយ នៅពេលរួមបញ្ចូលរឿងក្តី ។

៣-បើរឿងក្តីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និង រឿងក្តីនៃការអនុវត្តចំពោះចលនវត្ថុ ត្រូវបានរួមបញ្ចូលគ្នា តាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ ចលនវត្ថុដែលត្រូវបានអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវចាត់ទុកថា បានរឹបអូសក្នុងរឿងក្តីនៃការអនុវត្តចំពោះចលនវត្ថុ នៅពេលរួមបញ្ចូលរឿងក្តី ហើយពាក្យសុំនៃរឿងក្តីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ននេះ មានអានុភាពជាការទាមទារឱ្យចែកចំណែក ។ បើម្ចាស់បំណុលនៃការអនុវត្ត បានដកពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ឬ នីតិវិធីដែលបានចាប់ផ្តើម ដោយពាក្យសុំនោះ ត្រូវបានលុបចោល ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីនៃការអនុវត្តចំពោះចលនវត្ថុនេះ ត្រូវចាត់ទុកថា បានអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ក្នុងរឿងក្តីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន នៅពេលរួមបញ្ចូលរឿងក្តី ។

៤-នៅពេលដែលបានរួមបញ្ចូលរឿងក្តី អាជ្ញាសាលាត្រូវជូនដំណឹងអំពីហេតុការណ៍នោះទៅម្ចាស់បំណុលនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និង កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៣៨៩.-** ទំហំដែលការរឹបអូសមានអានុភាព

ការរឹបអូសមានអានុភាពទៅលើផលធម្មជាតិដែលកើតចេញមកពីចលនវត្ថុដែលត្រូវបានរឹបអូស ។

**មាត្រា ៣៩០.-** ដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស

១-បើចលនវត្ថុត្រូវបានរឹបអូសរួចហើយ ហើយបែរជាធ្លាក់ទៅនៅក្រោមការកាន់កាប់របស់តតិយជន សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យតតិយជននោះប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូសនោះទៅអាជ្ញាសាលាបាន ដោយដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។

២-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតពីថ្ងៃដែលបានដឹងថា ចលនវត្ថុដែលត្រូវបានរឹបអូសនោះកាន់កាប់ដោយតតិយជន ។

៣-ចំពោះដីកាសម្រេចអំពីពាក្យសុំនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៤-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំត្រូវអនុវត្តឡើយ បើហួសអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានជូនដំណឹងទៅឱ្យអ្នកដាក់ពាក្យសុំ ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចអនុវត្តបានទោះនៅមុនពេលបញ្ជូនដីកាសម្រេចនោះទៅឱ្យតតិយជនដែលកាន់កាប់ចលនវត្ថុដែលត្រូវបានរឹបអូសក៏ដោយ ។

៦-សោហ៊ុយដែលចាំបាច់សម្រាប់ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ចំពោះនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ ។

**មាត្រា ៣៩១.–** ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ

១-ការរឹបអូសចលនវត្ថុ មិនត្រូវធ្វើឱ្យហួសកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្តទេ ។

២-ប្រសិនបើបានដឹងច្បាស់ថាការរឹបអូស លើសពីកម្រិតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ នៅក្រោយពេលដែលបានរឹបអូសរួចហើយ អាជ្ញាសាលាត្រូវលុបចោលការរឹបអូស ត្រឹមផ្នែកដែលបានហួសកម្រិតនោះ ។

**មាត្រា ៣៩២.–** ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់

១-អាជ្ញាសាលាមិនត្រូវរឹបអូសឡើយ ប្រសិនបើប៉ាន់ប្រមាណឃើញថា ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ ។

២-អាជ្ញាសាលាត្រូវលុបចោលការរឹបអូស ប្រសិនបើប៉ាន់ប្រមាណឃើញថា ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ក្រោយពីបានសងសិទ្ធិលើបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់នីតិវិធីហើយ ។

**មាត្រា ៣៩៣.–** ការលុបចោលនូវការរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថាមិនអាចលក់បាន

អាជ្ញាសាលាអាចលុបចោលការរឹបអូសចលនវត្ថុដែលត្រូវបានរឹបអូសហើយនោះបាន ក្នុងល័ក្ខខ័ណ្ឌដែលបានអនុវត្តការលក់តាមវិធីសមរម្យក៏ដោយ ក៏នៅតែមិនអាចលក់បាន ហើយប៉ាន់ប្រមាណឃើញថា នៅតែមិនអាចលក់បាន នៅពេលអនាគត ។

**មាត្រា ៣៩៤.–** ការទាមទារឱ្យចែកចំណែកពីអ្នកមានឯកសិទ្ធិ ជាអាទិ៍

បុគ្គលដែលមានឯកសិទ្ធិ ឬ មានសិទ្ធិលើការបញ្ចាំ អាចទាមទារឱ្យចែកចំណែកបាន ដោយដាក់ឯកសារដែលបញ្ជាក់អំពីសិទ្ធិនោះ ។

**មាត្រា ៣៩៥.–** វិធីលក់

១-ដើម្បីលក់ចលនវត្ថុដែលត្រូវបានរឹបអូស អាជ្ញាសាលាត្រូវលក់តាមវិធីលក់ឡាយឡុង ដោយផ្ទាល់មាត់ ឬ ដោយដាក់ស្រោមសំបុត្រ ។

២-ទោះបីមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើយល់ឃើញថាសមរម្យ ដោយគិតពិចារណាអំពីប្រភេទ និង ចំនួននៃចលនវត្ថុ ជាអាទិ៍ អាជ្ញាសាលាអាចអនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ ក្រៅពីរបៀបលក់តាមវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬ ដោយដាក់ស្រោមសំបុត្រ ឬ អាចឱ្យបុគ្គលផ្សេងពីអាជ្ញាសាលា អនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះបាន ដោយទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ។

៣-អាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុដែលត្រូវដាក់លក់ និង វិធីលក់ចលនវត្ថុនោះ ដោយបិទប្រកាស នៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ។

៤-កូនបំណុលនៃការអនុវត្ត មិនអាចធ្វើសំណើទិញចលនវត្ថុនោះបានឡើយ ។

៥-ប្រសិនបើអាជ្ញាសាលាអនុញ្ញាតឱ្យទិញ អ្នកទិញត្រូវបង់ថ្លៃភ្លាមៗ ។

៦-ប្រសិនបើចលនវត្ថុនោះត្រូវបានដាក់លក់ម្តងទៀត ដោយសារអ្នកទិញមិនបានបង់ថ្លៃ អ្នកសុំទិញមុននេះ មិនអាចធ្វើសំណើទិញម្តងទៀតបានឡើយ ។

៧-បើបានរឹបអូសចលនវត្ថុដែលមានតម្លៃខ្ពស់ អាជ្ញាសាលាត្រូវជ្រើសតាំងអ្នកវាយតម្លៃ ហើយឱ្យអ្នកវាយតម្លៃនោះ វាយតម្លៃចលនវត្ថុនោះ ។

**មាត្រា ៣៩៦.–** ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់

ចំពោះជនណាដែលធ្វើសកម្មភាពរំខានកុំឱ្យការអនុវត្តការលក់ធ្វើឡើងដោយត្រឹមត្រូវ ដូចជាបានធ្វើឱ្យរំខានដល់ជនដទៃទៀតក្នុងការធ្វើសំណើទិញ ឬ បានឃុបឃិតដើម្បីបញ្ចុះតម្លៃលក់ដោយមិនត្រឹមត្រូវ ឬ ចំពោះជនដែលបានប្រើឱ្យធ្វើសកម្មភាពនោះ អាជ្ញាសាលាអាចកម្រិតមិនឱ្យជននោះចូលកន្លែងលក់ ឬ អាចដេញជននោះចេញពីកន្លែងលក់ ឬ អាចមិនឱ្យស្នើសុំទិញបាន ។

**មាត្រា ៣៩៧.–** ការលក់នៅក្នុងពេលដែលការអនុវត្តកំពុងត្រូវបានផ្អាក

១-ក្នុងករណីដែលមានការដាក់ឯកសារដែលបានកំណត់នៅក្នុងចំណុច ក ឬ ចំណុច

ខ កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ប្រសិនបើមានការបារម្ភថា តម្លៃលក់ចលនវត្ថុដែលត្រូវបានរឹបអូស នឹងចុះថោកខ្លាំង ឬ បើត្រូវចំណាយសោហ៊ុយច្រើនមិនសមរម្យសម្រាប់រក្សាទុកនូវចលនវត្ថុនោះ អាជ្ញាសាលាអាចដាក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះលក់បាន ។

២-បើបានលក់ចលនវត្ថុដែលត្រូវបានរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាត្រូវផ្ញើទុកប្រាក់ដែលបានមកពីការលក់នោះនៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

**មាត្រា ៣៩៨.-** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែកជាប្រាក់

ម្ចាស់បំណុលដែលត្រូវទទួលចំណែក គឺបុគ្គលដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-ម្ចាស់បំណុលនៃការអនុវត្ត ។

ខ-ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលអាជ្ញាសាលាបានទទួលការប្រគល់ប្រាក់ ចំពោះប្រាក់ដែលបានមកពីការលក់ ។

គ-ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលបានរឹបអូសប្រាក់ ចំពោះប្រាក់ដែលត្រូវបានរឹបអូស ។

**មាត្រា ៣៩៩.-** ការចែកចំណែកដោយអាជ្ញាសាលា

១-ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬ ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស អាចសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន អាជ្ញាសាលាត្រូវចែកចំណែក ចំពោះម្ចាស់បំណុល ហើយត្រូវប្រគល់ប្រាក់នៅសេសសល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ ។

២-ក្រៅពីករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើបានទទួលប្រាក់ដែលបានពីការលក់ ឬ បានរឹបអូសប្រាក់ អាជ្ញាសាលាត្រូវកំណត់ថ្ងៃក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ជាថ្ងៃដែលត្រូវពិភាក្សាគ្នាអំពីការចែកចំណែកនៃប្រាក់ដែលបានមកពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស ហើយត្រូវជូនដំណឹងពីពេលវេលា និង ទីកន្លែង ទៅម្ចាស់

បំណុលនីមួយៗ ។ បើម្ចាស់បំណុលនីមួយៗបានពិភាក្សាគ្នាដាច់ស្រេចហើយ អាជ្ញាសាលាត្រូវចែកចំណែកតាមការពិភាក្សានោះ ។

៣-ក្នុងករណីដែលមានការដាក់ឯកសារដែលបានកំណត់ចាប់ពីចំណុច ក រហូតដល់ចំណុច ឆ កថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ក្រោយពេលអ្នកទិញបានបង់ថ្លៃហើយ បើមានម្ចាស់បំណុលដែលត្រូវទទួលចំណែកផ្សេងទៀត ក្រៅពីម្ចាស់បំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវចែកចំណែកឱ្យម្ចាស់បំណុលនោះ ។

៤-ក្នុងករណីដែលមានការដាក់ឯកសារដែលបានកំណត់នៅក្នុងចំណុច ក ឬ ចំណុច ខ កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ក្រោយពេលអ្នកទិញបានបង់ថ្លៃហើយ អាជ្ញាសាលាក៏ត្រូវចែកចំណែកនោះផងដែរ ។

៥-ចំពោះការចែកចំណែក សិទ្ធិលើបំណុលដែលកំណត់ពេលពិតប្រាកដពុំទាន់មកដល់ ត្រូវចាត់ទុកថា កំណត់ពេលសងនោះបានចូលមកដល់ហើយ ។

**មាត្រា ៤០០.-** ការផ្ញើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា

១-ក្នុងករណីដែលចែកចំណែក តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃមាត្រា ៣៩៩ (ការចែកចំណែកដោយអាជ្ញាសាលា) នៃក្រមនេះ ប្រសិនបើសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលត្រូវទទួលចំណែកនោះ មានមូលហេតុដូចបានកំណត់នៅក្នុងចំណុចខាងក្រោមនេះ អាជ្ញាសាលាត្រូវដាក់ប្រាក់ដែលស្មើនឹងចំណែកនោះ ផ្ញើទុកនៅសាលាដំបូងដែលខ្លួនស្ថិតនៅ ហើយត្រូវរាយការណ៍អំពីហេតុការណ៍នោះ ទៅសាលាដំបូងនោះ :

ក-បើសិទ្ធិលើបំណុលនោះមានភ្ជាប់នូវល័ក្ខខ័ណ្ឌបង្អង់ ឬ កំណត់ពេលមិនពិតប្រាកដ ។

ខ-បើសិទ្ធិលើបំណុលនោះជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្ដោះអាសន្ន ។

គ-បើមានការដាក់ឯកសារដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ។

ឃ-បើបានដាក់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលហាមឃាត់ការអនុវត្តមួយរយៈនៃឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ ។

២-អាជ្ញាសាលាត្រូវធ្វើទុកនូវទឹកប្រាក់ស្មើនឹងចំណែកចំពោះម្ចាស់បំណុល ដែលមិនបានបង្ហាញខ្លួនដើម្បីទទួលចំណែក នៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

**មាត្រា ៤០១.-** ការជូនដំណឹងទៅសាលាដំបូង

ប្រសិនបើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៩៩ (ការចែកចំណែកដោយអាជ្ញាសាលា) នៃក្រមនេះ ធ្វើមិនបានដាច់ស្រេចទេ អាជ្ញាសាលាត្រូវរាយការណ៍អំពីហេតុការណ៍នេះ ទៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

## ផ្នែកទី ៣
## ការអនុវត្តចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

**មាត្រា ៤០២.-** អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត

១-ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងប្រាក់ ឬ ប្រគល់ចលនវត្ថុ ត្រូវហៅថា ការអនុវត្តចំពោះសិទ្ធិលើបំណុល ។

២-កូនបំណុលនៃសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស ត្រូវហៅថា កូនបំណុលទី ៣ ។

៣-ក្នុងការអនុវត្តចំពោះសិទ្ធិលើបំណុល សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលនៃការអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ច ហើយក្នុងករណីដែលគ្មានកន្លែងខាងលើនោះ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលទី៣ដែលបានកំណត់នៅក្នុងមាត្រា ៨ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ចវិញ ។

៤-ក្នុងករណីដែលដីកាសម្រេចរឹបអូសបានចេញម្តងទៀតចំពោះសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស បើតុលាការអនុវត្តដែលបានចេញដីកាសម្រេចរឹបអូសនោះខុសគ្នា តុលាការអនុវត្តអាចផ្ទេររឿងក្តីនោះ ទៅតុលាការអនុវត្តផ្សេងបាន ។

**មាត្រា ៤០៣.-** ដីកាសម្រេចរឹបអូស

១-ពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវដាក់ទៅតុលាការអនុវត្ត ។

២-នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវបញ្ជាក់អំពីកូនបំណុលទី៣ផងដែរ ។

៣-ក្នុងករណីដែលសុំឱ្យអនុវត្តចំពោះផ្នែកណាមួយនៃសិទ្ធិលើបំណុល ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវទំហំនៃការអនុវត្តនោះ ក្នុងពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ។

៤-ការអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវចាប់ផ្តើម ដោយដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត ។

៥-ក្នុងដីកាសម្រេចរឹបអូស តុលាការអនុវត្តត្រូវហាមមិនឱ្យកូនបំណុលនៃការអនុវត្តធ្វើការប្រមូលសិទ្ធិលើបំណុល ឬ ការចាត់ចែងផ្សេងទៀត ហើយហាមមិនឱ្យកូនបំណុលទី ៣ សងបំណុលឱ្យកូនបំណុលនៃការអនុវត្តនោះ ។

៦-ដីកាសម្រេចរឹបអូសត្រូវធ្វើឡើង ដោយមិនត្រូវសួរកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ ទេ ។

៧-ដីកាសម្រេចរឹបអូសត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ ។

៨-អានុភាពនៃការរឹបអូស ត្រូវកើតឡើងនៅពេលដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅដល់កូនបំណុលទី ៣ ។

៩-នៅពេលដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ ក្រឡាបញ្ជីត្រូវជូនដំណឹងអំពីការណ៍នោះ និង ថ្ងៃ ខែ ឆ្នាំនៃការបញ្ជូននោះ ទៅម្ចាស់បំណុលនៃការអនុវត្ត ។

១០-បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូ-តែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានចុះបញ្ជី បានបង្កើតអានុភាព តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីបញ្ជាក់ថា សិទ្ធិលើបំណុលនោះត្រូវបានរឹបអូសហើយ ។

១១-ចំពោះសេចក្តីសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូស អាចប្តឹងជំទាស់បាន ។

**មាត្រា ៤០៤.–** ទំហំនៃការរឹបអូស

១-តុលាការអនុវត្ត អាចចេញដីកាសម្រេចរឹបអូសនូវសិទ្ធិលើបំណុលទាំងអស់ដែលត្រូវរឹបអូសនោះ ។

២-ប្រសិនបើតម្លៃនៃសិទ្ធិលើបំណុលដែលបានរឹបអូស លើសតម្លៃនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្ត នោះតុលាការអនុវត្តមិនត្រូវរឹបអូសសិទ្ធិលើបំណុលផ្សេងទៀតឡើយ ។

៣-ក្នុងករណីដែលសិទ្ធិលើបំណុលមួយភាគត្រូវបានរឹបអូស ឬ ត្រូវបានទទួលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ប្រសិនបើដីកាសម្រេចរឹបអូសផ្សេងទៀតបានចេញ ដោយលើសភាគដែលសល់នោះទៀត អានុភាពនៃការរឹបអូស ឬ ការអនុវត្តរឹបអូសជាបណ្តោះ-អាសន្ននីមួយៗនោះ មានចំពោះសិទ្ធិលើបំណុលទាំងអស់នោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃការរឹបអូស ក្នុងករណីដែលសិទ្ធិលើបំណុលទាំងអស់ត្រូវបានរឹបអូស ឬ បានទទួលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ហើយមានដីកាសម្រេចរឹបអូសផ្សេងទៀតដែលរឹបអូសមួយភាគនៃសិទ្ធិលើបំណុលនោះ ។

**មាត្រា ៤០៥.–** ការដាស់តឿនឱ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍

១-ប្រសិនបើមានពាក្យសុំពីម្ចាស់បំណុលនៃការអនុវត្ត នៅពេលបញ្ជូនដីកាសម្រេចរឹបអូស តុលាការអនុវត្តត្រូវដាស់តឿនឱ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍អំពីចំណុចដែលបានកំណត់ខាងក្រោមនេះ ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃបញ្ជូនដីកាសម្រេចរឹបអូស:

ក-អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះ ហើយប្រភេទចំនួនទឹកប្រាក់ និង ខ្លឹមសារនៃសិទ្ធិលើបំណុល បើមានសិទ្ធិនោះ ។

ខ-អត្ថិភាព ឬ នត្ថិភាពនៃឆន្ទៈសង និង ទំហំនៃការសង ឬ មូលហេតុដែលមិនសង ។

គ-បើមាន សញ្ញាណនៃជនដែលមានអាទិភាពជាងម្ចាស់បំណុលនៃការអនុវត្ត

ចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធ និង ប្រភេទនៃសិទ្ធិរបស់ជននោះ និង ទំហំនៃអាទិភាពនោះ ។

ឃ-អត្ថិភាព ឬ នត្ថិភាពនៃការរឹបអូស ឬ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធ ដោយម្ចាស់បំណុលផ្សេង ។

២-ប្រសិនបើកូនបំណុលទី ៣ មិនបានធ្វើសេចក្ដីថ្លែងការណ៍ តាមការដាស់តឿនដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយចេតនា ឬ ដោយកំហុសរបស់ខ្លួន ឬ បានធ្វើសេចក្ដីថ្លែងការណ៍ខុសពីការពិត កូនបំណុលទី ៣ នោះ ត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតដែលកើតឡើងដោយសារអំពើនេះ ។

**មាត្រា ៤០៦.–** ការប្រគល់លិខិតបញ្ជាក់សិទ្ធិលើបំណុល

១-ប្រសិនបើមានលិខិតបញ្ជាក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស កូនបំណុលនៃការអនុវត្តត្រូវប្រគល់លិខិតបញ្ជាក់នោះ ឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២-ម្ចាស់បំណុលនៃការអនុវត្តអាចទទួលការប្រគល់នូវលិខិតបញ្ជាក់ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តាមការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុដែលបានកំណត់ក្នុងមាត្រា ៥២៥ (ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ) នៃក្រមនេះ ដោយផ្អែកលើដីកាសម្រេចរឹបអូសបាន ។

**មាត្រា ៤០៧.–** ការរឹបអូសនូវតាវកាលិកដែលទទួលបន្តបន្ទាប់

អានុភាពនៃការរឹបអូសសិទ្ធិលើបំណុលដែលទាក់ទងនឹងប្រាក់បៀវត្សរ៍ ឬ តាវកាលិកផ្សេងទៀតដែលទទួលបន្តបន្ទាប់ មានលើតាវកាលិកដែលនឹងទទួលក្រោយពីការរឹបអូសនោះត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្ត ។

**មាត្រា ៤០៨.–** ការជូនដំណឹងអំពីការដកពាក្យសុំ ជាអាទិ៍

១-បើពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវបានដកវិញ ក្រឡាបញ្ជីត្រូវជូនដំណឹងនេះទៅឱ្យកូនបំណុលទី ៣ ដែលបានទទួលការបញ្ជូនដីកាសម្រេចរឹបអូសផងដែរ ។

២-បើមានដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុល ក្រឡា

បញ្ជីត្រូវជូនដំណឹងនេះ ទៅឱ្យកូនបំណុលទី ៣ ដែលបានទទួលការបញ្ជូនដីកាសម្រេចរឹបអូស ។

**មាត្រា ៤០៩.-** ការទាមទារឱ្យចែកចំណែក

១-ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត និង ម្ចាស់បំណុលដែលបញ្ជាក់ដោយឯកសារថា ខ្លួនមានឯកសិទ្ធិ អាចទាមទារឱ្យចែកចំណែកបាន ។

២-នៅពេលដែលមានការទាមទារឱ្យចែកចំណែកដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវបញ្ជូនឯកសារដែលបញ្ជាក់អំពីសេចក្តីទាមទារនោះទៅឱ្យកូនបំណុលទី ៣ ។

៣-ចំពោះដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែក អាចប្តឹងជំទាស់បាន ។

**មាត្រា ៤១០.-** ការប្រមូលបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់

១-ម្ចាស់បំណុលដែលបានរឹបអូសសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ អាចប្រមូលបំណុលនោះបាន បើ ១ (មួយ) សប្តាហ៍កន្លងហួស ក្រោយពីថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ ម្ចាស់បំណុលនៃការអនុវត្តនោះមិនអាចទទួលការសងលើសតម្លៃនៃសិទ្ធិលើបំណុលរបស់ខ្លួន និង សោហ៊ុយសម្រាប់ការអនុវត្តបានឡើយ ។

២-ពេលដែលម្ចាស់បំណុលនៃការអនុវត្តបានទទួលសំណងពីកូនបំណុលទី ៣ ត្រូវចាត់ទុកថា បំណុលនោះ និង សោហ៊ុយសម្រាប់ការអនុវត្ត ត្រូវបានសង ត្រឹមកម្រិតនៃចំនួនទឹកប្រាក់សំណងដែលខ្លួនបានទទួល ។

៣-ពេលដែលបានទទួលសំណងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នេះទៅតុលាការអនុវត្ត ។

៤-ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលខុសត្រូវចំពោះកូនបំណុលនៃការអនុវត្ត ក្នុងការសងការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តសិទ្ធិលើបំណុល ដែលខ្លួនបានរឹបអូស ។

**មាត្រា ៤១១.–** ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣

១-ពេលដែលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ត្រូវបានរឹបអូស កូនបំណុលទី ៣ អាចផ្ញើទុកប្រាក់ស្មើនឹងចំនួនប្រាក់ដែលត្រូវបានរឹបអូសក្នុងចំណោមសិទ្ធិលើបំណុលនោះ ឬ ប្រាក់ស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនោះទាំងអស់ នៅតុលា-ការអនុវត្តបាន ។

២-ក្នុងករណីខាងក្រោមនេះ កូនបំណុលទី៣ត្រូវផ្ញើទុកប្រាក់ស្មើនឹងចំនួនប្រាក់ដែលបានកំណត់ខាងក្រោម នៅតុលាការអនុវត្ត :

ក-បើបានចេញដីកាសម្រេចរឹបអូស ឬ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយលើសភាគសំណល់ពីការរឹបអូសសិទ្ធិលើបំណុល ហើយបានទទួលការបញ្ជូននូវដីកាសម្រេចនោះ មុនពេលដែលកូនបំណុលទី ៣ បានទទួលពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១២ (បណ្ដឹងទាមទារប្រមូលបំណុល) នៃក្រមនេះ : ចំនួនប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលនោះ ។

ខ-បើបានទទួលការបញ្ជូននូវឯកសារដែលបញ្ជាក់ថា មានការទាមទារឱ្យចែកចំណែក : ភាគនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ។

៣-បើបានផ្ញើប្រាក់ទុកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ កូនបំណុលទី ៣ ត្រូវជូនដំណឹងអំពីស្ថានភាពនោះ ទៅតុលាការអនុវត្ត ។

**មាត្រា ៤១២.–** បណ្ដឹងទាមទារប្រមូលបំណុល

១-បើម្ចាស់បំណុលបានដាក់ពាក្យបណ្ដឹងទាមទារឱ្យកូនបំណុលទី ៣ ផ្ដល់តាវកាលិកដែលទាក់ទងនឹងសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស តុលាការដែលទទួលពាក្យបណ្ដឹងនោះ អាចបង្គាប់ម្ចាស់បំណុលផ្សេងទៀតដែលបានរឹបអូសសិទ្ធិលើបំណុលនោះ មុនពេលដែលពាក្យបណ្ដឹងត្រូវបានបញ្ជូនឱ្យចូលរួមក្នុងនាមជាដើមចោទនៃសហបណ្ដឹងបាន តាមពាក្យសុំរបស់កូនបំណុលទី ៣ ដោយដីកាសម្រេច ។

២-អានុភាពនៃសាលក្រមដែលពាក់ព័ន្ធនឹងបណ្ដឹងដែលបានកំណត់នៅកថាខណ្ឌទី ១ មានចំពោះម្ចាស់បំណុលនៃការអនុវត្ត ដែលទទួលការបង្គាប់ឱ្យចូលរួមតាមបញ្ញត្តិនៃកថាខណ្ឌទី ១ តែមិនបានចូលរួមដែរ ។

៣-ក្នុងបណ្តឹងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ចំពោះកូនបំណុលទី ៣ ដែលមានករណីយកិច្ចធ្វើប្រាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤១១ (ការធ្វើប្រាក់ទុកដោយកូនបំណុលទី ៣) នៃក្រមនេះ ប្រសិនបើទទួលស្គាល់នូវការទាមទាររបស់ដើមចោទ តុលាការដែលទទួលពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ថា ការសងប្រាក់ដែលទាក់ទងនឹងការទាមទារ ត្រូវធ្វើតាមវិធីធ្វើប្រាក់ ។

**មាត្រា ៤១៣.-** ដីកាសម្រេចបង្គាប់ឱ្យលក់

១-បើសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស មានល័ក្ខខ័ណ្ឌ ឬ មានកំណត់ពេល ឬ មានការលំបាកក្នុងការប្រមូល ដោយសារភ្ជាប់នឹងតាវកាលិកតប ឬ មានហេតុផ្សេងទៀត តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុលនោះ ដោយវិធីដែលកំណត់ដោយតុលាការអនុវត្ត ហើយឱ្យយកប្រាក់ដែលបានមកពីការលក់នោះ ទៅឱ្យតុលាការអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។

២-ក្នុងករណីដែលចេញដីកាសម្រេចតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកូនបំណុលនៃការអនុវត្តនៅបរទេស ឬ មិនដឹងលំនៅឋានកូនបំណុលនោះ ។

៣-ប្រសិនបើយល់ឃើញថា ប្រាក់ដែលបានមកពីការលក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូសបាននោះ ក្រោយពីបានសងបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត ព្រមទាំងសងសោហ៊ុយសម្រាប់នីតិវិធី ហើយមិនសល់ទេនោះ តុលាការអនុវត្តមិនអាចចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះឡើយ ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៥-ដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មិនបង្កើតអានុភាពឡើយ បើដីកាសម្រេចនោះ មិនទាន់ចូលជាស្ថាពរ ។

៦-ក្នុងករណីដែលចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើយល់ឃើញថាចាំបាច់ តុលាការអនុវត្តអាចជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យ

ធ្វើការវាយតម្លៃសិទ្ធិលើបំណុលបាន ។

៧-អាជ្ញាសាលាមិនអាចលក់សិទ្ធិលើបំណុលបានឡើយ ប្រសិនបើប្រាក់ដែលបានមកពីការលក់សិទ្ធិលើបំណុលនោះ ក្រោយពីបានសងបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត ព្រមទាំងសងសោហ៊ុយសម្រាប់នីតិវិធី ហើយមិនសល់ទេនោះ ។

៨-ចំពោះការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលនៃការអនុវត្តមិនអាចធ្វើសំណើទិញបានឡើយ ។

៩-បើបានលក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស អាជ្ញាសាលាត្រូវជូនដំណឹងអំពីអនុប្បទាន ដោយលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្លាក់ ចំពោះកូនបំណុលទី ៣ ជំនួសកូនបំណុលនៃការអនុវត្ត ។

១០-បើបានបញ្ចប់ការលក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសិទ្ធិលើបំណុលដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១០ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) នៃក្រមនេះ តុលាការត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត សម្រាប់អ្នកទិញដែលបានទទួលសិទ្ធិលើបំណុលនោះ ហើយផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចលុបនូវការចុះបញ្ជីដែលបានធ្វើតាមបញ្ញត្តិនៃកថា-ខណ្ឌទី ១០ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) តាមពាក្យសុំរបស់អ្នកទិញ ។

**មាត្រា ៤១៤.–** ការអនុវត្តដីកាសម្រេចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ

១-ម្ចាស់បំណុលដែលរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ អាចទាមទារឱ្យកូនបំណុលទី ៣ ប្រគល់ចលនវត្ថុនោះ ទៅអាជ្ញាសាលាដែលទទួលពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន បើអំឡុងពេល ១ (មួយ) សប្តាហ៍ បានកន្លងហួស ដោយគិតពីថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត ។

២-ពេលដែលទទួលការប្រគល់ចលនវត្ថុ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះតាមវិធីលក់ចលនវត្ថុ ហើយត្រូវប្រគល់ប្រាក់ដែលបានមកពីការលក់នោះទៅតុលាការអនុវត្ត ។

**មាត្រា ៤១៥.–** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក

ម្ចាស់បំណុលដែលត្រូវទទួលចំណែក គឺម្ចាស់បំណុលដែលបានអនុវត្តការរឹបអូស ឬ

ការរឹបអូសជាបណ្ដោះអាសន្ន ឬ ទាមទារឱ្យចែកចំណែក មុនពេលដែលបានកំណត់ខាងក្រោមនេះ ៖

ក-ពេលដែលកូនបំណុលទី ៣ បានធ្វើការធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃមាត្រា ៤១១ (ការធ្វើប្រាក់ទុកដោយកូនបំណុលទី ៣) នៃក្រមនេះ ។

ខ-ពេលដែលពាក្យបណ្ដឹងទាមទារប្រមូលបំណុលត្រូវបានបញ្ជូនទៅកូនបំណុលទី ៣ ។

គ-ពេលដែលអាជ្ញាសាលាបានទទួលប្រាក់ពីការលក់តាមដីកាសម្រេចបង្គាប់ឱ្យលក់ ។

ឃ-ពេលអាជ្ញាសាលាបានទទួលការប្រគល់ចលនវត្ថុ ក្នុងករណីរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ។

**មាត្រា ៤១៦.-** ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេង ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និង សិទ្ធិលើបំណុល ត្រូវអនុវត្តតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល លើកលែងតែមានបញ្ញត្តិពិសេស ។

## ផ្នែកទី ៤
## ការអនុវត្តចំពោះអចលនវត្ថុ

### កថាភាគទី ១
### កម្មវត្ថុនៃការអនុវត្តចំពោះអចលនវត្ថុ ស្ថាប័នអនុវត្ត វិធីអនុវត្ត វិធីរឹបអូស មធ្យោបាយប្រកាសជាសាធារណៈ និង ការចាត់ចែងការរក្សាការពារ

**មាត្រា ៤១៧.-** កម្មវត្ថុ និងវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

១-នៅផ្នែកទី ៤ នេះ អចលនវត្ថុសំដៅទៅលើដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ អាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍និងផលុបភោគដែលត្រូវបានចុះបញ្ជី និង ចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម ។

២-ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ ។

៣-ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវភ្ជាប់ជាមួយឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និង ឯកសារខាងក្រោមនេះ :

ក-ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជី ថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

ខ-ចំពោះដីដែលមិនបានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៤១៨.-** តុលាការអនុវត្ត

ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ តុលាការដែលបានកំណត់ខាងក្រោមនេះ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ច :

ក-បើយកដី ឬ អាគារដែលបានចុះបញ្ជី ជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនោះ ។

ខ-បើយកចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ លើអាគារដែលបានចុះបញ្ជី ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគដែលបានចុះបញ្ជី ឬ ចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួមជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវចុះបញ្ជី ។

**មាត្រា ៤១៩.-** ដីកាសម្រេចចាប់ផ្ដើម ជាអាទិ៍

១-នៅពេលចាប់ផ្ដើមនីតិវិធីនៃការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ហើយត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុ ដើម្បីម្ចាស់បំណុលនៃការអនុវត្ត ក្នុងដីកាសម្រេចចាប់ផ្ដើមនេះ ។

២-ដីកាសម្រេចចាប់ផ្ដើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៣-ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៤២០.-** ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ជាអាទិ៍

១-បើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានចេញ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះជាបន្ទាន់ ។

២-បើបានធ្វើការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើការផ្ទុកផ្ដាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ស្ថាប័នដែលមានសមត្ថកិច្ចត្រូវផ្ញើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី ។

**មាត្រា ៤២១.-** អានុភាពនៃការរឹបអូស

១-អានុភាពនៃការរឹបអូសអចលនវត្ថុ មានទៅលើវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ និងជាផ្នែកមួយនៃអចលនវត្ថុនោះ ព្រមទាំងវត្ថុចំណុះនិងសិទ្ធិចំណុះនៃអចលនវត្ថុនោះ ។

២-អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានបញ្ជូន ទៅកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូស ត្រូវបានធ្វើនៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្ដើមនោះ អានុភាពនោះនឹងកើតឡើងនៅពេលបានចុះបញ្ជី ។

៣-ការរឹបអូសពុំត្រូវរារាំងកូនបំណុលនៃការអនុវត្តក្នុងការប្រើប្រាស់ ឬ អាស្រ័យផលពីអចលនវត្ថុ តាមវិធីប្រើធម្មតាឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ ត្រូវបានរឹបអូស ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) និង ករណីដែលការចាត់ចែងរក្សាការពារត្រូវបានបង្គាប់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤២៩ (ការចាត់ចែងការរក្សាការពារ) នៃក្រមនេះ ។

**មាត្រា ៤២២.-** ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ

១-ក្នុងករណីដែលអានុភាពនៃការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ បានកើតឡើង តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយគិតពិចារណានូវអំឡុងពេលចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ

លើកលែងតែករណីដែលបានចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រួតគ្នា ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) នៃក្រមនេះ ។

២-នៅពេលដែលពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកត្រូវបានកំណត់ តុលាការអនុវត្តត្រូវប្រកាសជាសាធារណៈអំពីការណ៍ដែលដីកាសម្រេចចាប់ផ្ដើមត្រូវបានចេញ និង អំពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ហើយត្រូវដាស់តឿនឱ្យជនដែលបានកំណត់ខាងក្រោមនេះ រាយការណ៍ទៅតុលាការអនុវត្ត អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុល និង មូលហេតុនិងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនោះ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក:

ក-ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំដំបូងចំពោះអចលនវត្ថុនោះ ។

ខ-ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវបានចុះបញ្ជី នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំដំបូង ចំពោះអចលនវត្ថុនោះ ។

គ-ស្ថាប័នដែលមានសមត្ថកិច្ចលើពន្ធដារ ឬ អាករសាធារណៈផ្សេងទៀត ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ តុលាការអនុវត្តត្រូវដាស់តឿនចំពោះជនដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខណ្ឌទី ២ អំពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ:

ក-ការរាយការណ៍អំពីអត្ថិភាព ឬ នត្ថិភាពនៃឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

ខ-កិច្ចដែលត្រូវដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ក្នុងករណីដែលមានឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ ។

៤-បើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្តអាចផ្លាស់ប្ដូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកបាន ។

៥-បើបានផ្លាស់ប្ដូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយ

យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ តុលាការអនុវត្តត្រូវប្រកាសជាសាធារណៈអំពីការផ្លាស់ប្តូរនោះ ។

**មាត្រា ៤២៣.–** ករណីយកិច្ចរបស់ជនដែលត្រូវបានដាស់តឿនក្នុងការរាយការណ៍អំពីសិទ្ធិលើបំណុល

១-ជនដែលបានកំណត់នៅក្នុងចំណុច ក ខ ឬ គ នៃកថាខណ្ឌទី ២ មាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្តូរពេលកំណត់នោះ) នៃក្រមនេះ ដែលត្រូវបានដាស់តឿន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ ទី ៣ នៃមាត្រា ៤២២ នោះ ត្រូវរាយការណ៍អំពីចំណុចដែលបានកំណត់នៅក្នុងសេចក្តីដាស់តឿននោះ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

២-បើមានការផ្លាស់ប្តូរចំនួនប្រាក់ដើមនៃសិទ្ធិលើបំណុល ដែលទាក់ទងនឹងសេចក្តីរាយការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ជនដែលបានធ្វើសេចក្តីរាយ-ការណ៍នោះ ត្រូវរាយការណ៍អំពីការផ្លាស់ប្តូរនោះ ។

៣-បើជនដែលត្រូវរាយការណ៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ពុំបានធ្វើសេចក្តីរាយការណ៍នោះ ឬ បានធ្វើសេចក្តីរាយការណ៍មិនពិត ដោយចេតនា ឬ ដោយមានកំហុស ជននោះត្រូវទទួលខុសត្រូវសងការខូចខាតដែលបានកើតឡើងដោយសារហេតុនោះ ។

**មាត្រា ៤២៤.–** ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា

១-បើមានពាក្យសុំឱ្យអនុវត្តដោយបង្ខំថ្មីទៀត ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានសម្រេចរួចហើយ ហើយបើទទួលស្គាល់ពាក្យសុំនោះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំថ្មីទៀត ។ ក្នុងករណីនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន ។

២-បើពាក្យសុំឱ្យលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន ត្រូវបានដក ឬ នីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមមុន ត្រូវបានលុបចោល តុលាការអនុវត្តត្រូវបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយ

បង្ខំក្រោយ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយនោះ ផ្អែកលើពាក្យសុំដែលបានដាក់ក្រោយពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកជាថ្មី ។ ក្នុងករណីនេះ តុលាការអនុវត្តមិនចាំបាច់ដាស់តឿន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ) ចំពោះជនដែលបានធ្វើសេចក្ដីរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤២៣ (ករណីយកិច្ចរបស់ជនដែលត្រូវបានដាស់តឿនក្នុងការរាយការណ៍អំពីសិទ្ធិលើបំណុល) នៃក្រមនេះឡើយ ។

៤-បើនីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុនត្រូវបានផ្អាក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមក្រោយ ។ ក្នុងករណីនេះ តុលាការអនុវត្តអាចចេញដីកាសម្រេចបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ក្រោយដែលផ្អែកលើពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលបានធ្វើឡើងនៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកតាមពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការផ្លាស់ប្ដូរនឹងកើតឡើងចំពោះចំណុចដែលបានកំណត់ពីចំណុចទី ១ ដល់ចំណុចទី ៣ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនេះ បើការលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមមុនត្រូវបានលុបចោល ។

៥-បើមានដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៦-ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៤២៥.-** ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ

បញ្ញត្តិចាប់ពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៣ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានចេញរួចហើយ ។

**មាត្រា ៤២៦.-** ការទាមទារឱ្យចែកចំណែក

១-ជនដែលបានកំណត់ខាងក្រោមនេះ អាចទាមទារឱ្យចែកចំណែកបាន :

ក-ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលអាចអនុវត្តដោយបង្ខំបាន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស ដែលនឹងបន្តអត្ថិ-ភាព ក្រោយការលក់អចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនេះ ។

ខ-ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសបណ្ដោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ។

គ-ម្ចាស់បំណុលដែលបានបញ្ជាក់ដោយឯកសារថា មានឯកសិទ្ធិទូទៅ ។

២-ការទាមទារឱ្យចែកចំណែកត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរដោយសរសេរនូវមូលហេតុ និង ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដោយរួមបញ្ចូលទាំងការប្រាក់ និង សិទ្ធិលើបំណុលបន្ទាប់បន្សំឯទៀត ។

៣-បើមានការទាមទារឱ្យចែកចំណែក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ។

៤-ចំពោះដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែក អាចប្ដឹងជំទាស់បាន ។

**មាត្រា ៤២៧.-** ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ជាអាទិ៍នៃអចលនវត្ថុ

បើមានភាពច្បាស់លាស់អំពីស្ថានភាពដែលបានបាត់បង់អចលនវត្ថុ ឬ ស្ថានភាពផ្សេងដែលរារាំងការផ្ទេរអចលនវត្ថុដោយការលក់ តុលាការអនុវត្តត្រូវលុបចោលនីតិវិធី

នៃការលក់ដោយបង្ខំ ។

**មាត្រា ៤២៨.–** ការផ្អាកផ្អាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស

១-បើពាក្យសុំឱ្យលក់ដោយបង្ខំត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ បានកើតឡើង ក្រឡាបញ្ជីត្រូវផ្អាកផ្អាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចលុបការចុះបញ្ជីអំពីការរឹបអូស ដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះ ។

២-សោហ៊ុយចាំបាច់សម្រាប់ការផ្អាកផ្អាក់ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដកពាក្យសុំចេញ ឬ ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចលុបចោលនោះ ។

**មាត្រា ៤២៩.–** ការចាត់ចែងការរក្សាការពារ

១-ប្រសិនបើកូនបំណុល ឬ អ្នកកាន់កាប់អចលនវត្ថុបានប្រព្រឹត្តអំពើដែលធ្វើឱ្យតម្លៃអចលនវត្ថុចុះថយគួរឱ្យកត់សំគាល់ ឬ ធ្វើឱ្យមានការលំបាកដល់ការលក់ ឬ ការប្រគល់អចលនវត្ថុ ឬ បើមានការបារម្ភថា អ្នកនោះនឹងប្រព្រឹត្តអំពើខាងលើនេះ តុលាការអនុវត្តអាចហាមឃាត់ជនដែលបានប្រព្រឹត្តអំពើទាំងនេះ ឬ ជនដែលត្រូវគេមានការបារម្ភថា នឹងប្រព្រឹត្តអំពើទាំងនេះ មិនឱ្យប្រព្រឹត្តអំពើនោះ ឬ បង្គាប់ឱ្យជននោះធ្វើសកម្មភាពណាមួយជាកំណត់ ឬ បង្គាប់ឱ្យជននោះលះបង់ការកាន់កាប់អចលនវត្ថុហើយឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុនោះបាន ដោយដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ដោយឱ្យដាក់ ឬ មិនឱ្យដាក់ប្រាតិភោគ ។ ប៉ុន្តែ មានតែករណីដែលអ្នកកាន់កាប់អចលនវត្ថុ មិនអាចយកមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់ តតាំងនឹងអ្នកទិញទេ ទើបអាចបង្គាប់ឱ្យជននោះប្រគល់អចលនវត្ថុឱ្យអាជ្ញាសាលា ដើម្បីឱ្យថែរក្សាគ្រប់គ្រងបាន ។

២-ក្នុងករណីចេញដីកាសម្រេចដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ចំពោះអ្នកកាន់កាប់ផ្សេងពីកូនបំណុល តុលាការអនុវត្តត្រូវសួរជននោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានភាពបន្ទាន់ចាំបាច់ត្រូវចេញដីកាសម្រេចនោះ ។

៣-បើស្ថានភាពមានការប្រែប្រួល តុលាការអនុវត្តអាចលុបចោល ឬ កែប្រែដីកា

សម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តាមពាក្យសុំបាន ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះជានៅមុនពេលដែលត្រូវបានបញ្ជូនទៅភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ។

៦-សោហ៊ុយចាំបាច់សម្រាប់ពាក្យសុំ ឬ ការអនុវត្តដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុនោះ ។

## កថាភាគទី ២
## លំនាំខណ្ឌនៃការលក់

**មាត្រា ៤៣០.–** ការវាយតម្លៃ

១-តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យវាយតម្លៃអចលនវត្ថុដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្នឯទៀត ។

២-ដើម្បីសុំជំនួយពីអាជ្ញាសាលាយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អ្នកវាយតម្លៃត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត ។

៣-នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬ អាចសួរសំណួរ ឬ ទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន ។

៤-បើមានភាពចាំបាច់ អាជ្ញាសាលាដែលអ្នកវាយតម្លៃបានសុំជាជំនួយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទបាន នៅក្នុងករណីដែលអ្នកវាយតម្លៃចូលទៅកាន់អចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ។

៥-អ្នកវាយតម្លៃត្រូវដាក់ជូនតុលាការអនុវត្តជាលាយល័ក្ខណ៍អក្សរ នូវលទ្ធផលនៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និង ការវាយតម្លៃអចលនវត្ថុនោះ ។

**មាត្រា ៤៣១.–** សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់

១-ក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួលដែលមានលើអចលនវត្ថុ ចំពោះសិទ្ធិដែលអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវបន្តអត្ថិភាពនៅក្រោយការលក់ ។

២-សិទ្ធិលើអចលនវត្ថុ ក្រៅពីសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរលត់ដោយសារការលក់ ។

៣-ការរឹបអូស ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ដែលពាក់ព័ន្ធនឹងអចលន-វត្ថុ និង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលពុំអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានធ្វើការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបាត់បង់អានុភាព ដោយសារការលក់ ។

៤-មុនពេលដែលតម្លៃលក់អប្បបរមាត្រូវបានកំណត់ បើបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍បានរាយការណ៍ថា ការព្រមព្រៀងដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវបានធ្វើឡើង ការប្រែប្រួលនៃសិទ្ធិលើអចលនវត្ថុ ដោយការលក់ ត្រូវអាស្រ័យតាមការព្រមព្រៀងនោះ ។

**មាត្រា ៤៣២.–** ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍

១-តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ដោយផ្អែកលើការវាយតម្លៃរបស់អ្នកវាយតម្លៃ ។

២-បើយល់ឃើញថាចាំបាច់ តុលាការអនុវត្តអាចផ្លាស់ប្ដូរតម្លៃលក់អប្បបរមាបាន ។

**មាត្រា ៤៣៣.–** ការលក់សរុប

បើយល់ឃើញថាជាការសមរម្យក្នុងការឱ្យអ្នកទិញណាមួយ ទិញសរុបតែម្ដងនូវអចល-នវត្ថុ ជាមួយនឹងអចលនវត្ថុផ្សេងទៀត ដោយយោងតាមទំនាក់ទំនងគ្នាក្នុងការប្រើប្រាស់ ទោះបីជាអចលនវត្ថុនីមួយៗនោះមានម្ចាស់បំណុលនៃការអនុវត្តផ្សេងគ្នា ឬ កូនបំណុល

នៃការអនុវត្តផ្សេងគ្នាក៏ដោយ ក៏តុលាការអនុវត្តអាចកំណត់ការលក់អចលនវត្ថុទាំងនោះសរុបតែម្តងបាន ។ ប៉ុន្តែ ក្នុងករណីដែលមានលទ្ធភាពអាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្តនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន ដោយការលក់អចលនវត្ថុណាមួយក្នុងតម្លៃលក់អប្បបរមា ក្នុងចំណោមអចលនវត្ថុច្រើន ដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានសម្រេច តាមពាក្យសុំតែមួយនោះ តុលាការអនុវត្តអាចកំណត់ការលក់សរុបតែម្តងបាន លុះត្រាតែមានការយល់ព្រមពីកូនបំណុលនៃការអនុវត្ត ។

**មាត្រា ៤៣៤.–** ឯកសារលំអិតអំពីវត្ថុ

១-តុលាការអនុវត្តត្រូវធ្វើឯកសារលំអិតអំពីវត្ថុ ហើយត្រូវទុកឯកសារចម្លងនៃឯកសារលំអិតអំពីវត្ថុនោះ នៅតុលាការអនុវត្ត ជាមួយគ្នានឹងឯកសារចម្លងនៃរបាយការណ៍វាយតម្លៃ ដើម្បីផ្តល់ឱ្យសាធារណជនមើល ។ ឯកសារលំអិតអំពីវត្ថុ ត្រូវសរសេរចំណុចដូចខាងក្រោមនេះ :

ក-សញ្ញាណនៃអចលនវត្ថុ ។

ខ-សិទ្ធិលើអចលនវត្ថុដែលនឹងបន្តអត្ថិភាពក្រោយការលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនេះ និង ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលមិនបាត់បង់អានុភាពដោយការលក់ ។

២-បើយល់ឃើញថាចាំបាច់ ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តអាចបង្គាប់ឱ្យអាជ្ញាសាលាស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ ដូចជាសណ្ឋាននៃអចលនវត្ថុ ស្ថានភាពនៃការកាន់កាប់ រចនាសម្ព័ន្ធនៃអាគារបើមានអាគារ ឬ បើកម្មវត្ថុនៃការអនុវត្តគឺជាអាគារ ជាអាទិ៍ ហើយរាយការណ៍លទ្ធផលនៃការស្រាវជ្រាវនោះជាលាយល័ក្ខណ៍អក្សរ ។

៣-នៅពេលធ្វើការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ តាមការបង្គាប់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាជ្ញាសាលាមានសិទ្ធិអំណាចដូចនឹងសិទ្ធិអំណាចរបស់អ្នកវាយតម្លៃដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៤៣០ (ការវាយតម្លៃ) នៃក្រមនេះ ។ បើមានភាពចាំបាច់ អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់

ដើម្បីបើកទ្វារដែលបិទបាន ។

**មាត្រា ៤៣៥.–** វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់

១-ប្រសិនបើយល់ឃើញថា តម្លៃលក់អប្បបរមានៃអចលនវត្ថុ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ គ្មានលទ្ធភាពសល់ទេនោះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២-តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត បើម្ចាស់បំណុលនៃការអនុវត្ត មិនបានធ្វើសកម្មភាពដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-សំណើថា ខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្នើសុំ ក្នុងករណីដែលគ្មានសំណើទិញក្នុងតម្លៃដែលឡើងដល់តម្លៃស្នើសុំនោះ ។ ប៉ុន្តែ សំណើនោះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ហើយតម្លៃស្នើសុំនោះ ត្រូវលើសពីតម្លៃប៉ាន់ប្រមាណនៃសោហ៊ុយសម្រាប់នីតិវិធី ។

ខ-ការដាក់ប្រាក់ធានាដែលស្មើនឹងតម្លៃស្នើសុំដែលបានកំណត់នៅក្នុងចំណុច ក ខាងលើនេះ ។

## កថាភាគទី ៣
## វិធីលក់

**មាត្រា ៤៣៦.–** វិធីលក់ ជាអាទិ៍

១-ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

២-តុលាការអនុវត្តអាចកំណត់វិធីលក់ ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ តែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

៣-ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់

តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និង ទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុ-វត្តការលក់នោះ ។

៤-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់ ។

៥-បញ្ញត្តិនៃមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។

**មាត្រា ៤៣៧.–** ការធានាលើសំណើទិញ

១-ជនដែលបម្រុងនឹងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងចំនួន ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការអនុវត្តអាចកំណត់ចំនួននៃប្រាក់ធានា លើសពីចំនួននេះបាន ។

២-ប្រសិនបើមានសំណើទិញពីបុគ្គលក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តុលាការអនុវត្តត្រូវសងភ្ជាមនូវប្រាក់ធានាដែលបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រោយពេលបញ្ចប់ការលក់ដែលធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៣៦ (វិធីលក់ជាអាទិ៍) នៃក្រមនេះ ។

**មាត្រា ៤៣៨.–** ការហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើសំណើទិញ

កូនបំណុលនៃការអនុវត្តពុំអាចធ្វើសំណើទិញបានឡើយ ។

**មាត្រា ៤៣៩.–** ការកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ជាអាទិ៍

១-បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់បានបញ្ចប់ អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្រោយពេលបានកំណត់អ្នកស្នើសុំទិញ ក្នុងតម្លៃអតិបរមា និង បានប្រកាសនូវនាម ឬ នាមករណ៍របស់អ្នកទិញ និង ថ្លៃលក់ឡាយឡុងនោះ ។

២-បើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា

មានច្រើននាក់ អាជ្ញាសាលាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយឱ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត ។ ក្នុងករណីនេះ អ្នកដេញថ្លៃមិនអាចដេញថ្លៃដោយតម្លៃតិចជាងតម្លៃដែលខ្លួនដេញមុនបានឡើយ ។

៣-បើអ្នកដេញថ្លៃដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនដេញថ្លៃម្តងទៀតទេ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ត្រូវបានកំណត់ដោយការចាប់ឆ្នោត ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដេញថ្លៃដោយស្រោមសំបុត្រដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា មានច្រើននាក់ នៅក្នុងការលក់ឡាយឡុងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នោះ ។

៤-បើបានអនុវត្តការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ហើយ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ដែលសរសេរនូវចំណុចដូចខាងក្រោម ហើយត្រូវដាក់ទៅតុលាការអនុវត្តភ្លាមៈ

ក-សញ្ញាណនៃអចលនវត្ថុ ។

ខ-កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

គ-សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និង អ្នកតំណាង ។

ឃ-តម្លៃទិញរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

ង-ហេតុការណ៍នោះ និង ស្ថានភាព បើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

ច-មូលហេតុ និង វិធានការដែលបានចាត់ធ្វើ បើបានចាត់វិធានការដែលបានកំណត់នៅក្នុងមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ។

៥-អាជ្ញាសាលាត្រូវឱ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកតំណាង ចុះហត្ថលេខាលើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

**មាត្រា ៤៤០.-** កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់

១-តុលាការអនុវត្តត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ហើយត្រូវប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ។

២-នៅពេលដែលបានកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ តុលា-

ការអនុវត្តត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនោះ ទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ៤៤១.–** ការថ្លែងយោបល់អំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់អចលនវត្ថុ អាចថ្លែងយោបល់អំពីហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ២ មាត្រា ៤៤២ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ដែលបណ្តាលឱ្យមានឥទ្ធិពលដល់សិទ្ធិរបស់ខ្លួន នៅក្នុងកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់បាន ។

**មាត្រា ៤៤២.–** ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១-លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ។

២-តុលាការអនុវត្តត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ បើទទួលស្គាល់ថា មានហេតុណាមួយដូចកំណត់ក្នុងចំណុចខាងក្រោមនេះ :

ក-មិនត្រូវចាប់ផ្តើម ឬ បន្តនីតិវិធីនៃការលក់ដោយបង្ខំ ។

ខ-អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានលក្ខណសម្បត្តិ ឬ សមត្ថភាពដើម្បីទិញអចលនវត្ថុ ឬ អ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានសិទ្ធិនោះ ។

គ-មានសេចក្តីស្នើសុំកុំឱ្យអនុញ្ញាតការលក់ ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៤៥ (ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលអចលនវត្ថុត្រូវបានខូចខាត) នៃក្រមនេះ ។

ឃ-មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ។

ង-មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការលក់ ។

**មាត្រា ៤៤៣.–** វិធានការក្នុងករណីលក់ហួសកម្រិត

១-ក្នុងករណីដែលបានលក់អចលនវត្ថុច្រើន បើតម្លៃស្នើសុំទិញនៃអចលនវត្ថុណាមួយ ឬ ច្រើន ក្នុងចំណោមអចលនវត្ថុទាំងអស់នោះ ត្រូវបានប៉ាន់ប្រមាណឃើញថា អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់

បានតុលាការអនុវត្តត្រូវបម្រុងទុកនូវដីកាសម្រេចអនុញ្ញាតឱ្យលក់អចលនវត្ថុផ្សេងទៀត ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើមានអចលនវត្ថុច្រើនដែលត្រូវបានប៉ាន់ប្រមាណថា តម្លៃស្នើសុំទិញនៃអចលនវត្ថុនីមួយៗនោះ អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន ឬ បើសមាយោគនៃអចលនវត្ថុមានច្រើនដែលត្រូវបានប៉ាន់ប្រមាណថា តម្លៃស្នើសុំទិញនៃសមាយោគនីមួយៗនោះ អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន តុលាការអនុវត្តត្រូវសួរយោបល់របស់កូនបំណុលនៃការអនុវត្តជាមុន អំពីអចលនវត្ថុដែលត្រូវអនុញ្ញាតឱ្យលក់ ។

៣-អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានៃអចលនវត្ថុដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ត្រូវបានបម្រុងទុក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចលុបចោលសំណើទិញនោះ ដោយជូនដំណឹងទៅតុលាការអនុវត្តបាន ។

៤-បើថ្លៃលក់ត្រូវបានបង់ចំពោះអចលនវត្ថុដែលមានដីកាសម្រេចអនុញ្ញាតឱ្យលក់ តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងអចលន-វត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។

**មាត្រា ៤៤៤.–** បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១-ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចប្តឹងជំទាស់បាន លុះត្រាតែក្នុងករណីដែលដីកាសម្រេចនោះបណ្តាលឱ្យមានខូចខាតដល់សិទ្ធិរបស់ខ្លួន ។

២-បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់ ត្រូវយកហេតុដូចបានកំណត់ក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ នៃមាត្រា ៤៤២ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ឬ កំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ មកធ្វើជាមូលហេតុ ។

៣-បើទទួលស្គាល់ថាចាំបាច់ តុលាការនៃបណ្តឹងជំទាស់ អាចកំណត់ភាគីម្ខាងទៀតនៃម្ចាស់បណ្តឹងជំទាស់បាន ។

៤-ដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់នេះ ពុំមានអានុភាពឡើយ បើមិន

ទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៤៥.-** ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលអចលនវត្ថុត្រូវបានខូចខាត

១-ក្នុងករណីដែលអចលនវត្ថុបានទទួលការខូចខាតធ្ងន់ធ្ងរ នៅក្រោយពេលធ្វើសំណើទិញដោយសារគ្រោះធម្មជាតិ ឬ ដោយសារមូលហេតុផ្សេងទៀតដែលមិនមែនជាបន្ទុករបស់ខ្លួន អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញអាចស្នើសុំទៅតុលាការអនុវត្តកុំឱ្យអនុញ្ញាតការលក់ ប្រសិនបើនៅមុនពេលចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ អាចដាក់ពាក្យសុំទៅតុលាការអនុវត្តឱ្យលុបចោលដីកាសម្រេចនោះ នៅមុនពេលបង់ប្រាក់បាន ប្រសិនបើនៅក្រោយពេលចេញដីកាសម្រេចអនុញ្ញាតការលក់ហើយ ។

២-ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៣-ដីកាសម្រេចលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៤៦.-** ការដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលមានសំណើទិញ

ដើម្បីដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលដែលមានសំណើទិញហើយ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលការយល់ព្រមពីសំណាក់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ។

## កថាភាគទី ៤
## អានុភាពនៃការលក់

**មាត្រា ៤៤៧.-** ការបង់ថ្លៃលក់

១-បើដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត នៅមុនពេលដែលតុលាការអនុវត្តបានកំណត់ ។ ពេលកំណត់នេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល ១ (មួយ) ខែចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ បានចូលជាស្ថាពរ ។

២-ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើសំណើទិញ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់ ។

៣-បើអ្នកទិញគឺជាម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកពីប្រាក់លក់ អ្នកទិញនោះអាចបង់ថ្លៃលក់ ដោយដកនូវចំនួនទឹកប្រាក់ដែលខ្លួនត្រូវទទួលពីការចែកចំណែកនៅកាលបរិច្ឆេទនៃការចែកចំណែកបាន ដោយស្នើសុំទៅតុលាការអនុវត្ត នៅមុនពេលបញ្ចប់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ។ ក្នុងករណីនេះ បើមានសេចក្តីថ្លែងតវ៉ាអំពីចំនួនប្រាក់នៃការចែកចំណែកដែលអ្នកទិញត្រូវទទួល អ្នកទិញត្រូវបង់ចំនួនប្រាក់ដែលស្មើនឹងភាគដែលមានការតវ៉ានោះជាបន្ទាន់ ។

៤-អ្នកទិញធ្វើលទ្ធកម្មនូវអចលនវត្ថុ នៅពេលដែលខ្លួនបានបង់ថ្លៃលក់ហើយ ។

**មាត្រា ៤៤៨.–** ការផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយការបង់ថ្លៃលក់

១-ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី និង លុបការចុះបញ្ជីនូវចំណុចដូចកំណត់ខាងក្រោមនេះ :

ក-ការចុះបញ្ជី អំពីការផ្ទេរសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

ខ-ការលុបការចុះបញ្ជី អំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬសិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

គ-ការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្នដែលបានបាត់បង់អានុភាពដោយការលក់ ។

ឃ-ការលុបការចុះបញ្ជី អំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន ។

២-ដើម្បីផ្ទុកផ្តាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឱ្យលក់ ជាមួយនឹងលិខិតផ្ទុកផ្តាក់នោះ ។

៣-សោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្តាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់អ្នកទិញ ។

**មាត្រា ៤៤៩.–** ការទទួលខុសត្រូវរបស់អ្នកទិញ

១-ចំពោះសិទ្ធិប្រាតិភោគដែលនឹងបន្តអត្ថិភាពក្រោយការលក់ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់

ក្រោយការលក់) នៃក្រមនេះ បើកូនបំណុលនៃការអនុវត្ត ជាកូនបំណុលនៃសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគទាំងនេះ អ្នកទិញត្រូវទទួលខុសត្រូវក្នុងការសង នូវសិទ្ធិលើបំណុលនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសិទ្ធិប្រាតិភោគ ដែលនឹងបន្តអត្ថិភាពក្រោយការលក់ ជាហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អ្នកទិញត្រូវ ទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានា បំណុលអណ្ដែតនោះ ក្នុងកម្រិតនៃចំនួនអតិបរមា ។

**មាត្រា ៤៥០.–** ដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ

១-តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នក កាន់កាប់អចលនវត្ថុ ប្រគល់អចលនវត្ថុនោះទៅឱ្យអ្នកទិញ តាមពាក្យសុំរបស់អ្នកទិញដែល បានបង់ថ្លៃលក់ហើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលត្រូវ បានទទួលស្គាល់ថា កាន់កាប់អចលនវត្ថុនោះ ដោយផ្អែកលើសិទ្ធិដែលអាចតតាំងជាមួយ នឹងអ្នកទិញ ដោយយោងទៅតាមសំណុំរឿងនៃការអនុវត្តដោយបង្ខំ ។

២-បើហួសអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលអ្នកទិញបានបង់ថ្លៃលក់ ហើយ អ្នកទិញនោះ ពុំអាចដាក់ពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានទេ ។

៣-ក្នុងករណីដែលបានចេញដីកាសម្រេចចំពោះអ្នកកាន់កាប់ ក្រៅពីកូនបំណុលនៃ ការអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរជននោះ ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះ អាចប្ដឹងជំទាស់បាន ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុ-ភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៥១.–** អានុភាពនៃការមិនបង់ថ្លៃលក់

១-បើអ្នកទិញមិនបានបង់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ នឹងបាត់បង់ អានុភាព ។ ក្នុងករណីនេះ អ្នកទិញមិនអាចទាមទារឱ្យសងទឹកប្រាក់ដែលខ្លួនបានដាក់ជា

ការធានាលើសំណើទិញបានទេ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្ត ត្រូវលក់ដោយបង្ហិសាជាថ្មី ។

៣-ក្នុងការលក់ដោយបង្ហិតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អ្នកទិញដែល បានកំណត់នៅក្នុងកថាខណ្ឌទី ១ ពុំអាចធ្វើសំណើទិញបានឡើយ ។

**មាត្រា ៤៥២.-** ថ្លៃលក់

១-ប្រាក់ដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ជាថ្លៃលក់សម្រាប់ការចែកចំណែក :

ក-ថ្លៃលក់អចលនវត្ថុ ។

ខ-ទឹកប្រាក់ដែលអ្នកទិញពុំអាចទាមទារឱ្យសងមកវិញបាន តាមបញ្ញត្តិនៃវាក្យ-ខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ៤៥១ (អានុភាពនៃការមិនបង់ថ្លៃលក់) នៃក្រមនេះ ។

២-ក្នុងករណីដែលអចលនវត្ថុត្រូវបានលក់ឱ្យស្រេចតែម្តង ដោយយោងតាមបញ្ញត្តិ នៃមាត្រា ៤៣៣ (ការលក់សរុប) នៃក្រមនេះ បើចាំបាច់ត្រូវកំណត់ចំនួនថ្លៃលក់នៃអចល-នវត្ថុនីមួយៗ ចំនួននោះចាត់ជាចំនួនដែលចែកចំនួនសរុបនៃថ្លៃលក់ តាមសមាមាត្រនៃតម្លៃ លក់អប្បបរមានៃអចលនវត្ថុនីមួយៗ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះ បន្ទុកនៃសោហ៊ុយសម្រាប់ការអនុវត្តចំពោះអចលនវត្ថុនីមួយៗ ។

**មាត្រា ៤៥៣.-** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក

ម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកថ្លៃលក់ គឺជាបុគ្គលដែលកំណត់ដូច ខាងក្រោមនេះ :

ក-ម្ចាស់បំណុលដែលបានដាក់ពាក្យសុំការលក់ដោយបង្ហិ ឬ ការលក់ដោយបង្ហិ ដែលជាការអនុវត្តឯកសិទ្ធិទូទៅ រហូតដល់កំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យ ចែកចំណែក ។

ខ-ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលកំណត់ចុង ក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

គ-ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន មុនការចុះ បញ្ជីអំពីការរឹបអូសដែលជាមូលដ្ឋាននៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ហិជាដំបូង ។

# ផ្នែកទី ៥
# ការអនុវត្តដោយបង្ខំចំពោះនាវា

**មាត្រា ៤៥៤.–** អត្ថន័យនៃនាវា ជាអាទិ៍

១-នៅក្នុងគន្ថីទី ៦ នេះ និង គន្ថីទី ៧ នាវា សំដៅទៅលើជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និង លើសពី ២០ (ម្ភៃ) តោន ទោះជាមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ និង ជលយានដែលមានចំណុះសរុបជាតោន ក្រោម ២០ (ម្ភៃ) តោន ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ។

២-នៅក្នុងគន្ថីនេះ និង គន្ថីទី ៧ លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សំដៅទៅលើឯកសារដែលបញ្ជាក់សញ្ជាតិរបស់នាវា និង ឯកសារផ្សេងទៀតដែលចាំបាច់ដើម្បីបើកបរនាវាដោយស្របច្បាប់ ។

**មាត្រា ៤៥៥.–** ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត

១-ការអនុវត្តដោយបង្ខំចំពោះនាវា ត្រូវធ្វើដោយតុលាការអនុវត្ត តាមវិធីលក់ដោយបង្ខំ ។

២-ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា ក្រៅពីសរសេរចំណុចនីមួយៗដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) នៃក្រមនេះ ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរ អំពីទីកន្លែងដែលនាវានោះស្ថិតនៅ ព្រមទាំងឈ្មោះរបស់មេបញ្ជាការ ឬ បរិបាលនាវានោះ និង ទីកន្លែងដែលមេបញ្ជាការ ឬ បរិបាលនាវានោះនៅពេលបច្ចុប្បន្ន ។

៣-ក្នុងពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់មកជាមួយនូវឯកសារដែលកំណត់ដូចខាងក្រោមនេះ :

ក-ចំពោះនាវាកម្ពុជាដែលបានចុះបញ្ជី គឺ ឯកសារចម្លងនៃសៀវភៅចុះបញ្ជីដែលមានសេចក្តីបញ្ជាក់ ។

ខ-ចំពោះនាវាកម្ពុជាដែលមិនបានចុះបញ្ជី ឬ ជានាវាផ្សេងទៀតក្រៅពីនាវា

កម្ពុជា គឺ ឯកសារដែលបញ្ជាក់ថា នាវានោះជានាវាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៤៥៤ (អត្ថន័យនៃនាវា ជាអាទិ៍) នៃក្រមនេះ និង ឯកសារបញ្ជាក់ថា នាវានោះស្ថិតនៅជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៤៥៦.–** តុលាការអនុវត្ត

ចំពោះការអនុវត្តដោយបង្ខំចំពោះនាវា សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវាស្ថិតនៅ នៅពេលចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ មានសមត្ថកិច្ចជាតុលាការអនុវត្ត ។

**មាត្រា ៤៥៧.–** ដីកាសម្រេចចាប់ផ្ដើម ជាអាទិ៍

១-នៅពេលចាប់ផ្ដើមនីតិវិធីនៃការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ហើយត្រូវបង្គាប់ឱ្យអាជ្ញាសាលាដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវានោះ ជាអាទិ៍ មកប្រគល់ជូនតុលាការអនុវត្ត ។

២-ក្នុងដីកាសម្រេចចាប់ផ្ដើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវប្រកាស អំពីការរឹបអូសនាវានោះជាប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ហើយត្រូវហាមឃាត់កូនបំណុលនៃការអនុវត្ត ចំពោះការចេញដំណើរនៃនាវានោះ ។

៣-ដីកាសម្រេចចាប់ផ្ដើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៤-បើបានចេញដីកាសម្រេចចាប់ផ្ដើមដែលយោងទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ចំពោះនាវាកម្ពុជាដែលបានចុះបញ្ជីហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះជាបន្ទាន់ ។

៥-អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលបានធ្វើការបញ្ជូនដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូសត្រូវបានធ្វើមុនការបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ អានុភាពនោះនឹងកើតឡើងនៅពេលបានចុះបញ្ជី ។

៦-បើអាជ្ញាសាលាបានដកហូតយកលិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍ នៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ឬ នៅមុនពេលចុះបញ្ជីអំពីការរឹបអូសអានុភាពនៃការរឹបអូសនោះ កើតឡើងនៅពេលដកហូត ។

៧-ចំពោះដីកាសម្រេចលើកចោលពាក្យសុំការលក់ដោយបង្ខំនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៤៥៨.-** ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ

១-ក្នុងករណីដែលអានុភាពនៃការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ បានកើតឡើង តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

២-បើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្តអាចផ្លាស់ប្ដូរកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកនោះបាន ។

**មាត្រា ៤៥៩.-** ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំ

១-ក្នុងករណីដែលមានការបារម្ភថា នឹងមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំចំពោះនាវា បើមិនដកហូតយកលិខិតបញ្ជាក់សញ្ញាតិនាវានោះ ជាអាទិ៍ នៅមុនការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវាទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះត្រូវបានចុះបញ្ជី អាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ប្រគល់លិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលាបាន តាមពាក្យសុំ ។ បើនាវានោះពុំបានចុះបញ្ជីទេ ឬ បើមានស្ថានភាពជាបន្ទាន់ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ អាចចេញដីកាសម្រេចនេះបាន ។

២-ដើម្បីដាក់ពាក្យសុំតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង្ហាញនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ។

៣-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៤-ចំពោះដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៥-ចំពោះដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះនៅមុនពេលបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្តក៏ដោយ ក៏អាចអនុវត្តបានដែរ ។ សោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ក្នុងនីតិវិធីនៃការលក់ដោយបង្ខំ ។

៦-ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលាដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំត្រូវអនុវត្តឡើយ បើហួសអំឡុងពេល ២ (ពីរ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានជូនដំណឹងទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

៧-បើម្ចាស់បំណុលនៃការអនុវត្តមិនបានដាក់លិខិតដែលបញ្ជាក់ថា ខ្លួនបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា នៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់លិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍នោះទេ អាជ្ញាសាលាត្រូវសងលិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍នោះ ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ ។

**មាត្រា ៥៦០.-** ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍

១-បើទទួលស្គាល់ថាចាំបាច់ តុលាការអនុវត្តអាចជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រងចំពោះនាវាដែលត្រូវបានចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន ។

២-តុលាការអនុវត្តត្រូវត្រួតពិនិត្យអ្នកថែរក្សាគ្រប់គ្រង ។ អ្នកថែរក្សាគ្រប់គ្រងត្រូវបំពេញមុខនាទីរបស់ខ្លួន ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។ នៅក្នុងករណីដែលអ្នកថែរក្សាគ្រប់គ្រងបានបញ្ចប់ភារកិច្ចនោះ អ្នកនោះត្រូវរាយការណ៍អំពីការគណនានូវចំណូលចំណាយក្នុងការថែរក្សាគ្រប់គ្រងទៅតុលាការអនុវត្ត ដោយគ្មានការយឺតយ៉ាវ ។

៣-អ្នកថែរក្សាគ្រប់គ្រងអាចទទួលជាមុននូវសោហ៊ុយចាំបាច់ក្នុងការថែរក្សាគ្រប់គ្រង និង ប្រាក់បំណាច់ដែលកំណត់ ដោយដីកាសម្រេចនៃតុលាការអនុវត្តបាន ។ សោហ៊ុយដែលអ្នកថែរក្សាគ្រប់គ្រងបានចំណាយដើម្បីថែរក្សាគ្រប់គ្រងនាវា និង ប្រាក់បំណាច់ ត្រូវចាត់ជាសោហ៊ុយសម្រាប់នីតិវិធី ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៥៦១.-** ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយដាក់ប្រាក់ធានា

១-នៅក្នុងករណីដែលមានការដាក់លិខិតដូចបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ២ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត បើកូនបំណុលនៃការអនុវត្តបានដាក់ប្រាក់ធានាដែលស្មើនឹងចំនួនទឹកប្រាក់សរុបនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក និង សោហ៊ុយសម្រាប់ការអនុវត្ត នៅមុនពេលមានសំណើទិញ តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ តាមពាក្យសុំ លើកលែងតែនីតិវិធីចែកចំណែក ។ បើដាក់ប្រាក់ធានានៅមុនពេលផុតកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកវិញ ចំនួនទឹកប្រាក់ដែលកូនបំណុលនៃការអនុវត្តត្រូវដាក់ គឺចំនួនស្មើនឹងចំនួនទឹកប្រាក់សរុបនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលនោះ និង សោហ៊ុយសម្រាប់ការអនុវត្ត ។

២-បើការផ្អាកការអនុវត្តដោយការដាក់លិខិតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបាត់បង់អានុភាព តុលាការអនុវត្តត្រូវចែកចំណែកឱ្យម្ចាស់បំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះប្រាក់ធានាដែលត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ។

៣-ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៤-បញ្ញត្តិនៃមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្ដូរប្រាតិភោគ) និង មាត្រា ៧២

(សិទ្ធិរបស់អ្នកដែលទទួលការផ្តល់ប្រាតិភោគ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផង ដែរ ចំពោះការដាក់ប្រាក់ធានាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៤៦២.-** ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ

១-នៅក្នុងករណីដែលទទួលស្គាល់ថា មានភាពចាំបាច់សម្រាប់អាជីវកម្ម និង មូល ហេតុសមរម្យផ្សេងទៀត បើមានការយល់ព្រមពីម្ចាស់បំណុលនីមួយៗ និង អ្នកស្នើសុំទិញ ក្នុងតម្លៃអតិបរមា ឬ អ្នកទិញ តុលាការអនុវត្តអាចអនុញ្ញាតឱ្យនាវានោះធ្វើដំណើរបាន តាម ពាក្យសុំរបស់កូនបំណុលនៃការអនុវត្ត ។

២-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះ អាចប្តឹងជំទាស់បាន ។

៣-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះមិនមានអានុ-ភាព បើមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៦៣.-** ការផ្ទេររឿងក្តី

ក្នុងករណីដែលនាវាដែលត្រូវបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ បែរជាស្ថិតនៅទីកន្លែងផ្សេង ក្រៅពីតំបន់ដែលមានសមត្ថកិច្ច តុលាការអនុវត្តអាចផ្ទេររឿង ក្តីនោះទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ បាន ។

**មាត្រា ៤៦៤.-** ការលុបចោលនីតិវិធីលក់ដោយបង្ខំ នៅក្នុងករណីដែលពុំអាចដកហូត យកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍

បើអាជ្ញាសាលាពុំអាចដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅក្នុងអំឡុង ពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយ បង្ខំបានទេ តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីលក់ដោយបង្ខំនោះ ។

**មាត្រា ៤៦៥.-** ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយការវិនាសបាត់បង់នាវា ជាអាទិ៍

បើស្ថានភាពដែលបណ្តាលឱ្យរាំងស្ទះក្នុងការផ្ទេរនាវាដោយការលក់ មានពិតប្រាកដ ដោយសារនាវានោះត្រូវបានវិនាសបាត់បង់ ឬ ដោយមូលហេតុផ្សេងទៀត តុលាការអនុវត្ត ត្រូវលុបចោលនីតិវិធីលក់ដោយបង្ខំនោះ ។

**មាត្រា ៤៦៦.–** ការផ្អាកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស

១-បើពាក្យសុំលក់ដោយបង្ខំត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ បានកើតឡើង ក្រឡាបញ្ជីត្រូវផ្អាកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចលុបការចុះបញ្ជីអំពីការរឹបអូស ដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះ ។

២-សោហ៊ុយចាំបាច់សម្រាប់ការផ្អាកផ្តាក់ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដកពាក្យសុំចេញ ឬ ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចលុបចោលនោះ ។

**មាត្រា ៤៦៧.–** ការវាយតម្លៃ

១-តុលាការអនុវត្ត អាចជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យវាយតម្លៃនាវា បាន ។

២-ដើម្បីសុំជំនួយពីអាជ្ញាសាលាយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អ្នកវាយតម្លៃត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត ។

៣-នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅក្នុងនាវា ឬ អាចសួរសំណួរ ឬ ទាមទារឱ្យបង្ហាញឯកសារចំពោះកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់នាវានោះបាន ។

៤-បើមានភាពចាំបាច់ អាជ្ញាសាលាដែលត្រូវបានសុំជំនួយពីអ្នកវាយតម្លៃ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទបាន នៅក្នុងករណីដែលអ្នកវាយតម្លៃចូលទៅក្នុងនាវា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ។

**មាត្រា ៤៦៨.–** ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍

១-បើមានការវាយតម្លៃដោយអ្នកវាយតម្លៃ តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ដោយផ្អែកលើការវាយតម្លៃនោះ ។

២-បើយល់ឃើញថាចាំបាច់ តុលាការអនុវត្ត អាចផ្លាស់ប្តូរតម្លៃលក់អប្បបរមាបាន ។

៣-បញ្ញត្តិនៃមាត្រា ៤៣៥ (វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់)

នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តចំពោះនាវា ។

**មាត្រា ៤៦៩.-** វិធីលក់ ជាអាទិ៍

១-ការលក់នាវា ក្រៅអំពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ត្រូវអនុវត្តតាមវិធីដែលកំណត់ដោយតុលាការអនុវត្ត ។

២-ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់ថ្ងៃ ពេលវេលា និង ទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុ-វត្តការលក់នោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនាវាដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងថ្ងៃ ពេលវេលា និង ទីកន្លែងលក់ ។

៤-បញ្ញត្តិនៃមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

**មាត្រា ៤៧០.-** ការធានាលើសំណើទិញ

១-ជនដែលបម្រុងនឹងធ្វើសំណើទិញនាវា ត្រូវដាក់ប្រាក់ធានាដែលស្មើនឹង ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការអនុវត្ត អាចកំណត់ចំនួនប្រាក់ធានាលើសពី ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា នោះបាន ។

២-ប្រសិនបើមានសំណើទិញពីបុគ្គល ក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តុលា-ការអនុវត្តត្រូវសងប្រាក់ធានាដែលត្រូវបានដាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ភ្លាម ក្រោយពេលបញ្ចប់ការលក់ដែលធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៦៩ (វិធីលក់ ជាអាទិ៍) នៃក្រមនេះ ។

**មាត្រា ៤៧១.-** ការហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើសំណើទិញ

កូនបំណុលនៃការអនុវត្ត ពុំអាចធ្វើសំណើទិញបានទេ ។

**មាត្រា ៤៧២.-** កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់

១-តុលាការអនុវត្តត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ហើយត្រូវប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ។

២-នៅពេលបានកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ តុលាការអនុវត្តត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនោះ ទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ៤៧៣.-** ការថ្លែងយោបល់អំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់នាវា អាចធ្វើសេចក្ដីថ្លែងយោបល់អំពីហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ២ មាត្រា ៤៧៤ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ហើយដែលបណ្ដាលឱ្យមានឥទ្ធិពលដល់សិទ្ធិរបស់ខ្លួន នៅក្នុងកាលបរិច្ឆេទនៃដីកាសម្រេចការលក់ ។

**មាត្រា ៤៧៤.-** ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១-លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ។

២-តុលាការអនុវត្តត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ បើទទួលស្គាល់ថាមានហេតុដូចកំណត់ក្នុងចំណុចខាងក្រោមនេះ :

ក-មិនត្រូវចាប់ផ្ដើម ឬ បន្តនីតិវិធីនៃការលក់ដោយបង្ខំ ។

ខ-អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានលក្ខណសម្បត្តិ ឬ សមត្ថភាពដើម្បីទិញនាវា ឬ អ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានសិទ្ធិនោះ ។

គ-មានសេចក្ដីស្នើសុំកុំឱ្យអនុញ្ញាតការលក់ ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៧៦ (ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលនាវាត្រូវបានខូចខាត) នៃក្រមនេះ ។

ឃ-មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ។

ង-មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការលក់ ។

**មាត្រា ៤៧៥.—** បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១-ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចប្តឹងជំទាស់បាន លុះត្រាតែក្នុងករណីដែលដីកាសម្រេចនោះបណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិរបស់ខ្លួន ។

២-បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់ ត្រូវយកហេតុដូចបានកំណត់ក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ២ មាត្រា ៤៧៤ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ឬ ហេតុដែលមានកំហុសធ្ងន់ធ្ងរ នៅក្នុងនីតិវិធីនៃដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ មកធ្វើជាមូលហេតុ ។

៣-បើទទួលស្គាល់ថាចាំបាច់ តុលាការនៃបណ្តឹងជំទាស់ អាចកំណត់ភាគីម្ខាងទៀតនៃម្ចាស់បណ្តឹងជំទាស់បាន ។

៤-ដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់នេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៧៦.—** ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលទាវាត្រូវបានខូចខាត

១-ក្នុងករណីដែលទាវាត្រូវបានទទួលការខូចខាតធ្ងន់ធ្ងរ ដោយសារគ្រោះធម្មជាតិ ឬ ដោយសារមូលហេតុផ្សេងទៀតដែលមិនមែនជាបន្ទុករបស់ខ្លួន ដែលបានកើតឡើងនៅក្រោយពេលធ្វើសំណើទិញ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញអាចស្នើសុំទៅតុលាការអនុវត្ត កុំឱ្យអនុញ្ញាតការលក់ ប្រសិនបើនៅមុនពេលចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ បើនៅក្រោយពេលដែលបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ហើយ អាចដាក់ពាក្យសុំឱ្យលុបចោលដីកាសម្រេចនោះ ទៅតុលាការអនុវត្ត នៅមុនពេលដែលខ្លួនបង់ប្រាក់បាន ។

២-ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៣-ដីកាសម្រេចលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៧៧.-** ការដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលមានសំណើទិញ

ដើម្បីដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលដែលមានសំណើទិញហើយ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលការយល់ព្រមពីសំណាក់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ។

**មាត្រា ៤៧៨.-** កំណត់ពេលបង់ថ្លៃលក់

បើដីកាសម្រេចអនុញ្ញាតឱ្យលក់ ចូលជាស្ថាពរ តុលាការអនុវត្តត្រូវកំណត់ពេលត្រូវបង់ថ្លៃលក់ ហើយជូនដំណឹងទៅឱ្យអ្នកទិញ ។

**មាត្រា ៤៧៩.-** ការបង់ថ្លៃលក់

១-អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត មុនពេលកំណត់ដែលតុលាការអនុវត្តបានកំណត់ តាមបញ្ញត្តិនៃមាត្រា ៤៧៨ (កំណត់ពេលបង់ថ្លៃលក់) នៃក្រមនេះ ។

២-ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើការស្នើសុំទិញ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់ ។

**មាត្រា ៤៨០.-** ពេលដែលទទួលកម្មសិទ្ធិលើនាវា

អ្នកទិញ ទទួលបាននូវកម្មសិទ្ធិលើនាវា នៅពេលដែលបានបង់ថ្លៃលក់ហើយ ។

**មាត្រា ៤៨១.-** អានុភាពនៃការមិនបង់ថ្លៃលក់

១-បើអ្នកទិញមិនបានបង់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ នឹងបាត់បង់អានុភាព ។ ក្នុងករណីនេះ អ្នកទិញមិនអាចទាមទារឱ្យសងប្រាក់ដែលបានដាក់ តាមបញ្ញត្តិនៃមាត្រា ៤៧០ (ការធានាលើសំណើទិញ) នៃក្រមនេះ បានទេ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវលក់ ដោយបង្ខំសាជាថ្មី ។

៣-ក្នុងការលក់ដោយបង្ខំតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អ្នកទិញដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មិនអាចធ្វើសំណើទិញបានឡើយ ។

**មាត្រា ៤៨២.–** ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជី ដោយការបង់ថ្លៃលក់

១-ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី និង លុបការចុះបញ្ជីនូវចំណុចដូចកំណត់ខាងក្រោមនេះ :

ក-ការចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

ខ-ការលុបការចុះបញ្ជី អំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន ។

២-ដើម្បីផ្ទុកផ្ដាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឱ្យលក់ ជាមួយនឹងលិខិតផ្ទុកផ្ដាក់នោះ ។

៣-សោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្ដាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់អ្នកទិញ ។

**មាត្រា ៤៨៣.–** ដីកាសម្រេចបង្គាប់ឱ្យប្រគល់នាវា

១-តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកកាន់កាប់នាវា ប្រគល់នាវានោះទៅឱ្យអ្នកទិញ តាមពាក្យសុំរបស់អ្នកទិញដែលបានបង់ថ្លៃលក់ហើយបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលត្រូវបានទទួលស្គាល់ថា កាន់កាប់ដោយផ្អែកលើមូលហេតុគតិយុត្តនៃសិទ្ធិ ដែលអាចតតាំងជាមួយនឹងអ្នកទិញ នៅលើសំណុំរឿងក្តីបាន ។

២-បើហួសអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលអ្នកទិញបានបង់ថ្លៃលក់ហើយ អ្នកទិញនោះពុំអាចដាក់ពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានទេ ។

៣-ក្នុងករណីដែលបានចេញដីកាសម្រេចចំពោះអ្នកកាន់កាប់ ក្រៅពីកូនបំណុលនៃការអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរជននោះ ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៨៤.–** ថ្លៃលក់

ប្រាក់ដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ជាថ្លៃលក់សម្រាប់ការចែកចំណែក ៖

ក-ថ្លៃលក់នាវា ។

ខ-ប្រាក់ដែលអ្នកទិញពុំអាចទាមទារឱ្យសងមកវិញបាន តាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ៤៨១ (អានុភាពនៃការមិនបង់ថ្លៃលក់) នៃក្រមនេះ ។

**មាត្រា ៤៨៥.–** ការទាមទារឱ្យចែកចំណែក

១-បុគ្គលដែលកំណត់ដូចខាងក្រោមនេះ អាចទាមទារឱ្យចែកចំណែកបាន ៖

ក-ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលអាចអនុវត្តដោយបង្ខំបាន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

ខ-ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ ។

គ-ម្ចាស់បំណុលដែលបានអនុវត្តការរឹបអូសជាបណ្តោះអាសន្ន យោងតាមវិធីដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។

ឃ-បុគ្គលដែលបញ្ជាក់ដោយឯកសារអំពីឯកសិទ្ធិទូទៅ ឬឯកសិទ្ធិលើនាវា ។

២-ចំពោះដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែកនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ៤៨៦.–** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក

ម្ចាស់បំណុលដែលត្រូវទទួលចំណែកថ្លៃលក់ គឺជាបុគ្គលដែលកំណត់ដូចខាងក្រោមនេះ ៖

ក-ម្ចាស់បំណុលនៃការអនុវត្ត ។

ខ-ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់កំណត់ពេលចុងក្រោយនៃការទាមទារឱ្យចែកចំណែក ។

គ-ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នៅមុនការ

ចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ។

## ផ្នែកទី ៦
## នីតិវិធីចែកចំណែកដោយតុលាការ

**មាត្រា ៤៨៧.–** តុលាការដែលត្រូវអនុវត្តការចែកចំណែក

តុលាការដែលត្រូវអនុវត្តការចែកចំណែក គឺសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅចំពោះការអនុវត្តដោយបង្ខំ ចំពោះចលនវត្ថុ ឬ តុលាការអនុវត្ត ចំពោះករណីផ្សេងទៀត ។

**មាត្រា ៤៨៨.–** ការរៀបចំការចែកចំណែក

១-បើមានមូលហេតុដែលចែងនៅចំណុចនីមួយៗខាងក្រោម តុលាការដែលត្រូវចែកចំណែកត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយផ្តល់ដំណឹងអំពីពេលវេលា និង ទីកន្លែងនោះ ទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក និង កូនបំណុល :

ក-ក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ពេលដែលមូលហេតុនៃការផ្ញើប្រាក់បានរលត់ ក្នុងករណីដែលមានការជូនដំណឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤០០ (ការផ្ញើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា) ឬ ពេលដែលមានការជូនដំណឹងតាមបញ្ញត្តិនៃមាត្រា ៤០១ (ការជូនដំណឹងទៅសាលាដំបូង) នៃក្រមនេះ ។

ខ-ក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ពេលដែលបានធ្វើការផ្ញើប្រាក់ តាមបញ្ញត្តិនៃមាត្រា ៤១២ (បណ្តឹងទាមទារប្រមូលបំណុល) ឬ ពេលដែលបានធ្វើការលក់ ដោយដីកាសម្រេចបង្គាប់ឱ្យលក់ តាមបញ្ញត្តិនៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឱ្យលក់) ឬ ពេលដែលប្រាក់ដែលបានមកពីការលក់ ត្រូវបានប្រគល់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤១៤ (ការអនុវត្តដីកាសម្រេចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ) នៃក្រមនេះ ។

គ-ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ពេលដែលមានការបង់ថ្លៃលក់តាមបញ្ញត្តិនៃមាត្រា ៤៤៧ (ការបង់ថ្លៃលក់) ឬ ពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ នៅក្នុងករណីដែលមានការស្នើសុំ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ មាត្រា ៤៤៧ (ការបង់ថ្លៃលក់) នៃក្រមនេះ ។

ឃ-ក្នុងការអនុវត្តដោយបង្ខំចំពោះនាវា ពេលដែលមានការបង់ថ្លៃលក់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤៧៩ (ការបង់ថ្លៃលក់) នៃក្រមនេះ ។

២-នៅពេលដែលកាលបរិច្ឆេទនៃការចែកចំណែកត្រូវបានកំណត់ហើយ ក្រឡាបញ្ជីត្រូវដាស់តឿនម្ចាស់បំណុលម្នាក់ៗ ឱ្យផ្តល់លិខិតគណនាអំពីប្រាក់ដើមនៃសិទ្ធិលើបំណុល ការប្រាក់ រហូតដល់កាលបរិច្ឆេទនៃការចែកចំណែក និង សោហ៊ុយសម្រាប់ការអនុវត្ត ទៅតុលាការដែលត្រូវចែកចំណែក ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ។

**មាត្រា ៤៨៩.–** ការអនុវត្តការចែកចំណែក

១-ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៨៨ (ការរៀបចំការចែកចំណែក) នៃក្រមនេះ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការបែងចែក ដោយផ្អែកលើតារាងចែកចំណែក ។ ប៉ុន្តែ ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ មិនចាំបាច់ផ្អែកលើតារាងចែកចំណែកឡើយ ។

២-ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬ ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយទឹកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះ អាចសងសព្វគ្រប់ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវចែកទៅម្ចាស់បំណុលគ្រប់រូប ហើយផ្តល់ទឹកប្រាក់ដែលសេសសល់ ទៅកូនបំណុលនៃការអនុវត្ត ។

៣-ក្នុងករណីដែលមានការផ្តល់នូវលិខិតដែលបានកំណត់ពីចំណុច ក ដល់ចំណុច ឆ នៃកថាខណ្ឌទី ១ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ក្រោយពេលត្រូវចាប់ផ្តើមអនុវត្តការចែកចំណែក បើមានម្ចាស់បំណុលដែលត្រូវទទួលចំណែកផ្សេងពីម្ចាស់បំណុលនៃការអនុវត្ត តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវចែកចំណែកឱ្យម្ចាស់បំណុលនោះ ។

៤-ក្នុងករណីដែលមានការផ្តល់នូវលិខិតដែលបានកំណត់នៅក្នុងចំណុច ក និង ចំណុច ខ នៃកថាខណ្ឌទី ២ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ក្រោយពេលត្រូវចាប់ផ្តើមអនុវត្តការចែកចំណែក តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែកផងដែរ ។

**មាត្រា ៤៩០.–** ការធ្វើតារាងចែកចំណែក

១-តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើតារាងចែកចំណែក នៅកាលបរិច្ឆេទនៃការចែកចំណែកនោះ លើកលែងតែករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤៨៩ (ការអនុវត្តការចែកចំណែក) នៃក្រមនេះ ។

២-នៅកាលបរិច្ឆេទនៃការចែកចំណែក តុលាការត្រូវកោះហៅម្ចាស់បំណុលដែលបានកំណត់ខាងក្រោមនេះ និង កូនបំណុលនៃការអនុវត្ត:

ក-ករណីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៣៩៨ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែកជាប្រាក់) នៃក្រមនេះ ។

ខ-ករណីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៤១៥ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ ។

គ-ករណីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៤៥៣ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ ។

ឃ-ករណីអនុវត្តដោយបង្ខំចំពោះនាវា : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៤៨៦ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ ។

៣-ពាក់ព័ន្ធនឹងការធ្វើតារាងចែកចំណែក តុលាការអាចសួរម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្តដែលបង្ហាញខ្លួន ហើយអាចធ្វើការពិនិត្យភស្តុតាងជាឯកសារដែលអាចធ្វើការពិនិត្យភ្លាមៗបាន នៅកាលបរិច្ឆេទនៃការចែកចំណែក ។

៤-នៅលើតារាងចែកចំណែក ទន្ទឹមគ្នានឹងចំនួនទឹកប្រាក់ខាងក្រោមនេះ តុលាការត្រូវសរសេរអំពីចំនួនប្រាក់ដើម ការប្រាក់ សិទ្ធិលើបំណុលបន្ទាប់បន្សំផ្សេងៗនៃសិទ្ធិលើបំណុល សោហ៊ុយសម្រាប់ការអនុវត្ត និង លំដាប់និងចំនួនទឹកប្រាក់នៃការចែកចំណែក:

ក-ករណីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ : ចំនួនទឹកប្រាក់បានមកពីការលក់វត្ថុ ដែលត្រូវបានរឹបអូស និង ចំនួនទឹកប្រាក់ដែលត្រូវបានរឹបអូស ។

ខ-ករណីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត : ចំនួនទឹកប្រាក់ដែលត្រូវអនុវត្តការចែកចំណែក ។

គ-ករណីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ៖ ចំនួនទឹកប្រាក់ដែលបានមកពីការលក់ ។

ឃ-ករណីអនុវត្តដោយបង្ខំចំពោះនាវា ៖ ចំនួនទឹកប្រាក់ដែលបានមកពីការលក់ ។

៥-លំដាប់ និង ចំនួនទឹកប្រាក់នៃការចែកចំណែក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ ត្រូវសរសេរតាមការព្រមព្រៀង ក្នុងករណីដែលកិច្ចព្រមព្រៀងបានសម្រេចឡើងរវាងម្ចាស់បំណុលគ្រប់រូប នៅកាលបរិច្ឆេទនៃការចែកចំណែក ឯក្នុងករណីផ្សេងទៀតត្រូវសរសេរតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ច្បាប់ដែលទាក់ទងនឹងពាណិជ្ជកម្ម ឬ ច្បាប់ផ្សេងទៀត ។

៦-ពាក់ព័ន្ធនឹងការចែកចំណែក សិទ្ធិលើបំណុលដែលពេលកំណត់ពិតប្រាកដពុំទាន់ឈានចូលមកដល់ ត្រូវចាត់ទុកថា ពេលកំណត់សងបានចូលមកដល់ ។

**មាត្រា ៥៩១.-** ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

១-ម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្តដែលមានឧបាស្រ័យ ចំពោះសិទ្ធិលើបំណុល ឬ ចំនួនប្រាក់ចំណែក របស់ម្ចាស់បំណុលម្នាក់ៗដែលត្រូវបានសរសេរលើតារាងចែកចំណែក អាចថ្លែងសេចក្តីតវ៉ាបាន នៅកាលបរិច្ឆេទនៃការចែកចំណែក ។

២-តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែកតែផ្នែកដែលគ្មានការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ។

៣-ជាលទ្ធផលនៃការអនុវត្តការចែកចំណែក បើម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានទាមទារចំណែក ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត បានទទួលនូវចំណែកគ្រប់ចំនួននៃសិទ្ធិលើបំណុល នោះកូនបំណុលនៃការអនុវត្តអាចទាមទារឱ្យក្រឡាបញ្ជីប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តដែលម្ចាស់បំណុលនោះបានផ្តល់ ។

៤-លើកលែងតែករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ កាលដែលរឿងក្តីបានបញ្ចប់ហើយ ម្ចាស់បំណុលដែលបានកំណត់នៅកថាខណ្ឌទី ៣ នោះ អាចទាមទារឱ្យក្រឡាបញ្ជីប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តបាន ។ ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលនោះជាជនដែលបានទទួលចំណែកនៃសិទ្ធិលើបំណុលតែមួយ

ផ្នែក ក្រឡាបញ្ជីត្រូវប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដោយចារនូវចំនួននៃចំណែកដែលម្ចាស់បំណុលនោះ បានទទួលលើឯកសារនោះ ។

**មាត្រា ៩៩២.-** បណ្ដឹងតវ៉ារបស់ម្ចាស់បំណុលដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

១-ម្ចាស់បំណុលដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវដាក់ពាក្យបណ្ដឹងតវ៉ា ចំពោះការសរសេរលើតារាងចែកចំណែក ដោយយកម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការស្នើសុំតវ៉ាជាចុងចម្លើយ ។

២-បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលត្រូវអនុវត្តការចែកចំណែក ។

៣-បើម្ចាស់បំណុលដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកមិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅកថាខណ្ឌទី ១ ទៅតុលាការ ក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ ចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវចាត់ទុកថា បានដកវិញ ។

៤-ក្នុងសាលក្រមនៃបណ្ដឹងដែលបានកំណត់នៅកថាខណ្ឌទី ១ បើយល់ឃើញថាការតវ៉ាមានភាពត្រឹមត្រូវ តុលាការត្រូវធ្វើការផ្លាស់ប្ដូរតារាងចែកចំណែក ឬ លុបចោលតារាងចែកចំណែកដើម្បីធ្វើតារាងចែកចំណែកថ្មី ។

**មាត្រា ៩៩៣.-** បណ្ដឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

១-កូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ចំពោះម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ត្រូវដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ដោយយកម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការស្នើសុំតវ៉ាជាចុងចម្លើយ ។

២-កូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ចំពោះម្ចាស់បំណុលដែលគ្មានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ត្រូវដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

ដោយយកម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការស្នើសុំតវ៉ាជាចុងចម្លើយ ។

៣-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលត្រូវអនុវត្តការចែកចំណែក ។

៤-បើកូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក មិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ទៅតុលាការ ហើយមិនផ្តល់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចបង្គាប់ឱ្យផ្អាកការអនុ-វត្តដែលទាក់ទងនឹងបណ្តឹងរបស់ខ្លួន ទៅតុលាការ ឬ មិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ទៅតុលាការ ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកត្រូវចាត់ទុកថា បានដកវិញ ។

៥-ក្នុងសាលក្រមនៃបណ្តឹងដែលបានកំណត់នៅកថាខណ្ឌទី ១ បើយល់ឃើញថាការតវ៉ាមានភាពត្រឹមត្រូវ តុលាការដែលត្រូវអនុវត្តការចែកចំណែកត្រូវធ្វើការផ្លាស់ប្តូរតារាងចែកចំណែក ឬ លុបចោលតារាងចែកចំណែកដើម្បីធ្វើតារាងចែកចំណែកថ្មី ។

**មាត្រា ៤៩៤.-** ការផ្អាកទុកចំនួនប្រាក់ចំណែក

១-ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលត្រូវទទួលចំណែក បើមានមូលហេតុដូចខាងក្រោមនេះ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវផ្អាកទុកទឹកប្រាក់ដែលស្មើនឹងចំនួននៃចំណែកនោះ :

ក-សិទ្ធិលើបំណុលនោះភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ។

ខ-សិទ្ធិលើបំណុលនោះជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន ។

គ-ឯកសារដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវបានផ្តល់ ។

ឃ-ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចហាមឃាត់មួយរយៈនូវការអនុវត្តឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែកដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ ត្រូវបានផ្តល់ ។

ង-ពាក្យបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៩២ (បណ្ដឹងតវ៉ារបស់ម្ចាស់បំណុលដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក) ឬ កថាខណ្ឌទី ២ នៃមាត្រា ៤៩៣ (បណ្ដឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែក ចំណែក) នៃក្រមនេះ ។

២-តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវផ្អាកទុកទឹកប្រាក់ដែលស្មើនឹងចំនួននៃចំណែករបស់ម្ចាស់បំណុលដែលពុំបានបង្ហាញខ្លួនចំពោះមុខតុលាការដើម្បីទទួលចំណែកនោះ ។

**មាត្រា ៤៩៥.-** ការអនុវត្តការចែកចំណែក ដោយការសម្រេចសិទ្ធិជាស្ថាពរ ជាអាទិ៍

១-ក្នុងករណីដែលការផ្អាកទុកត្រូវបានអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក) នៃក្រមនេះ បើហេតុនៃការផ្អាកទុកនោះបានរលត់ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែកចំពោះប្រាក់ផ្អាកទុកនោះ ។

២-ក្នុងករណីដែលត្រូវអនុវត្តការចែកចំណែក តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការផ្លាស់ប្ដូរតារាងចែកចំណែក ដើម្បីម្ចាស់បំណុលដែលមិនបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកផងដែរ បើត្រូវនឹងចំណុចណាមួយខាងក្រោមនេះ :

ក-បើមិនអាចធ្វើការចែកចំណែកបាន ចំពោះម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក ដោយមានហេតុដែលបានកំណត់ចាប់ពីចំណុច ក ដល់ចំណុច ឃ នៃកថាខណ្ឌ ទី ១ មាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក) នៃក្រមនេះ ។

ខ-បើម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក ដោយមានហេតុដែលបានកំណត់នៅក្នុងចំណុច ង នៃកថាខណ្ឌទី ១ មាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក) បានចាញ់ក្ដីក្នុងបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដែលកូនបំណុលនៃការអនុវត្តបានដាក់ពាក្យ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤៩៣ (បណ្ដឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក) នៃក្រមនេះ ។

## ជំពូកទី ៣
## បទប្បញ្ញត្តិពិសេសស្ដីពីការអនុវត្តសិទ្ធិប្រាតិភោគ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៤៩៦.–** លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ

ទោះបីមានបញ្ញត្តិនៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះក៏ដោយ ក៏ការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវធ្វើឡើង ដោយលិខិតអនុវត្តដែលបានកំណត់ខាងក្រោមនេះ :

ក-សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរនោះ ។

ខ-លិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ។

**មាត្រា ៤៩៧.–** បញ្ញត្តិពិសេសស្ដីពីសមត្ថកិច្ចលើបណ្ដឹងតវ៉ាចំពោះការទាមទារ និង បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ដែលពាក់ព័ន្ធនឹងលិខិតអនុវត្ត ដើម្បីអនុវត្តសិទ្ធិប្រាតិភោគ

១-ទោះបីមានបញ្ញត្តិនៃមាត្រា ៣៦៣ (បណ្ដឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះក៏ដោយ បណ្ដឹងតវ៉ាចំពោះការទាមទារដែលពាក់ព័ន្ធនឹងលិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ដែលបានកំណត់នៅក្នុងចំណុចនីមួយៗ តាមប្រភេទនៃលិខិតអនុវត្តដែលបែងចែកដូចខាងក្រោមនេះ :

ក-ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ក នៃមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ : សាលាដំបូងដែលបានធ្វើនីតិវិធីនៃបណ្ដឹងនោះ ។

ខ-ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ខ នៃមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ : តុលាការមានសមត្ថកិច្ចលើទីកន្លែងរបស់ចុងចម្លើយដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់

ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ។ បើគ្មានតុលាការដែលមានសមត្ថកិច្ចតាមមាត្រា ៨ នោះទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃសិទ្ធិប្រាតិភោគស្ថិតនៅ ។ បើកម្មវត្ថុនៃសិទ្ធិប្រាតិភោគជាសិទ្ធិលើបំណុល តុលាការដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ។

**មាត្រា ៤៩៨.–** ការផ្អាក និង ការលុបចោលការអនុវត្តសិទ្ធិប្រាតិភោគ

១-តុលាការអនុវត្ត ឬ អាជ្ញាសាលាត្រូវផ្អាកនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ហើយត្រូវលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ បើឯកសារដែលបានកំណត់ខាងក្រោមនេះត្រូវបានដាក់ :

ក-ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា លុបចោលលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងចំណុច ក នៃមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ ។

ខ-ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា មិនអនុញ្ញាតឱ្យអនុ-វត្តសិទ្ធិប្រាតិភោគ ។

គ-អនុសារសាលក្រមស្ថាពរ ឬ អនុសារសាលដីកាស្ថាពរដែលប្រកាសថា ការផ្សះផ្សា ឬ ការទទួលស្គាល់ ដែលទាក់ទងនឹងលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងចំណុចទី ១ នៃមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ គ្មានអានុភាព ។

ឃ-ឯកសារចម្លងយថាភូតនៃកំណត់ហេតុអំពីការសះជាតាមនីតិវិធីតុលាការដែលកំណត់ថា មិនអនុវត្តសិទ្ធិប្រាតិភោគ ឬ ការដកពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ។

ង-ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តសិទ្ធិប្រាតិភោគ និង លុបចោលការចាត់ចែងការអនុវត្ត ។

២-តុលាការអនុវត្ត ឬ អាជ្ញាសាលា ត្រូវផ្អាកនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ បើឯកសារដែលបានកំណត់ខាងក្រោមនេះ ត្រូវបានដាក់មក :

ក-ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តសិទ្ធិប្រាតិភោគមួយរយៈ ។

ខ-ឯកសារដែលសរសេរថា ម្ចាស់បំណុលបានទទួលសំណងនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ឬ បានយល់ព្រមពន្យារពេលត្រូវសងចំពោះសិទ្ធិលើបំណុលនោះ នៅក្រោយពេលលិខិតអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ ត្រូវបានបង្កើត ។

ប៉ុន្តែ ចំពោះករណីដែលបានកំណត់នៅក្នុងចំណុច ខ ខាងលើ អានុភាពផ្អាក មានត្រឹមតែ ២ (ពីរ) ខែប៉ុណ្ណោះ ។

៣-បញ្ញត្តិនៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគ ។

៤-បញ្ញត្តិនៃមាត្រា ៣៤៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលលុបចោលការចាត់ចែងការអនុវត្ត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៤៩៩.-** ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្តូរជាប្រាក់

ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្តូរជាប្រាក់ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ ដែលកំណត់អំពីការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ។

## ផ្នែកទី ២
## ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

**មាត្រា ៥០០.-** ល័ក្ខខ័ណ្ឌនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

ទោះបីជាក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តមិនដាក់លិខិតអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ ទៅអាជ្ញាសាលាក៏ដោយ បើបានដាក់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ឬ បានដាក់ឯកសារ

ដែលបញ្ជាក់ថា អ្នកកាន់កាប់ចលនវត្ថុបានយល់ព្រមចំពោះការរឹបអូស ក៏ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុអាចចាប់ផ្តើមបានដែរ ។

**មាត្រា ៥០១.–** ការតវ៉ាចំពោះការអនុវត្ត នូវការរឹបអូសចលនវត្ថុ

បើការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុត្រូវបានចាប់ផ្តើម ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥០០ (ល័ក្ខខ័ណ្ឌនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ) នៃក្រមនេះ កម្មសិទ្ធិករនៃចលនវត្ថុ ឬ កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា អាចយកនត្ថិភាព ឬ ការរលត់នៃសិទ្ធិប្រាតិភោគ មកធ្វើជាមូលហេតុ ក្នុងពាក្យសុំតវ៉ាចំពោះការអនុវត្តនូវការរឹបអូសនោះបាន ។

**មាត្រា ៥០២.–** ចំណុចដែលត្រូវសរសេរ ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ អ្នកដាក់ពាក្យសុំត្រូវសរសេរនូវចំណុចខាងក្រោមនេះ :

ក-សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង ។

ខ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា ។

គ-សញ្ញាណនៃចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ និង ទីកន្លែងនៃចលនវត្ថុនោះ ។

ឃ-ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ ។

**មាត្រា ៥០៣.–** បញ្ញត្តិស្តីពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលមិនត្រូវអនុវត្ត

បញ្ញត្តិនៃមាត្រា ៣៨០ (ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) មាត្រា ៣៨១ (ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) និង មាត្រា ៣៩១ (ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ។

**មាត្រា ៥០៤.-** នីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

១-ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ អាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចអនុញ្ញាតឱ្យយកវត្ថុបញ្ចាំនោះមកសងផ្ទាល់តែម្តង ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច ដោយផ្អែកលើបញ្ញត្តិស្តីពីការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេបដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ។

២-ក្នុងការចេញដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសួរម្ចាស់សិទ្ធិលើការបញ្ចាំ កម្មសិទ្ធិករនៃវត្ថុបញ្ចាំ និង កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។

៣-បើចេញដីកាសម្រេចអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកវាយតម្លៃឱ្យវាយតម្លៃនូវវត្ថុបញ្ចាំជាមុន ដោយផ្អែកលើបញ្ញត្តិស្តីពីការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំបានដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយកំណត់តម្លៃនៃវត្ថុបញ្ចាំ តាមការវាយតម្លៃនៃវត្ថុបញ្ចាំដោយខ្លួនឯង ហើយកម្មសិទ្ធិករនៃវត្ថុបញ្ចាំបានយល់ព្រមនឹងតម្លៃនោះ ។

៤-បើតុលាការចេញដីកាសម្រេចអនុញ្ញាតដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ សោហ៊ុយសម្រាប់នីតិវិធីនោះ ត្រូវចាត់ជាបន្ទុករបស់កម្មសិទ្ធិករនៃវត្ថុបញ្ចាំ ។

៥-ក្នុងដីកាសម្រេចអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវប្រកាសអនុញ្ញាតឱ្យយកវត្ថុបញ្ចាំមកសងដោយផ្ទាល់ ក្នុងចំនួនទឹកប្រាក់ដែលអ្នកវាយតម្លៃ បានវាយតម្លៃ ហើយព្រមជាមួយគ្នានេះ បើចំនួនដែលអ្នកវាយតម្លៃបានវាយតម្លៃនោះ លើសពីចំនួនទឹកប្រាក់សរុបនៃកាតព្វកិច្ចដែលត្រូវសង និង សោហ៊ុយសម្រាប់នីតិវិធី តុលាការត្រូវបង្គាប់ឱ្យសងចំនួនលើសនោះទៅឱ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំវិញ ។

៦-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៧-ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

## ផ្នែកទី ៣
## ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

**មាត្រា ៥០៥.–** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ជាអាទិ៍

១-ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ មាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) នៃក្រមនេះក៏ដោយ ក៏ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរនូវចំណុចខាងក្រោមនេះ :

ក-សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា កូនបំណុលទី ៣ និង អ្នកតំណាង ។

ខ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា ។

គ-សញ្ញាណនៃសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ ។

ឃ-ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ ។

២-អ្នកដាក់ពាក្យសុំ ត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ ជាមួយនឹងពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥០៦.–** ការរឹបអូសសិទ្ធិលើបំណុលដោយផ្អែកលើឧបាទេសកម្មលើវត្ថុ

១-ចំពោះការអនុវត្តសិទ្ធិប្រាតិភោគ ដែលធ្វើឡើងដោយម្ចាស់សិទ្ធិប្រាតិភោគនោះ ចំពោះប្រាក់ ឬ វត្ថុផ្សេងទៀតដែលម្ចាស់បំណុលត្រូវទទួល ដោយការលក់ ការជួល ការបាត់បង់ ឬ ការខូចខាតនៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ឬ ការបង្កើតសិទ្ធិប្រត្យក្សលើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ ដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ក្រៅពីបញ្ញត្តិនៃមាត្រានេះ បញ្ញត្តិនៃមាត្រា ៥០៥ (ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ជាអាទិ៍) នៃក្រមនេះ ត្រូវយកមក

អនុវត្ត ។

២-ចំពោះការអនុវត្តសិទ្ធិដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ មាត្រា ៥០៥ (ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ជាអាទិ៍) នៃក្រមនេះ អ្នកដាក់ពាក្យសុំត្រូវសរសេរអំពីទំនាក់ទំនងរវាងសិទ្ធិលើបំណុលដែលត្រូវបានធានា និង សិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស ។

៣-ចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ដោយម្ចាស់សិទ្ធិប្រាតិភោគនោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៥០៥ (ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ជាអាទិ៍) ក៏ដោយ ក៏ម្ចាស់បំណុលនៃការអនុវត្តអាចភ្ជាប់ឯកសារចម្លងយថាភូតនៃឯកសារដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ជាមួយនឹងពាក្យសុំ ជំនួសឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិ ប្រាតិភោគ) នៃក្រមនេះ បានដែរ ។

**មាត្រា ៥០៧.‒** ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ការអនុវត្តសិទ្ធិប្រាតិភោគដែលយកសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ជាកម្មវត្ថុត្រូវអនុលោមតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងផ្នែកទី ៣ (ការអនុវត្តចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) ជំពូកទី ២ នៃគន្ថីទី ៦ នៃក្រមនេះ លើកលែងតែមានបញ្ញត្តិពិសេស ។

**មាត្រា ៥០៨.‒** បញ្ញត្តិដែលមិនត្រូវយកមកអនុវត្ត

បញ្ញត្តិនៃមាត្រា ៣៨២ (សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស) មាត្រា ៣៨៣ (ការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស) និង កថាខណ្ឌទី ២ នៃមាត្រា ៤០៤ (ទំហំនៃការរឹបអូស) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះផ្នែកនេះ ។

## ផ្នែកទី ៤
## ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

**មាត្រា ៥០៩.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ជាអាទិ៍

១-ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ អ្នកដាក់ពាក្យសុំត្រូវសរសេរនូវចំណុចខាងក្រោមនេះ :

ក-សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃអចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង ។

ខ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវធានា ។

គ-សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ ។

ឃ-ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។

២-ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដូចខាងក្រោមនេះ :

ក-ករណីដែលអនុវត្តសិទ្ធិប្រាតិភោគផ្សេងពីឯកសិទ្ធិទូទៅ : ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី ។

ខ-ករណីដែលអនុវត្តឯកសិទ្ធិទូទៅ : ចំពោះអចលនវត្ថុដែលបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត បានចុះនៅក្នុងសៀវភៅចុះបញ្ជីថា ជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។ ចំពោះដីធ្លីដែលមិនទាន់បានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីធ្លីជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៥១០.-** សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ

១-សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផលលើអចលនវត្ថុ និង សិទ្ធិជួលអចលនវត្ថុ ដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបន្តអត្ថិភាព ក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ។

២-ក្រៅពីសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិលើអចលនវត្ថុត្រូវរលត់ដោយការលក់ ។

៣-ការរឹបអូស ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន និង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលមិនអាចតតាំងនឹងម្ចាស់បំណុលដែលបានធ្វើការរឹបអូសជាបណ្ដោះអាសន្ន ដែលទាក់ទងនឹងអចលនវត្ថុ នឹងបាត់បង់អានុភាពដោយការលក់ ។

៤-បើអ្នកដែលមានទំនាក់ទំនងផលប្រយោជន៍ បានរាយការណ៍ថា បានធ្វើការព្រមព្រៀងផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មុនពេលតម្លៃលក់អប្បបរមាត្រូវបានកំណត់ការប្រែប្រួលនៃសិទ្ធិលើអចលនវត្ថុ ត្រូវអនុលោមតាមការព្រមព្រៀងនោះ ។

**មាត្រា ៥១១.-** ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ

១-បើមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ត្រូវបានសម្រេចរួចហើយ តាមបញ្ញត្តិនៃមាត្រា ៤១៩ (ដីកាសម្រេចចាប់ផ្ដើម ជាអាទិ៍) នៃក្រមនេះ ហើយទទួលស្គាល់ពាក្យសុំនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំថ្មីទៀត ។ ក្នុងករណីនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមមុន ។

២-បើពាក្យសុំឱ្យលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានដក ឬ នីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានលុបចោល តុលាការអនុវត្តត្រូវបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយ

បង្ខំក្រោយ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយនេះ ផ្អែកលើពាក្យសុំដែលបានដាក់ក្រោយពេលកំណត់ចុងក្រោយ សម្រាប់ការទាមទារឱ្យចែកចំណែក តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកជាថ្មី ។ ក្នុងករណីនេះ តុលាការអនុវត្តមិនចាំបាច់ដាស់តឿន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ) នៃក្រមនេះ ចំពោះជនដែលបានធ្វើសេចក្ដីរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤២៣ (ករណីយកិច្ចរបស់ជនដែលត្រូវបានដាស់តឿនក្នុងការរាយការណ៍អំពីសិទ្ធិលើបំណុល) ឡើយ ។

៤-បើនីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុនត្រូវបានផ្អាក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមក្រោយ ។ ក្នុងករណីនេះ ប្រសិនបើសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តនេះ អាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តមុនបាន តុលាការអនុវត្តអាចចេញដីកាសម្រេចបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយ តាមពាក្យសុំបាន ។

៥-បើមានដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នេះ ទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៦-ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៥១២.-** ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ

១-បើមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគថែមទៀត ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្ដើមការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានសម្រេចរួចហើយ ហើយទទួលស្គាល់ពាក្យសុំនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំថ្មីទៀត ។ ក្នុង

ករណីនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមមុន ។

២-បើពាក្យសុំឱ្យលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបាន ដក ឬ នីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានលុប ចោល តុលាការអនុវត្តត្រូវបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយ បង្ខំក្រោយ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើដីកាសម្រេច ចាប់ផ្ដើមការលក់ដោយបង្ខំក្រោយនេះ ផ្អែកលើពាក្យសុំដែលបានដាក់ក្រោយពេលកំណត់ ចុងក្រោយ សម្រាប់ការទាមទារឱ្យចែកចំណែក តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយ សម្រាប់ការទាមទារឱ្យចែកចំណែកជាថ្មី ។ ក្នុងករណីនេះ តុលាការអនុវត្តមិនចាំបាច់ដាស់ តឿន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៤២២ (ការកំណត់ពេលចុងក្រោយ សម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ) នៃក្រមនេះ ចំពោះ ជនដែលបានធ្វើសេចក្ដីរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤២៣ (ករណីយកិច្ចរបស់ជនដែលត្រូវបានដាស់តឿនក្នុងការរាយការណ៍អំពីសិទ្ធិលើបំណុល) ឡើយ ។

៤-បើនីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុនត្រូវបាន ផ្អាក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែល ទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមក្រោយ ។ ក្នុងករណីនេះ ប្រសិនបើសិទ្ធិប្រាតិភោគរបស់ ម្ចាស់បំណុលនៃការអនុវត្តនេះ អាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្ត មុនបាន តុលាការអនុវត្តអាចចេញដីកាសម្រេចបន្តនីតិវិធីដោយផ្អែកលើដីកាសម្រេចចាប់ ផ្ដើមការលក់ដោយបង្ខំក្រោយ តាមពាក្យសុំបាន ។

៥-បើមានដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ តុលា-ការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នេះ ទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៦-ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៥១៣.-** សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់ដោយបង្ខំ ដែលជាការអនុវត្តចំពោះអចលនវត្ថុ ឬ ការអនុវត្តសិទ្ធិប្រាតិភោគដែលមានដំណើរការមុន

១-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១១ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បើពាក្យសុំឱ្យលក់ដោយបង្ខំក្រោយដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ផ្អែកលើសិទ្ធិប្រាតិភោគដែលអាចតតាំងនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តមុន សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំក្រោយនោះ ព្រមទាំងសិទ្ធិប្រាតិភោគផ្សេង សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួល ដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគនោះ ត្រូវរលត់ ដោយការលក់ដោយបង្ខំ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១២ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បើពាក្យសុំឱ្យលក់ដោយបង្ខំក្រោយ ផ្អែកលើសិទ្ធិប្រាតិភោគដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តមុន សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំក្រោយនោះ ព្រមទាំងសិទ្ធិប្រាតិភោគផ្សេង សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួល ដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគនោះ ត្រូវរលត់ដោយការលក់ដោយបង្ខំ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលពាក្យសុំក្រោយ ត្រូវបានដាក់នៅក្រោយពេលដែលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ការលក់ឡាយឡុងដោយផ្ទាល់មាត់ នៅក្នុងនីតិវិធីដោយផ្អែកលើពាក្យសុំមុនបានចាប់ផ្តើម ។

**មាត្រា ៥១៤.-** ការផ្ញើឯកសារលំអិតអំពីវត្ថុ ជាអាទិ៍ ក្នុងករណីដែលមានដីកាសម្រេចចាប់ផ្តើមត្រួតគ្នា

១-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ នៃមាត្រា ៥១៣ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់ដោយបង្ខំ ដែលជាការអនុវត្ត

ចំពោះអចលនវត្ថុ ឬ ការអនុវត្តសិទ្ធិប្រាតិភោគដែលមានដំណើរការមុន) នៃក្រមនេះ នៅពេលកំណត់តម្លៃលក់អប្បបរមា និង ធ្វើឯកសារលំអិតអំពីវត្ថុ តុលាការអនុវត្តត្រូវពិចារណាអំពីការរលត់នៃសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំក្រោយ និង សិទ្ធិប្រាតិភោគផ្សេង សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួល ដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើមានភាពចាំបាច់ តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ឬ ធ្វើឯកសារលំអិតអំពីវត្ថុឡើងវិញ ។

**មាត្រា ៥១៥.-** ការចាត់ចែងក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយពេលដែលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលន-វត្ថុ បានចាប់ផ្ដើម

១-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១១ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បើពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្ត សិទ្ធិប្រាតិភោគ ត្រូវបានដាក់ ក្រោយពេលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំមុន បានចាប់ផ្ដើម តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំនោះ ហើយព្រមជាមួយគ្នានេះ ត្រូវផ្អាកនីតិវិធីលក់ដោយបង្ខំក្រោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិប្រាតិភោគនោះ មិនអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តមុនបាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១២ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បើពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានដាក់ ក្រោយពេលកាលបរិ-ច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំមុន បានចាប់ផ្ដើម តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំនោះ ហើយព្រមជាមួយគ្នានេះ ត្រូវផ្អាកនីតិវិធីលក់ដោយបង្ខំក្រោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិន

ត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលបានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំក្រោយ មិនអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តមុនបាន ។

៣-បើមានការបង់ថ្លៃលក់ក្នុងនីតិវិធីលក់ដោយបង្ខំមុន ក្រោយពីបានផ្អាកនីតិវិធីលក់ដោយបង្ខំក្រោយ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ តុលាការអនុវត្តត្រូវលុបចោលដីកាសម្រេចចាប់ផ្ដើមដែលទាក់ទងនឹងនីតិវិធីលក់ដោយបង្ខំក្រោយ ។

**មាត្រា ៥១៦.-** ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ

១-ក្នុងករណីដែលអានុភាពនៃការរឹបអូសកើតឡើង ចំពោះអចលនវត្ថុ ដោយដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ បើម្ចាស់បំណុលនៃការអនុវត្ត ដាក់ពាក្យសុំឱ្យរឹបអូសសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុនោះ តុលាការអនុវត្តអាចចេញដីកាសម្រេចរឹបអូសនោះបាន ។ ដីកាសម្រេចនេះត្រូវធ្វើឡើង ដោយមិនសួរកូនបំណុលនៃការអនុវត្ត និង អ្នកដែលមានករណីយកិច្ចបង់ថ្លៃឈ្នួលអចលនវត្ថុនោះ ។

២-ក្នុងដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវហាមឃាត់កូនបំណុលនៃការអនុវត្ត ក្នុងការប្រមូលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួល ឬ ធ្វើការចាត់ចែងផ្សេងទៀត ហើយត្រូវហាមឃាត់ជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ក្នុងការសងទៅឱ្យកូនបំណុលនៃការអនុវត្ត ហើយត្រូវបង្គាប់ឱ្យជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួលនោះ ផ្ញើនូវប្រាក់ដែលស្មើនឹងចំនួនសរុបនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស នៅតុលាការអនុវត្ត ។

៣-ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និង ជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ។

៤-អានុភាពនៃការរឹបអូស នឹងកើតឡើង នៅពេលដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបញ្ជូនទៅដល់ជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ។

**មាត្រា ៥១៧.-** អានុភាពនៃការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល

១-ម្ចាស់បំណុលនៃការអនុវត្តដែលបានរឹបអូសសិទ្ធិលើបំណុលដែលមានគោល

បំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) នៃក្រមនេះ អាចទាមទារឱ្យអ្នកដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ផ្ញើប្រាក់ដែលស្មើនឹងចំនួនសរុបនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះ នៅតុលាការអនុវត្តបាន បើអំឡុងពេល ១ (មួយ) សប្តាហ៍ បានកន្លងហួស ដោយគិតពីថ្ងៃដែលដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ត្រូវបានបញ្ជូនទៅដល់កូនបំណុលនៃការអនុវត្ត ។

២-ការរឹបអូស ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) នៃក្រមនេះ ត្រូវមានអានុភាពលើថ្លៃឈ្នួលដែលកូនបំណុលនៃការអនុវត្តត្រូវទទួល ក្រោយការរឹបអូស រហូតដល់ពេលដែលអ្នកទិញបង់ថ្លៃលក់អចលនវត្ថុនោះ ។

៣-ថ្លៃឈ្នួលដែលកូនបំណុលនៃសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួល បានផ្ញើនៅតុលាការ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់ ។

**មាត្រា ៥១៨.-** ទំនាក់ទំនងរវាងការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលន-វត្ថុ និង នីតិវិធីអនុវត្តចំពោះសិទ្ធិលើបំណុល

១-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ បើដីកាសម្រេចរឹបអូសដែលបានកំណត់នៅក្នុងមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) នៃក្រមនេះ ត្រូវបានបញ្ជូនទៅដល់ភតិកៈដែលជួលអចលនវត្ថុ មុនពេលដីកាសម្រេចរឹបអូសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) បង្កើតអានុភាព នោះដីកាសម្រេចរឹបអូសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) មិនត្រូវបង្កើតអានុភាពឡើយ លើកលែងតែករណីដែលសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចរឹបអូស ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) ត្រូវបានចុះបញ្ជីមុនពេលបញ្ជូនដីកាសម្រេចរឹបអូសនោះ ។

២-សិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ មិនអាចត្រូវ

បានរឹបអូស ដោយយោងតាមមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) នៃក្រមនេះ បានឡើយ នៅក្រោយពេលដែលដីកាសម្រេចរឹបអូសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) បានបង្កើតអានុភាព ចំពោះសិទ្ធិលើបំណុលនោះ ។

**មាត្រា ៥១៩.-** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក

ក្រៅពីជនដែលបានកំណត់នៅក្នុងមាត្រា ៤៥៣ (វិសាលភាពនៃម្ចាស់បំណុលដែល ត្រូវទទួលចំណែក) នៃក្រមនេះ ម្ចាស់បំណុលដែលត្រូវទទួលចំណែកពីប្រាក់ដែលបានមក ពីការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ គឺនៅមានម្ចាស់បំណុលដែលមានសិទ្ធិប្រា- តិភោគដែលត្រូវរលត់ដោយការលក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះ ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលបានចុះបញ្ជី ក្រោយពេលអានុភាពនៃការរឹប អូសបានកើតឡើង ។

**មាត្រា ៥២០.-** បញ្ញត្តិស្តីពីការអនុវត្តចំពោះអចលនវត្ថុ ដែលមិនត្រូវយកមកអនុវត្ត

បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយ បង្ខំ) កថាខណ្ឌទី ៣ នៃមាត្រា ៤១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចល- នវត្ថុ) កថាខណ្ឌទី ១ នៃមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ ក្រោយការលក់) ព្រមទាំងមាត្រា ៤៥៣ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលន វត្ថុ ។

## ផ្នែកទី ៥
## ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា

**មាត្រា ៥២១.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះ នាវា ជាអាទិ៍

១-ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ ទី ២ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) នៃក្រម

នេះក៏ដោយ ក៏ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរនូវចំណុចខាងក្រោមនេះ :

ក-សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃនាវាដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង ។

ខ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា ។

គ-សញ្ញាណនៃនាវាដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ ។

ឃ-ទីកន្លែងដែលនាវាស្ថិតនៅ ព្រមទាំងឈ្មោះរបស់មេបញ្ជាការ ឬ បរិបាលនាវា និង ទីកន្លែងដែលមេបញ្ជាការ ឬ បរិបាលនាវានោះនៅនាពេលបច្ចុប្បន្ន ។

ង-ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) នៃក្រមនេះក៏ដោយ ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ករណីដែលអនុវត្តសិទ្ធិប្រាតិភោគផ្សេងពីឯកសិទ្ធិទូទៅ : ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី ។

ខ-ករណីដែលអនុវត្តឯកសិទ្ធិទូទៅ : ចំពោះនាវាដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជីថាជាកម្មសិទ្ធិករ គឺ ឯកសារដែលបញ្ជាក់ថា នាវានោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។ ចំពោះនាវាដែលមិនត្រូវបានចុះបញ្ជី គឺឯកសារដែលបញ្ជាក់ថា នាវាជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

៣-តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យអ្នកកាន់កាប់នាវាប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលា តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុ-វត្តបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលត្រូវបានទទួលស្គាល់ថា កំពុងកាន់កាប់ដោយផ្អែកលើមូលហេតុគតិយុត្តនៃសិទ្ធិ ដែលអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្តបាន ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៥-ចំពោះដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ទោះជានៅមុនពេលបញ្ជូនទៅឱ្យភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ។

**មាត្រា ៥២២.-** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

បញ្ញត្តិនៃផ្នែកទី ៤ (ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ) ជំពូកទី ៣ គន្ថីទី ៦ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគដែលយកនាវាជាកម្មវត្ថុ លើកលែងតែមានបញ្ញត្តិពិសេស ។

**មាត្រា ៥២៣.-** បញ្ញត្តិដែលត្រូវបានបកស្រាយ

ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤៥៩ (ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំ) នៃក្រមនេះ ត្រូវបានបកស្រាយថា ឯកសារដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) ។

## ជំពូកទី ៤
## ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់

**មាត្រា ៥២៤.-** ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍

១-ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ឬ នាវាឬវត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ រំលាយការកាន់កាប់វត្ថុដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្ត ទទួលបាននូវការកាន់កាប់នោះ ។

២-ការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់ម្ចាស់បំណុលនៃការអនុវត្ត

នោះ បានបង្ហាញខ្លួននៅកន្លែងអនុវត្ត ។

៣-នៅពេលធ្វើការអនុវត្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាអាចចូលទៅក្នុងអចលនវត្ថុ នាវា ឬ វត្ថុផ្សេងទៀតដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ហើយបើចាំបាច់អាចធ្វើការចាត់ចែងជាចាំបាច់ដើម្បីបើកទ្វារដែលបិទនោះ ។

៤-នៅក្នុងការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាត្រូវដកចេញនូវចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះ ហើយត្រូវប្រគល់ចលនវត្ថុទាំងនោះទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់កូនបំណុលនោះ ឬ ញាតិនៅជាមួយឬអ្នកបម្រើឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យ ។ ក្នុងករណីនេះ ប្រសិនបើមិនអាចប្រគល់ចលនវត្ថុនោះទៅឱ្យជនទាំងឡាយដែលបានរៀបរាប់ខាងលើនេះបានទេ អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះ ។

៥-សោហ៊ុយសម្រាប់ថែរក្សាគ្រប់គ្រងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ការអនុវត្ត ។

៦-បើមិនអាចប្រគល់ចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ឱ្យទៅជនដូចបញ្ញត្តិក្នុងកថាខណ្ឌនោះទេ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះ តាមវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុបាន ។

៧-បើបានលក់ចលនវត្ថុតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ អាជ្ញាសាលាត្រូវដកចេញពីចំនួនទឹកប្រាក់ដែលបានមកពីការលក់នូវសោហ៊ុយដែលបានចំណាយក្នុងការលក់ និង ការថែរក្សាគ្រប់គ្រង ហើយត្រូវធ្វើទុកប្រាក់ដែលនៅសេសសល់នោះ នៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

៨-បើបានបញ្ចប់ការអនុវត្តដោយបង្ខំដូចបញ្ញត្តិក្នុងកថាខណ្ឌទី ១ និង ទី ៤ ខាងលើនេះហើយ អាជ្ញាសាលាត្រូវជូនដំណឹងនោះទៅឱ្យកូនបំណុលនៃការអនុវត្ត ។

**មាត្រា ៥២៥.–** ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ

១-ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុក្រៅពីចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍) នៃក្រម

នេះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ ដកយកចលនវត្ថុពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់ចលនវត្ថុនោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២-ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងពុំបានបង្ហាញខ្លួននៅទីកន្លែងធ្វើការអនុវត្តដោយបង្ខំ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះទេ អាជ្ញាសាលាអាចល្បួរការអនុវត្តដោយបង្ខំនោះបាន បើទទួលស្គាល់ថា ពុំអាចជៀសវាងបានដោយគិតពិចារណាលើប្រភេទ និង ចំនួន ជាអាទិ៍ នៃចលនវត្ថុដែលពាក់ព័ន្ធនោះ ។

៣-ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំ ឬ អ្នកតំណាងពុំបានបង្ហាញខ្លួន នៅទីកន្លែងធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុទេ បើបានដកយកចលនវត្ថុនោះពីកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៦ នៃមាត្រា ៣៨៤ (ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ) កថាខណ្ឌទី ២ នៃមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) និង បញ្ញត្តិចាប់ពីកថាខណ្ឌទី ៤ រហូតដល់ទី ៨ នៃមាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥២៦.-** ការអនុវត្តដោយបង្ខំឱ្យប្រគល់ ក្នុងករណីវត្ថុដែលជាកម្មវត្ថុ ត្រូវបានកាន់កាប់ដោយតតិយជន

១-ក្នុងករណីដែលតតិយជនកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ហើយតតិយជននោះមានករណីយកិច្ចត្រូវប្រគល់វត្ថុនោះឱ្យទៅកូនបំណុលនៃការអនុវត្ត ការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុនេះ ត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តរឹបអូសសិទ្ធិទាមទារឱ្យប្រគល់របស់កូនបំណុលនៃការអនុវត្តដែលមានចំពោះតតិយជននោះ ហើយចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត អនុវត្តសិទ្ធិទាមទារនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ៣ និង ទី ៤ នៃមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) មាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) មាត្រា ៤០៥ (ការដាស់តឿនឱ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍) មាត្រា ៤០៦ (ការប្រគល់លិខិត

បញ្ជាក់សិទ្ធិលើបំណុល) ព្រមទាំងកថាខណ្ឌទី ១ ទី ២ និង ទី ៤ នៃមាត្រា ៤១០ (ការប្រមូលបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥២៧.–** ការអនុវត្តជំនួស

១-ក្នុងករណីដែលកាតព្វកិច្ចមានខ្លឹមសារដែលឱ្យធ្វើសកម្មភាពណាមួយ ហើយអាចឱ្យតតិយជនធ្វើជំនួសកូនបំណុលបាន ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចនោះ ត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត ឱ្យតតិយជនបំពេញសកម្មភាពនោះជំនួស ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។

២-តុលាការអនុវត្តដែលបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺតុលាការដែលបានកំណត់នៅក្នុងចំណុចនីមួយៗ តាមការបែងចែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច ក ឬ ចំណុច គ កថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះ ។

៣-បើចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្ត ។

៤-បើចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តអាចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់សោហ៊ុយដែលត្រូវការចាំបាច់សម្រាប់បំពេញសកម្មភាពដែលបានកំណត់ក្នុងដីកាសម្រេចនោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តជាមុនបានតាមពាក្យសុំ ។

៥-ចំពោះសេចក្តីសម្រេចអំពីពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ អំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៦-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអនុវត្តដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៧-បញ្ញត្តិចាប់ពីកថាខណ្ឌទី ១ រហូតដល់កថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកាតព្វកិច្ចមានខ្លឹមសារដែលមិនឱ្យធ្វើសកម្មភាពណាមួយ ហើយម្ចាស់បំណុលនៃការអនុវត្តទាមទារឱ្យដកយកចេញនូវលទ្ធផលនៃសកម្មភាពផ្ទុយនឹងករណីយកិច្ចមិនត្រូវធ្វើសកម្មភាព ទាមទារឱ្យបង្កើតការសាងសង់ ដើម្បីបង្ការសកម្មភាពផ្ទុយនោះ ឬ ទាមទារមធ្យោបាយផ្សេងទៀតដែលសមរម្យ ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៥២៨.–** វិធានបង្ខំដោយប្រយោល

១-ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពណាមួយ ក៏អាចធ្វើបានតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ច ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ស្របទៅតាមអំឡុងពេលនៃការយឺតយ៉ាវ ឬ កំណត់អំឡុងពេលដែលទទួលស្គាល់ថាសមរម្យដើម្បីអនុវត្តកាតព្វកិច្ច ហើយបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ច ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដោយភ្លាមៗ បើពុំបានអនុវត្តក្នុងអំឡុងពេលនោះ ។

២-តុលាការអនុវត្តដែលបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺតុលាការដែលកំណត់នៅក្នុងចំណុចនីមួយៗ តាមការបែងចែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច ក ឬ ចំណុច គ កថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះ ។

៣-បើមានការផ្លាស់ប្តូរស្ថានភាព តុលាការអនុវត្តអាចផ្លាស់ប្តូរដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬ របស់កូនបំណុលនៃការអនុវត្តបាន ។

៤-បើចេញដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ៣ ខាងលើនេះ តុលាការអនុវត្តត្រូវសួរភាគីម្ខាងទៀតនៃអ្នកដាក់ពាក្យសុំ ។

៥-ក្នុងករណីដែលមានការបង់ប្រាក់ដែលត្រូវបានបង្គាប់តាមបញ្ញត្តិនៃកថាខណ្ឌទី ១

ខាងលើនេះ បើចំនួនទឹកប្រាក់នៃការខូចខាតដែលបានកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច លើសចំនួនទឹកប្រាក់ដែលបានបង់នោះ ម្ចាស់បំណុលនៃការអនុវត្តអាចទាមទារសំណងការខូចខាតចំពោះចំនួនទឹកប្រាក់ដែលលើសនោះបាន ។

៦-ចំពោះសេចក្តីសម្រេចអំពីពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ អំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ៥២៩.-** ការចាត់ទុកថាបានបង្ហាញឆន្ទៈ

១-បើសាលក្រម សាលដីកា ឬ ដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តបង្ហាញឆន្ទៈ បានចូលជាស្ថាពរហើយ ឬ បើលិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់ដែលមានខ្លឹមសារថា កូនបំណុលនៃការអនុវត្តត្រូវបង្ហាញឆន្ទៈ បានបង្កើតអានុភាពឡើង ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តបានបង្ហាញឆន្ទៈ នៅពេលនៃការចូលជាស្ថាពរ ឬ ការបង្កើតអានុភាពនោះ ។ ប៉ុន្តែ បើសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈនោះ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តនោះបានបង្ហាញឆន្ទៈ នៅពេលដែលរូបមន្តអនុវត្តត្រូវបានផ្តល់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ ។ បើការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតប ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តនោះបានបង្ហាញឆន្ទៈ នៅពេលដែលរូបមន្តអនុវត្តត្រូវបានផ្តល់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតបរបស់ម្ចាស់បំណុលនៃការអនុវត្ត រូបមន្តអនុវត្តអាចផ្តល់បានលុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានដាក់លិខិតបញ្ជាក់ថា ខ្លួនបានផ្តល់ ឬ បានស្នើផ្តល់តាវកាលិកតបនោះហើយ ។

# គន្ថីទី ៧
# ការចាត់ចែងរក្សាការពារ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៣០.–** គោលគំនិត

ប្រសិនបើមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

**មាត្រា ៥៣១.–** ប្រភេទនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារសំដៅទៅលើការចាត់ចែងនីមួយៗ ដែលមានខ្លឹមសារដូចកំណត់នៅក្នុងចំណុចនីមួយៗ ខាងក្រោមនេះ :

ក-ការរឹបអូសជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។

ខ-ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ : ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

គ-ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូល

ជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

**មាត្រា ៥៣២.–** ស្ថាប័នចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន

១-ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ ។

២-ការអនុវត្តការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ ។

៣-តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ ត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រា ៣៣៦ (ស្ថាប័នអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការចាត់ចែងរក្សាការពារ ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៣.–** សមត្ថកិច្ចផ្ដាច់មុខ

សមត្ថកិច្ចរបស់តុលាការដែលបានកំណត់នៅក្នុងគន្ថីនេះ គឺជាសមត្ថកិច្ចផ្ដាច់មុខ ។

**មាត្រា ៥៣៤.–** របៀបដាក់ពាក្យសុំ

ពាក្យសុំដែលបានកំណត់ខាងក្រោមនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ :

ក-ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

ខ-ពាក្យបណ្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

គ-ពាក្យសុំតវ៉ាចំពោះការរក្សាការពារ ។

ឃ-ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ង-ពាក្យបណ្ដឹងជំទាស់ដែលបានកំណត់នៅក្នុងមាត្រា ៥៦១ (បណ្ដឹងជំទាស់) នៃក្រមនេះ ។

ច-ពាក្យសុំឱ្យអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៥.-** ការសម្រេចសេចក្តីចំពោះនីតិវិធីនៃការរក្សាការពារ ជាអាទិ៍

១-ការសម្រេចសេចក្តីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ និង នីតិ-វិធីដែលតុលាការធ្វើចំពោះការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តការរក្សាការពារ អាចសួរជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬ ជនដែលពាក់ព័ន្ធផ្សេងទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាលាដំបូងត្រូវសម្រេចសេចក្តីអំពីឧបាស្រ័យចំពោះការចាត់ចែងការអនុវត្ត ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៦.-** ការផ្តល់នូវប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីធ្វើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៧.-** សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅតុលាការ ។

២-ពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារទៅតុលាការអនុវត្តការរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការអនុវត្តការរក្សាការពារ ដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តការរក្សាការពារ ។

៣-ប្រសិនបើអ្នកដែលដាក់ពាក្យសុំមិនបានបង់សោហ៊ុយនោះទុកជាមុនទេ តុលា-ការអនុវត្តការរក្សាការពារ អាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារ ឬ អាចលុបចោលនូវនីតិវិធីអនុវត្តការរក្សាការពារបាន ។

៤-ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ អាចប្តឹងជំទាស់បាន ។

៥-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារចំពោះអាជ្ញាសាលា អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធ តាមបញ្ញត្តិដែលបានកំណត់ផ្សេង ។

**មាត្រា ៥៣៨.–** ការមើលសំណុំរឿងនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះនីតិវិធីទាក់ទងនឹងដីកាសម្រេចរក្សាការពារ ឬ នីតិវិធីដែលតុលាការធ្វើឡើងចំពោះការអនុវត្តរក្សាការពារ អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដី ពីតុលាការបាន ដោយបង់ពន្ធ ។

២-ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តរក្សាការពារដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដី ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

**មាត្រា ៥៣៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤

បញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស ។

## ជំពូកទី ២

## ដីកាសម្រេចរក្សាការពារ

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៤០.–** តុលាការដែលមានសមត្ថកិច្ច

១-រឿងក្ដីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ ។

២-តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទី ១ ។ ប៉ុន្តែ បើអង្គសេចក្តី ត្រូវបានចាត់ការ ក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៣-បើកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើបំណុល ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះ ស្ថិតនៅកន្លែងរបស់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍) នៃក្រមនេះ ។ ប៉ុន្តែ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងប្រគល់នាវា ឬ ចលនវត្ថុ ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះស្ថិតនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ ។

៤-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ហើយមានកូនបំណុលទី ៣ ឬ បុគ្គលដែលមានលក្ខណៈដូចជាកូនបំណុលទី ៣ ។

**មាត្រា ៥៤១.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និង សេចក្តីបញ្ជាក់ដំបូង

១-ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរបញ្ជាក់នូវចំណុចដូចបានកំណត់ខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ។

គ-សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ។

ឃ-ភាពចាំបាច់នៃការរក្សាការពារ ។

២-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ គប្បីសរសេរឱ្យបានច្បាស់លាស់ និង សរសេរនូវភស្តុតាង តាមហេតុនីមួយៗដែលត្រូវបញ្ជាក់ ។

៣-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

**មាត្រា ៥៤២.–** ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ។

**មាត្រា ៥៤៣.–** ការបញ្ជូន

តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ។

**មាត្រា ៥៤៤.–** បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចលើកចោល

១-ចំពោះសេចក្តីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលអាចប្តឹងជំទាស់បាន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ២
## ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

**មាត្រា ៥៤៥.–** ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

១-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។

២-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបាន ទោះបីជាសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ ។

**មាត្រា ៥៤៦.–** កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្តោះអាសន្ន អាចចេញបាន

ដោយមិនចាំបាច់កំណត់កម្មវត្ថុ ។

**មាត្រា ៥៤៧.–** ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

១-ក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះ-អាសន្ន ។

២-ការផ្ញើប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ ។

## ផ្នែកទី ៣
## ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

**មាត្រា ៥៤៨.–** ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ជាអាទិ៍

១-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

២-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

៤-តុលាការមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការ

ទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានស្ថានភាពពិសេស ដែលនាំឱ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារឆ្លងកាត់តាមកាលបរិច្ឆេទនោះ ។

**មាត្រា ៥៤៩.–** វិធីចាត់ចែងជាបណ្ដោះអាសន្ន

តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់ ឬ ឱ្យកូនបំណុលផ្ដល់តាវកាលិក ឬ ឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬ ធ្វើការចាត់ចែងផ្សេងទៀតបាន តាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

## ផ្នែកទី ៤
## ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥០.–** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទៅតុលាការដែលបានចេញដីកាសម្រេចនោះ ។

**មាត្រា ៥៥១.–** ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្ត តាមពាក្យសុំដោយឱ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងក្រោមនេះ ក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ លុះត្រាតែមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង អំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរក្សាការពារ ។

២-ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់បានចេញដីកាសម្រេចរក្សាការពារ បើមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្ដី តាម

បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានដែរ ។

៣-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវសេចក្តីសម្រេចដែលបានធ្វើរួចហើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥២.–** ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។

**មាត្រា ៥៥៣.–** ការបញ្ចប់ការវិនិច្ឆ័យ

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យ ។

**មាត្រា ៥៥៤.–** ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

១-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរក្សាការពារ ។

២-ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដែលធ្វើឡើងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចដាក់ល័ក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ។

**មាត្រា ៥៥៥.–** ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន

បើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬ ការបង់ប្រាក់ ឬ ប្រើប្រាស់ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចបង្គាប់

ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬ សងប្រាក់ដែលកូនបំណុលបានបង់ ឬ បង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រងបាន តាមពាក្យសុំរបស់កូនបំណុល នៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ។

**មាត្រា ៥៥៦.–** អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ

ដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។ ប៉ុន្តែ បើយល់ឃើញថា ចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ ។

## ផ្នែកទី ៥
## ការលុបចោលដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥៧.–** ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍

១-តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានរយៈពេលមិនតិចជាង ២ (ពីរ) សប្ដាហ៍ ។

៣-បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ តាមបញ្ញត្តិនៃកថាខណ្ឌដដែលនោះ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល ។

៤-ក្នុងករណីដែលពាក្យបណ្ដឹងអង្គសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែល

បានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនោះ ត្រូវបានដាក់ ត្រូវចាត់ទុកថា ឯកសារនោះ មិនបានដាក់ឡើយ ។

៥-ចំពោះការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៣ ខាងលើនេះ បើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្តី ការចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្ម ត្រូវចាត់ទុកជាការដាក់ពាក្យបណ្តឹងអង្គសេចក្តី ។

៦-បើនីតិវិធីមជ្ឈត្តកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ បានចប់មិនមែនដោយសេចក្តីសម្រេចមជ្ឈត្តករ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងអង្គសេចក្តី ក្នុងអំឡុងពេលដូចគ្នានឹងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ចាប់ពីថ្ងៃដែលនីតិវិធីមជ្ឈត្តកម្មនោះបានចប់ ។

៧-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ហើយបញ្ញត្តិនៃកថាខណ្ឌទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបណ្តឹងអង្គសេចក្តីត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ៦ តែក្រោយមកត្រូវបានដកវិញ ឬ ត្រូវបានលើកចោល ។

៨-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចតាមកថាខណ្ឌទី ៣ និង ទី ៧ ។

**មាត្រា ៥៥៨.-** ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព

១-បើមានការរលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន ។

២-ចំពោះការផ្លាស់ប្តូរស្ថានភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង កថាខណ្ឌទី ២ នៃមាត្រា ៥៥៤ (ដីកា

សម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥៩.-** ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារស្ថានភាពពិសេស

១-ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដីអាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះបាន ដោយមានល័ក្ខខ័ណ្ឌតម្រូវឱ្យដាក់ប្រាតិភោគ តាមពាក្យសុំរបស់កូនបំណុល ។

២-ចំពោះស្ថានភាពពិសេសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៦០.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការ-ពារ ជាអាទិ៍

១-បញ្ញត្តិពីមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) ដល់មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) និង មាត្រា ៥៥៦ (អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្ដីអំពីការលុបចោលដីកាសម្រេចរក្សាការពារ លើកលែងតែចំពោះការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) ។

២-ចំពោះការសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្ត

ដូចគ្នា នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការនៃបណ្តឹងអង្គសេចក្តី ផ្សេងពីតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ហើយមានសំណុំរឿងនៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ តុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ ក៏អាចធ្វើការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

## ផ្នែកទី ៦
## បណ្តឹងជំទាស់

**មាត្រា ៥៦១.–** បណ្តឹងជំទាស់

១-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ អាចប្តឹងជំទាស់ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូននោះ :

ក-ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ខ-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ។

គ-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ១ មាត្រា ៥៦០ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍) ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្តីសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដែលបានធ្វើឡើងដោយតុលាការនៃបណ្តឹងជំទាស់ ។

២-អំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានទេ ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីបណ្តឹងជំទាស់ ហើយបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៥២ (ការវិនិច្ឆ័យអំពីការតវ៉ា

ចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៣ (ការបញ្ឈប់ការវិនិច្ឆ័យ) និង មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងបណ្ដឹងជំទាស់ ហើយបញ្ញត្តិនៃមាត្រា ៣១៧ (ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសេចក្ដីសម្រេចដែលអាចប្ដឹងជំទាស់បាន បានចូលជាស្ថាពរ ។

៤-ចំពោះការសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងករណីដែលមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

## ជំពូកទី ៣
## ការអនុវត្តរក្សាការពារ

**មាត្រា ៥៦២.–** លក្ខខណ្ឌនៃការអនុវត្តរក្សាការពារ

១-ការអនុវត្តរក្សាការពារត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ។ ប៉ុន្តែ ការអនុវត្តរក្សាការពារចំពោះ ឬ សម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត ។

២-ការអនុវត្តរក្សាការពារ មិនត្រូវធ្វើឡើយ បើអំឡុងពេល ២ (ពីរ) សប្ដាហ៍ បានកន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅម្ចាស់បំណុល ។

៣-ទោះបីនៅមុនពេលដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅកូនបំណុលក៏ដោយ ក៏ការអនុវត្តរក្សាការពារ អាចធ្វើបានដែរ ។

**មាត្រា ៥៦៣.–** ករណីពិសេសនៃតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងតវ៉ារបស់តតិយជន

ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) នៃក្រមនេះក៏ដោយ ក៏បណ្ដឹងតវ៉ារបស់តតិយជន ចំពោះដីកាសម្រេចរក្សាការពារដែលសាលាឧទ្ធរណ៍បានធ្វើ ក្នុងនាមជាតុលាការអនុវត្តរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុត្រូវរឹបអូសជាបណ្ដោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ ។

**មាត្រា ៥៦៤.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦

លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងជំពូកនេះ បញ្ញត្តិពីមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) ដល់មាត្រា ៣៤៥ (បណ្ដឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៤៨ (អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ) បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ នៃមាត្រា ៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ) កថាខណ្ឌទី ២ នៃមាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) កថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ៣៥៥ (ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត) ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ពីមាត្រា ៣៥៧ (ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត) ដល់មាត្រា ៣៥៩ (ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត) មាត្រា ៣៦២ (ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៦៤ (បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត) និង មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) និង បញ្ញត្តិពីមាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) ដល់មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ចំពោះការអនុវត្តរក្សាការពារ ។

**មាត្រា ៥៦៥.-** ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ។

២-អាជ្ញាសាលាត្រូវធ្វើប្រាក់ដែលបានមកពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ន នៅតុលាការដែលខ្លួនស្ថិតនៅ។

៣-បើមានការបារម្ភថា ចលនវត្ថុដែលការរឹបអូសជាបណ្តោះអាសន្នត្រូវបានអនុវត្តនឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងផ្នែកទី ២ ជំពូកទី ២ នៃគន្ថីទី ៦ នៃក្រមនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន ឬ កូនបំណុល ហើយធ្វើប្រាក់ដែលបានមកពីការលក់នោះនៅតុលាការដែលខ្លួនស្ថិតនៅ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៤ (ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ) ពីមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) ដល់មាត្រា ៣៩២ (ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ។

**មាត្រា ៥៦៦.-** ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី ៣ សងទៅកូនបំណុល។

២-ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលបានចេញដីកាសម្រេចរឹបអូសបណ្តោះអាសន្ន ត្រូវមានសមត្ថ-

កិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្នុងករណីដែលការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ បើកូនបំណុលទី៣បានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនៅតុលាការ ត្រូវចាត់ទុកថា កូនបំណុលបានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះភាគដែលលើសពីចំនួនប្រាក់នោះ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ ទី ៣ ទី ៦ ទី៧ ទី ៨ ទី ១០ និង កថាខណ្ឌទី ១១ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) បញ្ញត្តិពីមាត្រា ៤០៤ (ទំហំនៃការរឹបអូស) ដល់មាត្រា ៤០៨ (ការជូនដំណឹងអំពីការដកពាក្យសុំ ជាអាទិ៍) មាត្រា ៤១១ (ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣) និងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះ-អាសន្នចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

**មាត្រា ៥៦៧.–** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) នៃក្រមនេះ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាកាពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤២០ (ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស

ជាអាទិ៍) វាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ នៃមាត្រា ៤២១ (អានុភាពនៃការរឹបអូស) កថាខណ្ឌទី ១ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) មាត្រា ៤២៥ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) និង មាត្រា ៤២៨ (ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) នៃក្រមនេះ ត្រូវយកមកអនុ-វត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ។

**មាត្រា ៥៦៨.–** ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្តល់លិខិតនោះទៅ តុលាការអនុវត្តរក្សាការពារ ។ របៀបទាំងនេះ អាចអនុវត្តរួមគ្នាបាន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ រីឯការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) មាត្រា ៤៦៥ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយការវិនាសបាត់បង់នាវា ជាអាទិ៍) និង មាត្រា ៤៦៦ (ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះ-អាសន្នតាមរបៀបចុះបញ្ជី ហើយបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) កថាខណ្ឌទី ៧ នៃមាត្រា ៤៥៧ (ដីកាសម្រេចចាប់ផ្តើម ជាអាទិ៍) មាត្រា ៤៦០ (ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍) និង

មាត្រា ៤៦២ (ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផង ដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន តាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិត បញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។

**មាត្រា ៥៦៩.–** ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

១-បើកូនបំណុលបានធ្វើប្រាក់ស្មើនឹងចំនួនប្រាក់ដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ នៅតុលាការ តុលាការអនុវត្តរក្សាការពារ ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ត្រូវលុបចោលនូវការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៤៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកអនុវត្តដូចគ្នា នៅក្នុងមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) ក៏ដោយ ក៏ដីកាសម្រេចដែលធ្វើឡើង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមៗដែរ ។

**មាត្រា ៥៧០.–** ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្តោះអាសន្ន ឬវិធីអនុវត្តដោយបង្ខំ ។

**មាត្រា ៥៧១.–** អានុភាពនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

១-បើដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាប់កាប់វត្ថុ និង បង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវបានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាប់កាប់វត្ថុនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដោយបិទលិខិតប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត ។

២-បើការចាត់ចែងជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្ដី ។ ប៉ុន្តែ ម្ចាស់បំណុលអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននោះត្រូវបានធ្វើហើយ ។

៣-ជនដែលកាន់កាប់វត្ថុដែលពាក់ព័ន្ធក្រោយពេលការអនុវត្តចាត់ចែងជាបណ្ដោះ-អាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានសន្មតថា កាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ននោះ ត្រូវបានធ្វើហើយ ។

# គន្ថីទី ៨
# អន្តរប្បញ្ញត្តិ
## ជំពូកតោល
## អន្តរប្បញ្ញត្តិ

**មាត្រា ៥៧២.–** គោលការណ៍នៃវិធានការអន្តរកាល

ចំពោះបណ្ដឹងដែលបានដាក់មុនពេលក្រមនេះត្រូវបានអនុវត្ត នីតិវិធីពាក់ព័ន្ធនឹងបណ្ដឹង ក្រោយពេលក្រមនេះ ត្រូវបានអនុវត្ត ត្រូវបន្តអនុវត្តបញ្ចប់តាមក្រមនេះ លើកលែងតែករណីដែលមានចែងពិសេសនៅក្នុងគន្ថីទី ៨ (អន្តរប្បញ្ញត្តិ) នេះ ។ ក្នុងករណីនេះ បញ្ញត្តិនេះ ពុំរារាំងអានុភាពដែលបានកើតឡើងនៅក្នុងនីតិវិធីដែលបានធ្វើ មុនពេលដែលក្រមនេះ ត្រូវបានអនុវត្តឡើយ ។

**មាត្រា ៥៧៣.–** វិធានការអន្តរកាលស្ដីពីសមត្ថកិច្ច

ចំពោះសមត្ថកិច្ចនៃបណ្ដឹង និង ការផ្ទេរបណ្ដឹង ដែលកំពុងចាត់ការនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

**មាត្រា ៥៧៤.–** វិធានការអន្តរកាលស្ដីពីការបែងចែករឿងក្ដី

១-នៅក្រោយពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ ប្រសិនបើក្រមនេះត្រូវបានអនុវត្ត នៅមុនការចាត់តាំងចៅក្រមទទួលបន្ទុកស៊ើបសួរ ឬ នីតិវិធីផ្សះផ្សា (ខាងក្រោមនេះហៅថា "ចៅក្រមទទួលបន្ទុកអង្កេតស៊ើបសួរ ជាអាទិ៍") ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្ដឹងនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ហើយត្រូវយកបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្ដី) នៃក្រមនេះ មកអនុវត្ត ។

២-នៅក្រោយពេលដែលចៅក្រមទទួលបន្ទុកអង្កេតស៊ើបសួរ ជាអាទិ៍ ត្រូវបានចាត់តាំងរួចហើយ ប្រសិនបើក្រមនេះត្រូវបានអនុវត្ត នៅមុនពេលចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមនៅក្នុងថ្នាក់ជំនុំជម្រះក្ដីនោះ ត្រូវចាត់ទុកថា ចៅក្រមទទួលបន្ទុកអង្កេតស៊ើបសួរ ជាអាទិ៍ នោះ បានទទួលការបែងចែករឿងក្ដី តាមបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្ដី) នៃក្រមនេះ ។ ប៉ុន្តែ ប្រសិនបើប្រធានសាលាដំបូងទទួលបន្ទុកផ្សះផ្សា ត្រូវចាត់

ទុកថា ប្រធាននោះបានទទួលការបែងចែករឿងក្តី តាមបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្តី) ។

៣-ក្នុងករណីនៃកថាខណ្ឌទី ២ ខាងលើនេះ ចំពោះរឿងក្តីដែលបានបញ្ញត្តិនៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ២៣ (ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម) នៃក្រមនេះ ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្តឹងនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ហើយត្រូវយកបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្តី) មកអនុវត្ត ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ។

៤-ក្រោយពេលដែលរឿងក្តីត្រូវបានទទួល នៅក្នុងការជំនុំជម្រះក្តីលើបណ្តឹងឧទ្ធរណ៍ ប្រសិនបើក្រមនេះត្រូវបានអនុវត្ត នៅមុនពេលចាត់តាំងចៅក្រមនៅក្នុងថ្នាក់ជំនុំជម្រះក្តីនោះ ត្រូវចាត់ទុកថា បានទទួលរឿងក្តីនោះ នៅពេលដែលក្រមនេះត្រូវបានអនុវត្ត ហើយត្រូវយកបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្តី) នៃក្រមនេះ មកអនុវត្ត ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបែងចែករឿងក្តី ក្នុងការជំនុំជម្រះក្តីលើបណ្តឹងសាទុក្ខ ។

**មាត្រា ៥៧៥.-** វិធានការអន្តរកាលស្តីពីការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្ត

នៅក្នុងសាលាដំបូងដែលមិនមានចៅក្រមគ្រប់គ្រាន់ដើម្បីធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ អំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្តទេ បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៣០ (ការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្ត ដោយប្តូរពីឃ្លាថា “ក្រុមប្រឹក្សាជំនុំជម្រះនៅតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម” មកជា “ចៅក្រមផ្សេងទៀតនៅតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម” សម្រាប់មួយរយៈពេល ។

**មាត្រា ៥៧៦.-** វិធានការអន្តរកាលស្តីពីនីតិវិធីអង្កេតស៊ើបសួរ ឬ នីតិវិធីក្រោយនីតិវិធីអង្កេតស៊ើបសួរ

១-ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្តនៅពេលដែលនីតិវិធីអង្កេតស៊ើបសួរកំពុងត្រូវបានប្រតិបត្តិ តុលាការត្រូវបញ្ឈប់នីតិវិធីអង្កេតស៊ើបសួរនោះភ្លាម ហើយត្រូវកំណត់

កាលបរិច្ឆេទដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកោះហៅភាគីឱ្យមកចូលរួមដោយគ្មានការយឺតយ៉ាវ ។

២-ក្រោយពីនីតិវិធីអង្កេតស៊ើបសួរត្រូវបានបញ្ចប់ ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្តនៅមុនពេលបើកកាលបរិច្ឆេទនៃសវនាការ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកោះហៅភាគីឱ្យមកចូលរួម ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ បញ្ញត្តិនេះពុំត្រូវយកមកអនុវត្តឡើយ ក្នុងករណីដែលតុលាការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៥៧៨ (វិធានការអន្តរកាលស្តីពីកាលបរិច្ឆេទនៃការជំនុំជម្រះ) នៃក្រមនេះ ។

៣-នៅក្នុងករណីនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សកម្មភាពបណ្តឹងដែលបានធ្វើនៅក្នុងនីតិវិធីអង្កេតស៊ើបសួរ ត្រូវចាត់ទុកថា បានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្នុងទំហំនៃសិទ្ធិអំណាចរបស់តុលាការ ដូចបានបញ្ញត្តិនៅក្នុងមាត្រា ១០៦ (សកម្មភាពនៃបណ្តឹង ជាអាទិ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) នៃក្រមនេះ ។

៤-ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត ក្រោយការបើកកាលបរិច្ឆេទនៃសវនាការ ចំពោះសាក្សីដែលត្រូវបានសាកសួរនៅក្នុងនីតិវិធីអង្កេតស៊ើបសួរដោយភាគី ឬ សាមីភាគីដែលមិនត្រូវបានសាកសួរនៅក្នុងថ្នាក់ជំនុំជម្រះក្តី ប្រសិនបើភាគីបានស្នើសុំឱ្យសាកសួរនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធ្វើការសាកសួរ ។

**មាត្រា ៥៧៧.–** វិធានការអន្តរកាលស្តីពីប្រាក់ប្រដាប់ក្តី

១-ចំពោះប្រាក់ប្រដាប់ក្តីនៃបណ្តឹងរដ្ឋប្បវេណី ដែលភាគី ឬ បុគ្គលពាក់ព័ន្ធផ្សេងទៀតត្រូវទទួលបន្ទុក ទាក់ទងទៅនឹងបណ្តឹងដែលបានដាក់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

២-បញ្ញត្តិស្តីពីប្រាតិភោគនៃប្រាក់ប្រដាប់ក្តី មិនត្រូវយកមកអនុវត្តឡើយ ចំពោះបណ្តឹងដែលបានដាក់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ។

**មាត្រា ៥៧៨.–** វិធានការអន្តរកាលស្តីពីកាលបរិច្ឆេទនៃការជំនុំជម្រះ

១-កាលបរិច្ឆេទនៃការជំនុំជម្រះក្តីដែលបានកំណត់ហើយ នៅពេលដែលក្រមនេះ

ត្រូវបានអនុវត្ត ត្រូវចាត់ទុកថា បានកំណត់ជាកាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តាមបញ្ញត្តិនៃក្រមនេះ ។

២-ក្នុងករណីនៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើកាលបរិច្ឆេទនៃការជំនុំជម្រះក្តីនោះ គឺជាកាលបរិច្ឆេទទី ១ បន្ទាប់ពីការបញ្ចប់នីតិវិធីអង្កេតស៊ើបសួរ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅមុនការចាប់ផ្តើមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បាន ។

៣-ក្នុងករណីនៃកថាខណ្ឌទី ២ ខាងលើនេះ ប្រសិនបើតុលាការពុំអាចបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានទេ តុលាការត្រូវកំណត់កាលបរិច្ឆេទមួយទៀតសម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយលុបចោល ឬ លើកកាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

**មាត្រា ៥៧៩.-** វិធានការអន្តរកាលស្តីពីទណ្ឌកម្មនៅក្នុងការពិនិត្យភស្តុតាង

១-បញ្ញត្តិស្តីពីពិន័យស៊ីវិល ដែលមានចែងនៅក្នុងជំពូកទី ៣ (ភស្តុតាង) នៃគន្ថីទី ២ នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះករណីដែលដីកាសម្រេចពិនិត្យភស្តុតាង ត្រូវបានចេញដោយអនុលោមតាមបញ្ញត្តិនៃក្រមនេះ ឬ ចំពោះករណីដែលភាគី ឬ អ្នកតំណាងរបស់ភាគីប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ ក្រោយពេលក្រមនេះត្រូវបានអនុវត្ត ។

២-ចំពោះបញ្ញត្តិនៃជំពូកទី ៣ (ភស្តុតាង) នៃគន្ថីទី ២ ដែលត្រូវយកទៅអនុវត្តដូចគ្នាផងដែរ ដោយមាត្រា ២៧៣ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១) និង មាត្រា ២៨៦ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍) នៃក្រមនេះ ក៏ត្រូវអនុវត្តដូចគ្នានឹងកថាខណ្ឌទី ១ ដែរ ។

**មាត្រា ៥៨០.-** វិធានការអន្តរកាលស្តីពីសាលក្រមកំបាំងមុខ

ចំពោះនីតិវិធី នៅក្នុងករណីដែលដើមចោទ ឬ ចុងចម្លើយមិនបានបង្ហាញខ្លួននៅក្នុងកាលបរិច្ឆេទ តាមនីតិវិធីនៃការកោះហៅ នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

**មាត្រា ៥៨១.-** វិធានការអន្តរកាលស្តីពីការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

១-ការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រម ឬ សាលដីកា ដែលត្រូវបានសម្រេចដោយផ្អែកលើការដេញដោលដែលបានចប់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

២-ការអាច ឬ មិនអាចធ្វើបណ្តឹងសាទុក្ខ និង អំឡុងពេលនៃបណ្តឹងសាទុក្ខ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ អំពីរឿងក្តីដែលតុលាការកំពូលបានសម្រេចបញ្ជូនត្រឡប់វិញនៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

៣-ចំពោះរឿងក្តីដែលតុលាការកំពូលបានសម្រេចទុកជាមោឃៈនូវសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេច ដោយផ្អែកលើការដេញដោលដែលបានចប់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត និង បញ្ជូនត្រឡប់ទៅសាលាឧទ្ធរណ៍វិញ ការអាច ឬ មិនអាចធ្វើបណ្តឹងសាទុក្ខ និង អំឡុងពេលនៃបណ្តឹងសាទុក្ខ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

៤-ចំពោះសេចក្តីសម្រេច ក្រៅពីសាលក្រម និង សាលដីកា ដែលត្រូវបានជូនដំណឹងនៅមុនពេលក្រមនេះត្រូវបានអនុវត្ត ការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

**មាត្រា ៥៨២.-** វិធានការអន្តរកាលស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ

១-បណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ចំពោះសាលដីកាដែលត្រូវបានសម្រេច ដោយផ្អែកលើការដេញដោល ដែលបានចប់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

២-បណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ អំពីរឿងក្តីដែលតុលាការកំពូលបានសម្រេចបញ្ជូនត្រឡប់វិញនៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

៣-ចំពោះរឿងក្តីដែលតុលាការកំពូលបានសម្រេចទុកជាមោឃៈនូវសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេច ដោយផ្អែកលើការដេញដោលដែលបានចប់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត និង បញ្ជូនត្រឡប់ទៅសាលាឧទ្ធរណ៍វិញ បណ្តឹងសាទុក្ខ និង នីតិ-វិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

**មាត្រា ៥៨៣.–** វិធានការអន្តរកាលស្តីពីអានុភាពចំណងនៃសាលដីការបស់តុលាការកំពូលដែលទុកជាមោឃៈ នូវសាលដីកាសាលាឧទ្ធរណ៍

ក្នុងករណីដែលបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥៨២ (វិធានការអន្តរកាលស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ) នៃក្រមនេះ ប្រសិនបើតុលាការកំពូលសម្រេចទុកជាមោឃៈនូវសាលដីកាដើម ហើយបញ្ជូនត្រឡប់ទៅសាលាឧទ្ធរណ៍វិញ ឬ ផ្ទេរទៅតុលាការផ្សេង បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ២៩៩ (ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍) មិនត្រូវយកមកអនុវត្តឡើយចំពោះសាលដីកានោះ ។

**មាត្រា ៥៨៤.–** វិធានការអន្តរកាលស្តីពីការជំនុំជម្រះសាជាថ្មី

បញ្ញត្តិនៃគន្ថីទី ៤ (ការជំនុំជម្រះសាជាថ្មី) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះការសម្រេចសេចក្តីដែលចូលជាស្ថាពរ នៅក្រោយពេលដែលក្រមនេះត្រូវបានអនុវត្តតែប៉ុណ្ណោះ ។

**មាត្រា ៥៨៥.–** វិធានការអន្តរកាលស្តីពីការអនុវត្តដោយបង្ខំ

១-ចំពោះរឿងក្តីនៃការអនុវត្តដោយបង្ខំ ដែលបានដាក់ពាក្យសុំនៅមុនពេលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក លើកលែងតែបញ្ញត្តិដែល

មានចែងនៅក្នុងជំពូកទី ៣ (អំពីការដាក់គុកបង្ខំដល់រូបកាយ) នៃច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

២-សេចក្តីសម្រេចបង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយ ដែលបានចេញដោយអនុលោមតាមបញ្ញត្តិនៃជំពូកទី ៣ (អំពីការដាក់គុកបង្ខំដល់រូបកាយ) នៃច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី នៅមុនពេលក្រមនេះត្រូវបានអនុវត្ត ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះ ត្រូវបានអនុវត្ត ។

៣-នៅពេលដែលក្រមនេះត្រូវបានអនុវត្ត ប្រសិនបើកូនបំណុលទទួលការដាក់គុកបង្ខំដល់រូបកាយ តាមបញ្ញត្តិនៃជំពូកទី ៣ (អំពីការដាក់គុកបង្ខំដល់រូបកាយ) នៃច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដែលបានបង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយ ឬ ប្រធានតុលាការត្រូវបង្គាប់ឱ្យដោះលែងកូនបំណុលនោះភ្លាម ។

**មាត្រា ៥៨៦.-** វិធានការអន្តរកាលស្តីពីការចាត់ចែងរក្សាការពារ

១-ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត នៅមុនពេលចេញសេចក្តីសម្រេចលើរឿងក្តីចាត់ចែងរក្សាការពារ ដែលបានដាក់ពាក្យសុំនៅមុនពេលក្រមនេះត្រូវបានអនុវត្ត នីតិវិធីបន្ទាប់ ត្រូវបន្តអនុវត្តបញ្ចប់ ដោយក្រមនេះ ។ ក្នុងករណីនេះ នីតិវិធីដែលបានធ្វើនៅមុនពេលក្រមនេះត្រូវបានអនុវត្ត ពុំត្រូវបាត់បង់អានុភាពឡើយ ។

២-ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត នៅក្រោយពេលចេញសេចក្តីសម្រេចលើរឿងក្តីចាត់ចែងរក្សាការពារ នីតិវិធីបន្ទាប់ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

# គន្ថីទី ៩

## អវសានប្បញ្ញត្តិ

### ជំពូកទោល

### អវសានប្បញ្ញត្តិ

**មាត្រា ៥៨៧.–** ការអនុវត្តក្រមនេះ

ក្រោយពីចូលជាធរមាន ក្រមនេះត្រូវផ្សព្វផ្សាយរយៈពេល ១ ( មួយ ) ឆ្នាំ ទើបអនុវត្ត ។

**មាត្រា ៥៨៨.–** ការធ្វើឱ្យនិរាករណ៍នូវច្បាប់ផ្សេង ជាអាទិ៍

១-ច្បាប់ដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត :

ក-ច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥១ ក្រ ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ១៩៩២ ។

ខ-ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

២-បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលក្រមនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៦

៣៖ល.០៧០៦.៣១០ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ : ៤៨៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែកក្កដាឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

## ឧបសម្ព័ន្ធ
## នីតិវិធីក្នុងការធ្វើសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំធ្វើដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិ នៅទីកន្លែងនៃតុលាការនីមួយៗ ឬ នៅទីណាមួយ តាមការព្រមព្រៀងរបស់គូក្តី ។ បើមិនមានការចុះសម្រុងគ្នាទេ តុលាការជាអ្នកសម្រេច ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជាចំពោះវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ ។ បន្ទាប់មក ក្រឡាបញ្ជីត្រូវអានប្រារព្ធវាទ ខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់រួចអាន**ពាក្យសច្ចាប្រណិធាន** ឱ្យអ្នកស្បថ ថាតាម ។

ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឱ្យស្បថនោះ បញ្ជាក់ថា បានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង ។

## ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និង បារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើរ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវិវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែង ជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ត្បិតគូក្តីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និង បានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យយកអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់ តាមពិត ។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និង បានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និង បារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិ ឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់

ប្រាំរយជាតិ ។

បើអ្នកណាឆ្លើយឱ្យការណ៍ ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលំអៀង ព្រោះជាញាតិ សាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និង បារមីដ៏សក្តិសិទ្ធិក្នុងលោក ជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រលាញ់រាប់អាន លុះអនាគតជាតិ បានជួបតែ សេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើងរុងរឿង សមដូចសេចក្តី បំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និង បានចាំផ្ទាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និង បារមីដ៏សក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និង ស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និង រស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសន្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។